ក្រសួងកិច្ចការនារី

ក្រសួងអប់រំយុវជន និងកីឡា

# ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងវិស័យអប់រំ និងការងារ

២០១០

ក្រសួងកិច្ចការនារី

ក្រសួងអប់រំយុវជន និងកីឡា

# ស្ត្រី និងបច្ចេកវិទ្យា
# គមនាគមន៍ ព័ត៌មានវិទ្យា
# ក្នុងវិស័យអប់រំ និងការងារ

២០១០

របាយការណ៍នៃការសិក្សាស្រាវជ្រាវស្ដីអំពី ស្ត្រី និងបច្ចេកវិទ្យា ក្នុងវិស័យអប់រំ និងការងារត្រូវបាន៖

**រៀបរៀងដោយ៖**


ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និង កីឡា និងអង្គការវិទ្យាស្ថានបើកទូលាយ



© រក្សាសិទ្ធិ ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និង កីឡា និងអង្គការវិទ្យាស្ថានបើកទូលាយ

© Copyright Ministry of Women's Affairs, Ministry of Education, Youth and Sport, and the Open Institute



**Ministry of Women's Affairs**
#3, Norodom Blvd, Phnom Penh,
Cambodia
Fax: ( 855 ) 23 428 965
Tel: ( 855 ) 23 428 965
http://www.mwa.gov.kh

**Ministry of Education, Youth and Sport**
#80, Preah Norodom Blvd, Phnom Penh,
Cambodia
Fax: ( 855 ) 23 212 512
Tel: ( 855 ) 23 217 253
http://www.moeys.gov.kh

**Open Institute**
#19, 374, Tuol
Svayprey I, Chamkarmorn,
Phnom Penh, Cambodia
Tel: ( 855 ) 23 222 819
http://women.open.org.kh



របាយការណ៍នៃការសិក្សាស្រាវជ្រាវនេះ ស្ថិតនៅក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution-Share Alike 3.0 license,

http://creativecommons.org/licenses/by-sa/3.0/

អ្នកអាចចម្លង ចែកចាយ ផ្ទេរផ្នែកណាមួយ និងយកលំនាំតាមសៀវភៅនេះ ប៉ុន្តែអ្នកត្រូវតែបញ្ជាក់ការរក្សាសិទ្ធិម្ចាស់ដើម របស់ ក្រសួងកិច្ចការនារី ក្រសួងក្រសួងអប់រំ យុវជន និង កីឡា និងអង្គការវិទ្យាស្ថានបើកទូលាយ។

ការងារណាដែលយកចេញពីផ្នែកណាមួយនៃរបាយការណ៍នេះ ត្រូវតែចែកចាយ និងដាក់នៅក្រោមអាជ្ញាប័ណ្ណដូចគ្នាដដែល គឺ Creative Commons Attribution-Share Alike 3.0 license



**ដោយមានកិច្ចសហការជាមួយ៖**

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ  និងអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល

# អារម្ភកថា

ក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ( Information Communication Technology-ICT ) កម្ពុជាបានរៀបចំច្បាប់ គោលនយោបាយ និងកម្មវិធីដើម្បីអភិវឌ្ឍលើវិស័យទំនើបនេះ ។ គោលនយោបាយពាក់ព័ន្ធ ដូចជា យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ សំណើគោលនយោបាយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា របស់អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NIDA) ឆ្នាំ២០០៩ អំពីគោលនយោបាយជាតិស្តីពី បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានឆ្នាំ២០១៥ គោលនយោបាយ ICT ក្នុងវិស័យអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៤ ផែនការសកម្មភាពទីក្រុងប៉េកាំង ឆ្នាំ១៩៩៥ ដែលកម្ពុជា ជាប្រទេសហត្ថលេខីមួយ ។ល។ បានចែងយ៉ាងច្បាស់ ពីការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តរហូតដល់ថ្នាក់ជនបទ និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងសមធម៌លើវិស័យ ICT ។

ការអភិវឌ្ឍសង្គមមួយប្រកបដោយសមធម៌ និងចិរភាព ទាមទារឲ្យមានការចូលរួមរបស់ស្ត្រីនិងបុរស និងការផ្តល់ឱកាសដល់ស្ត្រីដើម្បីចូលរួមក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា គឺមានសារសំខាន់ណាស់ ដោយជាផ្នែកមួយក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រី ឲ្យក្លាយជាធនធានមនុស្សដ៏មានតម្លៃក្នុងសង្គម ។ រហូតមកទល់បច្ចុប្បន្ននៅកម្ពុជាយើង មិនទាន់មានការស្រាវជ្រាវណាមួយ ដែលអាចបង្ហាញអំពី ចំនួនប្រជាជននិងសមាមាត្ររវាងបុរសនិង ស្ត្រី ដែលបានសិក្សា និងទទួលបានការងារផ្នែក បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា នៅឡើយ ។ ដូច្នេះហើយ ការសិក្សាស្រាវជ្រាវអំពី "ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងវិស័យអប់រំ និងការងារ" ពិតជាមានសារសំខាន់ណាស់ ក្នុងការផ្តល់នូវទិន្នន័យនិងសូចនាករនានា និងមូលហេតុច្បាស់លាស់អំពីស្ថានភាព និងនិន្នាការបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាដោយផ្អែកលើទស្សនៈយេនឌ័រ សម្រាប់រៀបចំយុទ្ធសាស្ត្រ និងផែនការ អនាគតដែលជាប្រយោជន៍ធ្វើឲ្យស្ថានភាពរបស់ស្ត្រីប្រសើរឡើង ។

ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា របាយការណ៍នៃការសិក្សាស្រាវជ្រាវនេះ នឹងរួមចំណែកជាប្រយោជន៍សម្រាប់ក្រសួង ស្ថាប័ននានា អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងការអោយតម្លៃ ផ្តល់ឱកាស និងជួយសម្របសម្រួលឲ្យស្ត្រីទទួលបាន និងប្រើប្រាស់បាននូវបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ព្រមទាំងលើកកម្ពស់សមភាព និងពង្រីកវិសាលភាពយេនឌ័រនៅក្នុងបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ និងការងារឲ្យបានកាន់តែប្រសើរ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ក្រសួងអប់រំ យុវជននិងកីឡា អង្គការវិទ្យាស្ថានបើកទូលាយ ស្ថាប័នដែលបានសហការរួមមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ដែលបានផ្តល់ជំនួយបច្ចេកទេសក្នុងការចងក្រងការសិក្សាស្រាវជ្រាវនេះ ព្រមទាំងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសអេស្ប៉ាញ AECID ដែលបានឧបត្ថម្ភគាំទ្រថវិកាក្នុងការស្រាវជ្រាវនេះ ។ ជាមួយគ្នានេះ ក៏សូមថ្លែងអំណរគុណចំពោះក្រសួងនានា រួមទាំងអាជ្ញាធរជាតិ អង្គការសង្គមស៊ីវិល គ្រឹះស្ថានឧត្តមសិក្សា ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ហាងអ៊ីនធឺណិត និងបុគ្គលិកនៃស្ថាប័នខាងលើដែលបានចូលរួមសហការ និងផ្តល់នូវទិន្នន័យសម្រាប់ការសិក្សានេះ រហូតដល់បានបោះពុម្ពជារបាយការណ៍នៃការសិក្សាស្រាវជ្រាវនេះឡើង ។

ភ្នំពេញ ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ ២០១០

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**លោកជំទាវវេជ្ជ. អ៊ឹង កន្ថាផាវី**

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ក្រុមការងារសិក្សាស្រាវជ្រាវសូមសំដែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងនានា ព្រមទាំងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៏វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា អង្គការសង្គមស៊ីវិល គ្រឹះស្ថានឧត្តមសិក្សា និងក្រុមហ៊ុនផ្ដល់សេវាកម្មអ៊ីនធឺណិតដែលបានអនុញ្ញាត និងចាត់តាំងមន្ត្រីរបស់ខ្លួនចូលរួមក្នុងការសម្ភាសសម្រាប់ការស្រាវជ្រាវនេះ ។

ការសិក្សាស្រាវជ្រាវនេះ នឹងមិនអាចលេចជារូបរាងបានឡើយ បើមិនមានការចូលរួមចំណាយពេលវេលា និងកម្លាំងក្នុងការឆ្លើយតប អាន គិត និងបំពេញកម្រងសំណួរពីសំណាក់មន្ត្រីរាជការ បុគ្គលិកអង្គការសង្គមស៊ីវិល សាស្ត្រាចារ្យ និស្សិតបុគ្គលិកមកពីក្រុមហ៊ុនឯកជន និងបុគ្គលិកនៅតាមហាងអ៊ីនធឺណិត ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះបុគ្គលដូចបានរៀបរាប់ខាងលើ ។

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះអ្នកតំណាងរបស់ស្ថាប័ននានា ដែលបានចូលរួមយ៉ាងសកម្ម និងសហការយ៉ាងស្អិតល្មួតចាប់តាំងពីការប្រជុំបង្កើតគោលគំនិតនៃការសិក្សាស្រាវជ្រាវ ការចូលរួមផ្ដល់មតិនៅក្នុងកិច្ចប្រជុំលើកទី១ និងលើកទី២ ស្ដីពីរបាយការណ៍បឋមនៃការសិក្សាស្រាវជ្រាវ រហូតដល់ការបោះពុម្ភរបាយការណ៍នៃការសិក្សាស្រាវជ្រាវ ។ ការផ្ដល់មតិរិះគន់ស្ថាបនា ការផ្ដល់គំនិតល្អៗក្នុងគម្រោងបញ្ញត្តិស្រាវជ្រាវ ការផ្ដល់ឯកសារពាក់ព័ន្ធ ការពិនិត្យឯកសារឡើងវិញ កិច្ចសហការក្នុងការប្រមូលព័ត៌មាន ការកែសម្រួលខ្លឹមសារក្នុងរបាយការណ៍ និងការសម្របសម្រួលផ្សេងទៀត គឺជាវិភាគទានយ៉ាងធំធេង ដែលអាចបង្កើតអោយមានជារបាយការណ៍ស្រាវជ្រាវនេះ ។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសអេស្ប៉ាញ( AECID ) ដែលបានផ្ដល់ថវិកាសម្រាប់ការសិក្សាស្រាវជ្រាវនេះ ហើយដំណើរការទាំងស្រុងនៃការសិក្សាស្រាវជ្រាវ នឹងមិនអាចប្រព្រឹត្តទៅបានឡើយបើមិនមានការគាំទ្រនេះ ។

យើងខ្ញុំ សង្ឃឹមថាអ្នកប្រើប្រាស់របាយការណ៍នេះ នឹងបន្តគាំទ្រដល់ការជំរុញអោយស្ត្រីចូលរួមអោយបានច្រើនក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ។ របាយការណ៍នេះ ជារបាយការណ៍ស្រាវជ្រាវលើកដំបូងអំពី ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងវិស័យអប់រំ និងការងារ ។ ដូច្នេះវាជៀសមិនផុតពីការខុសឆ្គងនានាបានឡើយ ។ យើងខ្ញុំ សូមស្វាគមន៍យ៉ាងកក់ក្ដៅរាល់ការរិះគន់កែលំអនិងសំណូមពរផ្សេងៗពីសំណាក់ប្រិយមិត្តអ្នកអាន និងអ្នកប្រើប្រាស់ទាំងអស់ ។

# តារាងមាតិកា

អារម្ភកថា ...... i
សេចក្ដីថ្លែងអំណរគុណ ...... ii
បញ្ជីតារាង និងក្រាហ្វិក ...... iii
សេចក្ដីសង្ខេប ...... iv
១. សេចក្ដីផ្ដើម ...... ១
១.១. លំនាំដើម ...... ១
១.២. ន័យនៃពាក្យ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ឬ ICT ប្រើក្នុងការសិក្សាស្រាវជ្រាវនេះ ...... ២
១.៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ...... ២
១.៣.១. គោលបំណងរួម ...... ២
១.៣.២. វត្ថុបំណងនៃការស្រាវជ្រាវ ...... ៣
១.៣.២.១. សមាមាត្រនៃស្ត្រី ដែលទទួលបាន និងប្រើប្រាស់ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងវិស័យអប់រំ និងការងារ ...... ៣
១.៣.២.២. ទស្សនៈវិស័យរបស់ស្ត្រីក្នុងវិស័យការងារ និងអប់រំដែលមានទំនាក់ទំនងជាមួយផ្នែក ICT ...... ៣
១.៣.២.៣. ឧបសគ្គដែលរារាំងស្ត្រី ពីការចូលទៅកាន់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ និងការងារ ...... ៣
២. ឯកសារដែលពាក់ព័ន្ធ ...... ៥
២.១. ប្រវត្តិនៃការប្រើបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការអភិវឌ្ឍន៍ ...... ៥
២.២. បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ ...... ៦
២.២.១. ស្ថានភាពនៃការអប់រំរបស់ក្មេងស្រី និងស្ត្រីជាសាកល ...... ៦
២.២.២. ផលប្រយោជន៍នៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ...... ៧
២.២.៣. កត្តារាំងស្ទះពីការទទួលបានផលប្រយោជន៍នៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ...... ៨
២.២.៤. យុទ្ធសាស្ត្រដើម្បីជំរុញអោយស្ត្រីចូលរួមក្នុងការអប់រំវិទ្យាសាស្ត្រ និងបច្ចេកទេស ...... ៩
២.៣. បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យការងារ ...... ១០
២.៤. ការសិក្សាស្រាវជ្រាវនានាទាក់ទងនឹងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងប្រទេសកម្ពុជា ...... ១២
២.៥. គោលនយោបាយបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ...... ១៦
២.៥.១. ការដកស្រង់ចំណុចសំខាន់ៗដែលបានចែង ក្នុងច្បាប់ និងគោលនយោបាយក្នុងប្រទេសកម្ពុជា ដែលនិយាយពីបញ្ហាការងារ និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ...... ១៦
២.៥.២. ផែនការសកម្មភាពទីក្រុងប៉េកាំង (Beijing Platform for action, 1995) ...... ១៨
៣. វិធីសាស្ត្រនៃការស្រាវជ្រាវ ...... ២១
៣.១. ក្រុមគោលដៅនៃការស្រាវជ្រាវ ...... ២៤
៣.២. វិធីសាស្ត្រប្រមូលទិន្នន័យ ...... ២៤

# តារាងមាតិកា


៣.៣. ការវិភាគទិន្នន័យ..........២៥
៣.៤. ការបណ្តុះបណ្តាលអំពីការប្រមូលទិន្នន័យ និងក្រមសីលធម៌..........២៦
៣.៥. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ..........២៧
៤. លទ្ធផលនៃការស្រាវជ្រាវ..........២៩
៤.១. ព័ត៌មានទូទៅ..........២៩
៤.២. ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ..........៣០
៤.២.១. ស្ថិតិរបស់ស្ត្រីក្នុងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ..........៣០
៤.២.២. ភាពឆ្លើយតបនៃកម្មវិធីសិក្សាផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានៅតាមគ្រឹះស្ថានឧត្តមសិក្សាចំពោះការងារ..........៣៤
៤.៣. ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យការងារ..........៣៦
៤.៤. គំនាបរបស់ស្ត្រី ពីការចូលក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា..........៤៥
៤.៥. ទស្សនៈវិស័យផ្សេងៗ..........៤៩
៥. ការពិភាក្សា..........៥៧
៥.១. ពិភាក្សាលើវិធីសាស្ត្រស្រាវជ្រាវ..........៥៧
៥.២. ពិភាក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ..........៥៧
៥.២.១. ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ..........៥៧
៥.២.២. ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យការងារ..........៥៨
៦. សរុបលទ្ធផល..........៦៥
៧. អនុសាសន៍..........៦៩
ឯកសារយោង..........៧១
ឧបសម្ព័ន្ធ..........៧៥
ឧបសម្ព័ន្ធទី១៖ កម្រងសំណួរ សម្រាប់អ្នកតំណាងស្ថាប័ន..........៧៥
ឧបសម្ព័ន្ធទី២៖ កម្រងសំណួរបន្ថែម សម្រាប់អ្នកតំណាងស្ថាប័នអប់រំ..........៧៩
ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរ សម្រាប់បុគ្គលិក..........៨៤
ឧបសម្ព័ន្ធទី៤៖ កម្រងសំណួរសម្រាប់សម្ភាសស៊ីជម្រៅជាមួយបុគ្គលិកដែលមានតួនាទីសំខាន់ក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា..........៩៣
ឧបសម្ព័ន្ធទី៥៖ កម្រងសំណួរសម្រាប់ការពិភាក្សាជាក្រុមជាមួយនិស្សិតសិក្សាផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា.....៩៥
ឧបសម្ព័ន្ធទី៦៖ សូចនាករក្នុងការវាយតម្លៃការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានៅលើគេហទំព័រការងារ..........៩៦
ឧបសម្ព័ន្ធទី៧៖ ការដកស្រង់នូវចំណុចសំខាន់ៗដែលបានចែង ក្នុងច្បាប់ និងគោលនយោបាយក្នុងប្រទេសកម្ពុជា ដែលនិយាយពីបញ្ហាការងារ និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា..........៩៧

# បញ្ជីតារាង និងក្រាហ្វិក

## បញ្ជីតារាង

តារាងទី១៖ វិធីសាស្ត្រសិក្សាស្រាវជ្រាវ និងឧបករណ៍ស្រាវជ្រាវ.....២១
តារាងទី២៖ កម្រងសំណួរដែលប្រមូលបាន.....២៩
តារាងទី៣៖ ចំនួនជាមធ្យមនៃបុគ្គលិកតាមស្ថាប័ននីមួយ.....៣០
តារាងទី៤៖ ស្ថិតិនិស្សិតដែលបានបញ្ចប់ការសិក្សា និងកំពុងសិក្សាមុខវិជ្ជា ICT ថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់.....៣០
តារាងទី៥៖ កម្រិតនៃភាពឆ្លើយតបរបស់កម្មវិធីសិក្សា ICT ចំពោះទីផ្សារការងារ ICT របស់ស្ថាប័នអប់រំ.....៣៥
តារាងទី៦៖ សមាមាត្រនៃស្ត្រីដែលធ្វើការក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា.....៣៦
តារាងទី៧៖ អត្រាតម្រូវការស្ត្រីដែលមានចំណេះដឹងផ្នែក ICT នៅតាមស្ថាប័នផ្សេងគ្នា.....៣៧
តារាងទី៨៖ ការលំបាកក្នុងការស្វែងរកការងារ រវាងអ្នកមានសញ្ញាប័ត្រផ្នែក ICT ធៀបជាមួយសញ្ញាប័ត្រផ្សេងទៀត .....៣៧
តារាងទី៩៖ ផលប្រយោជន៍នៃការប្រើប្រាស់កុំព្យូទ័រ និងអ៊ីនធឺណិតរបស់អ្នកដែលមានតួនាទីសំខាន់ក្នុងផ្នែក ICT .....៣៩
តារាងទី១០៖ រយៈពេលប្រើប្រាស់អ៊ីនធឺណិត (ខែ/ឆ្នាំ).....៤០
តារាងទី១១៖ បម្រែបម្រួលនៃការប្រើប្រាស់កុំព្យូទ័រធៀបជាមួយឆ្នាំមុនៗ.....៤១
តារាងទី១២៖ ការប្រើប្រាស់បច្ចេកវិទ្យា ICT ផ្សេងៗទៀតក្រៅពីកុំព្យូទ័រនិងអ៊ីនធឺណិត.....៤២
តារាងទី១៣៖ ទំនាក់ទំនងរវាងជំនាញនៃការប្រើប្រាស់កុំព្យូទ័រ និងកម្រិតការងារ.....៤៣
តារាងទី១៤៖ កម្រិតនៃការយល់ស្រប អំពីគំនាបរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា.....៤៥
តារាងទី១៥៖ វប្បធម៌ខ្មែរមានការលើកទឹកចិត្តដល់រវាងបុរសនិងស្ត្រីក្នុងការចូលរួមសិក្សា.....៤៦
តារាងទី ១៦៖ គំនាប និងឧបសគ្គដែលរារាំងស្ត្រីពីការចូលសិក្សាក្នុងផ្នែកអប់រំ និងការងារបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ..........៤៦
តារាងទី១៧៖ ទស្សនវិស័យ ការប្តេជ្ញា និងការលះបង់ របស់បុគ្គលដើម្បីទទួលបាន ICT.....៤៩
តារាងទី១៨៖ ទស្សនវិស័យចំពោះស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងប្រទេសកម្ពុជា.....៥០

## បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១៖ បំណែងចែកនៃកម្រិតតម្រូវការ ICT នៅតាមប្រភេទការងារនៅលើគេហទំព័រការងារ.....៣៨
ក្រាហ្វិកទី២៖ ចំណាត់ថ្នាក់នៃជំនាញការប្រើប្រាស់ ICT តាមភេទ.....៣៩
ក្រាហ្វិកទី៣៖ ទីកន្លែងដែលពួកគាត់តែងតែប្រើប្រាស់ ICT.....៤០
ក្រាហ្វិកទី៤៖ បំណែងចែកនៃការប្រើប្រាស់អ៊ីនធឺណិតតាមភេទ.....៤១
ក្រាហ្វិកទី៥៖ ភាគរយតាមស្ថាប័ននីមួយៗដែលមានគោលនយោបាយលើកកម្ពស់ស្ត្រី.....៤៤
ក្រាហ្វិកទី៦ ៖ ស្ត្រីអាចត្រូវបានគេផ្តល់ភាពអង់អាចតាមរយៈការប្រើប្រាស់ ICT (អ្នកតំណាងស្ថាប័ន).....៥៣
ក្រាហ្វិកទី៧៖ ស្ត្រីអាចត្រូវបានគេផ្តល់ភាពអង់អាចតាមរយៈការប្រើប្រាស់ ICT (បុគ្គលិកស្ថាប័ន).....៥៣
ក្រាហ្វិកទី៨៖ រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល គួរតែធ្វើសកម្មភាពអោយបានច្រើនថែមទៀតក្នុងការធ្វើអោយប្រសើរឡើងនូវស្ថានភាព ICT របស់ស្ត្រី ក្នុងវិស័យអប់រំ និងការងារ (អ្នកតំណាងស្ថាប័ន).....៥៤
ក្រាហ្វិកទី៩៖ រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល គួរតែធ្វើសកម្មភាពអោយបានច្រើនថែមទៀតក្នុងការធ្វើអោយប្រសើរឡើងនូវស្ថានភាព ICT របស់ស្ត្រី ក្នុងវិស័យអប់រំ និងការងារ (បុគ្គលិកស្ថាប័ន).....៥៤

## សេចក្តីសង្ខេប


នៅក្នុងពិភពលោកយើងនេះ បច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យា ដែលជាភាសាអង់គ្លេសហៅថា Information Communication Technology ឬហៅកាត់ថា ICT មានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃឥតឈប់ឈរ ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ។ ការទទួលយកនៃបច្ចេកវិទ្យា ICT មានភាគច្រើនចំពោះតែប្រជាជននៅតាមទីក្រុង ក៏ដូចជាប្រជាជនដែលមានចំណេះវិជ្ជាក្នុងការស្រូបយកផលចំណេញពីបច្ចេកវិទ្យានេះបានយ៉ាងគាប់ប្រសើរទាំងក្នុងវិស័យអប់រំ ក៏ដូចជាវិស័យការងារ ។ អត្រានៃការទទួលបាន និងប្រើប្រាស់បច្ចេកវិទ្យា ICT ថ្មីនេះ គឺនៅមានកម្រិតនៅឡើយ មិនថាតែនៅក្នុងប្រទេសអភិវឌ្ឍ ឬប្រទេសកំពុងអភិវឌ្ឍនោះទេ ពិសេស សមាមាត្ររបស់ស្ត្រី ធៀបជាមួយនឹងបុរស ។

ក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការវិទ្យាស្ថានបើកទូលាយ បានរៀបចំការសិក្សាស្រាវជ្រាវអំពី "ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យា ក្នុងវិស័យអប់រំ និងការងារ" នេះឡើង ក្នុងគោលបំណងស្វែងយល់ពីវិសាលភាពទស្សនវិស័យយេនឌ័រនៃវិស័យ ICT ដោយផ្តោតសំខាន់លើវិស័យអប់រំ និងការងារ ដើម្បីចូលរួមលើកកម្ពស់ប្រសិទ្ធភាពនៃការអប់រំ និងធ្វើអោយប្រសើរឡើងនូវស្ថានភាពការងាររបស់ស្ត្រីក្នុងផ្នែកបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា ។ ការសិក្សាស្រាវជ្រាវធ្វើនៅរាជធានីភ្នំពេញតែប៉ុណ្ណោះ ដោយផ្តោតលើស្ថាប័នគោលដៅបួន គឺក្រសួងនានានិងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៏វិស័យបច្ចេកវិទ្យា និងព័ត៌មានវិទ្យា គ្រឹះស្ថានឧត្តមសិក្សាផ្នែកសាធារណៈនិងឯកជន អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ដែលមានសរុបចំនួន៤៣១ ស្ថាប័ន ។

វិធីសាស្ត្រស្រាវជ្រាវ បែបគុណភាព និងបែបបរិមាណត្រូវបានសំយោគប្រើ ដើម្បីអោយទិន្នន័យរឹតតែអាចឆ្លុះបញ្ចាំងពីតថភាព និងនិន្នាការនៃការសិក្សា និងការប្រើប្រាស់ ICT ក្នុងរាជធានីភ្នំពេញ ។ ទិន្នន័យបែបបរិមាណបានទទួលពីការសម្ភាសជាមួយអ្នកតំណាងស្ថាប័ន និងបុគ្គលិកដែលបម្រើការងារនៅក្នុងស្ថាប័ន ។ ការប្រមូលទិន្នន័យក៏រួមបញ្ចូលនូវការវិភាគការងារដែលបានផ្សព្វផ្សាយនៅលើគេហទំព័រការងារសំខាន់ៗក្នុងប្រទេសកម្ពុជាពីរគឺ គេហទំព័រ បងធំ និងពេលព្រឹក ។ ចំណែកឯទិន្នន័យបែបគុណភាពទទួលបានពីការសម្ភាសបែបស៊ីជម្រៅជាមួយបុគ្គលិកដែលមានតួនាទី សំខាន់ក្នុងផ្នែក ICT របស់ស្ថាប័ន និងការពិភាក្សាជាក្រុមជាមួយនិស្សិតដែលសិក្សាមុខវិជ្ជានេះ នៅក្នុងស្ថាប័នអប់រំ ជាន់ខ្ពស់ ។ លើសពីនេះទៀត ការសិក្សាស្រាវជ្រាវក៏បានពិនិត្យឡើងវិញពីឯកសារពាក់ព័ន្ធនានា និងការសិក្សាស្រាវជ្រាវឯកសារ ដែលមាននៅក្នុងស្រុក និងក្រៅស្រុកផងដែរ ។ កម្រងសំណួរបានគ្រប់គ្រង និងវិភាគតាមរយៈកម្មវិធីវិភាគទិន្នន័យមួយចំនួនដូចជា Epidata 3.1, Nvivo 8.0 , SPSS 18.0 និងកម្មវិធីកុំព្យូទ័រជាភាសាខ្មែរ ។

ការសិក្សានេះបានរកឃើញលទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១. ក្នុងចំណោមមុខវិជ្ជា ICT ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ ឬព័ត៌មានវិទ្យា មាននិស្សិតសិក្សាច្រើនជាងគេ ប៉ុន្តែបើគិតពីសមាមាត្រនៃស្ត្រីវិញ ជំនាញប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ មានចំនួនច្រើនជាងគេ ។ គិតចាប់ពីឆ្នាំ២០០៥-២០០៩ មានអ្នកបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួន ៥៨៤៣នាក់ ដែលក្នុងនោះស្ត្រីបានបញ្ចប់ការសិក្សាផ្នែក ICT មាន ១២,៤% តែប៉ុណ្ណោះ ហើយបើធៀបជាមួយនឹងនិស្សិតកំពុងសិក្សាចាប់ពីឆ្នាំទី១ ដល់ឆ្នាំទី៤ នៃឆ្នាំសិក្សា២០០៩-២០១០ ដែលមាននិស្សិតសរុបចំនួន ១០៦១០នាក់ សមាមាត្រស្ត្រីបានធ្លាក់ចុះត្រឹមតែ ៩,១% ។

# សេចក្តីសង្ខេប

២. ចំនួននិស្សិតសិក្សាក្នុងកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ធ្លាក់ចុះប្រហែល ២,៥ដង បើធៀបនឹងអ្នកកំពុងសិក្សាឆ្នាំទី១ ជាមួយនឹងអ្នកសិក្សាកាលពីបីឆ្នាំមុនដែលថយចុះពី ៣២០នាក់ មកត្រឹមតែ ១៣៤ នាក់ ។ អត្រាស្ត្រីសិក្សានេះ ក៏មានការថយចុះយ៉ាងខ្លាំងពី ៣៥,៣% ក្នុងឆ្នាំ២០០៧-២០០៨ មកត្រឹម ៦,២% ក្នុងឆ្នាំ២០០៨-២០០៩ ។ បន្ថែមលើសនេះ សមាមាត្រស្ត្រីបន្តធ្លាក់ចុះមកត្រឹម ៥,៤% ក្នុងឆ្នាំទី២ និងបន្តធ្លាក់ចុះមកត្រឹម ៥,២% ក្នុងឆ្នាំទី១នៃឆ្នាំសិក្សា២០០៩-២០១០ ។

៣. តម្រូវការបុគ្គលិកស្ត្រី ក្នុងការងារ ICT នៅតាមស្ថាប័នដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ក្រសួងនានា មានតម្រូវការបុគ្គលិកច្រើនជាងគេ មានដល់ ៥៣% ដែលតម្រូវការបុគ្គលិកមានចំណេះដឹងផ្នែក ICT ជាមធ្យម១០នាក់ ក្នុងនោះស្រី ៦នាក់ (៦០%) ។ ស្ថាប័នអប់រំ មានតម្រូវការ ៣៥% តម្រូវការបុគ្គលិកដែលមានចំណេះដឹងផ្នែក ICT ជាមធ្យម ៥នាក់ និងស្រី ២នាក់ (៤០%) ។ អង្គការសង្គមស៊ីវិល បានត្រូវការប្រហែលពាក់កណ្តាលនៃតម្រូវការរបស់ក្រសួងនានា (២៥%) មានតម្រូវការបុគ្គលិកមានចំណេះដឹងផ្នែក ICT ជាមធ្យម២នាក់ ក្នុងនោះមានស្រី១នាក់ (៥០%) និងផ្នែកឯកជន (ISP និងហាងអ៊ីនធឺណិត) ១១,៧% មានតម្រូវការបុគ្គលិកផ្នែក ICT ជាមធ្យម ២នាក់ ក្នុងនោះមានស្រី១នាក់ (៥០%) ។

៤. តាមរយៈការផ្សព្វផ្សាយនៅក្នុងគេហទំព័រការងារពីរគឺ (បងធំ និងពេលព្រឹក) មានជ្រើសរើសបុគ្គលិកដែលធ្វើការក្នុងការងារកម្រិតខ្ពស់ និងកម្រិតកណ្តាល ចាំបាច់អោយមានជំនាញ ICT តែមិនចាំបាច់មានជំនាញខ្ពស់ទេ (ការងារកម្រិតកណ្តាលត្រូវការជំនាញ ICT ខ្ពស់ ៨,៣% និងការងារកម្រិតខ្ពស់ត្រូវការជំនាញ ICT ខ្ពស់ចំនួន ៥,៧%) ។

៥. ស្ត្រី និងបុរស ដែលមានសញ្ញាប័ត្រ ICT មានការលំបាកខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះក្នុងការស្វែងរកការងារផ្នែក ICT ធៀបនឹងអ្នកមិនមានសញ្ញាប័ត្រ ICT (ស្ត្រី ៤៦,២% ធៀបនឹងបុរស ៤៣,៨%) ។

៦. ក្នុងចំណោមបុគ្គលិកដែលចេះប្រើប្រាស់កុំព្យូទ័រ និងអ៊ីនធឺណិតមានស្ត្រីតែ២០,៤% ប៉ុណ្ណោះក្នុងនោះអង្គការសង្គមស៊ីវិល មានអ្នកចេះប្រើច្រើនជាងគេ គឺស្មើនឹង ៤៤,៤% ក្រសួងនានា ១៥,៥% ផ្នែកឯកជន (ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត និងហាងអ៊ីនធឺណិត) ៣២,៥% និងគ្រឹះស្ថានអប់រំឧត្តមសិក្សាមាន ៣៣,៣% ។

៧. ស្ត្រីជំនាញប្រើប្រាស់កុំព្យូទ័រមានចំនួន ៦,៩% តិចជាងបុរសប្រហែល ៥ដង (៣៣,៦%) ។ អ្នកជំនាញកុំព្យូទ័រ ក្នុងការងារកម្រិតទាប មាន ២,៩% កម្រិតកណ្តាលមាន ៨៤,៥% និងកម្រិតខ្ពស់មាន ១២,៦% ។

៨. គំនាប និងការរាំងស្ទះស្ត្រីក្នុងការចូលរួមការងារផ្នែក ICT មានបញ្ហាសំខាន់ៗមួយចំនួន ដែលការសិក្សាស្រាវជ្រាវ បានរកឃើញមកពីការស្ទង់មតិជាមួយបុគ្គលិកធ្វើការនៅតាមស្ថាប័ន រួមមាន៖

- ៧០% ឆ្លើយថា និស្សិតទើបបានបញ្ចប់ការសិក្សានៅខ្វះបទពិសោធន៍
- ៦៦% ឆ្លើយថា ស្ត្រីទទួលខុសត្រូវក្នុងគ្រួសារច្រើនជាងបុរស
- ៦៤% យល់ថា អាណាព្យាបាលភាគច្រើនអោយកូនប្រុសរៀនបានច្រើន និងខ្ពង់ខ្ពស់ជាងស្ត្រី
- ៦០% យល់ថាគោលនយោបាយ និងការអនុវត្តគោលនយោបាយ ក៏ជាបញ្ហារាំងស្ទះមួយដែរ
- ៥៧% យល់ថា ភាសាគឺជាបញ្ហារាំងស្ទះមួយដែរ

- ៥៣% យល់ថាហេដ្ឋារចនាសម្ព័ន្ធ ICT នៅមានកម្រិត
- ៥២% បានអោយដឹងថា តម្លៃអ៊ីនធឺណិត ថ្លៃ
- ៤៥% បណ្តាលមកពីលក្ខណៈជីវសាស្ត្រ
- ៤០% យល់ថាបច្ចេកវិជ្ជាដើរលឿនពេក
- ៣១% យល់ថាបទដ្ឋានសង្គម និងវប្បធម៌
- ២៦% យល់ថាចៅហ្វាយនាយមិនលើកទឹកចិត្តស្ត្រីឲ្យធ្វើការផ្នែក ICT ទេ ។

៩. អ្នកតំណាងស្ថាប័ន ៨៧% និងបុគ្គលិក ៩២% យល់ឃើញថា ស្ត្រីអាចត្រូវបានគេផ្តល់ភាពអង់អាច តាមរយៈការប្រើប្រាស់ ICT ។

## អនុសាសន៍

- រដ្ឋាភិបាល គួរបន្តជំរុញ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ សម្រាប់ផ្នែកICT អោយបានគ្រប់គ្រាន់នៅទូទាំងប្រទេស ។
- បើអាចធ្វើបាន រដ្ឋាភិបាល គួរបញ្ចូលកម្មវិធីសិក្សា ICT តាំងពីថ្នាក់វិទ្យាល័យ នៅជនបទ និងនៅទីក្រុង ។
- បន្តអនុវត្ត គោលនយោបាយ ជំរុញ និងលើកទឹកចិត្តអោយមានស្ត្រីកាន់តែច្រើនថែមទៀត បានចូលសិក្សាក្នុងមុខវិជ្ជា ICT ដោយផ្តល់ជាអាហារូបករណ៍ ការបញ្ចុះតម្លៃសិក្សា និងលើកទឹកចិត្តគ្រប់បែបយ៉ាងដល់និស្សិតស្រី ។
- ក្រសួង និងស្ថាប័ននានាទាំងផ្នែកសាធារណៈ និងឯកជន រួមទាំងសហគ្រាស និងផ្នែកឯកជន គួរផ្តល់ឱកាសដល់និស្សិតដែលទើបបញ្ចប់ការសិក្សា ពិសេសនិស្សិតស្រី អោយបានចូលបម្រើការងារសាកល្បង និងផ្តល់ឱកាសការងារ ។
- រដ្ឋាភិបាលគួរ លើកទឹកចិត្តបង្កើតអោយមានកម្មវិធីកុំព្យូទ័រជាភាសាខ្មែរ អោយបានកាន់តែច្រើន ។
- បើអាចធ្វើទៅបាន សូមអោយមានការសិក្សាស្រាវជ្រាវថ្មីបន្ថែមទៀត ស្តីអំពីបញ្ហានេះអោយបានទូលំទូលាយទូទាំងប្រទេស ក៏ដូចជាធ្វើការសិក្សាអោយបានស៊ីជម្រៅបន្ថែមទៀត។

# ១. សេចក្តីផ្តើម

## ១.១. លំនាំដើម

នៅទូទាំងសាកលលោក បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដែលជាភាសាអង់គ្លេសហៅថា Information Communication Technology ឬហៅកាត់ថា ICT មានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃឥតឈប់ឈរ ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ បានបង្កើតជាគ្រឹះនៃសេដ្ឋកិច្ចថ្មីមួយដែលគេអោយឈ្មោះថា "យកកម្លាំងអានុភាពពីបច្ចេកវិទ្យា ថាមពលពីព័ត៌មាន និងដឹកនាំតាមចំណេះដឹង" ( US Department of Labor, 1999 ) ។

បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា គឺជាយន្តការយ៉ាងសំខាន់បំផុត ក្នុងការកែប្រែសង្គម សេដ្ឋកិច្ច និងនយោបាយអោយមានការរីកចម្រើន ដោយមិនប្រកាន់អំពីអាយុ យេនឌ័រ ជាតិសាសន៍ ពិការភាព ឬទីតាំងឡើយ ។ វាបាននាំមកនូវការអភិវឌ្ឍថ្មីៗ និងលើកកម្ពស់ការប្រកួតប្រជែងនៅក្នុងបរិបទសេដ្ឋកិច្ចពិភពលោក ។ ការងារនៅក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដូចជា ទូរគមនាគមន៍ បណ្តាញអ៊ីនធឺណិត និងការងារពាក់ព័ន្ធមួយចំនួនទៀត គឺជាប្រភពដ៏សំខាន់សម្រាប់ការរីកចម្រើន និងមានសារសំខាន់សម្រាប់ការរីកលូតលាស់នៃសេដ្ឋកិច្ច ។

ទោះជាយ៉ាងនេះក្តី ភាពប្រកួតប្រជែងវាអាស្រ័យលើសមត្ថភាពទាក់ទាញប្រយោជន៍ និងបុគ្គលិកមានជំនាញដែលនៅក្នុងនោះមានស្ត្រីផងដែរ ។ នៅត្រង់ចំណុចនេះ យើងមានហេតុផលច្រើនណាស់ ក្នុងការសិក្សាពីប្រធានបទនេះនៅក្នុងប្រទេសកម្ពុជាដោយយើងបានសង្កេតឃើញថា៖

- បញ្ហាយេនឌ័រ គឺជាបញ្ហាសាកលមួយសម្រាប់យើងទាំងអស់គ្នានៅក្នុងការអភិវឌ្ឍ ដែលមានការពាក់ព័ន្ធមិនត្រឹមតែជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ ភ្នាក់ងារអភិវឌ្ឍន៍អង្គការជាតិប៉ុណ្ណោះទេ ប៉ុន្តែមានការពាក់ព័ន្ធសំខាន់ជាមួយអ្នកដឹកនាំ និងស្ថាប័នក្នុងស្រុកផងដែរ ។
- នៅក្នុងប្រទេសកម្ពុជា ស្ត្រីភាគច្រើននៅឃ្លាតឆ្ងាយពីសេដ្ឋកិច្ចដែលពឹងផ្អែកលើចំណេះដឹង ដោយសារតែបុរសភាគច្រើនជាអ្នកធ្វើការសម្រេចចិត្ត ឱកាសមិនស្មើគ្នារវាងបុរស និងស្ត្រីក្នុងការទទួលបានការអប់រំ ការខ្វះខ្ញឹមសារអត្ថបទជាភាសាខ្មែរ ការខ្វះចំណេះដឹងដើម្បីស្វែងរកការគាំទ្រមតិក្នុងគោលនយោបាយ និងឧបសគ្គមួយចំនួនទៀត ។ ស្ត្រីភាគច្រើន នៅមិនទាន់ទទួលបាននូវការភ្ជាប់សេវា បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាដែលមានតម្លៃសមរម្យ អាចទុកចិត្តបាន និងមានភាពគ្រប់គ្រាន់នៅឡើយទេ ។ គម្លាតឌីជីថលនេះ... 

- ការឆ្លើយតបរបស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងបុគ្គលិកដើម្បីធ្វើអោយប្រសើរឡើងនូវស្ថានភាពស្ត្រីក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា នៅមានកម្រិតនៅឡើយ ។ ជាក់ស្តែង ហេដ្ឋារចនាសម្ព័ន្ធ ICT ត្រូវបានទទួលការយកចិត្តទុកដាក់ពីសំណាក់អ្នកតាក់តែងគោលនយោបាយ ក៏ដូចជាការអនុវត្តក្នុងវិស័យអប់រំផងដែរ ប៉ុន្តែមិនទាន់បានដោះស្រាយអោយមានប្រសិទ្ធភាពនូវកត្តាមួយចំនួនដែលបានរាំងស្ទះដល់ស្ត្រីក្នុងការទទួលបាន បច្ចេកវិទ្យាថ្មីៗអោយដូចបុរសនោះទេ ។

# ១. សេចក្ដីផ្ដើម

- ថ្វីត្បិតតែមនុស្សគ្រប់រូបមិនសុទ្ធតែត្រូវការ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា តែការធ្វើអោយទទួលបានផលប្រយោជន៍ជាអតិបរមា អំពីបញ្ហានេះជារឿងសំខាន់ ។ ដូច្នេះ មានបញ្ហាជាច្រើនដែលយើងគួរតែយកចិត្តទុកដាក់ថែមទៀត ចំពោះមនុស្សទូទៅ ជាពិសេសស្ត្រីដែលស្ថិតនៅខាងក្រោយវិស័យ ICT ។
- ចំពោះការសិក្សានៅថ្នាក់ខ្ពស់ ចំនួនស្ត្រីនៅមានចំនួនតិចនៅឡើយ បើប្រៀបធៀបជាមួយបុរស ជាពិសេសផ្នែកព័ត៌មានវិទ្យា ។ បញ្ហាទាំងនេះ ក៏បានជះឥទ្ធិពលដោយផ្ទាល់ដល់តួនាទីរបស់ស្ត្រីក្នុងទីផ្សារការងារផងដែរ ហើយវាក៏ជាដើមហេតុធ្វើអោយពួកគេទាំងនោះមានសេដ្ឋកិច្ចទន់ខ្សោយ នៅក្នុងសង្គម និងសេចក្ដីសម្រេចចិត្តរបស់គេក៏នៅមានកម្រិតដែរ ។
- មិនមានរបាយការណ៍សិក្សាស្រាវជ្រាវអោយបានច្រើនដែលទាក់ទងនឹងបញ្ហាស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ចាប់តាំងពីការបង្កើតអោយមានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការ អភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានក្នុងឆ្នាំ២០០០ ។

ដោយយល់ឃើញពីបញ្ហាទាំងនេះហើយ ទើបក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការវិទ្យាស្ថានបើកទូលាយ បានរៀបចំការសិក្សាស្រាវជ្រាវនេះឡើង ក្នុងគោលបំណងស្វែងយល់ពីវិសាលភាពទស្សនវិស័យយេនឌ័រ នៃវិស័យ ICT ដោយផ្ដោតសំខាន់លើវិស័យអប់រំ និងការងារ ដើម្បីចូលរួមលើកកម្ពស់ប្រសិទ្ធភាពនៃការអប់រំ និងធ្វើអោយប្រសើរឡើងនូវស្ថានភាពការងាររបស់ស្ត្រីក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ។

ការសិក្សាស្រាវជ្រាវនេះ បានផ្ដល់នូវព័ត៌មានគ្រឹះមួយចំនួន អំពីស្ថានភាព និងនិន្នាការនៃការប្រើប្រាស់ និងទទួលយកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក៏ដូចជាបានផ្ដល់នូវអនុសាសន៍មួយចំនួនដល់ស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកដែលធ្វើការពាក់ព័ន្ធនឹងបញ្ហានេះ ។ នៅពេលនោះ វាពិតជាបានជួយបង្កើតអោយមានទស្សនវិស័យ យុទ្ធសាស្ត្រ គោលនយោបាយ និងគម្រោងល្អៗ ដើម្បីធ្វើអោយមានភាពជោគជ័យនៅក្នុងការអភិវឌ្ឍ ។

## ១.២. ន័យនៃពាក្យ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ឬ ICT ប្រើក្នុងការសិក្សាស្រាវជ្រាវនេះ

ក្នុងន័យទូទៅ ពាក្យថា ICT គឺគេសំដៅទៅលើការគ្របនៃបច្ចេកវិទ្យាទំនើបៗទាំងអស់នៅក្នុងដំណើរប្រតិបត្តិការ និងទំនាក់ទំនងព័ត៌មាន ដូចជាការរក្សាទុកនូវព័ត៌មាន (magnetic disk, optical disks (CD/DVD), flash memory) ការផ្សព្វផ្សាយព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ ទូរទស្សន៍) បច្ចេកវិទ្យាទំនាក់ទំនងតាមរយៈសំឡេង និងសូរ ឬក៏រូបភាព (មីក្រូហ្វូន កាមេរ៉ា អូប៉ាល័រ ទូរសព្ទ MP3, MP4, MP5, MP6) ហើយនិងផ្នែកទន់កុំព្យូទ័រ (PCs, Servers, mainframes and networked storage) ។

ទោះជាយ៉ាងនេះក្ដី ពាក្យថា បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ឬហៅកាត់ថា ICT ដែលបានប្រើនៅក្នុងការសិក្សាស្រាវជ្រាវនេះ គឺសំដៅត្រឹមតែការប្រើប្រាស់កុំព្យូទ័រ ឬកុំព្យូទ័រដែលភ្ជាប់អ៊ីនធឺណិតសម្រាប់ការសិក្សា និងការងារតែប៉ុណ្ណោះ ។

## ១.៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

### ១.៣.១. គោលបំណងរួម

ស្វែងយល់ពីវិសាលភាពទស្សនវិស័យយេនឌ័រ នៃវិស័យ ICT ដោយផ្ដោតសំខាន់លើវិស័យអប់រំ និងការងារ ។

### ១.៣.២. វត្ថុបំណងនៃការស្រាវជ្រាវ

ផ្តល់របាយការណ៍អំពីស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យារបស់ស្ត្រី ក្នុងវិស័យអប់រំ និងការងារនៅរាជធានីភ្នំពេញក្នុងឆ្នាំ២០១០ ។

**១.៣.២.១. សមាមាត្រស្ត្រីដែលទទួលបាន និងប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងវិស័យអប់រំ និងការងារ**

ក. ស្ត្រីដែលទទួលបានសញ្ញាប័ត្រ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (បរិញ្ញាបត្រ អនុបណ្ឌិត

ខ. ការទទួលបានវគ្គបណ្តុះបណ្តាលអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

គ. ស្ត្រីធ្វើការក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

**១.៣.២.២. ទស្សនវិស័យយេនឌ័រក្នុងវិស័យការងារ និងអប់រំដែលមានទំនាក់ទំនងជាមួយផ្នែក ICT**

ក. ការបង្ហាញពីតម្រូវការទីផ្សារការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (ការផ្សាយការងារ និងនៅតាមស្ថាប័ន)

ខ. ការផ្តល់ភាពអង់អាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត រវាងបុរស និងស្ត្រីក្នុងការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

គ. ការលះបង់របស់ស្ថាប័នដើម្បីធ្វើអោយប្រសើរឡើងនូវការបណ្តុះបណ្តាលស្ត្រីអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

**១.៣.២.៣. ឧបសគ្គដែលរារាំងស្ត្រី ពីការចូលទៅកាន់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ និងការងារ**

ក. ការវិភាគអំពីគោលនយោបាយបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

ខ. ឧបសគ្គ និងការរារាំងផ្នែកសេដ្ឋកិច្ច-សង្គម

គ. ទស្សនវិស័យបុគ្គល ឬការលះបង់ ដើម្បីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

## ២. ការសិក្សាលើឯកសារដែលពាក់ព័ន្ធ

នៅក្នុងប្រទេសកម្ពុជា ការសិក្សាស្រាវជ្រាវអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយទេ ។ ក្រុមការងារបានព្យាយាមប្រមូលឯកសារ និងព័ត៌មានផ្សេងៗអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ទាំងនៅលើឆាកអន្តរជាតិ និងនៅក្នុងស្រុក ដើម្បីយកមកបង្ហាញជូន ។ ដូច្នេះការសិក្សាស្រាវជ្រាវនេះនឹងអាចជួយរំលេចអំពីស្ថានភាពជាក់ស្តែងនៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងប្រទេសកម្ពុជា ។

### ២.១. ប្រវត្តិនៃការប្រើបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការអភិវឌ្ឍ

ឫសគល់នៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា សម្រាប់ការអភិវឌ្ឍ ត្រូវបានបង្កើតឡើងនៅក្នុងទសវត្សឆ្នាំ ១៩៧០ ដែលពេលនោះសេដ្ឋកិច្ច និងសង្គម កំពុងត្រូវបានគេធ្វើបដិវត្ត ដោយមិនប្រើប្រាស់ឧស្សាហកម្ម តែប្រើប្រាស់ព័ត៌មាន និងចំណេះដឹងដែលមានសារសំខាន់ក្នុងការការពារមធ្យោបាយផលិតកម្ម (McLuhan, 1964; Bell, 1973 and Porat, 1984) ។ ការពិភាក្សាពីគោលនយោបាយជាផ្លូវការអំពី "សង្គមព័ត៌មាន" ជាញឹកញាប់បានបង្កើតអោយមានការប្រកួតប្រជែង មិនមែនបង្កើតអោយមានកិច្ចសហប្រតិបត្តិការរវាងសាជីវកម្ម ឬកិច្ចសហប្រតិបត្តិការប្រទេសនានានោះឡើយ ។ អំណាចនៃប្រព័ន្ធផ្សព្វផ្សាយ និងសក្តានុពលទូរគមនាគមន៍ថ្មី បានពង្រីកក្នុងយុគសម័យមួយដែលពួកជាតិសាសន៍មូលធននិយមនៅតំបន់អឺរ៉ុប ផ្តោតការយកចិត្តទុកដាក់ទៅលើរោងចក្រអេឡិចត្រូនិក និងរោងចក្រស្វ័យប្រវត្តិរបស់ប្រទេសមួយចំនួនដូចជា សហភាពសូវៀត និងប្រទេសជប៉ុន ។ លើសពីនេះ សង្គ្រាមត្រជាក់បានពង្រឹងស្ថានភាពរបស់ពិភពលោកទី៣ ដែលជាប្រទេសក្រីក្រ អោយមានលទ្ធភាពផ្លាស់ប្តូរភក្តីភាពរបស់ពួកគេតាមផ្លូវពីរយ៉ាងគឺ យោធានិយម និងអំណាចនិយម មានលក្ខណៈជារួមជាងប្រជាធិបតេយ្យ ។

ភាពមិនយល់ស្របគ្នាក្នុងការរៀបចំពិភពលោកថ្មីនៃព័ត៌មាន និងគមនាគមន៍ ដែលបានបង្កើតឡើងដោយអង្គការយូនេស្កូ (UNESCO) ដើម្បីកាត់បន្ថយការកើនឡើងនៃការប្រកួតប្រជែង និងការគ្រប់គ្រងទៅលើព័ត៌មាន ។ នៅក្នុងឆ្នាំ១៩៨០ របាយការណ៍របស់ពហុស្ថាប័នពាក់ព័ន្ធនឹង "សំឡេងច្រើន ពិភពលោកតែមួយ" (UNESCO, 1980) ដែលផលិតឡើងដោយគណៈកម្មការអន្តរជាតិសម្រាប់ការសិក្សានៃបញ្ហាទំនាក់ទំនង (គេស្គាល់ផងដែរថាជា "Mac Bride Report") បានបង្ហាញអោយឃើញថា អតុល្យភាពរវាងប្រទេសឧស្សាហកម្ម និងប្រទេសកំពុងអភិវឌ្ឍនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងទូរគមនាគមន៍ ត្រូវបានកត់សំគាល់ខ្លាំងជាងគេ ។ អ្នកបង្កើតគោលនយោបាយនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ត្រូវគេជំរុញអោយទទួលស្គាល់គម្លាតនៅក្នុងសង្គមព័ត៌មាន ដែលទាក់ទិននឹងភាពខ្វះខាតនៃលទ្ធិប្រជាធិបតេយ្យ ។ ទោះជាយ៉ាងណា គណៈកម្មការក៏បាននិយាយតិចតួចផងដែរទាក់ទងនឹងតួនាទីរបស់ស្ត្រី ។ ភាពមិនយកចិត្តទុកដាក់នេះបានកើតឡើងច្រើនជាងមួយទសវត្សរួចទៅហើយលើបញ្ហាអាហារូបករណ៍ និងសកម្មជនលើផ្នែកយេនឌ័រដែលរួមបញ្ចូលទាំងការប្រារព្ធឡើងនូវសន្និសីទពិភពលោកអំពីស្ត្រីនៅប្រទេសម៉ិកស៊ិកូក្នុងឆ្នាំ ១៩៧៥ ។

សម្រាប់អ្នកស្ត្រីនិយម ប្រវត្តិនៃទំនាក់ទំនង និងព័ត៌មានដែលទាក់ទងនឹងសកម្មភាពនៃការអភិវឌ្ឍ ត្រូវបានផ្តល់អោយនូវសក្តានុពលក្នុងការធ្វើសមាហរណកម្មនៃសារជាក់លាក់ (ការឃោសនា) និងភាពលើសលប់នៃបុរសនៅក្នុងរចនាសម្ព័ន្ធប្រព័ន្ធផ្សព្វផ្សាយ ។ នៅក្នុងកំលុង និងក្រោយពីការគ្រប់គ្រងរបស់អាណានិគមនៅក្នុងបណ្តាប្រទេស

អាហ្វ្រិក និងអាស៊ី ការឃោសនាបញ្ចុះបញ្ចូលទំនាក់ទំនង គឺធ្វើឡើងតាមទិសដៅតែមួយដែលពាក់ព័ន្ធនឹងទីផ្សារសង្គមនៃសារក្នុងការអភិវឌ្ឍទៅលើសុខភាព អាហារូបត្ថម្ភ កសិកម្ម និងផែនការគ្រួសារ មិនមែនឃោសនាតាមរយៈការជជែកសន្ទនាគ្នាតាមទិសដៅពីរ នៃការអភិវឌ្ឍនោះទេ (Steeves, 2002) ។ ប្រព័ន្ធផ្សព្វផ្សាយ និងទូរគមនាគមន៍ ត្រូវបានផ្តោតអារម្មណ៍ខ្លាំងនៅក្នុងមជ្ឈមណ្ឌលតំបន់ទីក្រុងជាជាងនៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល ។

## ២.២. បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ

### ២.២.១. ស្ថានភាពនៃការអប់រំរបស់ក្មេងស្រី និងស្ត្រីជាសាកល

នៅក្នុងតំបន់មួយចំនួនដូចជា តំបន់អាស៊ីខាងកើត គម្លាតនៃការចូលសិក្សារវាងក្មេងប្រុស និងក្មេងស្រី មានទំហំតូច ហើយនៅកំលុងឆ្នាំ២០០៥ គេរំពឹងថា គម្លាតនេះនឹងមិនមានកើតឡើងទៀតទេ (Huyer, 2003) ។ ដោយបន្ថែមទៀតថាការបង្រួមគម្លាតនេះ កំពុងតែមានដំណើរការល្អ នៅក្នុងតំបន់អាហ្វ្រិកខាងជើង និងអាស៊ីខាងត្បូង ប៉ុន្តែនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍមួយចំនួន ក្មេងស្រី និងស្ត្រីទទួលបានការអប់រំតិចតួចគ្រប់កម្រិត ហើយអត្រាអក្ខរភាពនៅមានកម្រិតទាប ។ ស្ថាប័នអប់រំទទួលស្គាល់ថា ក្មេងស្រី និងស្ត្រី គឺនៅពីក្រោយ ហើយដើរមិនទាន់ក្មេងប្រុស និងបុរសទេនៅក្នុងវិស័យអប់រំ ដោយមូលហេតុថា៖

- ២នាក់ ក្នុងចំណោម ៣នាក់នៃកុមារចំនួន ១១០ លាននាក់នៅលើពិភពលោក ដែលមិនបានចូលសាលារៀន គឺជាក្មេងស្រី ហើយក្នុងនោះមានក្មេងស្រីចំនួន ៤២លាននាក់ តិចជាងក្មេងប្រុសក្នុងកម្រិតបឋមសិក្សា ។
- ក្មេងស្រីមួយចំនួនបានចុះឈ្មោះចូលរៀន ប៉ុន្តែពួកគេមិនមានលទ្ធភាពក្នុងការបញ្ចប់ការសិក្សាបានឡើយ ។ ក្មេងស្រីដែលមិនបានចូលរៀនកម្រិតបឋមសិក្សា បានក្លាយខ្លួនទៅជាស្ត្រីដែលមិនចេះអក្សរ មានចំនួន ២ ភាគ ៣ នៃអនក្ខរជនពិភពលោកចំនួន ៨៧៥លាននាក់ ។
- ការរស់នៅតំបន់ជនបទ បានធ្វើអោយគម្លាតនៃការចូលរៀនរវាងក្មេងប្រុស និងក្មេងស្រី កាន់តែមានទំហំធំ ព្រោះថា ក្មេងស្រីរស់នៅតំបន់ជនបទ មានអត្រានៃការបោះបង់ចោលការសិក្សា ច្រើនជាងក្មេងប្រុសនៅតំបន់ទីក្រុង៣ដង ។

ផ្អែកតាមរបាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សរបស់អង្គការ UNDP ក្នុងឆ្នាំ២០០២ បានអោយដឹងថា ក្មេងស្រីចំនួន៦០% នៃក្មេងទាំងអស់ជាសាកល មិនបានចូលរៀនកម្រិតបឋមសិក្សា ។ ភ្នាក់ងារអន្តរជាតិបានទទួលស្គាល់ថា អតុល្យភាពនៃការចូលរៀនរវាងក្មេងស្រី និងក្មេងប្រុស គឺជាបញ្ហាគួរអោយព្រួយបារម្ភរបស់ពិភពលោក ។ របាយការណ៍ដដែល ក៏បាននិយាយផងដែរថា ស្ត្រីដែលទទួលបានការអប់រំ អាចមានលទ្ធភាពទទួលបានលទ្ធផលវិជ្ជមានជាច្រើនដូចជា ឱកាសការងារ និងការរកប្រាក់ចំណូលបានខ្ពស់ (UNDP, 2002) ។

ម្យ៉ាងទៀត ចំនួនតិចតួចរបស់ក្មេងស្រី និងស្ត្រីក្នុងវិស័យអប់រំទូទៅ ជាបញ្ហានៃការអប់រំផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាមួយដែរ ដោយវាបានធ្វើអោយក្មេងស្រី និងស្ត្រីមានចំណេះដឹងទាបលើផ្នែកនេះ ។ ចំណេះដឹងទាបផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានេះ បានធ្វើអោយក្មេងស្រី និងស្ត្រី ធ្វើការបានតែក្នុងផ្ទះ ជួយការងារក្នុងកសិដ្ឋាន និងកសិកម្ម ធ្វើជាគិលានុបដ្ឋាយិកា គ្រូបង្រៀនថ្នាក់ទាប និងលេខា ជាដើម ។ បើធៀបនឹងបុរសដែលមានកម្រិតវប្បធម៌ប្រហាក់ប្រហែលគ្នា ស្ត្រីមានអត្រាខ្ពស់ជាង ក្នុងការធ្វើការងារក្រៅម៉ោង ការងារដែលមានប្រាក់ខែទាប និងគ្មានសុវត្ថិភាព ព្រមទាំងអត្រានៃភាពគ្មានការងារធ្វើរបស់ស្ត្រីក៏មានកម្រិតខ្ពស់ជាងបុរសដែរ (McGregor and Harding, 1996) ។

ការអប់រំបច្ចេកទេស និងការចូលរួមនៅក្នុងជំនាញវិជ្ជាជីវៈផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យារបស់ស្ត្រី គឺជាបញ្ហាដែលត្រូវយកមកពិចារណា សម្រាប់អនាគតរបស់ប្រទេសជាតិ ព្រោះដរាបណាធនធានមនុស្សក្នុងវិស័យបច្ចេកវិទ្យាមានច្រើន សេដ្ឋកិច្ច និងសង្គម ក៏អាចរីកចម្រើនបានល្អដែរ ។ ប៉ុន្តែ យើងដឹងហើយថា អត្រានៃការទទួលបាន ICT របស់ស្ត្រីក្នុងប្រទេសកំពុងអភិវឌ្ឍ គឺមានចំនួនតិចជាងបុរស ។

### ២.២.២. ផលប្រយោជន៍នៃបច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យា

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍វិស័យអប់រំ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការជួយបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីចូលរួមកសាងប្រទេសជាតិអោយរីកចំរើន ហើយ ICT បានរួមចំណែកផ្តល់ក្តីសង្ឃឹមក្នុងការទទួលបាន និងលើកកម្ពស់វិស័យអប់រំអោយមានភាពប្រសើរឡើង ។ ការសិក្សារបស់ Engauge, 2002 បានបង្ហាញថា ICT បានចូលរួមចំណែកយ៉ាងធំធេងក្នុងការចាប់យកចំណេះវិជ្ជាផ្សេងៗ បង្កើតឱកាសនានាដែលមិនធ្លាប់មានដល់ប្រទេសកំពុងអភិវឌ្ឍ ហើយវាបានចូលរួមចំណែកក្នុងការជំរុញប្រព័ន្ធអប់រំ និងលើកកម្ពស់លទ្ធភាពដល់ប្រជាជនក្នុងវិស័យការងារផងដែរ ។

ICT គឺជាឧបករណ៍ដ៏មានសារសំខាន់ និងមានសក្តានុពលក្នុងការចូលរួមបង្កើនឱកាសចំពោះមនុស្សទូទៅឲ្យឈានចាប់បានចំណេះវិជ្ជាណាមួយបាន ។ វាជាពន្លឺនៃក្តីសង្ឃឹមមួយក្នុងការកាត់បន្ថយគម្លាតបច្ចេកវិទ្យា ចំពោះប្រជាជននៅតំបន់ឆ្ងាយដាច់ស្រយាល ពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍដែលមានអត្រាអនក្ខរភាពខ្ពស់ ដោយសារមូលហេតុសង្គម វប្បធម៌ សាសនា ភេទ ពិការភាព ចាស់ជរា ក៏ដូចជាចំពោះអ្នកដែលមានសេដ្ឋកិច្ចទន់ខ្សោយ (World Bank, 1998) ។ ការទទួលបានចំណេះវិជ្ជាអប់រំពីចម្ងាយ ធ្វើអោយសាស្ត្រាចារ្យ និងនិស្សិត សិស្ស មិនចាំបាច់ពឹងផ្អែកតែលើឯកសារមិនរស់រវើកទៀតហើយ ។ ដោយសារ Internet, World wide web ឯកសារទាំងឡាយនៃកម្មវិធីសិក្សា គឺអាចស្វែងរកបានតាមរយៈឧបករណ៍ផ្សេងៗគ្នា មិនថានៅទីណា ប្រទេសណានោះទេ ។

អត្ថបទដែលនិយាយអំពីស្ត្រីក្នុងសម័យឌីជីថលរបស់អង្គការ UNESCAP ក្នុងឆ្នាំ២០០៩ បាននិយាយថា បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា បានកំណត់ឡើងវិញនូវរចនាសម្ព័ន្ធឱកាសសម្រាប់ផ្តល់ភាពអង់អាចដល់ស្ត្រី និងសមភាពយេនឌ័រតាមមធ្យោបាយជាច្រើន (UNESCAP, 2009)៖

- **ប្រផ្នូលនៃសេរីភាពថ្មី៖** ការផ្តល់ភាពអង់អាចដល់ស្ត្រី ដោយប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា បានបង្កើតអោយមានលក្ខខណ្ឌនៃការរស់នៅ និងការប្រព្រឹត្តថ្មី ដែលវាជាគំរូថ្មីនៃសេរីភាព ។ អ៊ីនធឺណិត គឺជាផ្នែកមួយនៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដែលរួមចំណែកធ្វើអោយស្ត្រីអាចចេញទៅពិភពខាងក្រៅបាន សម្រាប់សិក្សាស្វែងយល់ និងរុករកអត្តសញ្ញាណសង្គម និងវប្បធម៌ផ្សេងៗ ។ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា បានសម្របសម្រួល និងផ្តល់ឱកាសអោយស្ត្រីចេញផុតពីតួនាទីប្រពៃណី និងទំនៀមទម្លាប់ចាស់ៗ ហើយចូលមកក្នុងតួនាទីថ្មីក្នុងសង្គម ដូចជាធ្វើជាអ្នកបង្កើតកម្មវិធី Software ជាប្រតិបត្តិករនៅតាម Tele-Center និងជាសហគ្រិនផ្សេងៗ ។ តួនាទីថ្មីទាំងនេះ បានធ្វើអោយមានការផ្លាស់ប្តូរយ៉ាងខ្លាំងទៅលើបទដ្ឋានយេនឌ័រនៅតាមតំបន់ ។
- **ការធ្វើកំណែទម្រង់ឡើងវិញនៃចំណេះដឹងសាធារណៈ៖** ការប្រើប្រាស់សំឡេង មតិ និងការចូលរួមរបស់ប្រជាពលរដ្ឋ បានធ្វើអោយលេចឡើងនូវតំបន់ចំណេះដឹងសាធារណៈថ្មីមួយ ។ ក្នុងនោះប្រព័ន្ធផ្សព្វផ្សាយ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកកាត់បន្ថយអំណាច

ដែលគាបសង្កត់ប្រជាពលរដ្ឋ និងគាំទ្រដល់ស្ត្រីក្នុងការបង្កើតសហគមន៍ ការបង្កើតសម្ព័ន្ធមិត្តជាមួយនឹងសហគមន៍ខាងក្រៅ ហើយនិងបញ្ជ្រាបព័ត៌មានផ្សេងៗទៅដល់ស្ថាប័ននានាក្នុងការអនុវត្ត ។ ប្រព័ន្ធព័ត៌មានទាំងនោះ បានក្លាយជាតំបន់ចំណេះដឹងសាធារណៈ ដែលអាចធ្វើអោយប្រជាពលរដ្ឋមានចំណេះដឹង និងចេះតស៊ូមតិ ។

- **ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមថ្មី៖** បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា បានចូលរួមចំណែកក្នុងការអភិវឌ្ឍ ដោយធ្វើការផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធនៃសេដ្ឋកិច្ច និងសង្គមថ្មី ដូចជាសេវាកម្មសុខភាព សេវាកម្មអប់រំ និងសេវាកម្មសាធារណៈផ្សេងៗសម្រាប់ការរស់នៅក្នុងជីវភាពប្រចាំថ្ងៃ ធ្វើអោយវាមានលក្ខណៈកាន់តែប្រសើរឡើង ។ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា បានអភិវឌ្ឍនូវសមត្ថភាព ទទួលខុសត្រូវរបស់ស្ថាប័ន ព្រមទាំងពង្រីកសក្តានុពលលទ្ធិប្រជាធិបតេយ្យដោយមានការចូលរួមពីប្រជាពលរដ្ឋ រួមទាំងស្ត្រីផងដែរ ។
- **ការកសាងព័ត៌មាន និងចំណេះដឹងថ្មីៗ៖** បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា បានជួយសម្របសម្រួលដល់ស្ត្រី អោយជម្នះឧបសគ្គផ្សេងៗក្នុងការសិក្សា ដើម្បីទទួលយកចំណេះដឹង ។ ប្រព័ន្ធផ្សព្វផ្សាយ បានផ្តល់នូវគំរូរចនាសម្ព័ន្ធថ្មីមួយសម្រាប់ព័ត៌មាន និងការសិក្សា ការបង្រៀនតៗគ្នាតាមរយៈបណ្តាញ និងការបង្កើតចំណេះដឹងរួមគ្នា ទៅដល់ស្ត្រីក្រីក្រដែលមិនចេះអក្សរ ឲ្យអភិវឌ្ឍចំណេះដឹងរបស់ខ្លួន ។

### ២.២.៣. កត្តារាំងស្ទះស្ត្រីមិនអោយទទួលបានផលប្រយោជន៍ពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

ស្ត្រីមិនអាចទាញយកផលប្រយោជន៍ និងទទួលយកបច្ចេកវិទ្យាទំនើបទាំងអស់ដូចបុរសបាន នោះមិនមែនបណ្តាលមកពីមូលហេតុតែមួយនោះទេ (Stamp 1990; Cockburn & Ormrod 1993) ។ ជាទូទៅ មូលហេតុទាំងនោះបណ្តាលមកពីស្ត្រីមានប្រាក់ចំណូលទាប ការសិក្សាទាប ពេលវេលាតិច ការធ្វើសកម្មភាពមានកម្រិតទាប និងជំនឿសាសនា ព្រមទាំងវប្បធម៌ដែលរារាំងពួកគេមិនអោយទទួលយក និងប្រើប្រាស់បច្ចេកវិទ្យា ។ បើយើងក្រឡេកមើលក្រុមស្ត្រីនៅតំបន់ជនបទ យើងឃើញថា ពួកគាត់បាត់បង់ឱកាសទាញយកអត្ថប្រយោជន៍ពី ICT ច្រើនជាងស្ត្រីនៅតាមតំបន់ទីក្រុង ព្រោះស្ត្រីនៅទីក្រុងមានចំណេះដឹង និងធនធានច្រើនជាងស្ត្រីនៅជនបទ ។

តាមទ្រឹស្តី Totalizing Theories គម្លាតអ្នកទទួលបានបច្ចេកវិទ្យាថ្មីៗ ក្រោមរូបភាពផ្សេងៗគ្នានៃប្រព័ន្ធអប់រំ គឺជាកត្តាមួយចូលរួមបន្ទប់បង្អាក់ការរីកចម្រើនដល់សង្គម (Haraway 1990)។ បន្ថែមពីលើនេះទៀត ហានិភ័យរបស់យេនឌ័រ និងបច្ចេកវិទ្យា គឺសង្គមមិនយកចិត្តទុកដាក់នឹងភាពពិតជាក់ស្តែង ដែលទាំងស្ត្រី និងបុរស មិនអាចផ្តាច់ខ្លួនចេញពីវិទ្យាសាស្ត្រទំនើបសព្វថ្ងៃបានឡើយ ។ បញ្ហាទាំងនេះបានបង្កើតអោយមានការពិភាក្សាជាច្រើនទៅលើគម្លាតយេនឌ័រនៅក្នុង "Digital Divide" ។

ការសិក្សារបស់ Halkin និង Taggart (2001) បានរកឃើញឧបសគ្គមួយចំនួនដែលរាំងស្ទះស្ត្រីក្នុងការចាប់យក និងទទួលផលប្រយោជន៍ពីផ្នែក ICT សំខាន់ៗចំនួន៤ គឺ៖ <u>១). កត្តាវប្បធម៌ និងអាកប្បកិរិយា</u>ដែលនៅតែរើសអើងស្ត្រីក្នុងការចូលរៀន បើធៀបជាមួយនឹងបុរស ។ ឧទាហរណ៍ នៅ

ក្នុងគ្រួសារមួយដែលមានកូនៗកំពុងសិក្សានោះ ឪពុកម្ដាយនៅតែមានទស្សនៈមួយថា គាត់នឹងផ្ដល់ឱកាសអោយកូនប្រុសបានសិក្សារៀនសូត្រខ្ពស់ជាងកូនស្រី ព្រោះពួកគាត់យល់ថាកូនស្រីគួរតែនៅផ្ទះ ដើម្បីជួយការងារផ្ទះដល់ពួកគាត់ ។ ២). លក្ខខណ្ឌស្ថានភាព ក្នុងលក្ខខណ្ឌមួយចំនួន ស្ត្រីនៅតំបន់ដាច់ស្រយាល មិនបានទទួលការជួយឧបត្ថម្ភទេ ។ តម្លៃនៃការបង់ថ្លៃសិក្សា ជាបញ្ហាចម្បងមួយដែរដែលបានរាំងស្ទះដល់ស្ត្រីក្នុងការទទួលបានការសិក្សាខ្ពង់ខ្ពស់ ម្យ៉ាងទៀតនៅក្នុងសង្គមមួយចំនួន ទោះបីជាស្ត្រីមានចំណេះដឹងខ្ពង់ខ្ពស់ដូចបុរស ក៏ពួកគាត់មិនត្រូវបានគេអោយតម្លៃស្មើនឹងបុរសដែរ ។ ៣). គុណភាព ដោយសារស្ត្រីភាគច្រើនមិនសូវពូកែគណិតវិទ្យា ឬមុខវិជ្ជាវិទ្យាសាស្ត្រ ដូច្នេះវាក៏ជាកត្តារាំងស្ទះដល់ស្ត្រីក្នុងការសម្រេចចិត្តជ្រើសរើសមុខវិជ្ជា ICT ដែរ ។ ៤). ស្ថាប័នមិនទាន់បង្កលក្ខណៈងាយស្រួលដល់ស្ត្រីក្នុងការចូលរៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ករណីនេះមានច្រើនដោយរាប់បញ្ចូលទាំងស្ថាប័នអប់រំ ដែលនៅតែមានការខ្វះខាតសាស្ត្រាចារ្យជាស្ត្រីភេទ ។

### ២.២.៤. យុទ្ធសាស្ត្រដើម្បីជំរុញអោយស្ត្រីចូលរួមក្នុងការអប់រំវិទ្យាសាស្ត្រ និងបច្ចេកទេស

នៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍ យុទ្ធសាស្ត្រមួយចំនួនត្រូវបានទទួលស្គាល់ថាមានប្រសិទ្ធិភាពក្នុងការជំរុញក្មេងស្រី និងស្ត្រី អោយចូលរួមក្នុងវិស័យអប់រំ ។ យុទ្ធសាស្ត្រទាំងនោះរួមមាន៖ ការផ្ដល់ជាអាហារូបករណ៍ ការសម្របសម្រួលទៅលើកត្តាវប្បធម៌មួយចំនួន ការផ្ដល់គ្រូ និងសាស្ត្រាចារ្យជាស្ត្រី ផ្ដល់ជម្រើសដល់ពួកគេអំពីពេលវេលាសិក្សា និងសាលាដែលគេចង់រៀន និងការផ្ដល់វគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។ ខាងក្រោមនេះជាវិធីសាស្ត្រមួយចំនួនដើម្បីបង្កើនអត្រា ឬចំនួនរបស់ក្មេងស្រី និងស្ត្រីអោយចូលរួមការអប់រំអំពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាប្រកបដោយភាពជោគជ័យ៖

- ផ្លាស់ប្ដូរកម្មវិធីសិក្សា ដោយបញ្ចូលលក្ខណៈយេនឌ័រ ការគិតបែបវិទ្យាសាស្ត្រ និងមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តឧបករណ៍នានា ។
- ការអប់រំវិទ្យាសាស្ត្រ អំពីសកម្មភាពជាក់ស្ដែងនៅក្នុងជីវិតប្រចាំថ្ងៃ រួមទាំងសង្គម និងបរិស្ថាន ។
- ផ្ដល់នូវគំរូ និងជំនួទ្ធានទៅដល់ស្ត្រី ។
- លោកគ្រូ អ្នកគ្រូ ត្រូវមានស្មារតីប្រឹងប្រែង ដើម្បីធានាថា ទាំងក្មេងស្រី និងក្មេងប្រុស ត្រូវបានអោយតម្លៃ និងយកចិត្តទុកដាក់ថែទាំស្មើៗគ្នានៅក្នុងថ្នាក់ ។
- យុទ្ធសាស្ត្រដទៃផ្សេងទៀត អាចរួមបញ្ចូលនូវកម្មវិធីមួយចំនួនដូចជា អនុញ្ញាតអោយស្ត្រីដែលបានបញ្ចប់ថ្នាក់បច្ចេកទេស ចូលសិក្សាមុខវិជ្ជានេះបន្ថែមទៀតពេលដែលគេចង់សិក្សា បង្កើតកម្មវិធីផ្សេងៗដែលផ្ដល់អោយស្ត្រីយចំណាស់ ហើយនិងស្ត្រីដែលបោះបង់ចោលការសិក្សា អាចទទួលបានការអប់រំផ្នែកបច្ចេកទេស និងកម្មវិធីនៅតាមសហគមន៍ដោយផ្ទាល់ ដែលទាក់ទងនឹងបញ្ហាផ្សេងៗនៅក្នុងជីវភាពរស់នៅរបស់ស្ត្រី ។

សាកលវិទ្យាល័យវិទ្យាសាស្ត្រកុំព្យូទ័រ Carnegie Mellon នៅរដ្ឋ Pennsylvania សហរដ្ឋអាមេរិក បានបង្កើនអត្រាស្ត្រីក្នុងកម្មវិធីវិទ្យាសាស្ត្រកុំព្យូទ័រពី ៧% ក្នុងឆ្នាំ១៩៩៥ ដល់ ៤២% ក្នុងឆ្នាំ២០០០ ។ នៅក្នុងកំលុងពេលនោះ អត្រានៃសិស្សស្រីដែលបានបញ្ចប់ការសិក្សា មានការកើនឡើងប្រហាក់ប្រហែលនឹងចំនួនបុរសដែរ ។ ការទទួលបានជោគជ័យបែបនេះ កើតឡើងដោយសារតែសាកលវិទ្យាល័យបានបង្កើតគោលនយោបាយផ្ដល់ឱកាសដល់និស្សិត និងកែប្រែកម្មវិធីសិក្សាផ្សេងៗ ដូចជាការបង្កើតមុខវិជ្ជាមូលដ្ឋានគ្រឹះសម្រាប់អ្នកដែលមិនចេះកម្មវិធី ( programming ) ប្រើប្រាស់ការស្វែងរក ស្រាវជ្រាវពិតៗជាក់ស្ដែង និងតម្រង់

ទិសមកកាន់ពិភពលោក ។ គុណភាពនៃការបង្រៀន បាន អភិវឌ្ឍកាន់តែប្រសើរឡើង ដោយមានគ្រូជំនាញៗ និងមាន បទពិសោធន៍ខ្ពស់សម្រាប់បង្រៀនមុខវិជ្ជាមូលដ្ឋាន ។ ម៉្យាង វិញទៀត អ្នកជំនួយការគ្រូ ក៏បានទទួលការបណ្តុះបណ្តាល អំពីសមភាពយេនឌ័រដែរ ។ ជាងនេះទៅទៀត មុខវិជ្ជាទូទៅ ត្រូវបានផ្តួចផ្តើមបង្កើតឡើងជាមួយនឹងបរិបទនៃបច្ចេកវិទ្យា ពិភពលោកពិតៗ ( Margolis and Fisher, 2001 ) ។

## ២.៣. បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យការងារ

ស្រ្តីក្នុងវិស័យការងារ ដើរតួនាទីយ៉ាងសំខាន់ក្នុងការ កាត់បន្ថយភាពក្រីក្រ ដោយបានបង្កើតឱកាសក្នុងការទទួល បានចំណូលតាមរយៈធ្វើការងារខាងក្រៅ ឬប្រកបរបររកស៊ី ដោយខ្លួនឯង វាមានសារសំខាន់ក្នុងការកែប្រែជីវភាព៖

- ទី១ សិទ្ធជាទូទៅរបស់ស្ត្រី ក្នុងការផ្តល់អាទិភាព អោយស្ត្រីក្នុងវិស័យការងារ និងឯករាជ្យភាព ក្នុងការធ្វើការងារនៅទីកន្លែងដ៏សមរម្យណាមួយ សម្រាប់ពួកគាត់ ។
- ទី២ ការចូលរួមរបស់ស្ត្រីក្នុងវិស័យការងារ អាចជួយជំរុញអោយវិស័យសេដ្ឋកិច្ចមានការ រីកចម្រើន។ សព្វថ្ងៃនេះស្ត្រីភាគច្រើនបានចំណាយ ថវិកាជាច្រើន ដើម្បីធ្វើអោយប្រសើរឡើងនូវការ ហូបចុក ចំណីអាហារ អាហារូបត្ថម្ភ និងការអប់រំ សម្រាប់សមាជិកគ្រួសាររបស់គាត់ ។

ការរើសអើងចំពោះស្ត្រីនៅក្នុងវិស័យការងារ កំពុងតែ បន្តកើតមានឡើង ហើយបានធ្វើអោយខាតបង់រហូតដល់ ៨០ពាន់លានដុល្លារ ( UNESCAP, 2007 ) ។ លើសពីនេះ តាមការសិក្សារបស់ Costa និង Silva នៅបណ្តាប្រទេស អាមេរិកឡាទីន បានអោយដឹងថា របាំងគំនាបចំពោះស្ត្រីក្នុង វិស័យការងារ ជាកត្តាមួយដែលរាំងស្ទះដល់កាត់បន្ថយភាព ក្រីក្រ ( Costa and Silva, 2008 ) ។

នៅក្នុងវិស័យការងារផ្នែក ICT ស្ត្រីជួបបញ្ហាចំពោះមុខ សំខាន់ៗបី៖

- ស្ត្រីចូលរួមក្នុងវិស័យការងារដែលមិនមែនជា ការងារផ្នែកកសិកម្ម កើនឡើងតិចតួច ប៉ុន្តែ ជាទូទៅស្ត្រីមានទំនោរច្រើនជាងបុរសក្នុង ការទទួលយកការងារដែលមានចំណូលទាប សមិទ្ធផលទាប ហើយជួនពេលខ្លះការងារទាំង នោះងាយទទួលគ្រោះថ្នាក់ គ្មានសិទ្ធិសេរីភាព ច្បាស់លាស់ គ្មានទាំងការការពារពីសង្គម ឬ គ្មានសំឡេងក្នុងវិស័យការងារ ។ យោងតាម របាយការណ៍របស់អង្គការពលកម្មអន្តរជាតិ( ILO ) បានអោយដឹងថា គម្លាតយេនឌ័ររបស់ស្ត្រីក្នុងទី ផ្សារការងារនៅទូទាំងពិភពលោក គឺមិនទាន់មាន លក្ខណៈរួមតូចនៅឡើយទេ ( ILO, 2008 ) ។ ក្នុងនោះដែរ បើតាមការសិក្សារបស់ Avirgan, Bivens និង Grammage ក្នុងឆ្នាំ២០០៥ បានអោយ ដឹងថា ការលើកកម្ពស់ស្ត្រីក្នុងវិស័យការងារ កំពុង ជួបប្រទះឧបសគ្គសំខាន់ៗជាច្រើនដូចជា ស្ត្រីមាន ចំនួនតិចទៅៗក្នុងវិស័យការងារដែលទទួលបាន ប្រាក់កម្រៃ ស្ត្រីចូលចិត្តប្រកបរបររកស៊ីដោយផ្ទាល់ ខ្លួន ឬនៅផ្ទះ ស្ត្រីចូលចិត្តធ្វើការងារនៅកន្លែងមាន ប្រាក់ចំណូលទាប ហើយមានលក្ខខណ្ឌការងារ ងាយស្រួល ។
- ស្ត្រីនៅបណ្តាប្រទេសអាស៊ីអាគ្នេយ៍ មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងត្បូង កំពុងជួបប្រទះបញ្ហាចំពោះ មុខអំពីគម្លាតការងារ ។ គម្លាតរវាងបុរស និង ស្ត្រីក្នុងវិស័យការងារនៅទូទាំងពិភពលោក នៅ តែបន្តកើតមានឡើងជាក់ស្តែង( $P<0,05$ ) ។ យោងតាមរបាយការណ៍របស់អង្គការពលកម្ម អន្តរជាតិ បានអោយដឹងថា ក្នុងឆ្នាំ២០០៧ អត្រា ការងារធៀបជាមួយនឹងចំនួនប្រជាជនសរុបនៅ ទូទាំងពិភពលោក គឺស្ត្រីមានចំនួន ៤៩,១%

និងបុរសមានចំនួន ៧៤,៣% ( ILO, 2008 ) ។ របាយការណ៍ក៏បានបង្ហាញអោយដឹងថា គម្លាតការងាររបស់ស្ត្រី និងបុរសនៅតំបន់អាស៊ីអាគ្នេយ៍ មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងត្បូង មានលើសពី ៤០% ។ ប៉ុន្តែគួរអោយកត់សំគាល់ដែរថា គម្លាតការងារនៅបណ្តាប្រទេសក្នុងតំបន់អាស៊ីខាងកើត គឺគម្លាតនេះមានក្រោម ២០% ។ លោក Kolev និង Sirven ឆ្នាំ២០០៧ បានសិក្សាទៅលើ ១៨ប្រទេស នៃតំបន់អនុសាហារា បានអោយដឹងថា បណ្តាប្រទេសមួយចំនួនបានប្រឹងប្រែងបង្រួមគម្លាតការងារអោយតូច ហើយតំបន់មជ្ឈិមបូព៌ា បានប្រឹងប្រែងជំរុញអោយចំនួនស្ត្រីក្នុងវិស័យការងារកើនដល់ជាង ៣៥% ចាប់ពីឆ្នាំ១៩៩៧ ដល់២០០៧ ។ ក្នុងនោះដែរចំនួនស្ត្រីក្នុងវិស័យការងារនៃបណ្តាប្រទេសនៅអាហ្វ្រិកខាងជើង អាមេរិកឡាទីន និងការីប៊ៀន បានកើនឡើង១០% ថែមទៀត ។ ចំពោះស្ត្រីក្នុងប្រទេសកំពុងអភិវឌ្ឍ ក្នុងចំណោមស្ត្រី ១០នាក់ មាន ៦នាក់ ប្រកបរបរសម្រាប់តែមួយរស់ ។ ក្នុងចំណោមស្ត្រីទាំងនោះ ភាគច្រើនគាត់ធ្វើការងារនៅក្នុងគ្រួសាររបស់គាត់ មានអ្នកខ្លះទៀតពួកគាត់ធ្វើការអោយក្រុមហ៊ុនចម្ការរបស់គ្រួសារបងប្អូនគាត់ដោយគ្មានទទួលបានប្រាក់កម្រៃ ។ ការងារកសិកម្ម ជាជម្រើសដំបូងបង្អស់របស់ស្ត្រី ដែលក្នុងនោះអត្រាស្ត្រីធ្វើការក្នុងផ្នែកនេះមានចំនួន ៤១% ហើយតំបន់ដែលមានស្ត្រីចូលរួមក្នុងវិស័យការងារកសិកម្មខ្ពស់បំផុតនោះរួមមានតំបន់អាស៊ីអាគ្នេយ៍ មជ្ឈិមបូព៌ា និងតំបន់អនុសាហារា អាហ្វ្រិក ( ILO, 2008 ) ។ ជាទូទៅ នៅមានតម្រូវការស្ត្រីក្នុងវិស័យការងារច្រើនតាមស្ថាប័នផ្សេងៗ ប៉ុន្តែស្ត្រីភាគច្រើនបែរជាធ្វើការជាមួយក្រុមហ៊ុនឯកជន ។ រីឯស្ត្រីដែលធ្វើការក្នុងស្ថាប័នរដ្ឋាភិបាល គឺពួកគាត់ចង់ធ្វើការនៅកន្លែងដែលទទួលប្រាក់កម្រៃទាបក្នុងវិស័យសង្គម ដូចជាអប់រំ និងសុខភាព ។

- ឱនភាព គឺជាបញ្ហាមួយដែរ ដែលស្ត្រីកំពុងជួបប្រទះ ។ ជាទូទៅ ស្ត្រីមានប្រាក់ចំណូលទាបជាងបុរស បើទោះបីជាពួកគាត់មានសមត្ថភាពធ្វើការងារបានដូចគ្នាក៏ដោយ ។ Kolev និង Sirvin បានសិក្សាទៅលើបណ្តាប្រទេសនៅតំបន់អនុសាហារាអាហ្វ្រិក ឃើញថា ការទទួលបានប្រាក់កម្រៃរវាងស្ត្រីធៀបជាមួយនឹងបុរស គឺនៅមានគម្លាតខុសគ្នាយ៉ាងពិតប្រាកដ ជាមធ្យមគម្លាតរវាងប្រាក់កម្រៃប្រចាំសប្តាហ៍ មានចំនួន ២៣% ( Burkina Faso ) ទៅដល់ ៧៩% ( Ghana ) ។

ភាពខុសប្លែកគ្នានៅតាមតំបន់ និងប្រភេទការងារ ព្រមទាំងបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ជាកត្តាចូលរួមចំណែកធ្វើអោយមានគម្លាតរវាងស្ត្រី និងបុរស ក្នុងវិស័យការងារ ។ ម៉្យាងវិញទៀត កត្តាសង្គម និងវប្បធម៌មួយចំនួន ក៏ជារនាំងចំពោះស្ត្រីក្នុងការចូលរួមក្នុងវិស័យការងារដែរ ។ ក្នុងនោះ រដ្ឋាភិបាល បានវិនិយោគតិចតួចប៉ុណ្ណោះ ក្នុងការលើកកម្ពស់ស្ត្រីក្នុងវិស័យការងារ ។

ផ្អែកតាមទិន្នន័យរបស់អង្គការ UNDP ក្នុងឆ្នាំ២០០១ បានអោយដឹងថា អ្នកប្រើប្រាស់អ៊ីនធឺណិតជាបុរស ក្នុងប្រទេសអេត្យូពី ( Ethiopia ) មានចំនួន ៨៦% ក្នុងប្រទេសសេណេហ្គាល់ ( Senegal ) មានចំនួន ៨៣% ក្នុងប្រទេសចិន មានចំនួន ៧០% ប្រទេសបារាំងមានចំនួន ៦៧% និងអាមេរិកឡាទីន មានចំនួន ៦២% ។ អត្រាដែលស្ត្រីទទួលបាន និងប្រើប្រាស់អ៊ីនធឺណិតមានចាប់ពីតិចជាង ១% រហូតដល់លើស ៤០% ក្នុងប្រទេសម៉ិកស៊ិក្ ប្រេស៊ីល ហ្វីលីពីន និងអាហ្វ្រិកខាងត្បូង ។

## ២.៤. ការសិក្សាស្រាវជ្រាវនានាទាក់ទងនឹងបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាក្នុងប្រទេសកម្ពុជា

បន្ទាប់ពីការបោះឆ្នោត ជាលើកដំបូងនៅឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំអភិវឌ្ឍប្រទេសជាតិ ដោយបានធ្វើសមាហរណកម្មទៅក្នុងតំបន់ និងពិភពលោក ។ ដើម្បីបំពេញតម្រូវការ និងធ្វើអោយប្រជាជនមានភាពរីកចម្រើន គោលនយោបាយ និងកម្មវិធីជាច្រើន ត្រូវបានបង្កើតឡើងដូចជា គោលនយោបាយត្រីកោណដំណាក់កាលទី១ និងទី២ ផែនការយុទ្ធសាស្រ្តជាតិដើម្បីកាត់បន្ថយភាពក្រីក្រ យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី១ ដំណាក់កាលទី២ ផែនការអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ។ល។

រហូតដល់ឆ្នាំ២០០០ អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ត្រូវបានបង្កើតឡើង ដើម្បីធ្វើអោយការអភិវឌ្ឍព័ត៌មានវិទ្យាបានប្រសើរឡើង គោលនយោបាយអភិវឌ្ឍន៍ ការត្រួតពិនិត្យ និងធ្វើសវនកម្មរាល់គម្រោងដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន ។

ដោយបានពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិក សង្គមអេឡិចត្រូនិក ការធ្វើពាណិជ្ជកម្មតាមអេឡិចត្រូនិក និងរដ្ឋាភិបាលតាមអេឡិចត្រូនិកកាលពីឆ្នាំ២០០១ ប្រទេសកម្ពុជា ត្រូវបានគេចាត់ក្នុងលេខរៀងទី៨ ក្នុងចំណោម១០ ប្រទេស (IBM, 2001) ។ លក្ខណៈវិនិច្ឆ័យសំខាន់ពីរគឺ ១. ភាពរួចរាល់នៅក្នុងកម្រិតដែលសហគមន៍រៀបចំខ្លួនដើម្បីចូលរួមក្នុងសេដ្ឋកិច្ច ឌីជីថល និងទី២ គ្រប់ផ្នែកនៃសេដ្ឋកិច្ច (ដោយមិនគិតពីគ្រប់កម្រិតនៃការអភិវឌ្ឍ) ត្រូវបង្ហាញនូវភាពរួចរាល់នៅក្នុងពិភពលោកដោយរួមមាន គោលនយោបាយជាតិ កម្រិតសមាហរណកម្មបច្ចេកវិទ្យា និងការអនុវត្តបទដ្ឋាន ។

ការពិនិត្យឯកសារដែលមានស្រាប់នៅក្នុង ITU, 2002 បង្ហាញនូវព្រឹត្តិការណ៍សំខាន់ៗដូចតទៅ៖ ប្រទេស

### ស្ថិតិសំខាន់អំពីប្រទេសកម្ពុជា

- ផ្ទៃដី៖ ១៨១,០៣៥ គម២
- ប្រជាជន៖ ១៣,៣៩៥,៦៨២ (២០០៨)
- ប្រុស៖ ៤៨.៦% ស្រី ៥១.៤%
- អត្រាគ្មានការងារ ១៥+៖ ២.២៧% (CSES, 2004)
- ចំណូលសម្រាប់ប្រជាជនម្នាក់ៗ៖ ៧៣៩ ដុល្លារ (២០០៨)
- ភាគរយនៃប្រជាជនរស់នៅទីក្រុង៖ ១៩.៥%

(សម្រង់ទិន្នន័យពីជំរឿនឆ្នាំ២០០៨)

កម្ពុជា ជាប្រទេសដែលអ៊ីនធឺណិតមកដល់យឺតយ៉ាវ ដោយមានសេវាកម្មជំនួញនេះនៅក្នុងឆ្នាំ១៩៩៧ ។ កម្ពុជាមានអ៊ីនធឺណិតជ្រាបចូលតិចបំផុតនៅអាស៊ីអាគ្នេយ៍ ហើយមានតម្លៃខ្ពស់បំផុត ។ ដោយមានការជួយឧបត្ថម្ភពីមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិកាណាដា (IDRC) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបង្កើតក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត Camnet នៅក្នុងខែមិថុនា ឆ្នាំ១៩៩៧ ។ នៅក្នុងកំលុងពេលនោះ ការប៉ាន់ប្រមាណនៃអ្នកប្រើប្រាស់អ៊ីនធឺណិត មានចំនួន ១នាក់ក្នុងចំណោមប្រជាជន ៦,០០០ នាក់ និងបន្តកើនរហូតដល់ ១នាក់ក្នុងចំណោម ១,២០០នាក់ នៅក្នុងពាក់កណ្តាលឆ្នាំ២០០១ (អ្នកប្រើប្រាស់អ៊ីនធឺណិតប្រហែល ៨,០០០នាក់ក្នុងប្រទេសកម្ពុជា) ។ នៅខែធ្នូ ឆ្នាំ២០០០ ក្រុមហ៊ុន Camnet, Bigpond, Camitel និងអង្គការ Open Forum គឺជាអ្នកដើរតួសំខាន់ក្នុងការផ្តល់សេវាកម្មអ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជាដែលមានអ្នកចុះឈ្មោះប្រើប្រាស់ ៤,២២៤នាក់ ។

បីឆ្នាំក្រោយការបង្កើត អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងដំបូងដែលបានផ្តួចផ្តើមក្នុងការបង្កើតគោលនយោបាយ ICT ។ ដោយមានការគាំទ្រពីអង្គការយូនេស្កូ (UNESCO) នៅក្នុងប្រទេស

កម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានប្រារព្វធ្វើកិច្ចប្រជុំតុមូល ដើម្បីបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រអំពីការប្រើប្រាស់ ICT ក្នុងវិស័យអប់រំ នៅឆ្នាំ២០០៣ ដោយផ្តោតទៅលើវិធីសាស្ត្រ ៤ គឺ ICT ជាតម្រូវការរបស់គ្រូ និងសិស្សទាំងអស់គ្នា ICT គឺជាឧបករណ៍នៅក្នុងការបង្រៀន និងការសិក្សា ហើយក៏ជាមុខវិជ្ជាមួយសម្រាប់ខ្លួនវាផ្ទាល់ ICT គឺជាមធ្យោបាយដើម្បីធ្វើអោយប្រសើរឡើងនូវផលិតភាព សមត្ថភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យអប់រំ ICT សម្រាប់ជំរុញអោយមានការអភិវឌ្ឍវិស័យអប់រំដើម្បីឆ្លងកាត់ចន្លោះនៃការអប់រំ និងស្វ័យសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា ២០០៤)។

ការធ្វើបទបង្ហាញរបស់អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានក្នុងខែកញ្ញា ឆ្នាំ២០០៤ នៅទីក្រុងតៃប៉ិ នៅតៃវ៉ាន់ (និទ្ទាការ និងគោលនយោបាយបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងប្រទេសកម្ពុជា : សន្និសីទអំពី Software ប្រើប្រាស់ដោយសេរី នៅអាស៊ី លើកទី៤) បានទទួលស្គាល់អំពីសារសំខាន់នៃការប្រើប្រាស់ Software ដោយសេរី (FOSS) នៅក្នុងប្រទេសកម្ពុជា ។ ឧបសគ្គ និងការលំបាកដែលត្រូវបានលើកឡើង គឺផ្តោតទៅលើភាពខ្វះខាតធនធានមនុស្ស ភាពខ្វះខាតនៃជំនួយខាងបច្ចេកទេស ភាពខ្វះខាតនៃការយល់ដឹងទៅលើបញ្ញត្តិ និងសារប្រយោជន៍ដ៏មានសក្តានុពលនៃការប្រើប្រាស់ Software ដោយសេរី ការពឹងផ្អែកលើការថតចម្លង Software ខុសច្បាប់ច្រើនពេក ហើយនិងភាពខ្វះខាតនៃជំនួយខាងហិរញ្ញវត្ថុ ។ ស្ថាប័ននេះក៏បានទទួលស្គាល់ផងដែរនូវសារសំខាន់នៃការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិល នៅក្នុងការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ។ ឧទាហរណ៍ វេទិកាបើកទូលាយកម្ពុជា (Open Forum) បានរាយការណ៍ថា ប្រជាជនកម្ពុជាសព្វថ្ងៃ អាចផ្ញើ និងអានអ៊ីមែលជាភាសាខ្មែរដែលជាភាសាក្នុងកុំព្យូទ័រ ដែលមាន Software ប្រើប្រាស់ដោយសេរីគឺ Thunderbird ។

### ស្ថិតិសំខាន់អំពី ICTក្នុងប្រទេសកម្ពុជា

ការស្ទង់មតិអំពីការប្រើប្រាស់ ICT និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ សហគ្រាសធុនតូច និងមធ្យម ត្រូវបានអនុវត្តន ដោយ NiDA នៅចន្លោះខែធ្នូឆ្នាំ២០០៦ និងខែមេសាឆ្នាំ២០០៧ លើ១០០០SMEs នៅ១៤ខេត្តរាជធានីបានបង្ហាញលទ្ធផលសំខាន់ៗ៖

**អ្នកប្រើទូរសព្ទ៖** ១២.៩នាក់ លើប្រជាជន១០០នាក់ (រួមមានទូរសព្ទចល័ត និងលើតុ)

**ការប្រើប្រាស់កុំព្យូទ័រ៖**

- ៧៨.៤% ប្រើសម្រាប់វាយអត្ថបទ
- ៥៨.៥% ប្រើសម្រាប់អ៊ីនធឺណិត
- ៤២.៤% ប្រើសម្រាប់គណនា
- ៣៣.០% ប្រើសម្រាប់ទំនាក់ទំនងអតិថិជន
- ២០.៣% ប្រើសម្រាប់រចនាផលិតផល
- ១៩.០% ប្រើសម្រាប់ផ្តល់សេវាកម្ម
- ១៦.៤% ប្រើសម្រាប់ការអប់រំ

**ប្រព័ន្ធដំណើរការ**

- ៩០.០% សម្រាប់ Microsoft Windows
- ២.៨% សម្រាប់ Macintosh
- ៣.០% សម្រាប់ Linux

**ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត** ១៣,០០០នាក់ (ភាគច្រើននៅរាជធានីភ្នំពេញ និងខេត្តសៀមរាប

ប្រភេទនៃអាជីវកម្មដែលមានទំនាក់ទំនងបណ្តាញដោយយោងក្រុមហ៊ុន៤២២

- ក្រុមហ៊ុន ICT៖ ៨៩%មានអ៊ីនធឺណិត
- ហិរញ្ញវត្ថុ៖ ៨៣%
- ទេសចរណ៍៖ ៨២%
- អង្គការ៖ ៨១%
- ក្រុមហ៊ុនដឹកជញ្ជូន និងlogistics៖ ៨១%
- នាំចេញ-នាំចូល៖ ៧០%
- ផលិតកម្ម៖ ៦៦%
- អប់រំ៖ ៥១%

# ២. ឯកសារដែលពាក់ព័ន្ធ

របាយការណ៍មួយទៀតដែលមានលក្ខណៈស្រដៀងនឹងលទ្ធផលនៃការសិក្សានេះ ការសិក្សាអំពីស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងឆ្នាំ២០០៥ បានរកឃើញថា ឧបសគ្គសំខាន់ៗដែលមាននៅកម្ពុជា គឺហេដ្ឋារចនាសម្ព័ន្ធមិនមានគ្រប់គ្រាន់ និងមិនអាចជឿទុកចិត្តបាន បញ្ហាតម្លៃ អក្ខរភាព និងការអប់រំ ភាសា ទីតាំងភូមិសាស្ត្រក្នុងការផ្តល់ភាពងាយស្រួល ហើយនិងបទដ្ឋានសង្គម និងវប្បធម៌ (Hor, 2005) ។

នៅក្រោមការជួយឧបត្ថម្ភពី មូលនិធិស្រាវជ្រាវ HBF-RUPP ក្នុងឆ្នាំ២០០៥ សាស្ត្រាចារ្យមួយរូប នៅសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ បានរៀបចំការសិក្សាស្រាវជ្រាវមួយអំពី "និន្នាការ និងស្ថានភាពយេនឌ័រ នៅក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា" ក្នុងប្រទេសកម្ពុជា ក្នុងទីក្រុងភ្នំពេញ ហើយនិងខេត្ត៣ផ្សេងទៀត មានខេត្តបាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ។ លទ្ធផលសំខាន់ៗនៃការសិក្សាស្រាវជ្រាវនេះមាន ៖

- ចំនួនដ៏ច្រើននៃសាកលវិទ្យាល័យឯកជន និងវិទ្យាស្ថានបណ្តុះបណ្តាល បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា កំពុងតែរីកដុះដាលយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា ។ ទោះយ៉ាងណា យេនឌ័រជាកត្តាមួយនៅក្នុងការអប់រំគ្រប់ផ្នែក ដែលមានឥទ្ធិពលទៅលើអ្នកចូលរួមទាំងអស់ រួមមាន អ្នករដ្ឋបាល គ្រូបង្រៀន និងអ្នកសិក្សា ។ សមាមាត្រនៃសិស្សស្រី និងសិស្សប្រុសនៅក្នុងការអប់រំបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានៅក្នុងកម្រិតទី៣ គឺនៅមានកម្រិតទាប ។ ក្នុងឆ្នាំ២០០០ ស្ត្រីដែលបានចូលរួមនៅក្នុងផ្នែកផ្សេងៗពាក់ព័ន្ធនឹងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានចន្លោះពី ២៥% ទៅ ៤០% ក្នុងឆ្នាំ២០០១ មានចន្លោះពី ២៦% ទៅ ៤២% ក្នុងឆ្នាំ២០០២ មានចន្លោះពី ១៣% ទៅ ៤២% ក្នុងឆ្នាំ២០០៣ មានចន្លោះពី ១២% ទៅ ៤០% និងក្នុងឆ្នាំ ២០០៤ មានចន្លោះពី ១១% ទៅ ៤៤% ក្នុងឆ្នាំ២០០៤ ដែលពួកគេមកពីភ្នំពេញ (ITC, RULE, RUPP និង NUM), សៀមរាប (BBU, ACI, IMS និង CUS) បាត់ដំបង ( IME, NUM, CUP និង IMS) និងខេត្តបន្ទាយមានជ័យ (IC, IME និង IMS) ។
- តាមចម្លើយរបស់អ្នកផ្តល់ព័ត៌មានសំខាន់

### ស្ថិតិសំខាន់អំពី ICTក្នុងប្រទេសកម្ពុជា

ប្រភេទនៃបណ្តាញអាជីវកម្ម
- បណ្តាញក្នុងស្រុក ៦៩.៩%
- បណ្តាញតំបន់គ្មានខ្សែ ២២.៥%
- បណ្តាញតំបន់ក្នុងស្រុកគ្មានខ្សែ ៧.៩%

បំណែងចែកនៃក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត
- Online: ២៨.៨%
- Camitel: ១៨.៤%
- Camnet: ១៣.១%
- Telesurf: ១0%
- Citylink: ៨.៤%
- Camshin: ៨.១%
- Cogetel: ២.៥%
- Casacome: ១%
- AZ: ១%

ភាពពេញចិត្តទៅលើល្បឿនអ៊ីនធឺណិត
- ពេញចិត្ត ៥៥%
- មិនពេញចិត្ត ៤៥%

មូលហេតុដែលពេញចិត្ត
- តម្លៃ ២១.៥%
- ភាពដែលអាចជឿជាក់បាន ៤៤.៦%
- ល្បឿន ៥.៧%

ដកស្រង់ចេញពី ភ្នំពេញប៉ុស្តិ៍ ឆ្នាំ២០០៨ ការភ្ជាប់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងប្រទេសកម្ពុជា

(ប្រធានដេប៉ាតឺម៉ង់ ឬក៏នាយក) បានអោយដឹងថា មូលហេតុផ្សេងៗដែលធ្វើអោយមានចំនួនស្រ្តីតិចជាងបុរស គឺបណ្តាលមកពីៈ

- ☐ ទី១ មានចំនួនស្រ្តីតិចជាងបុរសដែលបានបញ្ចប់ថ្នាក់វិទ្យាល័យ
- ☐ ទី២ បទដ្ឋានវប្បធម៌ខ្មែរ រារាំងកូនស្រីមិនអោយចូលរួមការអប់រំកម្រិតខ្ពស់ ឬក៏ធ្វើដំណើរចេញឆ្ងាយពីផ្ទះ
- ☐ ទី៣ ឪពុកម្តាយផ្តល់អាទិភាពអោយកូនប្រុសនៅក្នុងការអប់រំ ព្រោះកូនប្រុសនឹងក្លាយជាអ្នកផ្គត់ផ្គង់សំខាន់ជាងគេក្នុងគ្រួសារនាពេលអនាគត
- ☐ ទី៤ វិសមភាពនៃការចូលទៅក្នុងវិស័យអប់រំផ្នែក បច្ចេកវិទ្យា គមនាគន៍ ព័ត៌មានវិទ្យា របស់សិស្សស្រី ដោយពួកគេខ្លួនឯងផ្ទាល់គិតថា បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា គឺសក្តិសមសម្រាប់តែសិស្សប្រុស ហើយវាមានលក្ខណៈលំបាកសម្រាប់ពួកគេក្នុងការចាប់យក ។

- ■ ទិន្នន័យសរុបអំពីយេនឌ័រនៃបុគ្គលិកនៅក្នុងផ្នែក បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា បានបង្ហាញថា បុគ្គលិកស្រ្តីនៅក្នុងការងារដែលពាក់ព័ន្ធនឹង បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានចំនួនតិចជាងបុរសបើប្រៀបធៀបនៅក្នុងតំណែងខ្ពស់ តំណែងកណ្តាល និងតំណែងទាប ។
- ■ ស្រ្តីទទួលបានផលប្រយោជន៍ចន្លោះពី ១១% ទៅ ២៥% នៅក្នុងកម្មវិធីមួយចំនួននៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា នៅក្នុងផ្នែកខ្លះនៃប្រទេសកម្ពុជា (ភ្នំពេញ សៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ) ។

ការអភិវឌ្ឍសំខាន់ៗនៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងប្រទេសកម្ពុជា ក៏ត្រូវបានបង្ហាញអោយដឹងតាមរយៈកាសែតភ្នំពេញ ប៉ុស្តិ៍ ដែលមានចំណងជើងថា "ការភ្ជាប់ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាកម្ពុជា ក្នុងឆ្នាំ ២០០៨" (ភ្នំពេញប៉ុស្តិ៍, ២០០៨) ។

- ■ ចំណេះដឹង និងជំនាញផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា របស់ប្រជាជនកម្ពុជា នឹងមានការកើនឡើង ហើយវាមានសារសំខាន់សម្រាប់ការរីកលូតលាស់នៃសេដ្ឋកិច្ចជាតិ ។
- ■ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ត្រូវបានគេប្រើរួចហើយក្នុងការសម្របសម្រួលការធ្វើទិដ្ឋាការតាមប្រព័ន្ធអេឡិចត្រូនិក ហើយគេក៏រំពឹងថា វានឹងចូលរួមចំណែកធ្វើអោយប្រសើរឡើងនូវការចុះបញ្ជីយានយន្ត និងអចលនទ្រព្យ ។ ការគ្រប់គ្រងរដ្ឋាភិបាលតាមបែបអេឡិចត្រូនិក ឬហៅថា E-government កំពុងមានការកើនឡើងនៅក្នុងការភ្ជាប់ជាមួយនឹងក្រសួងផ្សេងៗទៅកាន់សហគមន៍ (online) ។
- ■ បើតាមអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន នៅក្នុងប្រទេសកម្ពុជា មានមនុស្សប្រមាណ ១៣,០០០ នាក់ ក្នុងឆ្នាំ២០០៦ ត្រូវបានប៉ាន់ប្រមាណថា ប្រើប្រាស់អ៊ីនធឺណិតទៀងទាត់ ហើយភាគច្រើននៅទីក្រុងភ្នំពេញ និងខេត្តសៀមរាប ។
- ■ ខណៈពេលដែលតម្រូវការក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតរបស់ភ្ញៀវទេសចរបរទេស កាន់តែមានការកើនឡើង យុវវ័យកម្ពុជា ក៏កំពុងតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍវិស័យអ៊ីនធឺណិតផងដែរ ។
- ■ ទោះយ៉ាងណា តម្លៃថ្លៃនៅក្នុងការប្រើប្រាស់អ៊ីនធឺណិត បានពន្យឺតការរីកលូតលាស់របស់

អ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជា ជាពិសេស នៅក្នុងតំបន់ជនបទ បើទោះបីជាសព្វថ្ងៃនេះយើងអាចភ្ជាប់អ៊ីនធឺណិតនៅតាមតំបន់ដែលនៅឆ្ងាយពីទីក្រុង និងខេត្តក៏ដោយ ។

- អ្នកជំនាញនិយាយថា នៅក្នុងវិស័យទូរគមនាគមន៍ ផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានការអភិវឌ្ឍខ្លាំងក្លាជាងគេនៅក្នុងប្រទេសកម្ពុជា ។
- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន បាននិយាយថា វិស័យទូរគមនាគមន៍នៅក្នុងប្រទេសកម្ពុជាមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងទសវត្សចុងក្រោយនេះ ។
- បើតាមសម្តីលោក Morten Erikse នាយកប្រតិបត្តិនៃ Cadcomms ដែលជាក្រុមហ៊ុនផ្តល់សេវាកម្មទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា ឬហៅថាឃ្សប៊ី បាននិយាយថា "ការទទួលបានប្រព័ន្ធអ៊ីនធឺណិតចល័តដែលមានល្បឿនលឿន នឹងក្លាយជាសេវាកម្មដែលពេញនិយមក្នុងទីផ្សារកម្ពុជា ស្របពេលដែលប្រជាជនភាគច្រើន ជាពិសេសយុវវ័យចង់ប្រើប្រាស់នូវបច្ចេកវិទ្យាថ្មី" ។
- តាមអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន "ការអភិវឌ្ឍបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានការចូលរួមចំណែកយ៉ាងច្រើនពីផ្នែកឯកជន ហើយវាមានសារសំខាន់សម្រាប់ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជាទាំងមូល" ។
- " កម្ពុជា បានពិចារណាទៅលើគោលនយោបាយដើម្បីរក្សាទុកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាជាផ្នែកមួយនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម" ។ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន បានទទួលស្គាល់ថា "មធ្យោបាយទំនាក់ទំនងសាធារណៈនៅតាមភូមិ ខេត្ត និងរដ្ឋាភិបាល មានការអភិវឌ្ឍយឺតនៅក្នុងកំលុង១០ឆ្នាំចុងក្រោយនេះ បើធៀបនឹងប្រទេសជិតខាង ។

## ២.៩. គោលនយោបាយបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

### ២.៩.១. ការដកស្រង់ចំណុចសំខាន់ៗដែលមានចែងក្នុងច្បាប់ និងគោលនយោបាយក្នុងប្រទេសកម្ពុជា ដែលនិយាយពីបញ្ហាការងារ និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

ដូចបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៧ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំបង្កើតច្បាប់នានា ផែនការយុទ្ធសាស្ត្រជាតិរយៈពេលវែង និងមធ្យម គោលនយោបាយតាមផ្នែក និងកម្មវិធីជាច្រើនដើម្បីជួយសម្រួល និងបង្កលក្ខណៈវិជ្ជមាន ដល់ភាពចម្រើនថ្កើងថ្កាន និងសុខដុមរមនារបស់ប្រជាជនកម្ពុជា ។ ទាក់ទងនឹងការងារ និងការអប់រំ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៦ និងមាត្រា ៦៥ បានចែងពីសិទ្ធិក្នុងការជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន សិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា សិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត ។ ចំណែកមាត្រា ៦៧ បានចែងអំពីរដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សាទាំងផ្នែកសាធារណៈ និងឯកជន ព្រមជាមួយគ្នានេះបានចែងអំពីកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។

មួយវិញទៀត នៅក្នុងផែនការអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ ក៏បាននិយាយពីសមិទ្ធផល និងកត្តាប្រឈមចម្បងៗក្នុងអាណត្តិទី៣ និងគោលនយោបាយសកម្មភាពអាទិភាពសម្រាប់អនុវត្តក្នុងអាណត្តិទី៤ (សូមមើលក្នុងឧបសម្ព័ន្ធទី៧)។

- លទ្ធផលក្នុងការបន្តស្តារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ខាងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ បានបង្ហាញថា កំណើនវិនិយោគិនឯកជន មានការកើនឡើងលើវិស័យទូរគមនាគមន៍ចាប់ពីឆ្នាំ២០០៦ ។ គម្រោងការងារធំៗជាច្រើនដែលមានទឹកប្រាក់ច្រើនជាង២ពាន់លានដុល្លារអាមេរិក ត្រូវបានអនុវត្ត និងបន្តអនុវត្តដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាបអុបទិក សំដៅពង្រីកសេវាកម្មទូរគមនាគមន៍នៅទូទាំងប្រទេស ។ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតមានការកើនឡើងពី ៨,៦៣០ នាក់ក្នុងឆ្នាំ២០០៥ មកដល់ ២០,១០០នាក់ក្នុងឆ្នាំ ២០០៨ ។

- ច្បាប់ស្តីពីទូរគមនាគមន៍ ពុំទាន់បានអនុម័តពីរដ្ឋសភានៅឡើយ សេវាមាត់ច្រកទូរគមនាគមន៍អន្តរជាតិខុសច្បាប់នៅតែបន្តកើតមាន កិច្ចសហការរវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង ប្រតិបត្តិករភ្នាក់ងារអភិវឌ្ឍន៍ ពុំទាន់មានភាពល្អប្រសើរ តម្លៃប្រើប្រាស់សេវាអ៊ីនធឺណិតមានតម្លៃថ្លៃ សេវាប្រៃសណីយ៍របស់ក្រុមហ៊ុនឯកជន មានលក្ខណៈប្រកួតប្រជែងខ្លាំងជាងសេវាប្រៃសណីយ៍របស់រដ្ឋ ហើយសមត្ថភាពធនធានមនុស្សនៅក្នុងវិស័យប្រៃសណីយ៍នៅមានកម្រិតនៅឡើយ ។ ទាំងនេះគឺជាកត្តាប្រឈមសំខាន់នៅក្នុងផ្នែកនេះ ។ ដើម្បីឆ្លើយតបនឹងបញ្ហាលំបាកទាំងនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងពង្រីកសេវាកម្មប្រៃសណីយ៍ និងកាត់បន្ថយថ្លៃនានា ព្រមទាំងពង្រឹងក្របខ័ណ្ឌច្បាប់ក្រសួង ។

- លទ្ធផលស្តីពីការអភិវឌ្ឍវិស័យឯកជន និងការងារនៅក្នុងផែនការយុទ្ធសាស្ត្រជាតិដដែលនេះ ក៏បាននិយាយពីការ ទទួលស្គាល់ និងឯកភាពលើចំណុចមួយដ៏សំខាន់ដែលថា ផ្នែកឯកជនជាកម្លាំងដ៏សំខាន់សម្រាប់ការវិនិយោគនិងកំណើនក្នុងប្រទេស ។ យុទ្ធសាស្ត្ររយៈពេលវែងរបស់រាជរដ្ឋាភិបាលក្នុងវិស័យការងាររួមមានការបង្កើតការងារ ការជួយស្វែងរកការងារអោយធ្វើ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការកែលម្អលក្ខខណ្ឌការងារ ។ បន្តពីអាណត្តិទី៣ រាជរដ្ឋាភិបាលកម្ពុជានឹងពង្រឹង "វេទិការាជរដ្ឋាភិបាល-វិស័យឯកជន" កាត់បន្ថយការតម្រូវខាងឯកសារនានា ពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ ពង្រឹងបទដ្ឋានគតិយុត្តិ សម្រាប់គាំទ្រវិស័យឯកជន បន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ និងបណ្តុះបណ្តាលអ្នកផ្សះផ្សារវិវាទស្ម័គ្រចិត្ត ។

- សមិទ្ធផលនៅក្នុងវិស័យអប់រំ គឺការបង្កើតនូវធនធានមនុស្សដែលមានគុណភាព ដោយផ្អែកលើយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ ដោយផ្តោតសំខាន់លើបីចំណុច ក. ការធានាសមធម៌នៃការចូលរៀន ខ. ការកែលម្អគុណភាព និងប្រសិទ្ធភាពនៃការអប់រំ និង គ. ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពដើម្បីអភិវឌ្ឍវិមជ្ឈការ ។

បន្ថែមពីនេះ នៅក្នុងច្បាប់អប់រំ ក៏បាននិយាយអំពីការកំណត់វិធាន និងលក្ខខណ្ឌតម្រូវថ្នាក់ជាតិ  សម្រាប់កសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាព ដើម្បីអភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ។  ដោយផ្តោតលើបច្ចេកវិទ្យាសម្រាប់ការអប់រំ មាត្រា ២៨ នៃច្បាប់នេះបានចែងថា៖

*"រដ្ឋត្រូវលើកកម្ពស់ និងគាំទ្រដល់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ ការច្នៃប្រឌិត  និងការផលិតដែលមានលក្ខណៈវិទ្យាសាស្ត្រ  និងបច្ចេកវិទ្យា សម្រាប់*

*ការអប់រំ ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និង ស្របតាមសកលភាវូបនីយកម្ម ដើម្បីលើកស្ទួយ សមត្ថភាពធនធានមនុស្ស និងជំរុញការអភិវឌ្ឍប្រទេស ជាតិ ។*

*ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់ គោលការណ៍ស្តីពី វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ ការអប់រំគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំកម្ពុជា ស្របតាម គោលនយោបាយរបស់រាជរដ្ឋាភិបាល ។"*

នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ បានសរសេរថា យុទ្ធសាស្ត្រថ្មីស្តីពីបច្ចេកវិទ្យា ព័ត៌មាន ទូរគមនាគមន៍របស់ក្រសួងអប់រំ យុវជន និងកីឡា ដោយផ្តោតជាដំបូងនៅតាមសាលាមធ្យមសិក្សាទុតិយភូមិ និងសាលាគរុកោសល្យ និងភ្ជាប់ភាពជាដៃគូជាមួយអ្នកផ្តល់ សេវាឯកជន ។ ខ្ទង់ចំណាយនៃការពង្រីកសម្ភារបរិក្ខារបន្ទប់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង ICT គឺមានទឹកប្រាក់ប្រហែល ២២ ពាន់លានរៀលខ្មែរ ដែលស្មើនឹង ៥.៥. លានដុល្លារ សហរដ្ឋអាមេរិក ។ ស្របជាមួយគ្នានេះនៅក្នុងកម្មវិធីគាំទ្រ វិស័យអប់រំឆ្នាំ២០០៦-១០ ក៏បានសរសេរដែរថា នឹងបន្តការ អភិវឌ្ឍគ្រូបង្រៀន ផ្តល់ការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ (ICT) ដល់គ្រូឧទ្ទេស និងគ្រូមធ្យមសិក្សា ទាំងអស់ ។

មួយវិញទៀត គោលបំណងនៃសេចក្តីព្រាង គោលនយោបាយបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា គឺធ្វើ អោយសង្គមកម្ពុជា ពោរពេញដោយចំណេះដឹងតាមរយៈការ ប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានសមស្របតាម រយៈការបង្កើត និងផ្តល់នូវបទដ្ឋាន និងគោលនយោបាយ ជាតិ ព្រមទាំងការផ្តល់សេវាសាកល និងលទ្ធភាពអាច ប្រើប្រាស់បាននូវព័ត៌មាន និងបរិក្ខារទំនាក់ទំនងក្នុងស្រុក ។

ឯកសារគោលនយោបាយបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ បញ្ជាក់ថា បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ជាឧបករណ៍មួយនៅក្នុងចំណោម ឧបករណ៍សំខាន់ៗសម្រាប់រៀន សម្រាប់ការបង្រៀន សម្រាប់ ការសិក្សាស្រាវជ្រាវ និងសម្រាប់ចែករំលែកព័ត៌មាន ។

### ២.៩.២. ផែនការសកម្មភាពទីក្រុងប៉េកាំង (Beijing Platform for action, 1995)

សន្និសីទពិភពលោករបស់អង្គការសហប្រជាជាតិស្តី អំពីបញ្ហាស្ត្រី បីលើកដំបូង (លើកទី១ នៅឆ្នាំ១៩៧៥ នា ទីក្រុងម៉ិកស៊ិកូ ប្រទេសម៉ិកស៊ិកូ លើកទី២នៅឆ្នាំ១៩៨០ នា ទីក្រុង កូប៉េនហាហ្គេន ប្រទេសដាណឺម៉ាក និងលើកទី៣នៅ ទីក្រុង ណៃរ៉ូប៊ី ប្រទេសកេនយ៉ា) មិនបាននិយាយពីបញ្ហា ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាទេ ។ សន្និសីទ ពិភពលោកលើកទី៤ និងបន្តរហូតដល់លើកទី៧របស់អង្គការ សហប្រជាជាតិស្តីអំពីបញ្ហាស្ត្រី មានផ្នែកមួយបាននិយាយពី ស្ត្រី និងប្រព័ន្ធផ្សព្វផ្សាយ (UNITED NATION, 2010) ។

កម្ពុជា គឺជាប្រទេសហត្ថលេខីមួយ ក្នុងចំណោម ប្រទេសជាសមាជិកអង្គការសហប្រជាជាតិចំនួន ១៨៩ ផ្សេងទៀត ដែលត្រូវអនុវត្តផែនការសកម្មភាពទីក្រុងប៉េកាំង ឆ្នាំ១៩៩៥ ។

ខាងក្រោមនេះ គឺជាការសង្ខេបនៃសន្និសីទពិភពលោក លើកទី៤ របស់អង្គការសហប្រជាជាតិស្តីអំពីបញ្ហាស្ត្រី ដែល បានប្រព្រឹត្តទៅនៅទីក្រុងប៉េកាំង ខែកញ្ញាឆ្នាំ១៩៩៥ បាន និយាយពីសកម្មភាពជំរុញអោយមានសមភាព ការអភិវឌ្ឍ និងសន្តិភាព ។ នៅក្នុងសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ ការអនុវត្តដែលមាន១២ចំណុច ក្នុងនោះចំណុចទី១០ ក៏មាន និយាយពីស្ត្រី និងប្រព័ន្ធផ្សព្វផ្សាយ ។ យុទ្ធសាស្ត្រអនុវត្ត ទាំង១២ចំណុចនោះគឺ ចំណុចទី១ ស្ត្រីនិងភាពក្រីក្រ ចំណុច ទី២ ការអប់រំ និងការបណ្តុះបណ្តាលដល់ស្ត្រី ចំណុចទី៣ ស្ត្រីនិងសុខភាព ចំណុចទី៤ ការប្រឆាំងអំពើហិង្សាលើស្ត្រី ចំណុចទី៥ ស្ត្រីនិងជម្លោះប្រដាប់អាវុធ ចំណុចទី៦ និយាយពី ស្ត្រីនិងសេដ្ឋកិច្ច ចំណុចទី៧ ស្ត្រីនៅក្នុងអំណាច និងសេចក្តី

សម្រេចចិត្ត ចំណុចទី៨ យន្តកម្មស្ថាប័នដើម្បីភាពរីកចម្រើនរបស់ស្ត្រី ចំណុចទី៩ សិទ្ធិមនុស្សរបស់ស្ត្រី ចំណុចទី១០ ស្ត្រី និងប្រព័ន្ធផ្សព្វផ្សាយ ចំណុចទី១១ ស្ត្រី និងបរិស្ថាន ចំណុចទី១២ ក្មេងស្រី ។

ផែនការសកម្មភាពជាយុទ្ធសាស្ត្រក្នុងចំណុចទី១០ មានវត្ថុបំណងជាយុទ្ធសាស្ត្រពីរគឺ ទី១ បង្កើនការចូលរួម និងលទ្ធភាពទទួលបានរបស់ស្ត្រីក្នុងការបញ្ចេញមតិនិងធ្វើសេចក្តីសម្រេចចិត្ត តាមរយៈប្រព័ន្ធផ្សព្វផ្សាយនិងបច្ចេកវិទ្យាថ្មី ដើម្បីទំនាក់ទំនង និងទី២ ធ្វើអោយប្រសើរឡើងនូវតុល្យភាព និងធ្វើមិនអោយមានភាពលំអៀងសម្រាប់ស្ត្រីក្នុងប្រព័ន្ធផ្សព្វផ្សាយ ។

នៅក្នុងវត្ថុបំណងយុទ្ធសាស្ត្រទាំងពីរ ក្នុងចំណុចទី១០ ដែលនិយាយអំពីស្ត្រី និងប្រព័ន្ធផ្សព្វផ្សាយ មានចែងយ៉ាងច្បាស់នូវសកម្មភាពដែល ១. រដ្ឋាភិបាល ២. ប្រព័ន្ធផ្សព្វផ្សាយជាតិនិងអន្តរជាតិ ៣. តាមរយៈរដ្ឋាភិបាល ឬយន្តការជាតិដើម្បីធ្វើអោយស្ត្រីប្រសើរឡើង និង ៤. តាមអង្គការមិនមែនរដ្ឋាភិបាល និងសមាគមប្រព័ន្ធផ្សព្វផ្សាយអាជីពត្រូវអនុវត្ត ។ សកម្មភាពនៅក្នុងវត្ថុបំណងយុទ្ធសាស្ត្រទី១មាន៖

- តាមរយៈរដ្ឋាភិបាល សកម្មភាពដែលត្រូវអនុវត្តមាន ៨ចំណុច ក. គាំទ្រការអប់រំស្ត្រី ការបណ្តុះបណ្តាល និងការងារ ដើម្បីធ្វើអោយប្រសើរឡើងនូវឱកាសស្មើគ្នាសម្រាប់ស្ត្រី នៅក្នុងគ្រប់ជ្រុង និងកម្រិតទាំងអស់នៃប្រព័ន្ធផ្សព្វផ្សាយ ខ. គាំទ្រការសិក្សាស្រាវជ្រាវ ក្នុងគ្រប់ទិដ្ឋភាពទាំងអស់របស់ស្ត្រីក្នុងប្រព័ន្ធផ្សព្វផ្សាយ គ. លើកតម្កើងការចូលពេញមុខមាត់និងស្មើភាពគ្នារបស់ស្ត្រីក្នុងប្រព័ន្ធផ្សព្វផ្សាយ ឃ. សំដៅអោយមានតុល្យភាពក្នុងការតែងតាំងស្ត្រីនៅក្នុងលំដាប់ថ្នាក់នៃការងារក្នុងប្រព័ន្ធផ្សព្វផ្សាយ ង. លើកកម្ពស់ស្ថាប័នពាក់ព័ន្ធអោយបង្កើតកម្មវិធីអោយបានច្រើនសម្រាប់ស្ត្រី ស្របជាមួយនឹងសេរីភាពនៃការបញ្ចេញមតិ ក្នុងប្រព័ន្ធផ្សព្វផ្សាយ ច. លើកកម្ពស់ និងទទួលស្គាល់បណ្តាញប្រព័ន្ធផ្សព្វផ្សាយរបស់ស្ត្រី ឆ. លើកកម្ពស់ និងផ្តល់គ្រប់មធ្យោបាយ ឬលើកទឹកចិត្តដល់ការច្នៃប្រឌិតការប្រើប្រាស់កម្មវិធីក្នុងប្រព័ន្ធផ្សព្វផ្សាយជាតិ និង ជ. ធានានូវសេរីភាពនៃប្រព័ន្ធផ្សព្វផ្សាយ ។
- តាមរយៈប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ៖ អភិវឌ្ឍនូវយន្តកម្មបទដ្ឋាន ដែលលើកកម្ពស់ភាពស្មើគ្នា និងសំប្តូរបែបនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធទំនាក់ទំនងអន្តរជាតិ ព្រមទាំងបង្កើនការចូលរួមរបស់ស្ត្រីនិងបុរសក្នុងការផលិតនិងការធ្វើសេចក្តីសម្រេចចិត្ត ។
- តាមរយៈរដ្ឋាភិបាល ឬយន្តការជាតិដើម្បីធ្វើអោយស្ត្រីប្រសើរឡើង៖ មាន ៤ចំណុច ក. ជំរុញការអភិវឌ្ឍកម្មវិធី សិក្សា និងវគ្គបណ្តុះបណ្តាលសម្រាប់ស្ត្រី ដើម្បីបង្កើតព័ត៌មានសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ខ. ជំរុញការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនង រួមមានបច្ចេកវិទ្យាថ្មីៗជាមធ្យោបាយបង្កើនការចូលរួមរបស់ស្ត្រី គ. សម្របសម្រួលក្នុងការបង្កើតសៀវភៅសម្រាប់អ្នកជំនាញការប្រព័ន្ធផ្សព្វផ្សាយជាស្ត្រី និង ឃ. ជំរុញស្ត្រីក្នុងការបង្កើតការណែនាំពីអាជីព និងក្រមសីលធម៌ចាំបាច់នានា ។
- តាមរយៈអង្គការមិនមែនរដ្ឋាភិបាល និងសមាគមប្រព័ន្ធផ្សព្វផ្សាយអាជីព៖ មាន៤ចំណុច ក. ជំរុញនិងបង្កើតអោយមានក្រុមឃ្លាំមើលប្រព័ន្ធផ្សព្វផ្សាយ ដែលអាចត្រួតពិនិត្យ និងពិគ្រោះយោបល់ជាមួយប្រព័ន្ធផ្សព្វផ្សាយ ខ. បណ្តុះបណ្តាលស្ត្រីអោយចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានកាន់តែប្រសើរជាងមុន គ. បង្កើតបណ្តាញ

និងអភិវឌ្ឍកម្មវិធីព័ត៌មានសម្រាប់អង្គការមិនមែនរដ្ឋាភិបាល និង ឃ. ជំរុញវិស័យប្រព័ន្ធផ្សព្វផ្សាយ និងការអប់រំ និងស្ថាប័នបណ្តុះបណ្តាលប្រព័ន្ធផ្សព្វផ្សាយ ដើម្បីចែកចាយព័ត៌មានអភិវឌ្ឍន៍ និងបញ្ហាសង្គម ។

វត្ថុបំណងយុទ្ធសាស្រ្តទី២ មានសកម្មភាព៖

- តាមរយៈរដ្ឋាភិបាល និងអង្គការអន្តរជាតិ សកម្មភាពត្រូវអនុវត្តមាន ៦ចំណុចរួមមាន៖ ក. ធ្វើអោយប្រសើរឡើងនូវការសិក្សាស្រាវជ្រាវ និងការអនុវត្ត យុទ្ធសាស្រ្តព័ត៌មាន អប់រំ និងទំនាក់ទំនង ខ. ជំរុញប្រព័ន្ធផ្សព្វផ្សាយ និងភ្នាក់ងារផ្សព្វផ្សាយ ដើម្បីបង្កើតចំណេះដឹងជាក់លាក់ក្នុងការអនុវត្តសកម្មភាព គ. ជំរុញការបណ្តុះបណ្តាលដល់ប្រព័ន្ធផ្សព្វផ្សាយអាជីពពីបញ្ហារសើបរបស់យេនឌ័រ ឃ. ជំរុញប្រព័ន្ធផ្សព្វផ្សាយ មិនអោយបង្ហាញអ្វីដែលធ្វើអោយស្រ្តីអាប់អោន ឬកេងប្រវ័ញ្ចស្រ្តីឡើយ ង. ធ្វើអោយប្រសើរឡើងនូវបញ្ញត្តិ ដែលអ្នកភេទនិយមបង្ហាញក្នុងន័យរើសអើង និងបន្ទាបបន្ថោក និងច. ចាត់វិធានការយ៉ាងមានប្រសិទ្ធភាព ដោយរួមមានការអនុវត្តផ្លូវច្បាប់ប្រឆាំងរូបភាពអាសអាភាស និងអំពើហិង្សាដល់ស្រ្តីនិងកុមារ ។
- តាមរយៈប្រព័ន្ធផ្សព្វផ្សាយរួមមាន៖ ក. អភិវឌ្ឍសេចក្តីណែនាំ និងក្រមសីលធម៌វិជ្ជាជីវៈ អោយស្របនឹងសេរីភាពនៃការបញ្ចេញមតិ ខ.  អភិវឌ្ឍសេចក្តីណែនាំ និងក្រមសីលធម៌វិជ្ជាជីវៈដែលនិយាយពីអំពីហិង្សា ការធ្វើអោយអាប់អោន ឬរូបភាពអាសអាភាស គ. បង្កើតទស្សនវិស័យយេនឌ័រលើគ្រប់បញ្ហាទាំងអស់ក្នុងសហគមន៍ អ្នកប្រើប្រាស់ និងសង្គមស៊ីវិល  និង ឃ . លើកកម្ពស់ស្រ្តីនៅក្នុងការធ្វើសេចក្តីសម្រេចចិតលើគ្រប់កម្រិតនៃការងារ ។
- តាមរយៈប្រព័ន្ធផ្សព្វផ្សាយ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន ដោយមានកិច្ចសហការជាមួយយន្តការជាតិដើម្បីអោយមានភាពរីកចម្រើនដល់ស្រ្តីរួមមាន៖ ក. លើកកម្ពស់ការបែងចែកទំនួលខុសត្រូវស្មើគ្នាក្នុងគ្រួសារតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ខ. បង្កើត ឬចែកចាយសម្ភារប្រព័ន្ធផ្សព្វផ្សាយដល់អ្នកដឹកនាំជាស្រ្តី គ. ជំរុញយុទ្ធនាការផ្សព្វផ្សាយ ឃ. គាំទ្រជាថវិកា ឬគ្រប់មធ្យោបាយទំនាក់ទំនង និង ង. បង្កើតការបង្ហាញ និងបណ្តុះបណ្តាលអ្នកជំនាញ ដើម្បីវិភាគបញ្ហាយេនឌ័រក្នុងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយ ។

## ៣. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវបានកំណត់យករាជធានីភ្នំពេញជាកន្លែងសិក្សាស្រាវជ្រាវ ដោយសារតែហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាភាគច្រើនមាននៅភ្នំពេញ ហើយមានអ្នកប្រើប្រាស់ច្រើនលើសលប់នៅក្នុងតំបន់នេះ ។ ផ្អែកលើ គោលបំណង និងកម្មវត្ថុនៃការសិក្សាស្រាវជ្រាវ ដែលតម្រូវអោយប្រើប្រាស់ទិន្នន័យជាលេខ និងតម្រូវការយល់ដឹងអោយបានស៊ីជម្រៅ ការសិក្សាស្រាវជ្រាវនេះ បានប្រើវិធីសាស្ត្រទាំងបែបបរិមាណ និងគុណភាព ដោយមានប្រើប្រាស់ទិន្នន័យបឋម និងទិន្នន័យបន្ទាប់ ។

ទិន្នន័យបែបបរិមាណ ទទួលបានពីការសម្ភាសជាមួយតំណាងស្ថាប័ន និងបុគ្គលិក ដែលធ្វើការក្នុងប្រភេទស្ថាប័នបួនសំខាន់ៗដូចជា ក្រសួងនានា និងអាជ្ញាធរជាតិ អង្គការសង្គមស៊ីវិល ផ្នែកឯកជន (ដែលមានក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត និងហាងអ៊ីនធឺណិត) ព្រមទាំងគ្រឹះស្ថានឧត្តមសិក្សា ។ ទន្ទឹមនឹងគ្នានេះ ទិន្នន័យបែបបរិមាណក៏ត្រូវបានប្រមូលពីព័ត៌មានការផ្សព្វផ្សាយជ្រើសរើសបុគ្គលិកតាមប្រព័ន្ធគេហទំព័ររយៈពេល៣ខែ គិតចាប់ពីថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០១០ ពីគេហទំព័រដែលគេនិយមទស្សនាជាងគេក្នុងប្រទេសកម្ពុជាចំនួនពីរ គឺ bongthom (www.bongthom.com) និង pelprek(www.pelprek.com) ។ តាមផែនការប្រមូលទិន្នន័យពីគេហទំព័រ ការសិក្សានេះក៏គ្រោងប្រមូលព័ត៌មានពី គេហទំព័រ camhr (www.camhr.com) ដែរ តែដោយសារគេហទំព័រនេះ មិនអនុញ្ញាតអោយមានការស្ទង់មតិ ហើយម្យ៉ាងទៀត ការផ្សាយការងារនៃគេហទំព័រទាំងពីរ មានចំនួនការងារច្រើនគ្រប់គ្រាន់ហើយដែរនោះ ក្រុមការងារបានសម្រេចមិនយកគេហទំព័រនេះវិញ ។

ការសិក្សាស្រាវជ្រាវទទួលបានទិន្នន័យបែបគុណភាពមកពីការសម្ភាសបែបស៊ីជម្រៅជាមួយអ្នកដែលមានតួនាទីសំខាន់ផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងស្ថាប័នទាំងបួនដូចបានរៀបរាប់ខាងលើ ។ លើសពីនេះ ការសិក្សាបានបន្ថែមការពិភាក្សាជាក្រុមជាមួយនិស្សិតដែលសិក្សាផ្នែក ICT នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**តារាងទី១៖ វិធីសាស្ត្រសិក្សាស្រាវជ្រាវ និងឧបករណ៍ស្រាវជ្រាវ**

| កម្មវត្ថុស្រាវជ្រាវ | ប្រភេទអ្នកឆ្លើយតបសម្ភាស | គំរូតាង | សូចនាករ | វិធីសាស្ត្រប្រមូលទិន្នន័យ |
|---|---|---|---|---|
| *កម្មវត្ថុទី១ :* សមាមាត្រស្ត្រីដែលបានប្រើប្រាស់ ICT ក្នុងវិស័យអប់រំនិងការងារ | គ្រឹះស្ថានឧត្តមសិក្សាទាំងផ្នែកសាធារណៈ និងឯកជននៅទីក្រុងភ្នំពេញ | ៣៦ | <u>ទិន្នន័យបែបបរិមាណ</u><br>១. សមាមាត្រនិស្សិតថ្នាក់បរិញ្ញាបត្រ និងអនុបណ្ឌិតដែលបានបញ្ចប់ការសិក្សា និងកំពុងសិក្សានៅតាមបណ្តាសាកលវិទ្យាល័យនិងវិទ្យាស្ថានបណ្តុះបណ្តាលផ្សេងៗ<br>២. សមាមាត្រនៃបុគ្គលិកដែលកំពុងធ្វើការក្នុងស្ថាប័ន និងសមាមាត្រនៃបុរស និងស្ត្រីដែលធ្វើការក្នុងផ្នែក ICT | កម្រងបញ្ជីសំណួរដែលស្ថាប័នគោលដៅ ត្រូវបំពេញដោយខ្លួនឯង |
| | ក្រសួងនានា និងអាជ្ញាធរជាតិ | ២៨ | | |
| | អង្គការសង្គមស៊ីវិល | ១៥៨ | | |
| | ផ្នែកឯកជនមាន ហាងអ៊ីនធឺណិត និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត | ២១៤ | | |

| កម្មវត្ថុស្រាវជ្រាវ | ប្រភេទអ្នកឆ្លើយតបសម្ភាស | គំរូតាង | សូចនាករ | វិធីសាស្ត្រប្រមូលទិន្នន័យ |
|---|---|---|---|---|
| *កម្មវត្ថុទី២:* ទស្សនវិស័យយេនឌ័រក្នុងការងារ ICT | ការជ្រើសរើសការងារតាមរយៈគេហទំព័រ | ៣ | ទិន្នន័យបែបបរិមាណ ចំនួនការងារដែលបានផ្សព្វផ្សាយតាមរយៈប្រព័ន្ធអ៊ីនធឺណិត | សង្ខេបការផ្សព្វផ្សាយការងាររយៈពេលបីខែ |
| | គ្រឹះស្ថានឧត្តមសិក្សាទាំងផ្នែកសាធារណៈ និងឯកជននៅទីក្រុងភ្នំពេញ | ៣៦ | ទិន្នន័យបែបបរិមាណ ទស្សនវិស័យនានា អំពីស្ត្រី និងការងារផ្នែក ICT | កម្រងបញ្ជីសំណួរដែលស្ថាប័នគោលដៅ ត្រូវបំពេញដោយខ្លួនឯង |
| | | ១៥ | ទិន្នន័យបែបគុណភាព ទស្សនវិស័យនានា អំពីស្ត្រី និងការងារផ្នែក ICT | ការសម្ភាសបែបស៊ីជម្រៅ និងការពិភាក្សាជាក្រុមជាមួយនិស្សិត |
| | ក្រសួងនានា រួមនិងអាជ្ញាធរជាតិ | ២៨ | ទិន្នន័យបែបគុណភាព ទស្សនវិស័យនានា អំពីស្ត្រី និងការងារផ្នែក ICT | កម្រងបញ្ជីសំណួរដែលស្ថាប័នគោលដៅ ត្រូវបំពេញដោយខ្លួនឯង |
| | | ១៥ | ទិន្នន័យគុណភាព ទស្សនវិស័យនានា អំពីស្ត្រី និងការងារផ្នែក ICT | ការសម្ភាសបែបស៊ីជម្រៅ |
| | អង្គការសង្គមស៊ីវិល | ១៥៨ | ទិន្នន័យបរិមាណភាព ទស្សនវិស័យនានា អំពីស្ត្រី និងការងារផ្នែក ICT | កម្រងបញ្ជីសំណួរដែលស្ថាប័នគោលដៅ ត្រូវបំពេញដោយខ្លួនឯង |
| | | ១៥ | ទិន្នន័យគុណភាព ទស្សនវិស័យនានា អំពីស្ត្រី និងការងារផ្នែក ICT | ការសម្ភាសបែបស៊ីជម្រៅ |
| | ផ្នែកឯកជនមានហាងអ៊ីនធឺណិត និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត | ២១៤ | ទិន្នន័យបែបគុណភាព ទស្សនវិស័យនានា អំពីស្ត្រី និងការងារផ្នែក ICT | កម្រងបញ្ជីសំណួរដែលស្ថាប័នគោលដៅ ត្រូវបំពេញដោយខ្លួនឯង |
| | | ១៤ | ទិន្នន័យគុណភាព ទស្សនវិស័យនានា អំពីស្ត្រី និងការងារផ្នែក ICT | ការសម្ភាសបែបស៊ីជម្រៅ |

| កម្មវត្ថុស្រាវជ្រាវ | ប្រភេទអ្នកឆ្លើយតបសម្ភាស | គំរូតាង | សូចនាករ | វិធីសាស្ត្រប្រមូលទិន្នន័យ |
|---|---|---|---|---|
| *កម្មវត្ថុទី៣:* ឧបសគ្គរាំងស្ត្រីពីការចូលរួមក្នុងផ្នែក ICT ក្នុងវិស័យអប់រំ និងការងារ | ការវិភាគលើច្បាប់ និងគោលនយោបាយនានាដែលពាក់ព័ន្ធនឹងផ្នែក ICT | N/A | <u>ទិន្នន័យដែលមានស្រាប់</u> ច្បាប់ និងគោលនយោបាយនានាដែលពាក់ព័ន្ធនឹងផ្នែក ICT | ឯកសារដែលមាននៅក្នុងស្រុក និងក្រៅស្រុកដែលកម្ពុជាបានចុះហត្ថលេខា |
| | គ្រឹះស្ថានឧត្តមសិក្សាទាំងផ្នែកសាធារណៈ និងឯកជននៅទីក្រុងភ្នំពេញ | ៣៦ | <u>ទិន្នន័យបែបគុណភាព</u> ឧបសគ្គនានាដែលរារាំងស្ត្រី ពីការចូលក្នុងវិស័យអប់រំ និងការងារ | កម្រងបញ្ជីសំណួរដែលស្ថាប័នគោលដៅ ត្រូវបំពេញដោយខ្លួនឯង |
| | | ៣៦ | <u>ទិន្នន័យបែបគុណភាព</u> ឧបសគ្គនានាដែលរារាំងស្ត្រី ពីការចូលក្នុងវិស័យអប់រំ និងការងារ | ការសម្ភាសបែបស៊ីជម្រៅ និងការពិភាក្សាជាក្រុមជាមួយនិស្សិត |
| | ក្រសួងនានា និងអាជ្ញាធរជាតិ | ២៨ | <u>ទិន្នន័យបែបគុណភាព</u> ឧបសគ្គនានាដែលរារាំងស្ត្រី ពីការចូលក្នុងវិស័យអប់រំ និងការងារ | កម្រងបញ្ជីសំណួរដែលស្ថាប័នគោលដៅ ត្រូវបំពេញដោយខ្លួនឯង |
| | | ១៥ | <u>ទិន្នន័យបែបគុណភាព</u> ឧបសគ្គនានាដែលរារាំងស្ត្រី ពីការចូលក្នុងវិស័យអប់រំ និងការងារ | ការសម្ភាសបែបស៊ីជម្រៅ |
| | អង្គការសង្គមស៊ីវិល | ១៥៨ | <u>ទិន្នន័យបែបគុណភាព</u> ឧបសគ្គនានាដែលរារាំងស្ត្រី ពីការចូលក្នុងវិស័យអប់រំ និងការងារ | កម្រងបញ្ជីសំណួរដែលស្ថាប័នគោលដៅ ត្រូវបំពេញដោយខ្លួនឯង |
| | | ១៥ | <u>ទិន្នន័យបែបគុណភាព</u> ឧបសគ្គនានាដែលរារាំងស្ត្រី ពីការចូលក្នុងវិស័យអប់រំ និងការងារ | ការសម្ភាសបែបស៊ីជម្រៅ |
| | ផ្នែកឯកជនមានហាងអ៊ីនធឺណិត និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត | ២៤៦ | <u>ទិន្នន័យបែបគុណភាព</u> ឧបសគ្គនានាដែលរារាំងស្ត្រី ពីការចូលក្នុងវិស័យអប់រំ និងការងារ | កម្រងបញ្ជីសំណួរដែលស្ថាប័នគោលដៅ ត្រូវបំពេញដោយខ្លួនឯង |
| | | ១៥ | <u>ទិន្នន័យបែបគុណភាព</u> ឧបសគ្គនានាដែលរារាំងស្ត្រី ពីការចូលក្នុងវិស័យអប់រំ និងការងារ | ការសម្ភាសបែបស៊ីជម្រៅ |

## ៣.១. ក្រុមគោលដៅនៃការស្រាវជ្រាវ

នៅក្នុងការរៀបចំគោលគំនិតសិក្សាស្រាវជ្រាវ ក្រុមការងារបានធ្វើបទបង្ហាញអំពីគម្រោងនៃការសិក្សាស្រាវជ្រាវ កាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៩ ដើម្បីឲ្យអ្នកចូលរួមជួយផ្តល់មតិកែលំអ ដោយមានការចូលរួមពីតំណាងក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា អង្គការសង្គមស៊ីវិល និងអ្នកសិក្សាស្រាវជ្រាវ ។ ចំពោះទិន្នន័យបែបបរិមាណ អង្គប្រជុំនាពេលនោះ បានស្នើជ្រើសយកស្ថាប័នចំនួន ៤៣៦ ស្មើនឹង ៩៨៦កម្រងសំណួរ ដោយមានកម្រងសំណួរសម្រាប់ស្ថាប័នចំនួន ៤៣៦ និងកម្រងសំណួរសម្រាប់បុគ្គលិកចំនួន ៥៥០ ។ ដើម្បីអោយអ្នកចូលរួមស្រាវជ្រាវអាចតំណាងបានពីស្ថាប័នដែលសិក្សា ហើយជៀសផុតពីអត្រាអ្នកឆ្លើយតបទាប និងកំហុសឆ្គងក្នុងន័យស្ថិតិ ក្រុមការងារបានសម្រេចកំណត់យកស្ថាប័នចំនួនដដែល (៤៣៦) តែបានបន្ថែមចំនួនបុគ្គលិករហូតដល់១,៣០០នាក់ ។ ក្រុមគោលដៅ ត្រូវបានបែងចែកជា ៤ផ្នែកសំខាន់ៗគឺៈ

- ក្រសួងនានា និងអាជ្ញាធរជាតិ មាន ២៨ស្ថាប័ន ចែកជាកម្រងសំណួរសម្រាប់ ២៨ស្ថាប័ន និងកម្រងសំណួរសម្រាប់បុគ្គលិកចំនួន ១៥០កម្រងសំណួរ ។
- គ្រឹះស្ថានឧត្តមសិក្សា ទាំងផ្នែកសាធារណៈ និងឯកជននៅទីក្រុងភ្នំពេញចំនួន ៣៦ ត្រូវជាកម្រងសំណួរសម្រាប់ស្ថាប័ន ៣៦ និងកម្រងសំណួរសម្រាប់បុគ្គលិក ១៨០ ។
- អង្គការសង្គមស៊ីវិល សរុប ១៥៨ ចែកជាកម្រងសំណួរសម្រាប់ស្ថាប័ន ១៥៨ និងកម្រងសំណួរសម្រាប់បុគ្គលិកចំនួន ៤៧៤កម្រងសំណួរ ។
- ផ្នែកឯកជនដែលមាន ហាងអ៊ីនធឺណិត និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ដែលមានសរុប ២១៤ ត្រូវជាកម្រងសំណួរសម្រាប់ស្ថាប័ន ២១៤ និងកម្រងសំណួរសម្រាប់បុគ្គលិក ចំនួន ៧០ ។

ក្រុមការងារបានជ្រើសយកគេហទំព័រការងារសំខាន់ៗពីរ នៅក្នុងប្រទេសកម្ពុជាគឺ www.bongthom.com និង www.pelprek.com ដោយផ្សៀងផ្ទាត់ការងាររយៈពេលបីខែ ។

សម្រាប់ទិន្នន័យបែបគុណភាព ក្រុមការងារបានសម្រេចជ្រើសរើសយកការសម្ភាសបែបស៊ីជម្រៅជាមួយអ្នកដែលមានតួនាទីសំខាន់ផ្នែកបច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យាចំនួន ៥៩នាក់ ដែលក្នុងនោះមាន១៥នាក់មកពីក្រសួងនានា និងអាជ្ញាធរជាតិ ១៥នាក់មកពីគ្រឹះស្ថានឧត្តមសិក្សា ១៥នាក់មកពីអង្គការសង្គមស៊ីវិល និង១៤នាក់មកពីផ្នែកឯកជន ។ ជាងនេះទៀតដើម្បី អោយទិន្នន័យរឹតតែអាចបង្ហាញនូវតថភាពជាក់ស្តែង ការពិភាក្សាជាក្រុមជាមួយនិស្សិតដែលសិក្សាផ្នែក ICT នៅគ្រឹះស្ថានឧត្តមសិក្សាចំនួន ៦ ត្រូវបានជ្រើសរើសដែលមាននិស្សិតចាប់ពី ៥-៧នាក់ក្នុងស្ថាប័ននីមួយៗ ។

## ៣.២. វិធីសាស្រ្តប្រមូលទិន្នន័យ

ក្រុមការងារស្រាវជ្រាវ បានចុះទៅទំនាក់ទំនងដោយផ្ទាល់ជាមួយស្ថាប័ន ដូចបានរៀបរាប់ខាងលើដើម្បីបង្ហាញពីគោលបំណងនៃការស្រាវជ្រាវ ក៏ដូចជាផ្តល់លេខទូរសព្ទទំនាក់ទំនង ដើម្បីជួយសម្របសម្រួលបញ្ហាដែលកើតមានទាក់ទងនឹងការស្រាវជ្រាវ ។

កម្រងសំណួរបានបញ្ជូនទៅកាន់ស្ថាប័នដូចបានរៀបរាប់ខាងលើ តាមរយៈអ្នកជំនួយការស្រាវជ្រាវរបស់អង្គការវិទ្យាស្ថានបើកទូលាយ ដើម្បីអោយអ្នកតំណាងស្ថាប័ន និងបុគ្គលិកស្ថាប័នដែលចេះប្រើប្រាស់កុំព្យូទ័រជួយបំពេញ ហើយនិងទទួលបានការសម្ភាសស៊ីជម្រៅ ។ ក្នុងលក្ខខណ្ឌពិសេស ចំពោះស្ថាប័នឧត្តមសិក្សាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ មានលិខិតជួយសម្របសម្រួលដែលចេញពីក្រសួងទៅកាន់ស្ថាប័ន ដើម្បីអោយអ្នកតំណាងស្ថាប័ន និងបុគ្គលិកស្ថាប័នដែលចេះ

ប្រើកុំព្យូទ័រជួយបំពេញ ព្រមទាំងទទួលបានការសម្ភាសស៊ីជម្រៅជាមួយបុគ្គលិកដែលមានតួនាទីសំខាន់ផ្នែក ICT និងពិភាក្សាជាក្រុមជាមួយនិស្សិតដែលសិក្សាមុខវិជ្ជា ICT ។ ជាទូទៅក្រុមការងារបានបញ្ជូនកម្រងសំណួរ ៧ច្បាប់ទៅក្រសួងនានា និងអាជ្ញាធរជាតិ គ្រឹះស្ថានឧត្តមសិក្សា និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ដែលក្នុងនោះមានកម្រងសំណួរដោយឡែកពីគ្នាសម្រាប់ អ្នកតំណាងស្ថាប័ន ១រូប បុគ្គលិក ៥រូប និងការសម្ភាសស៊ីជម្រៅ ១រូប ។ ឯកម្រងសំណួរសម្រាប់ការពិភាក្សាជាក្រុមជាមួយនិស្សិត មានតែចំពោះស្ថាប័នអប់រំមួយចំនួនដែលបានផ្តល់ការអប់រំផ្នែក ICT ដល់និស្សិតតែប៉ុណ្ណោះ ។ ជាមធ្យមមានតែកម្រងសំណួរចំនួន ៤ច្បាប់ប៉ុណ្ណោះ ត្រូវបានផ្តល់ជូនអង្គការសង្គមស៊ីវិល ដើម្បីបំពេញ និងសម្ភាស ។ កម្រងសំណួរសម្រាប់ម្ចាស់ហាង អ៊ីនធឺណិត មានតែមួយច្បាប់ប៉ុណ្ណោះសម្រាប់ ម្ចាស់ហាងអ៊ីនធឺណិត ឬអ្នកទទួលខុសត្រូវក្នុងហាងនោះ ។

អ្នកដឹកនាំ ឬប្រធាន ឬគណៈគ្រប់គ្រងនៃស្ថាប័នដូចបានរៀបរាប់ខាងលើ ត្រូវបានស្នើ ដើម្បីជ្រើសតាំងតំណាងរបស់ខ្លួន និងបុគ្គលិកក្នុងស្ថាប័ន ដើម្បីចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ដោយមានរយៈពេល២សប្តាហ៍ ដើម្បីបំពេញកម្រងសំណួរបែបបរិមាណ និងចាត់ចែងអ្នកដែលមានតួនាទីសំខាន់សម្រាប់ធ្វើការសម្ភាសស៊ីជម្រៅរយៈពេលបីសប្តាហ៍ ។ ក្នុងពេលនោះដែរ ក្រុមការងារស្រាវជ្រាវ បានរក្សាទំនាក់ទំនងយ៉ាងល្អជាមួយស្ថាប័នគោលដៅ ព្រមទាំងបានស្នើសុំស្ថាប័នគោលដៅមួយចំនួនដែលក្រុមការងារយើងជ្រើសរើស ជួយសម្របសម្រួលពេលវេលាក្នុងការចាត់តាំងអ្នកគ្រប់គ្រងខាង ICT ដើម្បីអោយក្រុមការងារយើងសម្ភាសដោយផ្ទាល់ ហើយយើងក៏បានស្នើសុំទៅខាងស្ថាប័នអប់រំមួយចំនួនដែលយើងជ្រើសរើសជួយរៀបចំក្រុមនិស្សិតបានពិភាក្សាក្រុមផងដែរ ។ ក្នុងពេលប្រមូលកម្រងបញ្ជីសំណួរមកវិញ ក្រុមការងារបានត្រួតពិនិត្យមើលទិន្នន័យក្នុងកម្រងបញ្ជីសំណួរយ៉ាងច្បាស់លាស់ មុននឹងយក ហើយក្រុមការងារតែងតែពិភាក្សាគ្នា ក្នុងការចុះចែក និងប្រមូលទិន្នន័យដែលមានបញ្ហា ដើម្បីស្វែងរកដំណោះស្រាយ ។

## ៣.៣. ការវិភាគទិន្នន័យ

គ្រប់កម្រងសំណួរទាំងអស់ សុទ្ធតែបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ នៅពេលប្រមូលទិន្នន័យត្រឡប់មកវិញ និងបានលាងសម្អាតនូវរាល់កំហុសឆ្គងទាំងឡាយនៅក្នុងនិងឆ្លងវារីយ៉ាប ។ ក្រុមការងារបានប្រើកម្មវិធីវិភាគទិន្នន័យជាច្រើន ដើម្បីវិភាគរួមមាន៖

- ចំពោះការបញ្ចូលទិន្នន័យ គឺយើងបញ្ចូលតាម Epidata 3.1 ។ យើងបានបង្កើតរបៀបត្រួតពិនិត្យយ៉ាងត្រឹមត្រូវ ដើម្បីបង្ការរាល់កំហុសដែលអាចកើតមាននៅពេលបញ្ចូលទិន្នន័យ ។ ក្រោយពីបញ្ចូលរួចរាល់ហើយទិន្នន័យទាំងអស់នោះគឺយើងបានបម្លែងមកប្រើប្រាស់ក្នុង SPSS ។
- ការវិភាគទិន្នន័យបែបបរិមាណ ត្រូវបានប្រើប្រាស់នូវកម្មវិធីផ្នែកទន់ SPSS 18.0 ដើម្បីវិភាគស្វែងរកលទ្ធផលតាមរយៈគោលបំណងរបស់ការសិក្សាស្រាវជ្រាវ ។ ការវិភាគរួមមាន ភាគរយ(%) ប្រើប្រាស់តាមរយៈបម្លែងចែកប្រេកង់ជាមធ្យមភាគ ឬជាមេដ្យាន អាស្រ័យលើបម្លែងនៃទិន្នន័យ ។ មានន័យថា បើទិន្នន័យនោះមានបម្លែងចែករបាយស្មើសាច់គឺយើងប្រើមធ្យមភាគ(Mean) បើទិន្នន័យនោះមានលក្ខណៈមិនស្មើសាច់ គឺយើងប្រើមេដ្យាន(Median) ការប្រើប្រាស់តេស្តឃីកាវ៉េ ដើម្បីកំណត់ពីភាពខុសគ្នារវាងភាគរយពីរផ្សេងគ្នា និងកំណត់បញ្ហាទំនាក់ទំនងរវាងវ៉ារីយ៉ាបពីរផ្សេងៗគ្នា និងការវិភាគឆ្លងកាត់វ៉ារីយ៉ាប ជាដើម ។ល។
- តាមបែបគុណភាព ទិន្នន័យបានពីការសម្ភាសបែបស៊ីជម្រៅ និងការពិភាក្សាជាក្រុម ត្រូវបានបញ្ចូល និងវិភាគតាមកម្មវិធី NVIVO 8.0 ។ ការ

វិភាគរួមមានការបែងចែកតាមចំណាត់ថ្នាក់ និងតាមក្រុម ។

- បន្ទាប់មកលទ្ធផលនៃទិន្នន័យត្រូវបានបម្លែង ក្នុងកម្មវិធីការិយាល័យភាសាខ្មែរ ដើម្បីបកស្រាយទិន្នន័យ ។

ជាងនេះទៅទៀត ការវិភាគទិន្នន័យដែលមានស្រាប់ទាក់ទងនឹងច្បាប់ និងគោលនយោបាយនានាដែលពាក់ព័ន្ធនឹងផ្នែក ICT ដូចជា ច្បាប់រដ្ឋធម្មនុញ្ញ សេចក្តីព្រាងគោលនយោបាយជាតិស្តីពី បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន គោលនយោបាយ ICT ក្នុងវិស័យអប់រំ សន្និសីទលើកទី ៤ អំពីស្ត្រី នៅក្នុងទីក្រុងប៉េកាំងឆ្នាំ១៩៩៥ ជាអាទិ៍ ក៏បានបញ្ចូលនៅក្នុងការសិក្សានេះដែរ ។ មួយវិញទៀត ការប្រមូលឯកសារដែលពាក់ព័ន្ធពីប្រភពផ្សេងៗគ្នា (របាយការណ៍របស់រដ្ឋាភិបាល ស្ថិតិអំពី ICT និងបណ្ណាល័យ) ក៏ត្រូវបានប្រមូលផ្តុំដែរ ។ ការស្រាវជ្រាវតាមអ៊ីនធឺណិត គឺជាប្រភពដ៏សំខាន់ក្នុងការស្វែងរកឯកសារដែលមានស្រាប់ពីស្ថាប័នល្បីៗ លំដាប់ជាតិ និងអន្តរជាតិ ។

### ៣.៤. ការបណ្តុះបណ្តាលអំពីការប្រមូលទិន្នន័យ និងក្រមសីលធម៌

ការបណ្តុះបណ្តាលរយៈពេលប្រាំថ្ងៃដល់អ្នកជំនួយការសិក្សាស្រាវជ្រាវ ត្រូវបានធ្វើឡើងនៅអង្គការវិទ្យាស្ថានបើកទូលាយ ចាប់ពីថ្ងៃទី២១-២៦ ខែមិថុនា ឆ្នាំ២០១០ ។ ការបណ្តុះបណ្តាលផ្តោតលើ គោលបំណងនៃការសិក្សាស្រាវជ្រាវ ឧបករណ៍សម្រាប់ប្រមូលទិន្នន័យទូទៅ និងសិក្សាពីកម្រងបញ្ជីសំណួរទាំង ៤ប្រភេទក្នុងការប្រមូលទិន្នន័យ ការធ្វើតេស្តជាគូ ការធ្វើតេស្តសម្ភាសសាកល្បងជាមួយបុគ្គលិកនៅអង្គការវិទ្យាស្ថានបើកទូលាយ និងការហ្វឹកហាត់លើការប្រើប្រាស់ឧបករណ៍ថតសម្លេង ។ ការបណ្តុះបណ្តាល ក៏បានជួយសម្រួលខ្លឹមសារ អត្ថន័យ និងពាក្យពេចន៍មួយចំនួននៅក្នុងកម្រងបញ្ជីសំណួរ ដើម្បីអោយងាយយល់ និងមានលក្ខណៈច្បាស់លាស់ជាងមុន ។

ថ្វីត្បិតតែការសិក្សាស្រាវជ្រាវនេះ មិនមានការពាក់ព័ន្ធជាមួយនឹងបញ្ហារសើបណាមួយទេ តែក្នុងគោលបំណងការពារអ្នកឆ្លើយតបពីការប៉ះពាល់ណាមួយ ដោយមិនបានព្រាងទុកជាមុនណាមួយនោះ ការសិក្សាបានរៀបចំវិធីសាស្ត្រមួយចំនួនដូចខាងក្រោម៖

- ការបណ្តុះបណ្តាល អំពីក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ដល់អ្នកជំនួយការស្រាវជ្រាវ
- ការចែកចាយកម្រងសំណួរនៅតាមស្ថាប័ននានា សុទ្ធតែត្រូវបានទទួលការយល់ព្រមពីតំណាងស្ថាប័នទាំងនោះ ។ នៅក្នុងកម្រងសំណួរនីមួយៗ មានភ្ជាប់នូវការសុំការអនុញ្ញាតមុននឹងបំពេញកម្រងសំណួរ គោលបំណងនៃការសិក្សាស្រាវជ្រាវ ព្រមទាំងមានបែបបទណែនាំក្នុងការប្រើប្រាស់ឬឆ្លើយអោយបានត្រឹមត្រូវចំពោះសំណួរនីមួយៗ ។ ម៉្យាងទៀត អត្ថន័យនៃកម្រងសំណួរ មិនមានការប៉ះពាល់ដល់បុគ្គលិក ស្ថាប័ន ឬអ្នករួមការងាររបស់អ្នកតបសម្ភាសឡើយ ។ បន្ថែមលើសពីនេះ អ្នកចូលរួមឆ្លើយ មានសិទ្ធិគ្រប់គ្រាន់ក្នុងការបដិសេធមិនឆ្លើយ សំណួរណាដែរគាត់មិនពេញចិត្ត ។
- រាល់ទិន្នន័យដែលបានពីការសម្ភាស និងត្រូវដាក់លេខកូដ ដោយមិនអាចសម្គាល់ពីអត្តសញ្ញាណរបស់អ្នកតបសម្ភាសឡើយ ។ មានតែសមាជិកក្រុមសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ ដែលមានសិទ្ធិពិនិត្យទិន្នន័យដើម ហើយធ្វើការកែលម្អអោយសមស្របទៅតាមគោលបំណងនៃការសិក្សាស្រាវជ្រាវ ។
- លទ្ធផលនៃការសិក្សាស្រាវជ្រាវ នឹងត្រូវបានបោះពុម្ព និងផ្សព្វផ្សាយជាសាធារណៈ ដោយរក្សាអនាមិកភាពរបស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ ។

### ៣.៩. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ អំពីស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យា ក្នុងវិស័យអប់រំ និងការងារ គឺជាប្រធានបទថ្មីមួយ ដែលទើបតែមានការសិក្សាស្រាវជ្រាវនេះឡើង ។ ការសិក្សានេះធ្វើឡើងតែនៅ រាជធានីភ្នំពេញតែប៉ុណ្ណោះ ដូច្នេះចំនួនគំរូតាងនៅក្នុងការសិក្សានេះ វាអាចត្រឹមតែទីតាំង និងស្ថាប័នដែលបានធ្វើការសិក្សាតែប៉ុណ្ណោះ ហើយវាមិនអាចតំណាងអោយទូទាំងប្រទេសឡើយ ។ ទន្ទឹមនឹងគ្នានេះ ការសិក្សាស្រាវជ្រាវមានដែនកំណត់ដូចខាងក្រោម៖

- ការសិក្សាស្រាវជ្រាវបានព្យាយាមស្វែងរកឯកសារយោង សម្រាប់សរសេរក្នុងឯកសារពាក់ព័ន្ធ ក៏ដូចជានៅក្នុងការពិភាក្សា ក្នុងបរិបទប្រទេសកម្ពុជា ក៏ដូចជាឯកសារនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ នៅតាមបណ្ណាល័យ ព្រមទាំងនៅលើអ៊ីនធឺណិត ។ ទោះជាយ៉ាងនេះក្តីយើងបានរកឃើញឯកសារតិចតួចប៉ុណ្ណោះដែលមានលក្ខណៈពាក់ព័ន្ធ អាចធ្វើជាឯកសារយោងបាន ។
- ពេលវេលាមានកំណត់ និងមមាញឹក វាក៏ជាបញ្ហាមួយដែរ ក្នុងការបង្កើតអោយមានកំហុសដោយអចេតនាមួយចំនួនដូចជា៖ អក្ខរាវិរុទ្ធ ពាក្យពេចន៍ឃ្លាឃ្លោងមួយចំនួនដែលប្រើប្រាស់ក្នុងការសរសេរមិនសូវបានល្អ ។ ព្រមជាមួយគ្នានោះ នៅក្នុងប្រទេសកម្ពុជានៅពុំទាន់មានការបកប្រែភាសាបច្ចេកទេសក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យានៅឡើយទេ ។

# ៤. លទ្ធផលនៃការស្រាវជ្រាវ

## ៤.១. ព័ត៌មានទូទៅ

### តារាងទី២៖ កម្រងសំណួរដែលប្រមូលបាន

| ស្ថាប័ន | | អ្នកតំណាងស្ថាប័ន (នាក់) | បុគ្គលិក (នាក់) | សម្ភាសស៊ីជម្រៅ (នាក់) | ការពិភាក្សាក្រុម (នាក់) |
|---|---|---|---|---|---|
| ក្រសួងរបស់រដ្ឋាភិបាល | | ១៧ | ១១៤ | ១៩ | -- |
| អង្គការសង្គមស៊ីវិល | | ១១១ | ២៩០ | ២២ | |
| ផ្នែកឯកជន | ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត | ៧ | ២៦ | ៧ | |
| | ហាងអ៊ីនធឺណិត | ១៨១ | -- | -- | |
| ស្ថាប័នអប់រំ | | ៣៤ | ១០១ | ១៦ | ១១ |
| **សរុប (នាក់)** | | **៣៥០** | **៥៣១** | **៦៤** | **១១** |

ដោយមិនគិតពីកម្រងសំណួរសម្រាប់ការសម្ភាសបែបស៊ីជម្រៅ និងការសម្ភាសជាក្រុមជាមួយនិស្សិត កម្រងសំណួរចំនួន ១,៣០០ ត្រូវបានផ្ញើទៅកាន់ស្ថាប័នចំនួន ៤៣៦ ដែលរួមមាន ក្រសួងនានារបស់រដ្ឋាភិបាលចំនួន២៨ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ៣៦ អង្គការសង្គមស៊ីវិល១៥៨ និងហាងអ៊ីនធឺណិត២០០ ។ មានតែកម្រងសំណួរចំនួន ៨៨១មកពីស្ថាប័នចំនួន ៣៥០ប៉ុណ្ណោះ ដែលត្រូវបានយកមកវិភាគនៅក្នុងការសិក្សាស្រាវជ្រាវនេះ ។

ចំពោះការផ្សព្វផ្សាយការងារតាមគេហទំព័រ ក្រុមការងារបានកំណត់យកគេហទំព័រតែពីរប៉ុណ្ណោះ មកធ្វើការវិភាគ គឺ http://www.pelprek.com/ និង http://www.bongthom.com/ ដោយគេហទំព័រ ការងារ http://camhr.com/ មិនបានអនុញ្ញាតអោយមានការស្ទង់មតិអំពីការងារនៅលើគេហទំព័រនេះ ។ ការប្រមូលទិន្នន័យនៅលើគេហទំព័រនេះ គឺចាប់ផ្តើមពីថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១០ ដល់ថ្ងៃ ០៥ ខែតុលា ឆ្នាំ២០១០ ។

តាមវិធីសាស្ត្រស្រាវជ្រាវបែបគុណភាព ក្នុងការសម្ភាសស៊ីជម្រៅជាមួយអ្នកដែលទទួលខុសត្រូវខាងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានៅតាមស្ថាប័ន មានអ្នកឆ្លើយតប ៥៥នាក់ជាបុរស និង៩នាក់ជាស្ត្រី ដែលក្នុងនោះ អ្នកឆ្លើយតបចំនួន ៥០នាក់មានសញ្ញាប័ត្រខាងផ្នែកព័ត៌មានវិទ្យា (៣០នាក់ថ្នាក់បរិញ្ញាបត្រ ១៥នាក់ថ្នាក់អនុបណ្ឌិត និង២នាក់ថ្នាក់បណ្ឌិត) ។ បើគិតពីស្ថានភាពជីវភាពវិញ ២០នាក់មានកម្រិតជីវភាពមធ្យម និង៤៣នាក់មានជីវភាពប្រសើរ (មិនមានចម្លើយម្នាក់) ។ ដោយឡែកចំពោះកម្រិតការងារ ៣៦នាក់មានកម្រិតខ្ពស់ និង២៨នាក់គ្រាន់តែជាបុគ្គលិកធម្មតា ។ ការពិភាក្សាជាក្រុមជាមួយនិស្សិតដែលសិក្សាមុខវិជ្ជាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាចំនួន ១១ក្រុមពិភាក្សា ក៏ត្រូវបានធ្វើឡើងដែរនៅតាមគ្រឹះស្ថានអប់រំ ។

# ៤. លទ្ធផលនៃការស្រាវជ្រាវ

តារាងទី៣៖ ចំនួនជាមធ្យមនៃបុគ្គលិកតាមស្ថាប័ននីមួយ (n=៣៨០)

| ស្ថាប័ន | ភេទ | សមាមាត្រ |
|---|---|---|
| អង្គការសង្គមស៊ីវិល | ស្ត្រី | ២៥ (៤៦,៣) |
| | ចំនួនសរុប | ៥៤ |
| ក្រសួងនានា និងអាជ្ញាធរជាតិ | ស្ត្រី | ៣០៦ (៣៦,៣) |
| | ចំនួនសរុប | ៨៤៤ |
| ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត | ស្ត្រី | ៤២(៣២,១) |
| | ចំនួនសរុប | ១៣១ |
| គ្រឹះស្ថានឧត្តមសិក្សា | ស្ត្រី | ៣៧ (២៧,៨) |
| | ចំនួនសរុប | ១៣៣ (១០០) |

លទ្ធផលបានបង្ហាញអោយឃើញថា បើគិតពីចំនួន ជាទូទៅបុគ្គលិកនៅក្នុងក្រសួងនានា មានចំនួនច្រើនជាងគេ បើធៀបជាមួយនឹងបុគ្គលិកនៅតាមស្ថាប័នផ្សេងទៀត ។ តែបើគិតពីសមាមាត្របុគ្គលិកស្រីវិញ យើងឃើញថា អង្គការសង្គមស៊ីវិលមានសមាមាត្រស្ត្រីច្រើនជាងគេគឺ ៤៦,៣% បន្ទាប់មកក្រសួងនានា និងអាជ្ញាធរជាតិ ៣៦,៣% ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ៣២,១% និងចុងក្រោយគ្រឹះស្ថានឧត្តមសិក្សា ២៧,៨% ។

## ៤.២. ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ

### ៤.២.១. ស្ថិតិរបស់ស្ត្រីក្នុងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ

តារាងទី៤៖ ស្ថិតិនិស្សិតដែលបានបញ្ចប់ការសិក្សា និងកំពុងសិក្សាមុខវិជ្ជា ICT ថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់

| | | | ចំនួន ស្ថាប័ន | សរុប (នាក់) | ស្រី នាក់ (%) | តិចបំផុត (នាក់) | ច្រើនបំផុត (នាក់) | មធ្យម (នាក់) |
|---|---|---|---|---|---|---|---|---|
| បរិញ្ញាបត្រ | ២០០៥-២០០៦ | (១) | ១២ | ១១៧៧ | ១៥៦ (១៣,៣) | ៦ | ៣២៦ | ៩៨ |
| | | (២) | ៣ | ១៦៥ | ៦ (៣,៦) | ១១ | ១២៧ | ៥៥ |
| | | (៣) | ១ | ២២ | ៧ (៣១,៨) | ២២ | ២២ | ២២ |
| | | សរុប | ១២ | ១៣៦៤ | ១៦៩ (១២,៤) | ៦ | ៤៥៣ | ១១៤ |
| | ២០០៦-២០០៧ | (១) | ១៥ | ១២០៦ | ១០៩ (៩,០) | ៨ | ១៩៨ | ៨០ |
| | | (២) | ៣ | ៨២ | ១ (១,២) | ១២ | ៤៧ | ២៧ |
| | | (៣) | ១ | ១៥ | ៦ (៤០,០) | ១៥ | ១៥ | ១៥ |
| | | សរុប | ១៥ | ១៣០៣ | ១១៦ (៨,៩) | ១០ | ២២២ | ៨៧ |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

| | | | ចំនួនស្ថាប័ន | សរុប (នាក់) | ស្រី នាក់ (%) | តិចបំផុត (នាក់) | ច្រើនបំផុត (នាក់) | មធ្យម (នាក់) |
|---|---|---|---|---|---|---|---|---|
| បានបរិញ្ញាបត្រ | ២០០៧-២០០៨ | (១) | ១៣ | ១១៣៥ | ១០២ (៩,០) | ១១ | ២១០ | ៨៧ |
| | | (២) | ៤ | ១៤៣ | ៤ (២,៨) | ១៦ | ៥៤ | ៣៦ |
| | | (៣) | ១ | ៩ | ៥ (៥៥,៦) | ៩ | ៩ | ៩ |
| | | សរុប | ១៤ | ១២៨៧ | ១១១ (៨,៦) | ១៣ | ២៥៨ | ៩២ |
| | ២០០៨-២០០៩ | (១) | ១៧ | ១៧១៦ | ៣២៦ (១៩,០) | ៧ | ៣៤៤ | ១០១ |
| | | (២) | ៤ | ១៥៨ | ១ (០,៦) | ២០ | ៦៩ | ៤០ |
| | | (៣) | ១ | ១៥ | ២ (១៣,៣) | ១៥ | ១៥ | ១៥ |
| | | សរុប | ១៨ | ១៨៨៩ | ៣២៩ (១៧,៤) | ៧ | ៣៤៤ | ១០៥ |
| | សរុប | (១) | ១៨ | ៥២៣៤ | ៦៩៣ (១៣,២) | ១៧ | ៨៨៦ | ២៩១ |
| | | (២) | ៤ | ៥៤៨ | ១២ (២,២) | ៦២ | ២៩១ | ១៣៧ |
| | | (៣) | ១ | ៦១ | ២០ (៣២,៨) | ៦១ | ៦១ | ៦១ |
| | | សរុប | ១៨ | ៥៨៤៣ | ៧២៥ (១២,៤) | ១៧ | ១១៧៧ | ៣២៤ |
| បរិញ្ញាបត្រ | ឆ្នាំទី១ | (១) | ១៩ | ៣០៨៥ | ២៦៥ (៨,៦) | ១៤ | ៧៤០ | ១៦២ |
| | | (២) | ២ | ១៥៣ | ៦ (៣,៩) | ២៣ | ១៣០ | ៧៦ |
| | | (៣) | ២ | ៤១ | ២៣ (៥៦,១) | ១០ | ៣១ | ២០ |
| | | សរុប | ១៩ | ៣២៨៣ | ២៩៤ (៩,០) | ១៤ | ៧៤០ | ១៧៣ |
| | ឆ្នាំទី២ | (១) | ១៧ | ២៨៩៥ | ៣១១ (១០,៧) | ១០ | ៥៧៧ | ១៧០ |
| | | (២) | ៣ | ២៦៤ | ៩ (៣,៤) | ៤៩ | ១១ | ៨៨ |
| | | (៣) | ២ | ៣៤ | ១៣ (៣៨,២) | ២ | ១២ | ១៧ |
| | | សរុប | ១៨ | ៣១៩៣ | ៣៣៣ (១០,៤) | ១០ | ៥៩៩ | ១៧៧ |
| | ឆ្នាំទី៣ | (១) | ១៧ | ១៨៥៣ | ១៥២ (៨,២) | ២ | ៣៩០ | ១០៩ |
| | | (២) | ៣ | ២១៤ | ៨ (៣,៧) | ៥៤ | ៨៧ | ៧១ |
| | | (៣) | ២ | ២៦ | ១០ (៣៨,៥) | ៥ | ២១ | ១៣ |
| | | សរុប | ១៧ | ២០៩៤ | ១៧០ (៨,១) | ៧ | ៣៩០ | ១២៣ |
| | ឆ្នាំទី៤ | (១) | ១៦ | ១៨២២ | ១៦១ (៨,៨) | ៦ | ៣៥៣ | ១១៤ |
| | | (២) | ៣ | ១៩១ | ១ (០,៥) | ៤៥ | ៩៩ | ៦៤ |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

| | | | ចំនួនស្ថាប័ន | សរុប (នាក់) | ស្រី នាក់ (%) | តិចបំផុត (នាក់) | ច្រើនបំផុត (នាក់) | មធ្យម (នាក់) |
|---|---|---|---|---|---|---|---|---|
| | | (៣) | ១ | ២៣ | ១០ (៤៣,៥) | ២៣ | ២៣ | ២៣ |
| | | សរុប | ១៦ | ២០៣៦ | ១៧២ (៨,៤) | ៦ | ៣៥៣ | ១២៧ |
| បរិញ្ញាបត្រ | សរុប | (១) | ២០ | ៩៦៥៦ | ៨៨៩ (៩,២) | ៣៩ | ១៩២៨ | ៤៨២ |
| | | (២) | ៤ | ៨២២ | ២៤ (២,៩) | ១១១ | ៣៥២ | ២០៦ |
| | | (៣) | ២ | ១២៤ | ៥៦ (៤៥,២) | ២៧ | ៩៧ | ៦២ |
| | | សរុប | ២០ | ១០៦១០ | ៩៦៩ (៩,១) | ៦៦ | ១៩២៩ | ៥៣០ |
| កំពុងសិក្សាថ្នាក់អនុបណ្ឌិត | ឆ្នាំទី១ | (១) | ៤ | ១៣៤ | ៧ (៥,២) | ១០ | ៥៧ | ៣៤ |
| | | (៣) | - | - | - | - | - | - |
| | | សរុប | ៤ | ១៣៤ | ៧ (៥,២) | ១០ | ៥៧ | ៣៤ |
| | ឆ្នាំទី២ | (១) | ១ | ៥៣ | ៣ (៥,៧) | ៥៣ | ៥៣ | ៥៣ |
| | | (៣) | ១ | ២១ | ១ (៤,៨) | ២១ | ២១ | ២១ |
| | | សរុប | ២ | ៧៤ | ៤ (៥,៤) | ២១ | ៥៣ | ៣៧ |
| | ២០០៨-២០០៩ | (១) | ៤ | ១២១ | ៧ (៥,៨) | ២ | ៨៥ | ៣០ |
| | | (៣) | ១ | ៩ | ១ (១១,១) | ៩ | ៩ | ៩ |
| | | សរុប | ៤ | ១៣០ | ៨ (៦,២) | ២ | ៨៥ | ៣២ |
| | ២០០៧-២០០៨ | (១) | ៤ | ៣២០ | ១១៣ (៣៥,៣) | ៥ | ២៨៣ | ៨០ |
| | | (៣) | - | - | - | - | - | - |
| | | សរុប | ៤ | ៣២០ | ១១៣ (៣៥,៣) | ៥ | ២៨៣ | ៨០ |

សំគាល់៖
១ = វិស្វករ និងវិទ្យាសាស្ត្រកុំព្យូទ័រ ឬព័ត៌មានវិទ្យា (Computer Science and Engineering/Information Technology)
២ = អគ្គីសនី និងអេឡិចត្រូនិក (Electronics and Electrical Science)
៣ = ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (Media and Telecommunication)

គម្លាតគំរូនៃស្ថិតិរបស់និស្សិតនៅតាមស្ថាប័ននីមួយៗ មានភាពខុសគ្នាយ៉ាងខ្លាំង ដែលបញ្ជាក់ពីភាពខុសគ្នានៃគ្រឹះស្ថានឧត្តមសិក្សាដែលបានចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវនេះ ។ តាមតារាងទី៣ខាងលើ យើងឃើញថា ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រកាលពី៤ឆ្នាំកន្លងទៅ មានចំនួនច្រើនជាង១ពាន់នាក់ក្នុង១ឆ្នាំៗសិក្សា តែទោះជាយ៉ាងនេះក្តី ចំនួននិស្សិតស្រីមានប្រហែលតែ ១២%ប៉ុណ្ណោះ នៃនិស្សិតទាំងអស់ ។ ជំនាញ វិស្វករ និងវិទ្យាសាស្ត្រកុំព្យូទ័រ ឬព័ត៌មានវិទ្យា គឺជាជំនាញដែលមាននិស្សិតរៀនច្រើនជាងគេបំផុតក្នុងចំណោមជំនាញទាំងបី តែបើប្រៀបធៀបសមាមាត្រនៃនិស្សិតស្រីដែលមានច្រើន

ជាងគេ គឺជំនាញប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ។ ក្នុងឆ្នាំសិក្សា២០០៩-២០១០នេះ ចំនួននិស្សិតសរុបមានការកើនឡើង៣ដង ដែលមានរហូតទៅដល់បីពាន់នាក់ជាង បើធៀបនឹង៤ឆ្នាំកន្លងមក និងមានការកើនឡើង២ដង បើធៀបនឹងពីរឆ្នាំកន្លងមកនេះ ។ ចំពោះកម្រិតក្រោយឧត្តមសិក្សា មានសាកលវិទ្យាល័យតែ៤ប៉ុណ្ណោះដែលបានផ្តល់ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ ។ ក្នុងឆ្នាំសិក្សា២០០៧-២០០៨ និស្សិតហាក់ដូចជាមានការចាប់អារម្មណ៍ ក្នុងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រកុំព្យូទ័រ ដែលរួមទាំងនិស្សិតភេទស្រីដែលមានរហូតដល់ទៅ៣៥% ។ លុះឆ្នាំបន្ទាប់ និស្សិតមានការធ្លាក់ចុះស្ទើរតែបីដង ពី៣២០នាក់ មកត្រឹម១៣០នាក់ ។ នៅក្នុងឆ្នាំសិក្សា២០០៩-២០១០នេះ ចំនួននិស្សិតឆ្នាំទី២បន្តការធ្លាក់ចុះ មកត្រឹម៧៤នាក់ តែចំនួននេះមានការកើនឡើងនៅក្នុងឆ្នាំទី១ ។ ទោះជាយ៉ាងនេះក្តី សមាមាត្ររបស់និស្សិតស្រីក្នុងឆ្នាំសិក្សានេះ មានត្រឹមតែ៥%ប៉ុណ្ណោះ ។

ខាងក្រោមនេះ គឺជាការសង្ខេបលទ្ធផលនៃការពិភាក្សាជាក្រុមជាមួយនិស្សិត ដែលសិក្សាមុខវិជ្ជា បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា៖

**ហេតុអ្វីបានជ្រើសរើសមុខវិជ្ជាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ?**

- អាចធ្វើអោយប្រទេសកម្ពុជា មានការអភិវឌ្ឍ
- ងាយស្រួលរកការងារ
- ជាចំណង់ចំណូលចិត្តរបស់ខ្លួន
- ដឹងព័ត៌មានយ៉ាងច្រើន
- គ្រប់ការងារទាំងអស់សុទ្ធតែត្រូវការបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ត្រូវតែដឹងពីបច្ចេកវិទ្យា
- ងាយស្រួលរកលុយ
- ការទំនាក់ទំនងគ្នាយ៉ាងងាយស្រួល
- ទីផ្សារការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមានចំនួនច្រើន
- មុខវិជ្ជាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាជាមុខវិជ្ជាមានប្រជាប្រិយភាព
- ឪពុកម្តាយ ឬបងប្អូនណែនាំអោយសិក្សា
- ទទួលបានអាហារូបករណ៍
- ពូកែខាងគណិតវិទ្យា
- ការសិក្សាមុខវិជ្ជានេះអាចបង្កើនចំណេះដឹងភាសាអង់គ្លេស
- រៀន ICT អាចរកបានការងារធ្វើក្នុងការិយាល័យ

**ហេតុអ្វីបានជាស្ត្រីសិក្សាមុខវិជ្ជាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមានចំនួនតិចជាងបុរស ?**

- ការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ជាការងារលំបាក និងសម្រាប់តែបុរសប៉ុណ្ណោះ
- ពិបាកសិក្សា ដោយត្រូវប្រើគណិតវិទ្យា និងមានមុខវិជ្ជាច្រើន
- មានការខ្មាសអៀន និងពិបាកក្នុងការទំនាក់ទំនងជាមួយសាស្ត្រាចារ្យ និងនិស្សិតដែលភាគច្រើនជាបុរស
- មិនមានការលើកទឹកចិត្តពីគ្រួសារ
- ក្រុមហ៊ុនមិនជ្រើសរើសបុគ្គលិកនារីដែលមានជំនាញ ICT ( រើសតែបុរស )
- មិនមានចំណង់ចំណូលចិត្តរៀនផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- វប្បធម៌របស់ខ្មែរ ( ផ្នត់គំនិត និងគំនាបពីប្រពៃណីមិនអោយរៀន )
- មានស្រីតិចតួចដែលបានសិក្សាផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- មិនមានមូលដ្ឋានចំណេះដឹងច្រើនផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

- គិតថាការងារបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា គឺជាការងារជួសជុលតែប៉ុណ្ណោះ
- ចំណាយលុយច្រើន
- ស្ត្រីត្រូវធ្វើការងារផ្ទះ
- មានចំនួនស្ត្រីតិចតួចមកពីជនបទ
- ផ្សេងៗ (និស្សិតបុរសតាមចែចង់និស្សិតស្រីដែលរៀនផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា)
- ប្រើខួរក្បាលច្រើន (ឆាប់ចាស់)

**តើអ្នកចង់អោយមានស្ត្រីចូលសិក្សាផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាកាន់តែច្រើនជាងមុនទេ?**

- អាចធ្វើអោយមានភាពស្មើគ្នារវាងបុរស និងចំណេះដឹង
- អាចធ្វើការអភិវឌ្ឍសង្គមបាន
- គ្រប់ការងារសុទ្ធតែត្រូវការជំនាញបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ងាយស្រួលរកការងារ ដោយសារតែមានអាទិភាពការងារ
- ដើម្បីកុំអោយមានការខ្មាសអៀន (ងាយស្រួលក្នុងការទំនាក់ទំនងជាមួយសាស្ត្រាចារ្យ និងនិស្សិតដែលជាបុរស)
- ធ្វើការក្នុងការិយាល័យ
- អាចធ្វើការនៅផ្ទះ
- ស្ត្រីក៏ដឹងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដូចបុរសដែរ
- ផ្តល់តម្លៃអោយស្ត្រីកាន់តែច្រើនជាងមុន

### ៤.២.២. ភាពឆ្លើយតបកម្មវិធីសិក្សាផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានៅ តាមគ្រឹះស្ថានឧត្តមសិក្សាចំពោះការងារ

គ្រឹះស្ថានអប់រំបានបង្ហាញថា ពួកគាត់មានគោលនយោបាយចម្បងៗ ក្នុងការជំរុញអោយស្ត្រីចុះឈ្មោះចូលរៀនផ្នែក ICT អោយកាន់តែច្រើនឡើង ដោយបានបញ្ចុះតម្លៃនៃការសិក្សាមាន ៤0% និងស្វែងរកការងារដល់ស្ត្រីទាំងនេះក្រោយបញ្ចប់ការសិក្សាបាន ២0% ។ ទន្ទឹមនឹងនេះផងដែរ ពួកគាត់ជំរុញអោយស្ត្រីចូលរួម តាមរយៈការពិគ្រោះយោបល់អំពីការងារផ្នែក ICT និងតាមរយៈការបង្ហាញពីផលចំណេញរបស់ ICT ក្នុងការធ្វើការងារ និងលទ្ធភាពក្នុងការទទួលបានការងារខ្ពស់នៅក្នុងសេចក្តីប្រកាសស្វែងរកការងារ ឬការផ្តល់អាទិភាពការងារជូនពួកគាត់ ។

ក្នុងការអភិវឌ្ឍកម្មវិធីសិក្សាអោយមានភាពទាន់សម័យ និងអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ស្ថាប័នអប់រំបាននិយាយថា ពួកគេត្រៀមខ្លួនយ៉ាងមុឌមាំ ក្នុងការផ្តល់ឧបករណ៍និងមន្ទីរពិសោធន៍ចំពោះសិស្សក្នុងការអនុវត្ត ធ្វើការសហការជាមួយក្រុមហ៊ុនកុំព្យូទ័រដែលជាដៃគូ ព្រមទាំងពង្រីកនិងពង្រឹងគុណភាពសាស្ត្រាចារ្យជាមួយវិទ្យាស្ថានបរទេស ឬក៏ផ្លាស់ប្តូរកម្មវិធីថ្មីៗ ។

**តារាងទី៨៖ កម្រិតនៃភាពឆ្លើយតបរបស់កម្មវិធីសិក្សា ICT ចំពោះទីផ្សារការងារ ICT របស់ស្ថាប័នអប់រំ**

| | | សិក្សាសាធារណៈ ចំនួន (%) | សិក្សាឯកជន ចំនួន (%) | សរុប ចំនួន (%) |
|---|---|---|---|---|
| កម្មវិធីសិក្សាអាចឆ្លើយតបនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ន (n=២៨) | មិនយល់ស្រប | -- | -- | -- |
| | យល់ស្រប | ៨ (១០០) | ២០ (១០០) | ២៨ (១០០) |
| កម្មវិធីសិក្សាអាចឆ្លើយតបនឹងតម្រូវការទីផ្សារការងារនាពេលអនាគត (n=២៦) | មិនយល់ស្រប | ២ (២៥) | ២ (២២,២) | ៤ (១៥,៤) |
| | យល់ស្រប | ៦ (៧៥) | ១៦ (៨៨,៩) | ២២ (៨៤,៦) |
| កម្មវិធីសិក្សាអាចឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និន្នាការនៃការអភិវឌ្ឍវិស័យICT របស់ប្រទេស(n=២៦) | មិនយល់ស្រប | -- | ១ (៥,៦) | ១ (៣,៨) |
| | យល់ស្រប | ៨ (១០០) | ១៧ (៩៤,៦) | ២៥ (៩៦,២) |
| លទ្ធភាពក្នុងការទទួលបានការងារផ្នែក ICT បន្ទាប់ពីគេបានបញ្ចប់ការសិក្សានៅស្ថាប័ននេះ (n=២៣) | មិនយល់ស្រប | -- | -- | -- |
| | យល់ស្រប | ៧ (១០០) | ១៦ (១០០) | ២៣ (១០០) |

ទិន្នន័យខាងលើបានបង្ហាញអោយឃើញថាជាទូទៅ ទាំងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន គឺភាគច្រើនពួកគាត់ (៨៥%-១០០%) យល់ស្របចំពោះបញ្ហាសំណួរដែលលើកឡើងអំពីកម្មវិធីសិក្សារបស់ពួកគាត់ក្នុងការឆ្លើយតបនឹងតម្រូវការទីផ្សារបច្ចុប្បន្នទៅអនាគត ក្នុងនោះដែរយើងឃើញថាពួកគាត់ទាំងអស់(១០០%) យល់ថាក្រុមនិស្សិតដែលបញ្ចប់ការសិក្សាអាចមានលទ្ធភាពក្នុងការស្វែងរកការងារ ។

ដើម្បីផ្ទៀងផ្ទាត់ចម្លើយនេះ សំណួរដដែលនេះត្រូវបានសួរដល់និស្សិតដើម្បីអោយបញ្ជាក់ពីបញ្ហានេះ៖

*ការពិភាក្សាជាក្រុមជាមួយនិស្សិតអំពី កម្មវិធីសិក្សានៃគ្រឹះស្ថានដែលគេកំពុងសិក្សា អាចឆ្លើយតបនឹងតម្រូវការងារទីផ្សារក្នុងពេលបច្ចុប្បន្ន និងអនាគត*

*ឆ្លើយតប*

- មានគណៈកម្មាធិការដើម្បីធ្វើអោយកម្មវិធីសិក្សារៀងរាល់ឆ្នាំទាន់សម័យ
- សាកលវិទ្យាល័យផ្តល់សម្ភារៈសិក្សាគ្រប់គ្រាន់
- សាកលវិទ្យាល័យមានដាក់អ៊ីនធឺណិតអោយប្រើប្រាស់
- មានជំនាញសិក្សាច្រើន
- សាស្ត្រាចារ្យមានចំណេះដឹងខ្ពង់ខ្ពស់
- មានកម្មសិក្សា
- ស្វែងរកគម្រោងសម្រាប់និស្សិត
- កម្មវិធីសិក្សាដូចប្រទេសគេ
- ការធ្វើតេស្តលើបណ្តាញ
- សាស្ត្រាចារ្យមានពេលគ្រប់គ្រាន់ដើម្បីពន្យល់
- មានរៀបចំសិក្សាស្តីពីការងារផ្នែកបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា

*មិនឆ្លើយតប*

- ខ្វះសម្ភារៈសិក្សា
- ចំនួនម៉ោងនៃវគ្គសិក្សាមានរយៈពេលខ្លីពេក

# ៤. លទ្ធផលនៃការស្រាវជ្រាវ

*ការពិភាក្សាជាក្រុមជាមួយនិស្សិតអំពី ភាពមានចំណេះដឹងគ្រប់គ្រាន់ទេ នៅពេលដែលបញ្ចប់ការសិក្សាមុខវិជ្ជា បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា*

*គ្រប់គ្រាន់*

- មានចំណេះដឹងតែខ្លះបទពិសោធន៍
- មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ
- មានវគ្គបណ្តុះបណ្តាលច្រើន
- ក្រុមហ៊ុនមកទាក់ទង អោយធ្វើការងារ
- គ្រប់គ្រាន់សម្រាប់ឯកទេសជាក់លាក់ដែលបានជ្រើសរើស
- មានការយល់ដឹងទូទៅ តែមិនមានឯកទេសជាក់លាក់
- មានពេលវេលា ដើម្បីអនុវត្ត
- សាស្រ្តាចារ្យមានចំណេះដឹងខ្ពង់ខ្ពស់
- សាកលវិទ្យាល័យផ្តល់សម្ភារៈសិក្សាគ្រប់គ្រាន់
- និស្សិតខិតខំប្រឹងប្រែងសិក្សា

*មិនគ្រប់គ្រាន់*

- ត្រូវការបទពិសោធន៍បន្ថែម
- មានចំណេះដឹងត្រឹមកម្រិតមូលដ្ឋាន
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានបច្ចុប្បន្នភាពជានិច្ច
- មិនបានទៅរៀនគួរ

## ៤.៣. ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យការងារ

តារាងទី៦៖ សមាមាត្រនៃស្ត្រីដែលធ្វើការក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ស្ថាប័ន

| ស្ថាប័ន | បុគ្គលិកដែលចេះប្រើប្រាស់កុំព្យូទ័រ និងអ៊ីនធឺណិត | |
|---|---|---|
| | ស្ត្រីចំនួន (%) | សរុប (ចំនួន) |
| អង្គការសង្គមស៊ីវិល | ១៦ (៤៤,៤%) | ៣៦ |
| ក្រសួងរបស់រដ្ឋាភិបាល | ៧០ (១៥,៥%) | ៤៥២ |
| សេវាកម្មអ៊ីនធឺណិត | ៣៧ (៣២,៥) | ១១៤ |
| ស្ថាប័នអប់រំ | ៣១ (៣៣,៣) | ៩៣ |
| សរុប | ១២១ (២០,៤) | ៥៩៣ |

លទ្ធផលបានបង្ហាញអោយឃើញថា ស្ត្រីធ្វើការងារប្រើប្រាស់ចំណេះដឹង ICT នៅតាមអង្គការ មានចំនួន៤៤,៤% នៅតាមស្ថាប័នរដ្ឋមានចំនួន១៥,៥% តាម ISP មានចំនួន៣២,៥ និងតាមវិស័យអប់រំមានចំនួន៣៣,៣% ។

### តារាងទី៧៖ អត្រាតម្រូវការស្ត្រីដែលមានចំណេះដឹងផ្នែក ICT នៅតាមស្ថាប័នផ្សេងគ្នា

| | ចំនួនស្ថាប័នត្រូវការធៀបនឹងស្ថាប័នសរុបនីមួយៗ គិតជាចំនួន (%) | ចំនួនមនុស្សត្រូវការ គិតជាមធ្យម | ស្ត្រី គិតជាចំនួន (%) |
|---|---|---|---|
| អង្គការសង្គមស៊ីវិល | ២៨ (២៥,២) | ២ | ១ (៥០) |
| ក្រសួងនានា | ៩ (៥២,៩) | ១០ | ៦ (៦០) |
| អ្នកផ្តល់សេវាកម្មអ៊ីនធឺណិត | ២២ (១១,៧) | ២ | ១ (៥០) |
| ស្ថាប័នអប់រំ | ១២ (៣៥,៣) | ៥ | ២ (៤០) |

តួលេខខាងលើបានបង្ហាញអោយឃើញថា តម្រូវការរបស់ស្ថាប័ននីមួយៗផ្នែក ICT គឺមានភាគរយខុសគ្នាតែបន្តិចប៉ុណ្ណោះ ។ តម្រូវការបុគ្គលិកស្ត្រីផ្នែកICT ជាមធ្យម នៅតាមស្ថាប័ននីមួយៗ មានចាប់ពី ៤០ដល់ ៦០ភាគរយ ។

### តារាងទី៨៖ ការលំបាកក្នុងការស្វែងរកការងារ រវាងអ្នកមានសញ្ញាប័ត្រផ្នែក ICT ធៀបជាមួយសញ្ញាប័ត្រផ្សេងទៀត

| | | ជាអ្នកជំនាញកុំព្យូទ័រ ចំនួន ( %) | ប្រើប្រាស់កុំព្យូទ័រសម្រាប់ការងារ ចំនួន ( %) | អត្ថន័យក្នុងស្ថិតិ |
|---|---|---|---|---|
| បុរស | មិនលំបាក | ១៨ (៥៦,២) | ២០ (៥៧,១) | $x^2$=0,២១, p>0,0៥ |
| | លំបាក | ១៤ (៤៣,៨) | ១៥ (៤២,៩) | |
| ស្ត្រី | មិនលំបាក | ៧ (៥៣,៨) | ៣0 (៤៦,៩) | $x^2$= 0,0៥, p>0,0៥ |
| | លំបាក | ៦ (៤៦,២) | ៣៤ (៥៣,១) | |

តារាងនេះបានអោយឃើញថាទាំងបុរស និងស្ត្រីដែលមានសញ្ញាប័ត្រICT គឺភាគរយនៃអ្នកឆ្លើយថាពិបាក មានចំនួនមិនខុសគ្នាគួរអោយគត់សំគាល់ទេ បើធៀបជាមួយនឹងអ្នកមិនមានសញ្ញាប័ត្រកុំព្យូទ័រ ។ នៅពេលដែលស្នើសុំអោយពួកគាត់ពន្យល់បន្ថែមអំពីផលវិបាក ពួកគាត់បាននិយាយថា ទីផ្សារការងារចង្អៀត ការងារត្រូវការអ្នកដែលមានបទពិសោធន៍ ត្រូវការភាសាបរទេស មានបេក្ខជនប្រឡងប្រណាំងច្រើន និងប្រាក់ខែទាប ។

# ៤. លទ្ធផលនៃការស្រាវជ្រាវ

ទិន្នន័យបានមកពីការពិភាក្សាជាក្រុមជាមួយនិស្សិត ដែលសិក្សាមុខវិជ្ជានេះ បានបង្ហាញ ពីឱកាសច្រើនជាង ដូចគ្នា និងតិចជាងបុរសក្នុងការទទួលបានការងារផ្នែក ICT ។

*ច្រើនជាង*

- ការលើកកម្ពស់យេនឌ័រ (អាទិភាព)
- ការងារការិយាល័យមានភាពសមស្របចំពោះនារីច្រើនជាងបុរស
- អាចស្វែងរកការងារបាន
- ស្រីធ្វើការហ្មត់ចត់ច្រើនជាងបុរស

*ដូចគ្នា*

- ឱកាសការងារប្រហាក់ប្រហែលគ្នា
- ស្ត្រីមានសមត្ថភាពដូចបុរស

*តិចជាង*

- ការងារ ICT ត្រូវប្រើកម្លាំង និងមិនសមចំពោះនារី (បណ្តាញ ជួសជុល)
- បុរសមានសមត្ថភាពជាងស្ត្រី
- ក្រុមហ៊ុនមិនជួលនារីដែលមានចំណេះដឹងផ្នែកICT មកធ្វើការទេ
- ការងារបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ជួនពេលខ្លះតម្រូវអោយធ្វើការពេលយប់
- ការងារ ICT ជួនពេលខ្លះតម្រូវអោយធ្វើការនៅឆ្ងាយ
- មិនមានពេលវេលាគ្រប់គ្រាន់ជាមួយគ្រួសារ
- មិនទុកចិត្តលើការងាររបស់នារីលើផ្នែកនេះ

ក្រាហ្វិកទី១៖ បំណែងចែកកម្រិតតម្រូវការ ICT នៅតាមប្រភេទការងារនៅលើគេហទំព័រការងារ (n=៣៦៨៦)




ក្រាហ្វិកទី១៖ បង្ហាញថានៅក្នុងការផ្សព្វផ្សាយជ្រើសរើសការងារ នៅក្នុងគេហទំព័រការងារ ជាទូទៅការងារកម្រិតខ្ពស់ត្រូវការអ្នកដែលមានជំនាញ ICT ខ្ពស់មានតិចតួចប៉ុណ្ណោះ(ប្រហែល៥%) ប៉ុន្តែគេបែរជាត្រូវការអ្នកដែលមានជំនាញ ICT កម្រិតកណ្តាលដែលមានរហូតដល់ ៩៣,៩% ។ ទោះជាយ៉ាងនេះក្តី នៅក្នុងការងារកម្រិតទាប ក៏ការងារទាំងនោះទាមទារ អោយមានជំនាញ ICT កម្រិតកណ្តាលប្រហែល ១៤,៨%ផងដែរ ។

**ក្រាហ្វិកទី២៖ ចំណាត់ថ្នាក់នៃជំនាញការប្រើប្រាស់ ICT តាមភេទ (n=៤៨៧)**




$x^2$ = ៥៦,៨៦ , p<0,00១

យើងអាចសង្កេតឃើញថា មានភាពខុសគ្នាយ៉ាងខ្លាំងចំពោះការប្រើប្រាស់កុំព្យូទ័រជាអ្នកជំនាញ និងប្រើសម្រាប់តែកិច្ចការងាររវាងបុរស និងស្ត្រី (P<0,0៥%) គឺមានន័យថា ភាគរយបុរសដែលប្រើកុំព្យូទ័រជាអ្នកជំនាញនោះ មានច្រើនជាងស្ត្រី(បុរស ៣៣,៦% និងស្ត្រី៦,៩%) ។

**តារាងទី៩៖ ផលប្រយោជន៏នៃការប្រើប្រាស់កុំព្យូទ័រ និងអ៊ីនធឺណិតរបស់អ្នកដែលមានតួនាទីសំខាន់ក្នុងផ្នែក ICT**

| ផលប្រយោជន៍ | កត្តាធ្វើមិនអោយទាញយកប្រយោជន៍បាន |
|---|---|
| ១. ការសិក្សា និងស្រាវជ្រាវ (ឯកសារច្រើន ហើយប្លែក)<br>២. សម្រាប់ការងារ (អាចកែបាន ចំណេញពេល ងាយរក្សាឯកសារ )<br>៣. ការទំនាក់ទំនងតាមរយៈអ៊ីមែល facebook, messenger, skype...)<br>៤. ការទទួលបានព័ត៌មាន និងចំណេះដឹងផ្សេងៗ<br>៥. ការធ្វើអាជីវកម្ម (លក់ផលិតផល ផ្សាយពាណិជ្ជកម្ម)<br>៦. ក្លាយជាសង្គមទំនើប<br>៧. ការកម្សាន្ត (កំប្លែង រូបភាព ហ្គេម)<br>៨. ការងារខ្លះ ត្រូវការបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ជាដាច់ខាតដូចជា ការបង្កើតគេហទំព័រ បណ្តាញ ការវាយឯកសារ )<br>៩. អាចប្រើប្រាស់ក្នុងវិស័យផ្សេងៗ ដូចជាពេទ្យ កសិកម្ម<br>១០. ការបង្រៀន | ១. ខ្លឹមសារគេហទំព័រខ្លះមិនល្អ (វីដេអូ រូបភាព អត្ថបទ អាសអាភាស ឬប៉ះពាល់ដល់ស្មារតី)<br>២. តម្លៃនៃសម្ភារៈ និងសេវាកម្មអ៊ីនធឺណិតថ្លៃ<br>៣. សុវត្ថិភាព និងការគ្រប់គ្រង (មានមេរោគ ការលួចឯកសារ)<br>៤. មានតែនៅទីប្រជុំជន<br>៥. ភាសា<br>៦. ប្រជាជនភាគច្រើនមិនចេះប្រើកុំព្យូទ័រ និងអ៊ីនធឺណិត<br>៧. ចំណេះដឹងនៅមានកម្រិត<br>៨. គុណភាពនៃការអប់រំនៅមានកម្រិតទាប<br>៩. មានអ្នកបោកប្រាស់នៅលើអ៊ីនធឺណិត<br>១០. មន្ត្រីជាន់ខ្ពស់ (អ្នកធំ) មិនទាន់បានដឹងពីផលប្រយោជន៍នៃការប្រើប្រាស់ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា<br>១១. ការងារបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានប្រាក់ខែតិច<br>១២. ការសិក្សាស្រាវជ្រាវអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមានចំនួនតិចតួច<br>១៣. ល្បឿនអ៊ីនធឺណិតនៅមានដែនកំណត់<br>១៤. លេងហ្គេមច្រើន |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

ក្រាហ្វិកទី៣៖ ទីកន្លែងដែលពួកគាត់តែងតែប្រើប្រាស់ ICT ( n=៤៩៨ )




តាមការសិក្សានេះបានអោយដឹងថា មានរហូតដល់ ៨៤,៦% ក្នុងចំណោមអ្នកប្រើប្រាស់អ៊ីនធឺណិត តែងតែប្រើប្រាស់នៅកន្លែងធ្វើការ បន្ទាប់មកនៅតាមកន្លែងហាងអ៊ីនធឺណិត ៧,៥% តាមសាលារៀន ៤% និងតាមផ្ទះ ៣,៥% ។

តារាងទី១០៖ រយៈពេលប្រើប្រាស់អ៊ីនធឺណិត ( ខែ/ឆ្នាំ ) ( n=៣៤៨ )

| | **គិតជាចំនួន** | **គិតជា%** |
|---|---|---|
| ០-៣ ខែ | ១៨ | ៥,១ |
| ៣-៦ ខែ | ១៨ | ៥,១ |
| ៦-១២ ខែ | ១៨ | ៥,១ |
| ១-២ ឆ្នាំ | ២៥ | ៧,១ |
| ២-៣ ឆ្នាំ | ៤២ | ១១,៨ |
| ច្រើនជាង ៣ ឆ្នាំ | ២៣៣ | ៦៥,៨ |

ការសិក្សានេះបានរកឃើញថា មានចំនួន ៦៥,៨% បានប្រើប្រាស់អ៊ីនធឺណិត ក្នុងរយៈពេល ៣ឆ្នាំកន្លងមក ហើយក្នុងនោះមាន ៥,១% អ្នកដែលប្រើក្រោម ៣ខែ និង៥,១% ចន្លោះពី៣ទៅ ៦ខែ ។

តារាងទី១១៖ បម្រែបម្រួលនៃការប្រើប្រាស់កុំព្យូទ័រធៀបនឹងឆ្នាំមុនៗ (n=៤៨៤)

| | ស្ត្រី<br>ចំនួន (%) | បុរស<br>ចំនួន (%) | ចំនួនសរុប<br>ចំនួន (%) |
|---|---|---|---|
| កើនឡើងខ្លាំង | ៤៨ (១៧,៥) | ៦៤ (៣០,៣) | ១១២ (២៣,១) |
| កើនឡើងតិចតួច | ១៧១ (៦២,៤) | ១០៩ (៥១,៧) | ២៨០ (៥៧,៧) |
| នៅដដែល | ៤៥ (១៦,៤) | ៣៦ (១៧,១) | ៨១ (១៦,៧) |
| ថយចុះតិចតួច | ៨ (២,៩) | ២ (០,៩) | ១០ (២,១) |
| ថយចុះខ្លាំង | ២ (០,៧) | -- | ២ (០,៤) |

តារាងខាងលើបានបង្ហាញអោយឃើញភាគរយនៃអ្នកប្រើប្រាស់កុំព្យូទ័រទាំងពីរភេទមានការផ្លាស់ប្តូរ បើធៀបនឹងឆ្នាំមុនក្នុងនោះបុរសមានការផ្លាស់ប្តូរយ៉ាងខ្លាំងរហូតដល់ ៣០,៨% ចំណែកស្ត្រីវិញឃើញថា មានតែ ១៧,៥% ប៉ុណ្ណោះ ។ ម្យ៉ាងទៀតបើក្រឡេកមើលករណីមានការថយចុះ គឺមានស្ត្រីចំនួន ៣,៦% ឆ្លើយថាថយចុះ បើធៀបនឹងបុរសមានតែ ០,៩% តែប៉ុណ្ណោះ ។

ក្រាហ្វិកទី៤៖ បំណែងចែកនៃការប្រើប្រាស់អ៊ីនធឺណិតតាមភេទ




តួលេខខាងលើបានបង្ហាញអោយឃើញថា បុរសមានការប្រើប្រាស់អ៊ីនធឺណិតញឹកញាប់ជាងស្ត្រី ។ បុរសប្រើស្ទើររាល់ថ្ងៃមាន ១៧% ស្ត្រីមាន ១៥,៣% ប្រើច្រើនជាងពីរដងក្នុងមួយថ្ងៃ បុរសមាន ១២,១% និងស្ត្រីមាន ៩,៥% ប្រើរាល់ថ្ងៃ គឺបុរសមាន ៤៥,៦% ស្ត្រីមាន ៣៧,៨% ។

តារាងទី១២៖ ការប្រើប្រាស់បច្ចេកវិទ្យា ICT ផ្សេងៗទៀតក្រៅពីកុំព្យូទ័រ និងអ៊ីនធឺណិត

| តើអ្នកប្រើប្រាស់ ICT ញឹកញាប់ទេ? | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| | ចំនួន (%) | ចំនួន (%) | ចំនួន (%) | ចំនួន (%) | ចំនួន (%) |
| អានកាសែតនិងទស្សនាវដ្ដី សៀវភៅ និងឯកសារផ្សេងៗទៀត (n=៥០៩) | ១០២ (២០) | ២៥៨ (៥០,៧) | ៩៨ (១៩,៣) | ៣៧ (៧,៣) | ១៤ (២,៨) |
| ការស្ដាប់វិទ្យុ (n=៥០៧) | ៦៤ (១២,៦) | ១៨១ (៣៥,៧) | ១៩២ (៣៧,៩) | ៦២ (១២,២) | ៨ (១,៦) |
| ការមើលទូរទស្សន៍ (n=៥០៨) | ១៣២ (២៦,០) | ២១៩ (៤៣,១) | ៩០ (១៧,៧) | ៥៥ (១០,៨) | ១២ (២,៤) |
| ទូរសព្ទ (n=៥០៤) | ១៧៩ (៣៥,៥) | ១៩១ (៣៧,៩) | ៨៦ (១៧,១) | ៣៥ (៦,៩) | ១៣ (២,៦) |
| MP3, MP4, ប្រព័ន្ធផ្សព្វផ្សាយចំណុះ (n=៥០០) | ៥១ (១០,២) | ១៥៣ (៣០,៦) | ១៨៧ (៣៧,៤) | ៨៩ (១៧,៨) | ២០ (៤,០) |
| កំណត់ចំណាំ៖ ១=ស្ទើរតែរាល់ថ្ងៃ ២= ច្រើនជាងពីរដងក្នុង១ថ្ងៃ ៣= រាល់ថ្ងៃ ៤= ពីរ បីដងក្នុង១សប្ដាហ៍ ៥= មិនដែលសោះ | | | | | |

ការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាផ្សេងៗទៀត តួលេខខាងលើនេះបង្ហាញអោយឃើញថា ៥០,៧% គឺពួកគាត់ចូលចិត្តអានកាសែតញឹកញាប់ ២០% ចូលចិត្តអានជាប្រចាំ និង១៩,៣% គឺពួកគាត់ចូលចិត្តម្ដងម្កាល ក្នុងនោះដែរគឺមាន ២,៨% តែប៉ុណ្ណោះដែលមិនដែលអានកាសែតសោះ ។

ការស្ដាប់វិទ្យុមាន១២,៦% ស្ដាប់ជាប្រចាំ និង៣៥,៧% ស្ដាប់ញឹកញាប់ យូរៗម្ដងមាន ៣៧,៩% និងមានតែ ១,៦% ប៉ុណ្ណោះដែលមិនស្ដាប់សោះ ។

ការទស្សនាទូរទស្សន៍មាន ២៦% ទស្សនាជាប្រចាំ និង៤៣ ,១% ទស្សនាញឹកញាប់ និងមាន ២,៤% មិនដែលទស្សនាសោះ ។

ការប្រើប្រាស់ទូរសព្ទគឺមាន ៣៥,៥% ប្រើប្រាស់ជាប្រចាំ និង៣៧,៩% ប្រើប្រាស់ញឹកញាប់ និងមាន ២,៦% មិនដែលបានប្រើប្រាស់សោះ ។

ចំពោះករណី MP3, MP4 និងឧបករណ៍កម្សាន្តផ្សេងៗទៀតនោះ គឺមាន ១០,២% ដែលប្រើជាប្រចាំនៃ ៣០,៦% ដែលប្រើជាញឹកញាប់ក្នុងនោះមាន ៤% មិនដែលប្រើសោះ ។

ករណីប្រើប្រាស់ Internet គឺមាន ៣៦,៤% ដែលប្រើជាប្រចាំ និង៣៦,៦% ប្រើញឹកញាប់ ប៉ុន្តែមាន ៤,៧% ដែលមិនដែលប្រើសោះ ។

ករណីកុំព្យូទ័រ គឺមាន ៥២,១% ប្រើជាប្រចាំ និង៣២,៧% ប្រើជាញឹកញាប់មាន ៤,៦% មិនដែលប្រើសោះ ។

**តារាងទី១៣៖ ទំនាក់ទំនងរវាងជំនាញនៃការប្រើប្រាស់កុំព្យូទ័រ និងកម្រិតការងារ (n=៥១១)**

| | ប្រើប្រាស់កុំព្យូទ័រសម្រាប់ការងារ<br>ចំនួន (%) | ជាអ្នកជំនាញកុំព្យូទ័រ<br>ចំនួន (%) | ចំនួនសរុប<br>ចំនួន (%) |
|---|---|---|---|
| ការងារកម្រិតទាប | ៤២<br>(១០,៥%) | ៣<br>(២,៩%) | ៤៦<br>(៩,០%) |
| ការងារកម្រិតបណ្តាល | ៣៣២<br>(៨៣,០%) | ៨៧<br>(៨៤,៥%) | ៤២៦<br>(៨៣,៤%) |
| ការងារកម្រិតខ្ពស់ | ២៦<br>(៦,៥%) | ១៣<br>(១២,៦%) | ៣៩<br>(៧,៦%) |
| $x^2$ =១០,០២, p<០,០៥ | | | |

លទ្ធផលនេះបានបង្ហាញអោយឃើញថា ក្នុងចំណោមអ្នកដែលមិនចេះកុំព្យូទ័រ គឺគ្មានអ្នកណាម្នាក់ដែលចាត់ខ្លួនគាត់ឋិតនៅក្រុមដែលមានការងារក្នុងកម្រិតល្អនោះទេ ក្នុងនោះដែរបើយើងក្រឡេកមើលភាពខុសគ្នារវាងអ្នកដែលមានជំនាញកុំព្យូទ័រ និងអ្នកដែលប្រើកុំព្យូទ័រសម្រាប់ការងារ គឺទាំង២ក្រុមនេះមានជីវភាពឋិតនៅក្រុមកណ្តាលប្រហាក់ប្រហែលគ្នា ។ ប៉ុន្តែបើយើងក្រឡេកមើលទៅលើអ្នកដែលមានជីវភាពខ្ពស់នោះ គឺពួកទាំងនោះឋិតនៅក្នុងក្រុមដែលមានជំនាញកុំព្យូទ័រសម្រាប់តែប្រើប្រាស់ (P<០,០៥) ។

ការសម្ភាសស៊ីជម្រៅជាមួយអ្នកដែលមានតួនាទីសំខាន់ក្នុងផ្នែក ICT បានបង្ហាញពីភាពគ្រប់គ្រាន់នៃចំណេះដឹងរបស់បុគ្គលិក៖

*គ្រប់គ្រាន់*

- មានជំនាញខាងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- អាចប្រើប្រាស់កុំព្យូទ័របាន
- ធ្វើការមានប្រសិទ្ធភាព
- មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតបាន
- មានកម្មវិធីផ្លាស់ប្តូរបុគ្គលិក
- ចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗបានច្រើន
- សិក្សានៅបរទេស
- មិនត្រឹមតែដឹង តែបានបង្រៀនដល់អ្នកដទៃ

*មិនទាន់គ្រប់គ្រាន់*

- មិនមានមូលដ្ឋាននៃការសិក្សាខាងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ការងារខ្លះមិនត្រូវការជំនាញ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាទេ
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានបច្ចុប្បន្នភាពជានិច្ច
- ធ្វើការមិនទាន់មានប្រសិទ្ធភាព
- បុគ្គលិកខ្វះចំណេះដឹងខាងភាសា ពិសេសភាសាអង់គ្លេស
- ខ្វះធនធានមនុស្សខាងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ប្រើប្រាស់សម្ភារៈចាស់ៗ និងមិនគ្រប់គ្រាន់
- មិនមានថវិកាទិញកុំព្យូទ័រ និងសម្ភារៈអេឡិចត្រូនិក

**ក្រាហ្វិកទី៨៖ ភាគរយតាមស្ថាប័ននីមួយៗដែលមានគោលនយោបាយលើកកម្ពស់ស្ត្រី**




$x^2$=២៨,៥២, p<0,00១

នៅតាមស្ថាប័ននីមួយៗ មានការជំរុញ ឬមានគោលនយោបាយ ដើម្បីជំរុញអោយបុគ្គលិកស្ត្រីកសាងសមត្ថភាពគឺមានភាពខុសគ្នាដូចជានៅតាមអង្គការមិនមែនរដ្ឋាភិបាល ២២,៥% នៅតាមស្ថាប័នរដ្ឋមាន ៣៥,៣% តាមអ៊ីនធឺណិត ៩,៣% និងតាមស្ថាប័នអប់រំ ៣៤,៦% (P<0,00១) ។ ការជំរុញ ឬគោលនយោបាយនៃការជំរុញមានដូចជា ការពង្រឹងសមត្ថភាពស្ត្រី និងការបណ្តុះបណ្តាលធនធានមនុស្សបន្ថែម ។

នៅពេលដែលសួរថា តើស្ថាប័នរបស់លោកអ្នកបានផ្តល់វិភាគទានអ្វីខ្លះ ដើម្បីកសាងសមត្ថភាពរបស់ស្ត្រី អ្នកតបសម្ភាសពីស្ថាប័នទាំងបួនបានផ្តល់ចម្លើយថា៖

- អង្គការមិនមែនរដ្ឋាភិបាល មានរហូតដល់ ៤៨,២% ដែលពួកគាត់បានផ្តល់ជាថវិកា មាន៣២,៥% គាត់ផ្តល់ពេលវេលាអោយស្ត្រីកសាងសមត្ថភាព និង ១៩,៣ % គឺបានលើកទឹកចិត្តដល់បុគ្គលិកដែលជាស្ត្រីក្នុងការកសាងសមត្ថភាព ។
- ចំពោះស្ថាប័នរដ្ឋវិញ គឺមាន ៧៥,0% បានផ្តល់ជាថវិកា ១២,៥% ផ្តល់ជាពេលវេលា និង១២,៥% ទៀត គឺផ្តល់ការលើកទឹកចិត្ត ។
- ចំពោះ ISP មាន ៥៣,៦% ផ្តល់ថវិកា ២៨,៦% ផ្តល់ការលើកទឹកចិត្ត និង១៧,៨% ផ្តល់ជាពេលវេលា ។
- ចំពោះស្ថាប័នអប់រំវិញ គឺមាន ៣៨,៥% ផ្តល់ថវិកា ៣៨,0% ផ្តល់ពេលវេលា និង២៣% បានលើកទឹកចិត្ត ។

## ៤.៤. តំនាបរបស់ស្ត្រី ពីការចូលក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

### តារាងទី១៤៖ កម្រិតនៃការយល់ស្រប អំពីតំនាបរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

| | | អង្គការសង្គមស៊ីវិល ចំនួន (%) | ក្រសួងនានា ចំនួន (%) | អ្នកផ្តល់សេវាកម្មអ៊ីនធឺណិត ចំនួន (%) | ស្ថាប័នអប់រំ ចំនួន (%) | សរុប |
|---|---|---|---|---|---|---|
| ផ្តល់អោយស្ត្រីមានការទទួលខុសត្រូវតិចជាងបុរស នៅក្នុងស្ថាប័នរបស់លោកអ្នក | ១ | ១២ (១០,៩) | ៥ (២៩,៤) | ៥២ (២៩,៧) | ៤ (១៥,៤) | ៧៣ ២២,៣ |
| ១៖ $x^2$ = ៤៤,៣៧ p<0,00១ ២៖ $x^2$=២៦,១៧p<0,00១) | ២ | ៧៤ (២៩,២) | ៥៣ (៦២,៤) | ៨ (៣៦,៤) | ៣១ (៣៧,៣) | ១៦៦ (៣៧,៥) |
| ស្ត្រីទទួលបានផលប្រយោជន៍ ដូចបុរសនៅក្នុងស្ថាប័នរបស់លោកអ្នក | ១ | ៩៤ (៨៥,៥) | ១៤ (៨២,៤) | ១៣៣ (៧៦,៩) | ២២ (៨១,៥) | ២៦៣ (៨០,៤) |
| ១៖ $x^2$=១០,២៦p>0,00១ ២៖ $x^2$=១០,៨៧ p<0,0៥ | ២ | ២៤១ (៩៤,៩) | ៧៧ (៨៨,៥) | ១៤ (៨២,៤) | ៦៧ (៨៤,៨) | ៣៩៩ (៩១,៣) |
| ស្ត្រីមានសិទ្ធិច្រើនជាង បុរសក្នុងការធ្វើការសម្រេចចិត្ត នៅក្នុងស្ថាប័នរបស់លោកអ្នក | ១ | ១៥ (១៤,៣) | ២ (១១,៨) | ៤0 (២៣,៣) | ៨ (៣0,៨) | ៦៥ (២0,៣) |
| ១៖ $x^2$ =៩,៣៨ p>0,0៥ ២៖ $x^2$= ៦,៦៨ p>0,0៥ | ២ | ៥៣ (២៤,៤) | ១១ (១៦,៧) | ៤ (២៨,៦) | ១0 (១៥,២) | ៧៨ (២១,៥) |
| ស្ត្រីមានឱកាសតិចតួច ក្នុងការទទួលបានការងារក្នុងវិស័យ ICT ដោយសារលក្ខណៈជីវសាស្ត្រ បញ្ហាវប្បធម៌សង្គម និងឧបសគ្គផ្សេងៗទៀត | ១ | ៦0 (៦១,៩) | ៧ (៤១,២) | ៤៧ (៣0,៩) | ១៤ (៥៦,0) | ១២៨ (៣៩,៩) |
| ១៖ $x^2$ = ៣៨,២៥ p<0,00១ ២៖ $x^2$ = ៧,៩៥ p<0,00៥ | ២ | ១២១ (៥0,៨) | ៨0 (៦៨,៨) | ២0 (៦0,0) | ៨១ (៥៥,៦) | ៣0២ (៧២,១) |
| កំណត់ចំណាំ ១. អ្នកតំណាងស្ថាប័ន ២. បុគ្គលិក | | | | | | |

ទិន្នន័យខាងលើបង្ហាញអោយឃើញថា រាល់សំណួរនីមួយៗ ភាគរយនៃការយល់ស្របទាំងតំណាងបុគ្គលិក និងអ្នកធ្វើការនៅតាមស្ថាប័ននានាខុសគ្នាយ៉ាងច្បាស់លាស់ ។ (P<0,05) លើសពីនោះ យើងឃើញថា ភាគរយនៃអ្នកយល់ស្របដែលធ្វើការនៅតាមស្ថាប័ននានា គឺខ្ពស់ជាងនូវគ្រប់ចម្លើយយល់ស្របរបស់បុគ្គលិកតំណាងស្ថាប័ន ។

**តារាងទី១៥៖ វប្បធម៌ខ្មែរមានការលើកទឹកចិត្តដល់បុរស និងស្ត្រីក្នុងការចូលរួមសិក្សា**

| | គ្រឹះស្ថានឧត្តមសិក្សា | | |
|---|---|---|---|
| | **គ្រឹះស្ថានសាធារណៈ** ចំនួន (%) | **គ្រឹះស្ថានឯកជន** ចំនួន (%) | **ចំនួនសរុប** ចំនួន (%) |
| មិនយល់ស្រប | ១ (១៤,៣) | ៤ (២២,២) | ៥ (២០) |
| យល់ស្រប | ៦ (៨៥,៧) | ១៤ (៧៧,៨) | ២០ (៨០) |

ចំពោះបញ្ហាលើកឡើងដែលទាក់ទងនឹងវប្បធម៌ខ្មែរលើកទឹកចិត្តដល់ស្ត្រី និងបុរសក្នុងការចូលសិក្សាថ្នាក់ឧត្តមសិក្សាស្មើគ្នានោះ គឺចំពោះយោបល់របស់ថ្នាក់ដឹកនាំនៅតាមស្ថាប័នរដ្ឋមាន ៧៥% យល់ស្រប និងនៅតាមស្ថាប័នឯកជនមាន ៦៦,៦% ដែលយល់ស្រប ។

**តារាងទី ១៦៖ គំនាប និងឧបសគ្គដែលរារាំងស្ត្រីពីការចូលសិក្សាក្នុងផ្នែកអប់រំ និងការងារបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា**

| | ១ (ជា %) | ២ (ជា %) | ៣ (ជា %) | ៤ (ជា %) | ៥ (ជា %) |
|---|---|---|---|---|---|
| តម្លៃអ៊ីនធឺណិតថ្លៃ (n=៤៥៩) | ១,៦ | ២៤,៤ | ២១,៨ | ៣២,៦ | ១៩,៦ |
| បទដ្ឋានសង្គម និងវប្បធម៌ (n=៥០៩) | ១១,៨ | ៤៦,១ | ១១,៤ | ២៤,២ | ៦,៥ |
| លក្ខណៈជីវសាស្ត្ររបស់ស្ត្រី (n=៤៥១) | ៣,១ | ២៩,៥ | ២២,៨ | ៣៦,៦ | ៨ |
| ការវិនិយោគរបស់គ្រួសារលើការអប់រំ (n=៤៧៧) | ១,៥ | ១៣,១ | ២១,៤ | ៥៣,៩ | ១០,១ |
| តួនាទី និងភាពទទួលខុសត្រូវរបស់ស្ត្រីនៅក្នុងគ្រួសារ (n=៥០៣) | ១,៤ | ១៤,១ | ១៨,៧ | ៥៣,៧ | ១២,១ |
| ប្រភេទការងារ (n=៥០០) | ១០,៦ | ៥៥,៤ | ១៤,២ | ១៦,៨ | ៣ |
| ឱកាសស្មើគ្នាសម្រាប់ការងារ(n=៤៩១) | ១,៤ | ១២,៤ | ១៥,៣ | ៥៤ | ១៦,៩ |
| ហេដ្ឋារចនាសម្ព័ន្ធ ICT (n=៤១០) | ១,២ | ១៤,៤ | ៣១,២ | ៤៣,៤ | ៩,៨ |
| បច្ចេកវិទ្យាដើរលឿនពេក (n=៤៧១) | ៤,៥ | ៣០,១ | ២៥,៧ | ៣៣,៣ | ៦,៤ |
| ភាសា (n=៤៥២) | ១,៣ | ១៥,៣ | ២៦,៥ | ៤៨,៥ | ៨,៤ |
| ខ្ញុំទើបតែបញ្ចប់ការសិក្សា (n=៤៥១) | ០,៤ | ១៤,៦ | ៤,៦ | ៥៤,២ | ១៦,២ |
| គោលនយោបាយ/កម្មវិធីរដ្ឋ និងការអនុវត្តតាមផ្នែក (n=៣៩៩) | ១,៥ | ១១,៨ | ២៧,១ | ៤៩,៦ | ១០ |
| មិនត្រូវបានគេលើកទឹកចិត្ត អោយចូលរួមមុខវិជ្ជា/វគ្គ បណ្ដុះបណ្ដាលអំពី ICT (n=៤៥៩) | ៦,៣ | ៥០,១ | ១៧,០ | ២០,៧ | ៥,៩ |
| **ចំណាំ៖** ១មិនយល់ស្របខ្លាំង ២មិនយល់ស្រប ៣ធម្មតា ៤យល់ស្រប ៥យល់ស្របខ្លាំង | | | | | |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

ទាក់ទងជាមួយនឹងបញ្ហាគំនាប និងឧបសគ្គដើម្បីទទួលបាន ICT តួលេខបានបង្ហាញអោយឃើញថា មានបញ្ហាមួយចំនួនដែលវាជាកត្តាធ្វើអោយរាំងស្ទះក្នុងការទទួលបាននូវ ICT ដូចជា៖

- តម្លៃគឺមានរហូតដល់ ៣២,៥% ដែលយល់ស្រប ជាមួយបញ្ហានេះ ក្នុងនោះមានរហូតដល់ ១៩,៦% ដែលយល់ស្របយ៉ាងខ្លាំង ។
- បទដ្ឋាននៃវប្បធម៌ គឺមាន ២៤,២% យល់ស្រប និង៦,៥% យល់ស្របខ្លាំង ចំពោះបញ្ហាទាក់ទងជាមួយនឹងលក្ខណៈជីវសាស្ត្រវិញ គឺមានរហូតដល់៣៦,៦% យល់ស្រប និង៥៨% យល់ស្របខ្លាំង ។
- ការចំណាយក្នុងគ្រួសារ គឺមាន ៥៣,៩% យល់ស្រប និង១០,១% យល់ស្របខ្លាំង ។
- តួនាទី និងភាពទទួលខុសត្រូវរបស់ស្ត្រីក្នុងគ្រួសារមាន ៥៣,៧% យល់ស្រប និង១២,១% យល់ស្របខ្លាំង ។
- ប្រភេទការងារមិនសមស្របសម្រាប់ស្ត្រីធ្វើការងារបច្ចេកទេស គឺមាន ១៦,៨% យល់ស្រប និង៣% យល់ស្របខ្លាំង ។
- ឱកាសស្មើគ្នាសម្រាប់ការងារ គឺមាន៥៤%យល់ស្រប់ និង១៦,៩% យល់ស្របខ្លាំង ។
- ហេដ្ឋារចនាសម្ព័ន្ធ គឺមាន ៤៣,៤% យល់ស្រប និង៩,៨% យល់ស្របខ្លាំង ។
- បច្ចេកទេសដើរលឿនពេក គឺមាន ៣៣,៣% យល់ស្រប និង៦,៤% យល់ស្របខ្លាំង ។
- ចំពោះបញ្ហាភាសា គឺមាន ៤៨,៥% យល់ស្រប និង៨,៤% យល់ស្របខ្លាំង ។
- បទពិសោធន៍ការងារវិញ គឺមាន ៥៤,១% យល់ស្រប និង៨,៤% យល់ស្របខ្លាំង ។
- គោលនយោបាយកម្មវិធីរដ្ឋ គឺមាន ៤៩,៦% យល់ស្រប និង១៦,២% យល់ស្របខ្លាំង ។
- មិនត្រូវបានគេលើកទឹកចិត្ត គឺមានចំនួន ២០,៧% យល់ស្រប និង៥,៩% យល់ស្របខ្លាំង ។

ដើម្បីបង្ហាញអោយកាន់តែច្បាស់អំពីគំនាបនានាដែលកើតឡើងចំពោះនិស្សិតដែលសិក្សាមុខវិជ្ជាផ្នែក ICT ក្រុមការងារបានពិភាក្សាជាក្រុម ជាមួយនិស្សិត ១១ក្រុម នៅតាមសាកលវិទ្យាល័យនានា ។ ខាងក្រោមនេះ គឺជាការសង្ខេបលទ្ធផលដែលទទួលបានពីការពិភាក្សាជាក្រុម៖

*បញ្ហាដែលនិស្សិត( ទាំងប្រុសទាំងស្រី )ជួបប្រទះក្នុងការសិក្សាមុខវិជ្ជាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា*

- ពិបាកក្នុងការសិក្សា ( ត្រូវការអនុវត្ត និងស្រាវជ្រាវច្រើន បញ្ហាផ្នែកភាសា កម្មវិធី និងកូដក្នុងផ្នែកទន់មានភាពស្មុគស្មាញ រៀនមុខវិជ្ជាច្រើន និងត្រូវប្រើគណិតវិទ្យា )
- ចំណាយលុយច្រើនដើម្បីទិញកុំព្យូទ័រ ផ្នែករឹង និងកម្មវិធីកុំព្យូទ័រ
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានបច្ចុប្បន្នភាពជានិច្ច
- មិនមានចំណេះដឹងមូលដ្ឋានអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (ទើបតែស្គាល់កុំព្យូទ័រ និងស្គាល់កម្មវិធី )
- សាកលវិទ្យាល័យមិនមានសម្ភារៈគ្រប់គ្រាន់សម្រាប់ការសិក្សា
- រៀនទ្រឹស្តីច្រើនជាងការអនុវត្ត
- រៀនផង និងធ្វើការផង
- ត្រូវការពេលវេលា និងថវិកាដើម្បីភ្ជាប់អ៊ីនធឺណិត

# ៤. លទ្ធផលនៃការស្រាវជ្រាវ

- ត្រូវទៅរៀនគួរ (សិក្សាមុខវិជ្ជាបន្ថែមនៅខាងក្រៅ)
- ពិបាកក្នុងការជួសជុល
- មានមេរោគច្រើន

*បញ្ហាដែលនិស្សិតស្រីជួបប្រទះក្នុងការសិក្សាមុខវិជ្ជាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា*

- មានស្ត្រីតិចតួចក្នុងថ្នាក់រៀន ធ្វើអោយមានការខ្មាសអៀន និងពិបាកទំនាក់ទំនង
- ពិបាកសិក្សា (ត្រូវការអនុវត្ត និងសិក្សាច្រើន បញ្ហាផ្នែកភាសា សិក្សាមុខវិជ្ជាច្រើន ប្រើគណិតវិទ្យា
- ត្រូវធ្វើការងារផ្ទះ
- ផ្នែករឹងមានភាពស្មុគស្មាញ
- មានការខ្មាសអៀន និងពិបាកក្នុងការទំនាក់ទំនងជាមួយសាស្ត្រាចារ្យ និងនិស្សិតភាគច្រើនជាបុរស
- មិនសូវមានសុវត្ថិភាព (ត្រូវធ្វើការងារសាលាដល់យប់ ពិបាកធ្វើដំណើរ ខ្លាចឆក់ខ្សែភ្លើង)
- ចំណាយលុយច្រើនដើម្បីសិក្សា
- ក្នុងការអនុវត្ត និស្សិតស្រីក៏ត្រូវដោះគ្រឿងបន្លាស់ (វាធ្វើអោយស្ត្រីមិនស្អាត)
- ពិបាករកការងារធ្វើ
- មានការរើសអើងពីនិស្សិតបុរស (នៅពេលធ្វើកិច្ចការសាលា និស្សិតប្រុសមិនអោយចូលក្រុមជាមួយដោយយល់ថាមិនសូវចេះ)
- រៀនគួរបន្ថែម
- វប្បធម៌ខ្មែរ (មិនសម ស្រីតែឯង)

*ផលលំបាកដែលស្ត្រីជួបប្រទះនៅក្នុងការធ្វើការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា*

- ការងារផ្នែកបណ្តាញ ផ្នែករឹង ជួសជុល មិនសមស្របចំពោះនារី ដោយសារតែត្រូវការប្រើកម្លាំង
- ការងារមិនមានពេលវេលាច្បាស់លាស់ ដូចជាធ្វើការពេលយប់ ឬថ្ងៃចុងសប្តាហ៍
- កត្តាជីវសាស្ត្រ (មានផ្ទៃពោះ)
- មិនមានបទពិសោធន៍គ្រប់គ្រាន់
- មិនមានចំណេះដឹងគ្រប់គ្រាន់
- ស្ថាប័នមួយចំនួនមិនជួលស្ត្រី
- ការងារបច្ចេកវិទ្យា មានបច្ចុប្បន្នរហូត
- មានបញ្ហាខាងភាសាបរទេស
- ការសិក្សា និងការធ្វើការងារមានភាពខុសគ្នា
- ពិបាកធ្វើការងារក្នុងកន្លែងដែលមានបុរសភាគច្រើន
- មានរោគស្ត្រេសច្រើន
- ត្រូវការពេលវេលាច្រើនក្នុងការមើលថែគ្រួសារ និងកូនចៅ
- ស្ត្រីមិនសូវមានទំនុកចិត្តលើខ្លួនឯង
- គេមិនសូវទុកចិត្ត និងអោយតម្លៃលើការងាររបស់ស្ត្រី

- ធ្វើការជាមួយកុំព្យូទ័រ អាចប៉ះពាល់ដល់ភ្នែក

*តើលោកអ្នកចង់អោយមានស្ត្រីកាន់តែច្រើនធ្វើការក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាដែរឬទេ?*

*ចង់អោយមាន*

- ការធ្វើអោយមានភាពស្មើគ្នារវាងបុរស និងស្ត្រី
- ដើម្បីលុបបំបាត់ភាពអៀនខ្មាសក្នុងការងារ
- ជាផ្នែកមួយនៃការអភិវឌ្ឍសង្គម
- ស្ត្រី ដឹងពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាដូចបុរសដែរ
- ការងារបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមិនមែនជាការងារសម្រាប់តែបុរសទេ ស្ត្រីអាចធ្វើការក្នុងផ្នែកការរចនា និងកម្មវិធី ហើយបុរសធ្វើការក្នុងផ្នែកបណ្តាញ និងផ្នែករឹង
- ស្ត្រីមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីស្រាវជ្រាវទេ
- ស្ត្រី ធ្វើការហ្មត់ចត់ច្រើនជាងបុរស
- ស្ត្រីធ្វើអោយបុរសខំប្រឹងធ្វើការងារ
- ស្ត្រីធ្វើការក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាកាន់តែច្រើន នាំអោយមានស្ត្រីសិក្សាក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាកាន់តែច្រើន
- ស្ត្រីពូកែក្នុងការសម្របសម្រួល

*មិនចង់អោយមាន*

- ការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមិនសមស្របចំពោះនារី

## ៤.៥. ទស្សនវិស័យផ្សេងៗ

**តារាងទី១៧៖ ទស្សនវិស័យ ការប្តេជ្ញា និងការលះបង់របស់បុគ្គលដើម្បីទទួលបាន ICT**

| ទស្សនវិស័យ | ១ (%) | ២ (%) | ៣ (%) | ៤ (%) | ៥ (%) |
|---|---|---|---|---|---|
| ណែនាំស្ត្រីដទៃទៀតអោយចូលរៀន និងធ្វើការក្នុងវិស័យ ICT (n=៥០១) | ០,៤ | ១,៨ | ១២,២ | ៦០,៧ | ២៥,០ |
| ICT មានផលប្រយោជន៍សម្រាប់ខ្ញុំ ដើម្បីការធ្វើការងារ (n=៥០៩) | ០,៤ | ០,៦ | ៤,៣ | ៥៣,៨ | ៤០,៩ |
| ICT (កុំព្យូទ័រ និងអ៊ីនធឺណិត) មានសារប្រយោជន៍សម្រាប់សង្គមរបស់យើង (n=៥១២) | ០,២ | ០,២ | ២,៥ | ៤៨,០ | ៤៩,០ |
| ខ្ញុំតែងតែអភិវឌ្ឍខ្លួនខ្ញុំអោយដើរទាន់បច្ចេកវិទ្យាថ្មីៗ (n=៥០៩) | ០,២ | ០,៦ | ១០,០ | ៦០,៩ | ២៨,៣ |
| កំណត់ចំណាំ៖ ១. មិនយល់ស្របខ្លាំង ២. មិនយល់ស្រប ៣. ធម្មតា ៤. យល់ស្រប ៥. យល់ស្រប | | | | | |

តួលេខខាងលើ បានអោយដឹងថា អ្នកឆ្លើយតបសម្ភាសភាគច្រើន (មានលើសពី ៨៥%) យល់ស្របចំពោះការណែនាំស្ត្រីដទៃទៀតអោយចូលរៀន និងធ្វើការក្នុងវិស័យ ICT ព្រោះ ICT មានសារប្រយោជន៍សម្រាប់សង្គមរបស់យើង និងការអភិវឌ្ឍខ្លួន

ដើរឲ្យទាន់បច្ចេកវិទ្យាថ្មីៗ ។

**តារាងទី១៨៖ ទស្សនវិស័យចំពោះស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងប្រទេសកម្ពុជា**

| អ្នកតំណាងស្ថាប័ន | បុគ្គលិក |
|---|---|
| សុទិដ្ឋិនិយម<br>■ ស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលយកចំណេះវិជ្ជា និងធ្វើការ ICT<br>■ មានការលើកទឹកចិត្តចំពោះស្ត្រីក្នុងវិស័យICT<br>■ សិក្សាផ្នែកនេះមានសារសំខាន់ក្នុងការស្វែងរកការងារចំពោះស្ត្រី<br>■ ស្ត្រីមានចំណេះផ្នែក ICT គឺអាចចូលរួមចំណែកក្នុងការកសាងសង្គមជាតិដែរ ។<br>■ ស្ត្រីមានអំណត់អត់ធន់ក្នុងការងារបានល្អជាងបុរស | សុទិដ្ឋិនិយម<br>■ ស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលយកចំណេះវិជ្ជា និងធ្វើការផ្នែក ICT<br>■ ស្ត្រីចូលរួមសិក្សាផ្នែក ICT គឺអាចធ្វើអោយស្ត្រីស្គាល់តម្លៃខ្លួនឯងបានច្បាស់ជាងមុន<br>■ ស្ត្រីចូលសិក្សាផ្នែក ICT គឺអាចជួយអោយសង្គមមានការរីកចម្រើន<br>■ ស្ត្រីមានឆន្ទៈក្នុងការងារច្រើនជាងបុរស<br>■ ស្ទើរតែគ្រាប់ការងារទាំងអស់ត្រូវការស្ត្រីអោយមានចំណេះដឹងផ្នែក ICT |
| ទុទិដ្ឋិនិយម<br>■ មានស្ត្រីចូលរួមសិក្សាផ្នែកនេះតិចតួចណាស់ ដែលទាមទារអោយមានការលើកទឹកចិត្តបន្ថែមទៀត | ទុទិដ្ឋិនិយម<br>■ ភាពក្រីក្រក៏ជាកត្តាមួយដែលរាំងស្ទះមួយដែរ<br>■ មានស្ត្រីចូលរួមសិក្សាផ្នែកនេះតិចតួចណាស់ ដែលទាមទារអោយមានការលើកទឹកចិត្តបន្ថែមទៀត<br>■ មុខវិជ្ជា ICT មិនសមស្របឡើយចំពោះស្ត្រីភេទ |

**និស្សិត**

សុទិដ្ឋិនិយម

- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា កំពុងតែមានការរីកចម្រើនក្នុងប្រទេសកម្ពុជា
- វានឹងមានការរីកចម្រើនកាន់តែខ្លាំងក្នុងពេលអនាគត
- នឹងមានក្រុមហ៊ុនកាន់តែច្រើនចូលមកវិនិយោគក្នុងផ្នែកនេះ
- នឹងមានស្ថាប័នកាន់តែច្រើនប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- មានកម្មវិធីមួយចំនួនជាភាសាខ្មែរ
- ទូរសព្ទអាចភ្ជាប់អ៊ីនធឺណិតបាន
- ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានឹងរីកចម្រើនដល់ជនបទ
- នឹងមានមនុស្សកាន់តែច្រើនប្រើប្រាស់ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាដើម្បីសិក្សា
- អាចបង្កើតកម្មវិធីដើម្បីប្រកួតប្រជែងជាមួយប្រទេសដទៃ
- តម្លៃសេវាកម្មអ៊ីនធឺណិតនឹងធ្លាក់ចុះ
- នឹងមានស្ថាប័នកាន់តែច្រើនផ្តល់វគ្គបណ្តុះបណ្តាលអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- នឹងមានក្រុមហ៊ុនមកផលិតផ្នែករឹងក្នុងប្រទេសកម្ពុជា
- នឹងមានសេវាកម្មអ៊ីនធឺណិតឥតគិតថ្លៃនៅទីសាធារណៈ

ទុទិដ្ឋិនិយម

- មានការអភិវឌ្ឍតែនៅទីក្រុងប៉ុណ្ណោះ
- ការរីកចម្រើននៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងប្រទេសកម្ពុជាមានភាពយឺតយ៉ាវ
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានៅតែមានគុណភាពអន់

**អ្នកដែលមានតួនាទីសំខាន់ក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា**

ស្ត្រីនៅមានកម្រិតក្នុងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

- ចរិតលក្ខណៈ (ស្ត្រីមិនចូលចិត្តបច្ចេកវិទ្យា គណិតវិទ្យា ខ្លាចឆក់ មិនចូលចិត្តការងារជាប្រព័ន្ធ)
- ស្ត្រីសិក្សា បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមានចំនួនតិច
- យល់ថាមិនមែនជាការងាររបស់ស្ត្រី (ធ្ងន់ ប្រឡាក់ដៃ ត្រូវប្រើកម្លាំង)
- វប្បធម៌ខ្មែរ (ពិបាកធ្វើការយប់ ពិបាកធ្វើការនៅកន្លែងឆ្ងាយៗ មិនអោយរៀន)
- ស្ត្រីធ្វើការផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមានចំនួនតិច
- បុគ្គលិកវ័យចំណាស់ភាគច្រើនមិនមានការយល់ដឹងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ធ្វើការមិនចំជំនាញ
- មិនទុកចិត្តស្ត្រីលើការងារបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ការចំណាយនៅក្នុងគ្រួសារ (អោយកូនប្រុសរៀន ច្រើនជាងកូនស្រី)
- និន្នាការពិភពលោក (ស្ត្រីមិនចូលចិត្តរៀន និងធ្វើការផ្នែកនេះទេ)
- ខ្វះការលើកទឹកចិត្តដល់ស្ត្រី
- បញ្ហាខាងភាសា (អត្ថបទភាគច្រើនជាភាសាបរទេស)
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមានការរីកចម្រើនតែនៅទីក្រុង
- តម្រូវការរបស់សាលា (ត្រូវរៀនច្រើន ប្រើគណិតវិទ្យា)

មានកំណើននារីក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

- ស្ត្រីខំប្រឹងរៀនជាងបុរស
- ឱកាសការងារល្អ
- ពូកែខាង ផ្នែកកម្មវិធី
- មានកំណើនស្ត្រីធ្វើការខាងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងការងារ
- ស្ត្រីវ័យក្មេងកាន់តែមានចំនួនច្រើនក្នុងវិស័យ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ស្ត្រីខំប្រឹងធ្វើការជាងបុរស
- ធ្វើការក្នុងការិយាល័យ
- ផ្តល់អាទិភាពដល់ស្ត្រី
- ចូលចិត្តសិក្សាមុខវិជ្ជានេះ
- ជាសង្គមទំនើប
- មិនធ្វើការជាអ្នកជំនាញ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាទេ តែប្រើបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាជាមធ្យោបាយសម្រាប់ធ្វើការងារ
- មានការជំរុញលើកទឹកចិត្ត
- ចង់សិក្សាស្វែងយល់
- មានកម្មវិធីសិក្សាតាំងពីថ្នាក់វិទ្យាល័យ

ស្រ្តីមានលទ្ធភាពស្មើនឹងបុរស តែការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាបុរសមានភាពប្រសើរជាង

- អ្នកតបសម្ភាសចំនួន១០នាក់ បាននិយាយថាស្រ្តីមានភាពស្មើគ្នាចំពោះលទ្ធភាពក្នុងការទទួលបានការងារ និងលទ្ធភាពក្នុងការទទួលបានចំណេះដឹង គឺវាអាស្រ័យលើការខិតខំប្រឹងប្រែងរបស់បុគ្គលម្នាក់ៗ ។ តែទោះជាយ៉ាងនេះក្តី អ្នកតបសម្ភាស ១៨នាក់ផ្សេងទៀត បានបញ្ចេញទស្សនៈថា វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាបុរសមានការចេះដឹងច្រើនជាង ហើយបុរសមានលក្ខខណ្ឌអំណោយផលច្រើនទៀតដូចជា ចំណង់ចំណូលចិត្តក្នុងការសិក្សាកម្លាំងកាយ ការប្រើប្រាស់ពេលវេលា ( យប់ និងថ្ងៃសៅរ៍ អាទិត្យ ដើម្បីស្រាវជ្រាវការងារ និងធ្វើការ ) ។

ក្រាហ្វិកទី៦ ៖ ស្ត្រីអាចត្រូវបានគេផ្តល់ឱកាសអាចតាមរយៈការប្រើប្រាស់ ICT ( អ្នកតំណាងស្ថាប័ន )




ក្រាហ្វិកទី៧៖ ស្ត្រីអាចត្រូវបានគេផ្តល់ឱកាសអាចតាមរយៈការប្រើប្រាស់ ICT ( បុគ្គលិកស្ថាប័ន )



# ៤. លទ្ធផលនៃការស្រាវជ្រាវ

មានភាពខុសគ្នាចំពោះស្ថាប័នគេផ្តល់ភាពអង់អាចតាមរយៈ ICT តិចតួចបំផុត គឺចំពោះបុគ្គលិកតំណាងស្ថាប័នអង្គការមិនមែនរដ្ឋាភិបាលមានចំនួន ៩២% យល់ស្រប ក្រសួងនានាមាន ៩៣,៨% ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ៩៧,៦% និង គ្រឹះស្ថានឧត្តមសិក្សាមាន ១០០% (P>០,០៥) ។

ចំពោះតំណាងបុគ្គលិកនៅតាមស្ថាប័នអង្គការមិនមែនរដ្ឋាភិបាលមានរហូតដល់ ៨៧,៣% ក្រសួងនានាមាន ៩៦,៦% ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតមាន ៩០% និងគ្រឹះស្ថានឧត្តមសិក្សាមាន ៩១,១% យល់ស្របថាស្ត្រីគេអាចផ្តល់ភាពអង់អាចតាមរយៈ ICT បាន(p>០,០៥) ។

ក្រាហ្វិកទី៨៖ រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល គួរតែធ្វើសកម្មភាពអោយបានច្រើនថែមទៀតក្នុងការធ្វើអោយប្រសើរឡើងនូវស្ថានភាព ICT របស់ស្ត្រី ក្នុងវិស័យអប់រំ និងការងារ (អ្នកតំណាងស្ថាប័ន)




ក្រាហ្វិកទី៩៖ រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល គួរតែធ្វើសកម្មភាពអោយបានច្រើនថែមទៀតក្នុងការធ្វើអោយប្រសើរឡើងនូវស្ថានភាព ICT របស់ស្ត្រី ក្នុងវិស័យអប់រំ និងការងារ (បុគ្គលិកស្ថាប័ន)



# ៤. លទ្ធផលនៃការស្រាវជ្រាវ

ចំណែកឯបញ្ហាថា រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងផ្នែកឯកជន គួរធ្វើសកម្មភាពអោយបានច្រើនថែមទៀត ក្នុងការធ្វើអោយស្ថានភាពស្ត្រីក្នុងវិស័យអប់រំ និងការងារប្រសើរឡើងនោះ គឺគ្រប់បុគ្គលិកធ្វើការនៅតាមស្ថាប័ននានាមានគំនិតយល់ស្របប្រហាក់ប្រហែលគ្នា (លើសពី ៩៥%) P>0,0៥ ។

នៅពេលសួរនិស្សិតថា តើរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលគួរធ្វើសកម្មភាពអ្វី ដើម្បីអោយស្ថានភាពនៃការសិក្សា និងការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាកាន់តែមានលក្ខណៈទូលំទូលាយ និងល្អប្រសើរជាងមុន? ពួកគេបានឆ្លើយថា៖

*រដ្ឋាភិបាល*

- បញ្ចុះតម្លៃអ៊ីនធឺណិត និងគួរមិនយកថ្លៃអ៊ីនធឺណិតនៅកន្លែងសាធារណៈមួយចំនួន
- គួរតែបញ្ជ្រាបមុខវិជ្ជាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា តាំងពីបឋមសិក្សា
- គួរបង្កើនការយកចិត្តទុកដាក់ដល់តំបន់ដាច់ស្រយាល ជាជាងផ្តោតតែទៅលើទីក្រុង
- គួរតែបញ្ជ្រាបមុខវិជ្ជាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា តាំងពីវិទ្យាល័យ
- ផ្តល់ការលើកទឹកចិត្តចំពោះការរកឃើញថ្មីៗ
- ផ្តល់ជាអាហារូបករណ៍អោយបានច្រើន
- ផ្តល់វគ្គបណ្តុះបណ្តាលអំពី បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាអោយបានកាន់តែច្រើន
- បង្កើតជាសិក្ខាសាលា អំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាអោយបានច្រើន
- គួរតែផ្តោតលើគុណភាពជាជាងបរិមាណ
- គួរតែមានម៉ាស៊ីនបម្រើដោយខ្លួនឯង
- បញ្ចុះតម្លៃសម្រាប់ស្ត្រីដែលចង់សិក្សាផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ផ្តល់ឱកាសការងារដល់អ្នកដែលមានជំនាញបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- បញ្ចុះតម្លៃគ្រប់សម្ភារៈដែលទាក់ទងនឹងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ផ្តល់ឱកាសអោយបានចុះកម្មសិក្សា
- រៀបចំការប្រកួតប្រជែងផ្នែកព័ត៌មានវិទ្យា
- ស្វែងរកកិច្ចសហការជាមួយក្រុមហ៊ុនណាមួយដើម្បីអោយកុំព្យូទ័រមានតម្លៃថោក
- បង្កើតច្បាប់កម្មសិទ្ធិ
- បង្កើតច្បាប់អ៊ីនធឺណិត (Cyber law)
- ធ្វើការសិក្សាស្រាវជ្រាវអោយបានច្រើនពីផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ជំរុញអោយមានការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាអោយកាន់តែច្រើន
- ផ្តល់ការគាំទ្រទាំងផ្នែកថវិកា និងសម្ភារៈ
- ផ្តល់ប្រាក់ខែបុគ្គលិកអោយបានគ្រប់គ្រាន់
- បង្កើតការបង្ហាត់បង្រៀនអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាតាមទូរទស្សន៍
- បង្កើតកម្មវិធីផ្លាស់ប្តូរនិស្សិតជាមួយប្រទេសក្រៅ

# ៤. លទ្ធផលនៃការស្រាវជ្រាវ

*អង្គការសង្គមស៊ីវិល*

- ផ្តល់ជាអាហារូបករណ៍
- ជួយបណ្តុះបណ្តាលដល់ប្រជាជនដែលរស់នៅជនបទ
- បង្កើតជាសិក្ខាសាលាដើម្បីផ្សព្វផ្សាយពីសារសំខាន់នៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា
- ផ្តល់ឱកាសការងារដល់អ្នកដែលសិក្សាខាងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ផ្តល់ឱកាសអោយបានចុះកម្មសិក្សា
- រៀបចំការប្រកួតប្រជែងផ្នែកព័ត៌មានវិទ្យា
- ផ្តល់ការលើកទឹកចិត្តចំពោះការរកឃើញថ្មីៗ
- លើកទឹកចិត្តប្រជាជនអោយប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា
- ផ្តល់ការគាំទ្រទាំងផ្នែកថវិកា និងសម្ភារៈ
- ជួយបង្កើតកម្មវិធីសិក្សា ផ្នែកបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា
- ជួយផ្តល់ជាឯកសារបន្ថែមទាក់ទងនឹងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ។

# ៥. ការពិភាក្សា

## ៥.១. ពិភាក្សាលើវិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ជាការសិក្សាបែបពិពណ៌នា ដែលមានគោលបំណងស្វែងយល់អំពីស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាសម្រាប់ស្ត្រីក្នុងវិស័យអប់រំ និងការងារ ។ នៅប្រទេសកម្ពុជាយើង ជាពិសេសនៅទីក្រុងភ្នំពេញ នៅមិនទាន់មានការសិក្សាស្រាវជ្រាវអំពីបញ្ហានេះអោយបានច្រើននៅឡើយទេ ហើយកន្លងមកមានតែករណីធ្វើការសិក្សាដោយផ្អែកអំពីចំនួនភាគរយនៃស្ត្រីក្នុងការងារ ឬស្ត្រីក្នុងវិស័យអប់រំ ឬភាគរយនៃនិស្សិតស្ត្រីដែលបានបញ្ចប់ការសិក្សាផ្នែក ICT ប៉ុណ្ណោះ ដោយមិនផ្សារភ្ជាប់ពីការអប់រំមកកាន់ការងារ ។

ចំពោះការសិក្សាទៅលើបញ្ហាយេនឌ័រ ក្រុមការងារបានប្រើវិធីសាស្ត្រក្នុងការសម្ភាសបែបស៊ីជម្រៅ ដោយបានសិក្សាស្ដីអំពីទស្សនៈនានារបស់បុគ្គលិកដែលធ្វើការនៅស្ថាប័នផ្សេងៗគ្នា និងអំពីទស្សនៈរបស់ពួកគាត់ចំពោះការលើកកម្ពស់ស្ត្រីក្នុងផ្នែក ICT ក្នុងវិស័យការងារ ។ លើសពីនេះទៅទៀត ក្រុមការងារបានសិក្សាតាមគេហទំព័រផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកមួយចំនួន ដើម្បីស្វែងយល់ថាតើតម្រូវការរបស់ស្ថាប័ននីមួយៗ ក្នុងការជ្រើសរើសបុគ្គលិកអោយចូលបម្រើការងារនោះមានលក្ខណៈយ៉ាងដូចម្តេចខ្លះ ? ការសិក្សានេះ គឺជាការសិក្សាបែបកាត់ទទឹង (មិនមែនអន្តរាគមន៍) ដូច្នេះវាអាចមានកំហុសលក្ខណៈជាប្រព័ន្ធដែលកើតឡើងដោយមិនអាចព្រាងទុកបាន ។ បញ្ហាក្នុងការបំពេញកម្រងសំណួរដោយស្ថាប័នគោលដៅខ្លួនឯងផ្ទាល់ អាចមានលក្ខណៈមិនត្រឹមត្រូវ និងមានការច្រឡំ ជាដើម ។ ក្រុមការងារបានប្រឹងប្រែងដោះស្រាយបញ្ហាទាំងនេះ តាមរយៈការបណ្តុះបណ្តាលដល់អ្នកជំនួយការស្រាវជ្រាវអំពីវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ និងក្រមសីលធម៌នៅក្នុងការប្រមូលព័ត៌មាន ។ ទន្ទឹមនឹងនេះផងដែរ ក្រុមការងារ បានធ្វើទំនាក់ទំនងល្អជាមួយអ្នកតំណាងស្ថាប័ន ព្រមទាំងបុគ្គលិកនៃស្ថាប័នគោលដៅទាំងនោះ ដើម្បីដោះស្រាយឡើងវិញរាល់កម្រងសំណួរណាដែលមានលក្ខណៈមិនច្បាស់លាស់ ដោយធ្វើការសាកសួរពួកគាត់ម្តងទៀត ។

## ៥.២. ពិភាក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៥.២.១. ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យអប់រំ

លទ្ធផលនៃការសិក្សារកឃើញថា សមាមាត្រស្ត្រីដែលបានបញ្ចប់បរិញ្ញាបត្រផ្នែក ICT មានបម្រែបម្រួលតិចតួច ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ដែលមាននិស្សិតប្រហែល ១,៣០០នាក់ ដោយឡែកក្នុងឆ្នាំសិក្សា២០០៨-២០០៩ និស្សិតមានការកើនឡើងប្រហែល ៥០០នាក់បន្ថែមទៀត ក្នុងនោះនិស្សិតស្ត្រីមាន ១៧,៤% ។ បើប្រៀបធៀបមុខវិជ្ជាបីនៅក្នុងផ្នែកនេះ មុខវិជ្ជាវិស្វករ និងវិទ្យាសាស្ត្រកុំព្យូទ័រ ឬព័ត៌មានវិទ្យា មាននិស្សិតសិក្សាច្រើនជាងគេក្នុងចំណោម ៤ឆ្នាំកន្លងមក ដែលមានចំនួន ១០ដង ធៀបនឹងមុខវិជ្ជាអគ្គិសនី និងអេឡិចត្រូនិក និង៨៦ដងបើធៀបនឹងមុខវិជ្ជាប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ។ បើពិនិត្យមើលសមាមាត្រវិញ ស្ត្រីនៅក្នុងមុខវិជ្ជា ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ មានចំនួនច្រើនជាងមុខវិជ្ជាពីរផ្សេងទៀតទៅវិញ ដែលមានរហូតដល់ ៣២,៨% កាលពី៤ឆ្នាំកន្លងទៅ (ថ្នាក់បរិញ្ញា ២០០៥-២០០៩) និងបន្តកើនឡើងរហូតដល់៤៥,២% ក្នុងឆ្នាំសិក្សាទី១-ទី៤នៃឆ្នាំសិក្សា២០០៩-២០១០ ។ លើសពីនេះទៅទៀត ក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ គិតចាប់ពីឆ្នាំ២០០៥-២០០៩ ស្ត្រីសិក្សាក្នុងផ្នែក ICT មានតែ ១២,៤% តែប៉ុណ្ណោះ ប៉ុន្តែបើធៀបជាមួយនឹងអត្រាស្ត្រីដែលកំពុងសិក្សាចាប់ពីឆ្នាំទី១ ដល់ឆ្នាំទី៤ នៃឆ្នាំសិក្សា ២០០៩-២០១០ ស្ត្រីមានធ្លាក់ចុះមកត្រឹមតែ ៩,១% ។

ចំពោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្នុងឆ្នាំសិក្សា២០០៧-២០០៨ និង ២០០៨-២០០៩ ចំនួនស្ត្រីមានការថយចុះយ៉ាងខ្លាំងពី ៣៥,៣% ក្នុងឆ្នាំ២០០៧-២០០៨ មកត្រឹមតែ ៦,២% ក្នុងឆ្នាំ២០០៨-២០០៩ ។ សមាមាត្រស្ត្រីបន្តធ្លាក់ចុះ មកត្រឹម ៥,៤% ក្នុងឆ្នាំទី២ និងបន្តធ្លាក់ចុះមកត្រឹម ៥,២% ក្នុងឆ្នាំទី១ នៃឆ្នាំសិក្សា២០០៩-២០១០ ។ ចំពោះកម្រិតអនុបណ្ឌិត មិនទាន់មានគ្រឹះស្ថានឧត្តមសិក្សាណាមួយទេ បានផ្តល់មុខវិជ្ជាអគ្គិសនី និងអេឡិចត្រូនិក ។ ជាងនេះទៅទៀត មុខវិជ្ជាប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ក៏លែងមាននិស្សិតបានចូលសិក្សាហើយដែរក្នុងឆ្នាំ២០០៩-២០១០ ។

សរុបមក ចំនួនស្ត្រីចូលរួមសិក្សាផ្នែក ICT គឺនៅមានកម្រិតទាបនៅឡើយ បើធៀបជាមួយនឹងបុរសនៅក្នុងទីក្រុងភ្នំពេញ ។ ទោះបីយ៉ាងណាក៏ដោយ មិនថាតែប្រទេសអភិវឌ្ឍ ឬប្រទេសកំពុងអភិវឌ្ឍទេ ស្ត្រីចូលរួមក្នុងវិស័យអប់រំ ផ្នែក ICT នេះក៏នៅមានចំនួនតិចជាងបុរសដែរ ។ មូលហេតុសំខាន់ៗ ដែលនាំអោយស្ត្រីសិក្សាមានចំនួនតិចជាងបុរស មានដូចជា ការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ជាការងារលំបាក និងសម្រាប់តែបុរសប៉ុណ្ណោះ ពិបាកសិក្សា ដោយត្រូវប្រើគណិតវិទ្យា និងមានមុខវិជ្ជាច្រើន មានការខ្មាសអៀន និងពិបាកក្នុងការទំនាក់ទំនង ជាមួយសាស្ត្រាចារ្យ និងនិស្សិតដែលភាគច្រើនជាបុរស មិនមានការលើកទឹកចិត្តពីគ្រួសារ ក្រុមហ៊ុនមិនជ្រើសរើសបុគ្គលិកនារីដែលមានជំនាញ មិនមានចំណង់ចំណូលចិត្តរៀនផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា គិតថាការងារបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា គឺជាការងារជួសជុលតែប៉ុណ្ណោះ ចំណាយលុយច្រើន និងស្ត្រីត្រូវធ្វើការងារផ្ទះ -ល-។ ស្រដៀងគ្នានឹងការរកឃើញរបស់ការសិក្សានេះដែរ ការសិក្សារបស់ Sophia, 2005 បានអោយដឹងថានៅក្នុងគ្រួសារមួយ ដែលមានកូនកំពុងសិក្សានោះ ឪពុកម្តាយនៅតែមានទស្សនៈមួយថា គាត់នឹងផ្តល់ឱកាសអោយកូនប្រុស រៀនសូត្របានខ្ពស់ជាងកូនស្រី ព្រោះឪពុកម្តាយយល់ថា កូនស្រីអាចជួយការងារផ្ទះបានច្រើនជាងកូនប្រុស ។ ដោយបានពន្យល់បន្ថែមពីទំនាក់ទំនងរវាង ICT និងបរិបទសង្គម ការសិក្សារបស់ Papastergiou បានបង្ហាញអោយដឹងថា ទោះបីជាស្ត្រី មានចំណេះដឹងដូចបុរស ឬលើសបុរសក្នុងផ្នែកគណិតវិទ្យា ឬមុខវិជ្ជាវិទ្យាសាស្ត្រក៏ដោយ ក៏ជាទូទៅពួកគាត់(ស្ត្រី) មិនត្រូវបានលើកទឹកចិត្តពីក្រុមគ្រួសារ និងគ្រូបង្រៀន ក្នុងការសិក្សាមុខវិជ្ជានេះឡើយ (Papastergiou, 2008) ។

ឧបសគ្គមួយចំនួន បានរាំងស្ទះស្ត្រីមិនអោយចូលរួមក្នុងវិស័យអប់រំ មានដូចជាទីតាំងភូមិសាស្ត្រ តម្លៃនៃការបង់ថ្លៃការសិក្សា ភាពរើសអើងក្នុងសង្គមជាដើម ហើយក្នុងនោះមានហេតុផលនៅពីក្រោយមួយចំនួនទៀតដែលមិនទាន់បានរកឃើញ ។ ឧទាហរណ៍ ប្រទេសអាល្លឺម៉ង់ ដែលជាប្រទេសរីកចម្រើនផ្នែកឧស្សាហកម្ម ភាគរយនៃស្ត្រីដែលមានសញ្ញាប័ត្រផ្នែក ICT នៅតែមានចំនួនតិចជាងបុរសយ៉ាងខ្លាំងក្នុងនោះខ្ពស់បំផុត គឺមានតែជំនាញវិស្វករទេ ដែលមានអត្រាខ្ពស់ជាងគេ គឺ៣៧% តែប៉ុណ្ណោះ (EUROSTAT, 2009) ។

គោលនយោបាយ ឬកម្មវិធីរបស់ស្ថាប័នដើម្បីលើកកម្ពស់ស្ត្រីចូលរួមការងារផ្នែក ICT ក្នុងវិស័យអប់រំ និងការងារវិញ នៅមានកម្រិតទាបនៅឡើយ ដែលមានចាប់ពី៩,៣% ទៅដល់ខ្ពស់បំផុតគឺ ៣៥,៣% ។ ស្ថាប័នមិនបានបញ្ជាក់អោយច្បាស់ពីគោលនយោបាយ ដើម្បីធ្វើអោយប្រសើរឡើងនូវអត្រាស្ត្រីចូលរួមក្នុងផ្នែក ICT ដោយគ្រាន់តែបាននិយាយថាពួកគាត់បានផ្តល់ថវិកាដល់ស្ត្រីក្នុងការបណ្តុះបណ្តាល បញ្ជូនទៅសិក្សានៅខាងក្រៅ និងផ្តល់ពេលវេលាជាដើម ។

### ៥.២.២. ស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងវិស័យការងារ

យើងបានដឹងហើយថា វិស័យការងារ វាមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងភាពក្រីក្រ មានន័យថាការបង្កើតឱកាសក្នុងការទទួលបានចំណូលតាមរយៈការធ្វើការងារខាងក្រៅ ឬប្រកបរបររកស៊ីដោយខ្លួនឯងមានសារសំខាន់ក្នុងការកែប្រែជីវភាព ។ ទោះបីជាវាមាន

# ៥. ការពិភាក្សា

សារសំខាន់ពិតមែន ប៉ុន្តែក៏នៅមានបញ្ហាជាច្រើនទៀតដែលរាំងស្ទះចំពោះស្ត្រីក្នុងវិស័យការងារ ដូចជាភាពរើសអើងចំពោះស្ត្រីនៅក្នុងវិស័យការងារ កំពុងតែបន្តកើតមានឡើងនៅទូទាំងពិភពលោក ហើយភាពរើសអើងទាំងនោះបានធ្វើអោយខាតបង់រហូតដល់ ៨០ពាន់លានដុល្លារ (UNESCAP, 2007) ។

លទ្ធផលនៃការសិក្សាបានអោយដឹងថា ក្នុងស្ថាប័នទាំងបួន អង្គការសង្គមស៊ីវិល មានស្ត្រីចូលរួមក្នុងវិស័យការងារច្រើនជាងគេ គឺស្មើនឹង ៤៦,៣% បន្ទាប់មកស្ថាប័នរដ្ឋ គឺមានតែ ៣៦,៣% បន្តដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត មាន ៣២,១% និងចុងក្រោយគឺគ្រឹះស្ថានអប់រំឧត្តមសិក្សា មាន ២៧,៨% ។ លទ្ធផលនេះបើធៀបជាមួយនឹងលទ្ធផលនៃការសិក្សារបស់ UN បានអោយដឹងថា ជាទូទៅអត្រានៃស្ត្រីនៅក្នុងវិស័យការងារនៅតំបន់អាស៊ីភាគខាងត្បូង មានជាមធ្យមចំនួន ៤៣,៥% ។ ដូច្នេះបើយើងក្រឡេកមើលទិន្នន័យរបស់ការសិក្សាស្រាវជ្រាវយើងវិញ គឺអ្នកធ្វើការនៅ NGO គឺមានភាគរយប្រហាក់ប្រហែលគ្នានឹងទិន្នន័យនេះដែរ ម៉្យាងទៀតការសិក្សានេះក៏បានបង្ហាញអោយឃើញថា ក្នុងប្រទេសឥណ្ឌាគឺស្ត្រីចូលរួមក្នុងវិស័យការងារ មានតែ ២៦%តែប៉ុណ្ណោះ ចំណែកឯក្នុងឆ្នាំ២០០៨ នៅប្រទេសប៉ាឡេស្ទីនវិញ ភាគរយនៃស្ត្រីក្នុងវិស័យការងារមានតែ ១៤,៧% តែប៉ុណ្ណោះ (PWRDC, 2008) ។ ដូច្នេះយើងឃើញថាចំនួនស្ត្រីដែលធ្វើការនៅតាមស្ថាប័នរដ្ឋគឺ មានចំនួនប្រហាក់ប្រហែលនឹងប្រទេសឥណ្ឌាដែរ ។ ក្នុងនោះដែរមានប្រទេសមួយចំនួនដែលមានប្រពៃណីទំនៀមទម្លាប់តឹងរ៉ឹង ដូចជាម៉ាឡេស៊ី ឥណ្ឌូណេស៊ី និងប្រ៊ុយណេ គឺតួលេខនេះមានចំនួនទាបយ៉ាងខ្លាំង ដូច្នេះតាមការសិក្សានានា យើងឃើញថា ការចូលរួមក្នុងវិស័យការងាររបស់ស្ត្រីនៅមានកម្រិតទាបនៅឡើយ បើធៀបជាមួយនឹងបុរស ជាពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍ ។ ស្ត្រីនៅតែប្រឈមមុខចំពោះគម្លាតយេនឌ័រនៅក្នុងវិស័យការងារ ជាពិសេសនៅអាស៊ីខាងត្បូង អាហ្វ្រិកខាងត្បូង មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង ។ គម្លាតការងាររវាងស្ត្រី និងបុរសនៅបណ្តាប្រទេសទាំងនោះគឺ ៤០% ។ ចំណែកឯនៅអាស៊ីខាងកើត គឺមានក្រោម ២០% (Kolev and Sirven, 2007) ។ តាមការសិក្សាមួយរបស់ ILO បានអោយដឹងថាក្នុងឆ្នាំ២០០៧ នៅទូទាំងពិភពលោក ក្នុងវិស័យការងារ គឺមានស្ត្រីចូលរួម ៤៩,១% និងបុរស ៧៣,៣% ។ យោងតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ បានអោយដឹងថា ស្ត្រីចូលរួមក្នុងការវិស័យការងារមិនមែនជាការងារកសិកម្ម មានការកើនឡើងតិចតួច ប៉ុន្តែជាទូទៅស្ត្រីមានទំនោរច្រើនជាងបុរសក្នុងការទទួលយកការងារដែលមានចំណូលទាប សមិទ្ធផលទាប និងការងារងាយទទួលគ្រោះថ្នាក់ជាមួយនឹងភាពគ្មានសិទ្ធិសេរីភាពច្បាស់លាស់ គ្មានការការពារពីសង្គម ឬគ្មានសំឡេងក្នុងវិស័យការងារ (ILO, 2008) ។ មូលហេតុទាំងនេះ រួមមានស្ត្រីត្រូវចំណាយពេលសម្រាកនៅពេលមានផ្ទៃពោះ ចំណាយពេលក្នុងការថែរក្សាក្រុមគ្រួសារ ដែលជាកត្តានាំអោយថយចុះអត្រាការងារធៀបជាមួយនឹងបុរស (EC, 2009) ។ ក្នុងនោះដែរបើយើងពិនិត្យមើលចំពោះគោលនយោបាយជាក់ស្តែង ចំនួនភាគរយដែលស្ថាប័ននីមួយៗមានគោលនយោបាយដើម្បីជំរុញអោយបុគ្គលិកស្ត្រី ធ្វើការកសាងសមត្ថភាពគឺមានភាពខុសគ្នា ដូចជានៅតាមអង្គការក្រៅរដ្ឋាភិបាល មាន ៧២,៥% នៅតាមស្ថាប័នរដ្ឋមាន ៣៥,៣% តាមស្ថាប័នផ្គត់ផ្គង់សេវាកម្មអ៊ីនធឺណិត មាន៩,៣% និងតាមស្ថាប័នអប់រំ មាន ៣៤,៦% (P<0,00១) ។ គោលនយោបាយទាំងនោះ រួមមាន ការពង្រឹងសមត្ថភាពស្ត្រី និងការបណ្តុះបណ្តាលធនធានមនុស្សបន្ថែម ផ្តល់ជាថវិកា ផ្តល់ពេលវេលាអោយស្ត្រី និងបានលើកទឹកចិត្តដល់បុគ្គលិកដែលជាស្ត្រីក្នុងការកសាងសមត្ថភាព ។ សរុបមកយើងឃើញថាចំនួនស្ត្រីចូលរួមក្នុងវិស័យការងារនៅមានចំនួនតិចនៅឡើយ ហើយគោលនយោបាយចំពោះស្ត្រីក្នុងវិស័យការងារនៅតាមស្ថាប័ននានា ក៏មានចំនួនទាបនៅឡើយដែរ ។

### តម្រូវការស្ត្រីក្នុងផ្នែកការងារ ICT នៅតាមស្ថាប័ន

ក្នុងចំណោមស្ថាប័នចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ក្រសួងនានាមានតម្រូវការបុគ្គលិកមានចំណេះដឹងផ្នែក ICT ច្រើនជាងគេ ដែលមានរហូតដល់ ៥៣% ហើយជាមធ្យម តម្រូវការបុគ្គលិកមាន ១០នាក់ ដែលក្នុងនោះមានស្រី ៦នាក់ (៦០%) ។ ៣៥% នៃស្ថាប័នអប់រំ មានតម្រូវការបុគ្គលិក ដែលមានចំណេះដឹងផ្នែក ICT ជាមធ្យម ៥នាក់ ដែលក្នុង នោះមានស្រី ២នាក់ (៤០%) ។ អង្គការសង្គមស៊ីវិលចំនួន ២៥% មានតម្រូវការបុគ្គលិកផ្នែកនេះ ជាមធ្យម ២នាក់ ដែល ក្នុងនោះស្រី ១នាក់ (៥០%) ។ រីឯផ្នែកឯកជន (ISP និង ហាងអ៊ីនធឺណិត)ចំនួន ១១,៧% មានតម្រូវការបុគ្គលិក ដែលមានចំណេះដឹងផ្នែក ICT ជាមធ្យម ២នាក់ ដែលក្នុង នោះស្រី ១នាក់ (៥០%) ។

ប៉ុន្តែបើយើងក្រឡេកមើលតួលេខដែលបង្ហាញតាមរយៈ ការផ្សព្វផ្សាយនៅក្នុងគេហទំព័រការងារពីរ (បងធំ និងពេល ព្រឹក) បានអោយដឹងថា ជាទូទៅតម្រូវការជ្រើសរើសបុគ្គលិក មកបម្រើការងារ ការងារមានកម្រិតខ្ពស់ និងការងារកម្រិត កណ្តាល ទាមទារអោយបេក្ខជនមានចំណេះដឹងផ្នែក ICT ស្ទើរតែ១០០% ប៉ុន្តែមិនចាំបាច់អោយមានជំនាញ ICT ខ្ពស់ ទេ ។ ផ្ទុយមកវិញ ការងារកម្រិតទាប មិនទាមទារអោយ បេក្ខជនមានចំណេះដឹងផ្នែក ICT ច្រើនទេ ដែលមានប្រហែល ១៥% ។ នេះឆ្លុះបញ្ចាំងអោយឃើញថា ដើម្បីប្រកួតប្រជែង ក្នុងការទទួលបានការងារ យ៉ាងហោចណាស់បេក្ខជនទាំង អស់ត្រូវមានចំណេះដឹងផ្នែកកុំព្យូទ័រខ្លះៗ ។

ការជំរុញលើកទឹកចិត្តស្ត្រី ពេលប្រកាសជ្រើសរើស បុគ្គលិកតាមគេហទំព័រមកបម្រើការងារនៅតាមស្ថាប័ននានា មានតែ ១៣,៣% ប៉ុណ្ណោះ ។ ដើម្បីអោយការចូលរួមរបស់ ស្ត្រីក្នុងវិស័យការងារមានចំនួនកើនឡើងនោះ យើងត្រូវការ កិច្ចសហការពីគ្រប់ស្ថាប័នគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋ ខ្លួនឯង ក្នុងការលើកទឹកចិត្តស្ត្រី និងផ្តល់ឱកាសដល់ស្ត្រី ក្នុងការចាប់យកចំណេះវិជ្ជាផ្នែក ICT ។ ការសិក្សានេះ មាន លក្ខណៈស្រដៀងគ្នានឹងការរកឃើញរបស់អង្គការ ILO ដែល និយាយថា និយោជកភាគច្រើន ចង់បានបុគ្គលិកមកធ្វើការ ជាមនុស្សប្រុស ទោះបីជាស្ត្រីមានសមត្ថភាព និងចំណេះដឹង ដូចបុរសក៏ដោយ ។ ឧទាហរណ៍ នៅក្នុងដំណឹងជ្រើសរើស បុគ្គលិកផ្នែកជួសជុលកុំព្យូទ័រ និងបណ្តាញ (Network) គឺ បញ្ជាក់យ៉ាងច្បាស់ថាពួកគេត្រូវការបុគ្គលិកបុរស (ILO, 2008) ។

### ការលំបាករបស់អ្នកមានសញ្ញាប័ត្រ ICT ក្នុងការស្វែងរក ការងារធ្វើ

ក្នុងន័យស្ថិតិ មិនមានអ្វីខុសគ្នាគួរអោយគត់សំគាល់ទេ ទាំងបុរស និងស្ត្រីដែលមានសញ្ញាប័ត្រ ICT មានការលំបាក ក្នុងការស្វែងរកការងារ ICT ធៀបជាមួយនឹងអ្នកមិនមាន សញ្ញាប័ត្រ ICT ។ ប៉ុន្តែបើយើងធ្វើការពិនិត្យចំពោះអ្នកដែល មានសញ្ញាប័ត្រ ICT យើងឃើញថាស្ត្រី (៤៦,២%) ឆ្លើយ ថាមានការលំបាកក្នុងការស្វែងរកការងារ ខ្ពស់ជាងបុរស (៤៣,៨%) ។ នៅពេលដែលស្នើសុំអោយពួកគាត់ពន្យល់ បន្ថែមអំពីផលវិបាក ពួកគាត់បាននិយាយថាស្ថាប័ននីមួយៗ ត្រូវការបុគ្គលិកតិចតួច ទីផ្សារការងារចង្អៀត ការងារត្រូវការ អ្នកដែលមានបទពិសោធន៍ ត្រូវការភាសាបរទេស មាន បេក្ខជនប្រកួតប្រជែងច្រើន និងប្រាក់ខែទាប ។

ទិន្នន័យបានមកពីការពិភាក្សាជាក្រុមជាមួយនិស្សិត ដែលសិក្សាមុខវិជ្ជានេះ បានបង្ហាញយ៉ាងច្បាស់ពីមូលហេតុ ដែលបុរសអាចមានឱកាសទទួលបាននូវការងារផ្នែក ICT ច្រើនជាងស្ត្រី ដែលមានដូចជា៖ ការងារ ICT ត្រូវប្រើ កម្លាំង និងមិនសមចំពោះនារី (បណ្តាញ និងជួសជុល) បុរសមានសមត្ថភាពជាងស្ត្រី ក្រុមហ៊ុនមិនជួលនារីដែល មានចំណេះដឹងផ្នែក ICT មកធ្វើការទេ ការងារបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ជួនពេលខ្លះតម្រូវអោយធ្វើការពេល យប់ ការងារ ICT ជួនពេលខ្លះតម្រូវអោយធ្វើការនៅឆ្ងាយ មិន មានពេលវេលាគ្រប់គ្រាន់ជាមួយគ្រួសារ និងមិនទុកចិត្តលើ ការងាររបស់នារីលើផ្នែកនេះ ។

តាមរយៈការសិក្សារបស់ Halkin និង Taggart (2001) ក៏បានរកឃើញផងដែរថា មានបញ្ហាមួយចំនួនដែលជាឧបសគ្គចំពោះស្ត្រីក្នុងការឈានចាប់ផ្តើក ICT ដើម្បីយកមកបម្រើក្នុងផលប្រយោជន៍ផ្សេងៗដូចជា៖ កត្តាវប្បធម៌ និងអាកប្បកិរិយា ដែលនៅតែមានការរើសអើងចំពោះស្ត្រីក្នុងការចូលរួមក្នុងការសិក្សាបើធៀបជាមួយនឹងបុរស ។

### ការប្រើប្រាស់អ៊ីនធឺណិតរបស់ស្ត្រីធៀបជាមួយនឹងបុរស

ចំពោះព័ត៌មានអំពីការប្រើប្រាស់អ៊ីនធឺណិតវិញ ការសិក្សាបានបង្ហាញអោយឃើញថា បុរសមានការប្រើប្រាស់អ៊ីនធឺណិតញឹកញាប់ជាងស្ត្រី ។ ការប្រើប្រាស់ស្ទើររាល់ថ្ងៃរបស់បុរសមានចំនួន ១៧% រីឯវិញមានស្ត្រីមាន ១៥,៣% ប្រើច្រើនជាងពីរដងក្នុងមួយថ្ងៃរបស់បុរសមានចំនួន ១២,១% រីឯស្ត្រីមានចំនួន ៩,៥% ប្រើរាល់ថ្ងៃគឺបុរសមានចំនួន ៤៥,៦% រីឯស្ត្រីមាន ៣៧,៨% ។ ការសិក្សាមួយចំនួនបានអោយឃើញថា នៅប្រទេសម៉ាឡេស៊ី អត្រានៃការប្រើប្រាស់អ៊ីនធឺណិត មានរហូតទៅដល់ ៨២% ផ្ទុយទៅវិញមានតែ ៣៣% ប៉ុណ្ណោះដែលអ្នកប្រើប្រាស់ជាស្ត្រី ។ ក្នុងចំណោមបញ្ហាចម្បងជាច្រើនទាក់ទងនឹងការប្រើប្រាស់ អ៊ីនធឺណិត ចំណេះវិជ្ជារបស់ស្ត្រី គឺជាបញ្ហាចម្បងជាងគេ ។

យើងដឹងហើយថា ទាំងបុរស និងស្ត្រីត្រូវការចំណេះដឹងខាងអក្សរ និងការគិតលេខជាមូលដ្ឋាន ដើម្បីអាចអាន និងបង្កើតសារផ្សេងៗ ប្រើប្រាស់អ៊ីនធឺណិត និងអនុវត្តតាមការណែនាំផ្សេងៗនៅក្នុងកម្មវិធីកុំព្យូទ័រ ។ តាមការសិក្សារបស់ Huyer et al (2005) បានបង្ហាញអោយដឹងថានៅប្រទេសម៉ុងហ្គោលី អត្រាស្ត្រីចូលរៀននៅមហាវិទ្យាល័យមានចំនួនច្រើនជាងបុរស ទន្ទឹមនឹងនេះចំនួនស្ត្រីប្រើប្រាស់បច្ចេកវិទ្យា អ៊ីនធឺណិតក៏មានចំនួនច្រើនជាងបុរសដែរ ។ ប្រហាក់ប្រហែលនឹងការសិក្សារបស់ Huyer et al អត្រាស្ត្រីរៀនថ្នាក់វិទ្យាល័យនៅប្រទេសថៃ ក៏មានកម្រិតខ្ពស់ដែរ ដោយសាររដ្ឋាភិបាលមានគោលនយោបាយក្នុងការលើកទឹកចិត្តស្ត្រីក្នុងការចូលរួមក្នុងផ្នែក ICT ហើយស្របពេលជាមួយគ្នា យើងសង្កេតឃើញថា អត្រាស្ត្រីប្រើប្រាស់អ៊ីនធឺណិត ក៏មានកម្រិតខ្ពស់ដែរ (៥២%) ។ ម៉្យាងទៀតបើយើងពិនិត្យមើលនៅបណ្តាប្រទេសអឺរ៉ុបដែលជាប្រទេសឧស្សាហកម្មរីកចម្រើន ភាគរយស្ត្រីប្រើប្រាស់ ICT នៅមានចំនួនតិចជាងបុរស ២% (៧៧%ធៀបនឹង៧៩%) (EC, 2009) ។

លើសពីនេះទៀត ការសិក្សាស្រាវជ្រាវនេះ បានរកឃើញផងដែរថា អត្រានៃអ្នកទើបប្រើប្រាស់អ៊ីនធឺណិតនៅក្នុងរយៈពេល ៦ខែកន្លងទៅនេះ មានតែ ១០,២% ប៉ុណ្ណោះ ។ ប៉ុន្តែបើពិនិត្យមើលបម្រែបម្រួលនៃការប្រើប្រាស់អ៊ីនធឺណិតធៀបនឹងឆ្នាំមុនៗ បានអោយដឹងថា ការប្រើប្រាស់អ៊ីនធឺណិតមានការកើនឡើងរហូតដល់៨១% ។ ក្នុងន័យនេះ ចំនួនអ្នកទើបមកប្រើប្រាស់អ៊ីនធឺណិត មានការកើនឡើងតិចតួចខណៈអ្នកដែលធ្លាប់បានប្រើប្រាស់អ៊ីនធឺណិត បានបង្កើនការចូលទស្សនា គេហទំព័រកាន់តែច្រើនជាងមុន បើធៀបនឹងឆ្នាំមុន ។

### ចំណាត់ថ្នាក់នៃជំនាញប្រើប្រាស់ ICT តាមភេទ

បើតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានអោយដឹងថា ភាគរយនៃអ្នកប្រើប្រាស់កុំព្យូទ័រជាបុរសមានលក្ខណៈជំនាញ ច្រើនជាងស្ត្រី ២ដង (p<0,0៥) ។ លទ្ធផលនេះមានលក្ខណៈប្រហាក់ប្រហែលជាមួយនឹងលទ្ធផលដែលបានមកពីការស្រាវជ្រាវរបស់លោក(Financial Times, 2006)។

### គំនាប និងឧបសគ្គដែលរារាំងស្ត្រីពីការចូលរួមក្នុងផ្នែក ICT ក្នុងវិស័យអប់រំ និងការងារ

បណ្តាបញ្ហាដែលជាឧបសគ្គក្នុងការរាំងស្ទះស្ត្រីពីការចូលរួមផ្នែក ICT មាន៖ ៧០% យល់ថានិស្សិតភាគច្រើនដែលទើបបញ្ចប់ការសិក្សានៅមានបទពិសោធន៍តិចតួចនៅឡើយ ៦៦% យល់ថាស្ត្រីមានតួនាទីក្នុងគ្រួសារច្រើនជាងបុរស ៦០% យល់ថាគោលនយោបាយ និងការអនុវត្តគោលនយោបាយ ក៏ជាបញ្ហារាំងស្ទះមួយដែរ ៥៧% មានបញ្ហាខាងផ្នែកភាសា ៦៤% បណ្តាលមកពី

បញ្ហាការវិនិយោគរបស់គ្រួសារលើការអប់រំ ៥៣% យល់ថា ហេដ្ឋារចនាសម្ព័ន្ធ ICT នៅមានកម្រិត ៥២% យល់ថាតម្លៃអ៊ីនធឺណិតថ្លៃ ៤៥% បណ្តាលមកពីលក្ខណៈជីវសាស្ត្រ ៤០% យល់ថាបច្ចេកវិជ្ជាដើរលឿនពេក ៣១% យល់ថា បទដ្ឋានសង្គមនិងវប្បធម៌ និង២៦% យល់ថាស្ត្រីមិនត្រូវបានថៅហ្វាយនាយលើកទឹកចិត្តនោះទេក្នុងការចូលរួមផ្នែក ICT ។ បុគ្គលិកស្ថាប័នចំនួន ១៤% មិនយល់ស្របចំពោះមតិមួយទៀតដែលលើកឡើងថា ស្ត្រី និងបុរសមានឱកាសស្មើគ្នាសម្រាប់ការងារ ។ បើយើងពិនិត្យមើលទៅលើការសិក្សារបស់ Association for Progressive Communications (APC) ឆ្នាំ១៩៩៦ បានអោយដឹងថា ភាពលើសលប់នៃភាសាអង់គ្លេស និងកម្រិតនៃការប្រើប្រាស់ភាសាបរទេសដទៃទៀតមានចំនួនតិចនៅលើអ៊ីនធឺណិត បានផ្តល់ផលវិជ្ជមានមួយចំនួនទៅដល់ស្ត្រី និងក្រុមមនុស្សដែលប្រើប្រាស់ភាសាអង់គ្លេសជាភាសាកំណើត ដោយពួកគេមិនបាច់ចូលសិក្សា និងរៀនភាសាអន្តរជាតិផ្សេងៗ ប៉ុន្តែវាក៏បានប៉ះពាល់ដល់ប្រទេសផ្សេងៗនៅក្នុងតំបន់ដែលមិនប្រើប្រាស់ភាសាអង់គ្លេស ដូចជានៅតំបន់មជ្ឈិមបូព៌ា អាមេរិកឡាទីន និងបណ្តាប្រទេសអាហ្វ្រិកដែលប្រើប្រាស់ភាសាបារាំង ។

សមត្ថភាពរបស់ស្ត្រីក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា គឺត្រូវបានកំណត់ដោយបទដ្ឋានវប្បធម៌សង្គមដែលកំណត់ទៅលើអាកប្បកិរិយា និងចំណាប់អារម្មណ៍របស់ស្ត្រី ។ ដូចដែលបានពិភាក្សាពីដំបូង នៅក្នុងសង្គមដែលមានវប្បធម៌អភិរក្សនិយម ស្ត្រីគឺមិនត្រូវបានអនុញ្ញាតអោយទៅណាដោយមិនមានការគ្រប់គ្រងពីបុរសនោះទេ ។ ជាងនេះទៅទៀត ស្ត្រីប្រហែលជាមានអារម្មណ៍មិនមានផាសុកភាពនៅកន្លែងហាង Cafe internet ជាមួយនឹងចំនួនអតិថិជនបុរសដ៏លើសលុប ឬក៏ពេលស្ត្រីត្រូវការជំនួយពីបុគ្គលិកបុរសនោះទេ ។ បទដ្ឋានវប្បធម៌ មិនជំរុញលើកទឹកចិត្តអោយមានអន្តរទំនាក់ទំនងរវាងបុរស ហើយនិងស្ត្រីនៅខាងក្រៅគ្រួសារទេ ហើយស្ត្រីក៏មិនសូវមានទំនាក់ទំនងជាមួយបុរសដែរ ដូច្នេះពួកគេមានអារម្មណ៍មិនងាយស្រួលទេ ដោយសារតែមានការដាក់បែងចែកដាច់ដោយឡែករវាងសិស្សប្រុស និងសិស្សស្រីនៅក្នុងថ្នាក់ ដែលវាជាលក្ខណៈរួមនៅតំបន់មជ្ឈិមបូព៌ា (Hafkin, 2002) ។ តាមរបាយការណ៍របស់ធនាគារពិភពលោកក្នុងឆ្នាំ២០០៦ បានអោយដឹងថាស្ត្រី និងបុរសតែងតែមានឧបសគ្គផ្សេងៗគ្នាក្នុងការទទួលយកបាន ICT ។ ក្នុងសង្គមជាច្រើន បុរសក៏ដូចជាស្ត្រីការប្រើប្រាស់ ICT គឺវាមានទំនាក់ទំនងជាមួយនឹងទម្លាប់ វប្បធម៌ និងសាសនារបស់សង្គមនីមួយៗ៖

- វប្បធម៌ និងចរិតលក្ខណៈរបស់សង្គម តែងតែមិនអោយតម្លៃចំពោះស្ត្រីក្នុងការចូលរួមផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដូច្នេះហើយវាធ្វើអោយបរិមាណស្ត្រីចូលរួមផ្នែក ICT នៅមានដែនកំណត់នៅឡើយ ។
- ស្ត្រីតែងតែពឹងផ្អែកលើចំណូលរបស់បុរស ឬមិនមានលទ្ធភាពគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ ដូច្នេះវាជាបញ្ហាដែលធ្វើអោយស្ត្រីមានការលំបាកក្នុងការចាប់យកចំណេះវិជ្ជាផ្នែក ICT ។
- នៅប្រទេសមួយចំនួនស្ត្រីជួបការលំបាក ដោយសារពួកគេមិនត្រូវបានអនុញ្ញាតអោយនៅកន្លែងសាធារណៈជាមួយមនុស្សច្រើន ។
- ក្នុងសង្គមគ្រួសារភាគច្រើន ឪពុកម្តាយតែងតែជ្រើសរើសចំណាយលើការអប់រំកូនប្រុសច្រើនជាងកូនស្រី ។ ដូច្នេះដើម្បីកាត់បន្ថយគម្លាតយេនឌ័រលុះត្រាតែបញ្ហារើសអើងទាំងអស់នេះត្រូវបានគេកាត់បន្ថយ (World Bank, 2006) ។

### ការផ្តល់ភាពអង់អាចដល់ស្ត្រីតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

ទាំងអ្នកតំណាងស្ថាប័នលើស ៨៧% និងបុគ្គលិកធ្វើការនៅតាមស្ថាប័នផ្សេងៗលើសពី ៩២% បានយល់ស្របថា ស្ត្រីអាចទទួលបានការផ្តល់ភាពអង់អាចតាមរយៈការ

ប្រើប្រាស់ ICT ។ ទាំងអ្នកតំណាង ក៏ដូចជាបុគ្គលិកនៅតាមស្ថាប័នស្ទើរតែទាំងអស់ បានយល់ថាស្ថាប័ននានា គួរតែធ្វើសកម្មភាពអោយបានច្រើនថែមទៀតដើម្បីជំរុញអោយស្ត្រីចូលរួមក្នុងផ្នែក ICT ។ ទិន្នន័យខាងលើ បានបង្ហាញអោយដឹងថា ពួកគាត់មានការយល់ដឹងខ្ពស់ក្នុងការលើកកម្ពស់ស្ត្រីអោយចូលរួមក្នុងវិស័យ ICT ។ ផ្ទុយមកវិញពួកគាត់មួយចំនួនមិនយល់ស្របជាមួយនឹងប្រយោគដែលបានលើកឡើងថា ស្ត្រីទទួលបានផលប្រយោជន៍ ដូចបុរស ស្ត្រីមានសិទ្ធិដូចបុរសក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងស្ថាប័ន ហើយស្ត្រីមានឱកាសដូចបុរសក្នុងការទទួលបានការងារផ្នែកវិស័យ ICT ដោយសារលក្ខណៈជីវសាស្ត្រ បញ្ហាវប្បធម៌សង្គម និងឧបសគ្គផ្សេងៗទៀតនោះ ។ ជាទូទៅគេអាចនិយាយបានថា ពួកគាត់មានចំណេះដឹង និងយល់អំពីបញ្ហាក្នុងការលើកកម្ពស់ស្ត្រីអោយចូលរួមក្នុងផ្នែក ICT ក្នុងវិស័យការងារ ប៉ុន្តែការអនុវត្តជាក់ស្តែងរបស់ពួកគាត់នៅមានកម្រិតនៅឡើយ ។ ឃ្លាមួយចំនួន ដែលបង្ហាញពីភាពមិនសក្តិសមរបស់ស្ត្រីក្នុងការឈានទៅកាន់ការងារផ្នែក ICT ត្រូវបានរកឃើញផងដែរនៅក្នុងការសម្ភាសស៊ីជម្រៅជាមួយអ្នកដែលមានតួនាទីសំខាន់ក្នុងផ្នែក ICT របស់ស្ថាប័នដែលបានចូលរួមក្នុងការសម្ភាស៖ ស្ត្រីមិនសូវមានភាពសក្តិសមចំពោះវិស័យ ICT ដូចបុរស មុខវិជ្ជា ICT ជាមុខវិជ្ជាមួយដែលត្រូវការការគិត ស្ត្រីមិនមានកម្លាំងគ្រប់គ្រាន់ក្នុងការសិក្សាផ្នែក ICT ស្ត្រីមានពេលវេលាតិចតួចជាងបុរស និងស្ត្រីមិនសូវមានទេពកោសល្យលើវិស័យនេះ ។

### ទស្សនវិស័យនានា ទាក់ទងនឹងស្ត្រី និង ICT ក្នុងវិស័យការងារ និងវិស័យអប់រំ

ចំពោះទស្សនវិស័យរបស់ អ្នកឆ្លើយតបសម្ភាសភាគច្រើន (មានលើសពី៨៥%) យល់ស្របចំពោះការណែនាំស្ត្រីដទៃទៀតអោយចូលរៀន និងធ្វើការក្នុងវិស័យ ICT ព្រោះ ICT មានសារប្រយោជន៍សម្រាប់សង្គមរបស់យើង និងអភិវឌ្ឍខ្លួនដើម្បីអោយដើរទាន់បច្ចេកវិទ្យាថ្មីៗ ។ ក្នុងនោះដែរចំពោះការរៀបចំខ្លួន ដើម្បីធ្វើអោយទាន់សម័យបច្ចេកវិទ្យា ICT នោះ ពួកគាត់បានបញ្ជាក់ថា ពួកគាត់ត្រូវការស្រាវជ្រាវអ្វីដែលថ្មីៗស្តីអំពី ICT ស្រាវជ្រាវតាមរយៈទស្សនាវដ្តី អ៊ីនធឺណិត ទូរទស្សន៍ សៀវភៅថ្មីៗ ត្រូវការបណ្តុះបណ្តាលថែមទៀតចំពោះបច្ចេកវិទ្យាដែលទើបតែមានថ្មីៗក្នុងនោះ បញ្ហាភាសាក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ ។

តាមការសន្និដ្ឋានមួយរបស់សហគមន៍អឺរ៉ុប ឆ្នាំ ២០០៩ បានអោយដឹងថាផ្នែក ICT កំពុងតែធ្វើអោយបាត់ស្រមោលរបស់ស្ត្រីក្នុងពេលដែលការផ្តល់ប្រាក់ឈ្នួលមិនស្មើគ្នា ។ តាមរយៈការថ្លែងសុន្ទរកថាក្នុងទិវារំលឹកខួបទី ១០០ឆ្នាំនៃថ្ងៃសិទ្ធិនារីអន្តរជាតិ បានអោយដឹងថា តំបន់អឺរ៉ុបគួរតែមានសកម្មភាពថែមទៀតអោយបានឆាប់រហ័សក្នុងការដោះស្រាយភាពមិនស្មើគ្នាចំពោះការទទួលបានប្រាក់កម្រៃរវាងស្ត្រី និងបុរស ជាពិសេសក្នុងផ្នែក ICT ។ ស្ត្រីធ្វើការក្នុងផ្នែក IT គឺទទួលបានប្រាក់កម្រៃតែ ៨២% ធៀបជាមួយនឹងបុរស ។ នៅប្រទេសអង់គ្លេស ស្ថានភាពនេះវាមានលក្ខណៈធ្ងន់ធ្ងរជាងនេះទៅទៀត គឺស្ត្រីទទួលបានប្រាក់កម្រៃតែ ៧៩% បើធៀបជាមួយបុរស (EC, 2009) ។ ជាងនេះទៅទៀត គម្លាតនៃប្រាក់កម្រៃពលកម្ម នៅបណ្តាប្រទេសអឺរ៉ុបនៅតែបន្តកើតមានឡើង ។ នៅពេលដែលអាយុមានការកើនឡើង គម្លាតនៃប្រាក់ឈ្នួលរវាងបុរស និងស្ត្រីកាន់តែមានទំហំធំ ។ តួលេខបានបង្ហាញអោយឃើញថា អាយុចាប់ពី១៥ រហូតដល់ ៣៥ឆ្នាំ គម្លាតនៃប្រាក់ឈ្នួលស្មើនឹង ១៧% ៤៥ រហូតដល់៥៤ឆ្នាំ ស្មើ ៣៨% និងពី ៥៥ ទៅដល់ ៦៤ឆ្នាំ មាន ៣៧% ។ ក្នុងនោះដែរ ការសិក្សាក៏បានបង្ហាញអោយឃើញថា ជាទូទៅស្ត្រីនៅពេលកំពុងរៀននៅមធ្យមសិក្សា ពួកគាត់ហាក់ដូចជាពូកែជាងបុរស ចំពោះមុខវិជ្ជាវិទ្យាសាស្ត្រ ប៉ុន្តែគួរអោយកត់សំគាល់ថា ចំនួនអត្រាស្ត្រីចាប់យកជំនាញខាងផ្នែកវិទ្យាសាស្ត្រនៅមហាវិទ្យាល័យ មានចំនួនតិចជាងបុរសទៅវិញ ។

# ៥. ការពិភាក្សា

បើតាមការសិក្សារបស់ Gras, Joyce, & Debry (2009) លើប្រធានបទ " ហេតុអ្វីបានជាស្ត្រីមិនមានចំណាប់អារម្មណ៍ជាមួយ ICT " នៅឆ្នាំ២០០៧ បានរកឃើញថាក្នុងចំណោមនិស្សិតផ្នែក ICT ដែលបានបញ្ចប់ការសិក្សា មានបុរសរហូតដល់ ៧៤% ក្នុងនោះដែរមាន ២៧,៨% មានតួនាទីជាប្រធានគ្រប់គ្រងផ្នែក ICT ជាស្ត្រី ហើយក្នុងនោះស្ត្រីដែលមានសញ្ញាប័ត្រផ្នែកព័ត៌មានវិទ្យាផ្នែកទន់មានតែ ៩,៦% ប៉ុណ្ណោះ ។

ចំពោះការសិក្សាផ្សេងមួយទៀត បង្ហាញថានៅប្រទេសអ៊ីតាលី និស្សិតមានបំណងជ្រើសរើសមុខវិជ្ជាផ្នែក ICT មានត្រឹមតែ ១៥%ប៉ុណ្ណោះ បើធៀបនឹងបុរសមានចំនួន ៣០% ។ ឯកសារដដែលបាននិយាយថា នៅប្រទេសហុល្លង់ ការសិក្សានិងការងារផ្នែក ICT មិនបានធ្វើអោយស្ត្រីមានចំណាប់អារម្មណ៍ទេក្នុងនោះមានរហូតដល់ ៥៤% ហើយជួនពេលខ្លះពួកគាត់បានឈប់ធ្វើការងារនេះ បន្ទាប់ពីធ្វើការងារនេះបានមួយរយៈ ឬក៏ឈប់រៀនបន្តតែម្តង (OECD, 2006) ។

សរុបសេចក្តីមកយើងអាចវាយតម្លៃបានថា ស្ថាប័ននានានៅក្នុងការសិក្សាស្រាវជ្រាវនេះ នៅមានមតិមិនយល់ស្របទស្សនៈរបស់ពួកគាត់ចំពោះស្ត្រីអោយចូលរួមក្នុងការសិក្សាផ្នែក ICT ក៏ដូចជាក្នុងវិស័យការងារ គឺនៅមានមតិមិនយល់ស្របជាច្រើន ដូចដែលបានលើកឡើងនៅខាងដើម ។ ដូច្នេះសរុបមក យើងឃើញថា ទស្សនវិស័យរបស់ពួកគាត់មានលក្ខណៈសមស្របក្នុងការចូលរួមដោយប្រយោល ដើម្បីធ្វើយ៉ាងណាអោយស្ត្រីចូលរួមផ្នែក ICT មានការកើនឡើង ។

## ៦. សរុបលទ្ធផល

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំដែលបានបង្ហាញនៅក្នុងលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះគឺយើងបានសរុបលទ្ធផលសិក្សាស្រាវជ្រាវស្តីអំពីស្ត្រីក្នុងវិស័យ ICT ដូចខាងក្រោមៈ

១. ក្នុងចំណោមមុខវិជ្ជា ICT មុខវិជ្ជាវិទ្យាសាស្ត្រកុំព្យូទ័រ ឬព័ត៌មានវិទ្យា មាននិស្សិតសិក្សាច្រើនជាងគេ ប៉ុន្តែបើគិតពីសមាមាត្រនៃស្ត្រីវិញ មុខវិជ្ជាប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ មានចំនួនច្រើនជាងគេ ។ គិតចាប់ពីឆ្នាំ២០០៥-២០០៩ ស្ត្រីសិក្សាក្នុងផ្នែក ICT មានតែ ១២,៤%ប៉ុណ្ណោះ ប៉ុន្តែបើធៀបជាមួយអត្រាស្ត្រីដែលកំពុងសិក្សាចាប់ពីឆ្នាំទី១ ដល់ឆ្នាំទី៤ នៃឆ្នាំសិក្សា២០០៩-២០១០ ស្ត្រីមានធ្លាក់ចុះមកត្រឹមតែ ៩,១% ។

២. ក្នុងកម្រិតក្រោយឧត្តមសិក្សា អត្រាស្ត្រីមានការថយចុះយ៉ាងខ្លាំងពី ៣៥,៣%ក្នុងឆ្នាំ២០០៧-២០០៨ មកត្រឹមតែ ៦,២% ក្នុងឆ្នាំ២០០៨-២០០៩ ។ សមាមាត្រស្ត្រីបន្តធ្លាក់ចុះ មកត្រឹម ៥,៤% ក្នុងឆ្នាំទី២ និងបន្តធ្លាក់ចុះមកត្រឹម ៥,២% ក្នុងឆ្នាំសិក្សា២០០៩-២០១០ ។

៣. តម្រូវការស្ត្រី ក្នុងការងារ ICT នៅតាមស្ថាប័នដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ក្រសួងនានាមានតម្រូវការបុគ្គលិកច្រើនជាងគេ រហូតដល់ ៥៣% ដែលតម្រូវការបុគ្គលិកមានចំណេះដឹងផ្នែក ICT ជាមធ្យម ១០នាក់ និងស្រី៦នាក់ (៦០%) ។ ស្ថាប័នអប់រំ មានតម្រូវការ ៣៥% តម្រូវការបុគ្គលិកដែលមានចំណេះដឹងផ្នែក ICT ជាមធ្យម ៥នាក់ និងស្រី២នាក់ (៤០%) ។ អង្គការសង្គមស៊ីវិល ដែលត្រូវការប្រហែលពាក់កណ្តាលនៃតម្រូវការរបស់ក្រសួងនានា (២៥%) មានតម្រូវការបុគ្គលិកដែលមានចំណេះដឹងផ្នែក ICT ជាមធ្យម ២នាក់ និងស្រី១នាក់ (៥០%) និងផ្នែកឯកជន (ISP និងហាងអ៊ីនធឺណិត) ១១,៧% ដែលតម្រូវការបុគ្គលិកមានចំណេះដឹងផ្នែក ICT ជាមធ្យម២នាក់ និងស្រី១នាក់ (៥០%) ។

៤. តាមរយៈការផ្សព្វផ្សាយនៅក្នុងគេហទំព័រការងារពីរ (បងធំ និងពេលព្រឹក) តម្រូវការជ្រើសរើសបុគ្គលិកដែលធ្វើការក្នុងការងារកម្រិតខ្ពស់ និងកម្រិតកណ្តាល ចាំបាច់ត្រូវមានជំនាញ ICT តែមិនចាំបាច់មានជំនាញខ្ពស់ទេ (ការងារកណ្តាលត្រូវការជំនាញ ICT ខ្ពស់ ៨,៣% និងការងារកម្រិតខ្ពស់ ត្រូវការជំនាញ ICT ខ្ពស់ចំនួន ៥,៧%) ។

៥. ស្ត្រី និងបុរស ដែលមានសញ្ញាប័ត្រ ICT មានការលំបាកខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះក្នុងការស្វែងរកការងារ ICT ធៀបជាមួយនឹងអ្នកមិនមានសញ្ញាប័ត្រ ICT (ស្ត្រី ៤៦,២% ធៀបនឹងបុរស៤៣,៨% ) ។

៦. ក្នុងចំណោមបុគ្គលិកដែលចេះប្រើប្រាស់កុំព្យូទ័រ និងអ៊ីនធឺណិត មានស្ត្រីតែ ២០,៤% ប៉ុណ្ណោះ ដែលចេះប្រើប្រាស់កុំព្យូទ័រ និងអ៊ីនធឺណិត ដែលក្នុងអង្គការសង្គមស៊ីវិល មានច្រើនជាងគេ គឺស្មើនឹង ៤៦,៣% ក្រសួងនានា ៣៦,៣% ផ្នែកឯកជន (ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត និងហាងអ៊ីនធឺណិត) ២៨,៦% និងគ្រឹះស្ថានអប់រំឧត្តមសិក្សាមាន ២៧,៨% ។

៧. ស្ត្រី ដែលបានប្រើប្រាស់កុំព្យូទ័រជាអ្នកជំនាញមានចំនួន ៦,៩% តិចជាងបុរសប្រហែល ៥ដង (៣៣,៦% ។ អ្នកជំនាញកុំព្យូទ័រ ក្នុងកម្រិតការងារទាប មាន ២,៩% កម្រិតកណ្តាលមាន ៨៤,៥% និងកម្រិតខ្ពស់មាន ១២,៦% ។

៨. គំនាប និងការរាំងស្ទះស្ត្រីក្នុងការចូលរួមផ្នែក ICT មានបញ្ហាសំខាន់ៗមួយចំនួន ដែលបានមកពីការសិក្សាស្រាវជ្រាវ បានលើកឡើងអំពីគំនាបដែលរាំងស្ទះចំពោះស្ត្រីចូលរួមក្នុងវិស័យ ICT រួមមាន៖

- ៧០% ឆ្លើយថា និស្សិតបានបញ្ចប់ការសិក្សានៅខ្វះបទពិសោធន៍
- ៦៦% ឆ្លើយថា ស្ត្រីត្រូវមានភាពទទួលខុសត្រូវក្នុងគ្រួសារច្រើនជាងបុរស
- ៦៤% យល់ថា អាណាព្យាបាលភាគច្រើនអោយកូនប្រុស រៀនបានច្រើន និងខ្ពង់ខ្ពស់ជាងស្ត្រី
- ៦០%យល់ថាគោលនយោបាយ និងការអនុវត្តគោលនយោបាយ ក៏ជាបញ្ហារាំងស្ទះមួយដែរ
- ៥៧% ពួកគាត់យល់ថាភាសា គឺជាបញ្ហារាំងស្ទះមួយដែរ
- ៥៣% យល់ថាហេដ្ឋារចនាសម្ព័ន្ធ ICT នៅមានកម្រិត
- ៥២% បានអោយដឹងថា តម្លៃអ៊ីនធឺណិត ថ្លៃ
- ៤៥% បណ្តាលមកពីលក្ខណៈជីវសាស្ត្រ
- ៤០% យល់ថា បច្ចេកវិទ្យាដើរលឿនពេក
- ៣១% យល់ថា បទដ្ឋានសង្គម និងវប្បធម៌
- ២៦% យល់ថា ស្ត្រីមិនត្រូវបានចៅហ្វាយនាយលើកទឹកចិត្តនោះទេក្នុងការចូលរួមផ្នែក ICT ។

៩. អ្នកតំណាងស្ថាប័ន ៨៧% និងបុគ្គលិក ៩២% យល់ឃើញថា ស្ត្រីអាចត្រូវបានគេផ្តល់ភាពអង់អាចតាមរយៈការប្រើប្រាស់ ICT ។

១០. ក្រុមគោលដៅផ្សេងគ្នានៃអ្នកដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ មានទស្សនវិស័យវិជ្ជមាន ច្រើនជាងអវិជ្ជមាន ចំពោះស្ត្រីក្នុងការឈានទៅចូលរួមវិស័យ ICT ទាំងផ្នែកការអប់រំ និងការងារ ដោយបានបញ្ចេញទស្សនៈថា៖

ទស្សនៈសុទិដ្ឋិនិយម

- ស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលយកចំណេះវិជ្ជា ICT
- មានការលើកទឹកចិត្តចំពោះស្ត្រីក្នុងវិស័យ ICT
- ការសិក្សាផ្នែកនេះមានសារសំខាន់ក្នុងការស្វែងរកការងារចំពោះស្ត្រី
- ស្ត្រីមានចំណេះដឹងផ្នែក ICT គឺអាចចូលរួមចំណែកក្នុងការកសាងសង្គមជាតិដែរ
- ស្ត្រីមានភាពអំណត់អត់ធន់ក្នុងការងារបានល្អជាងបុរស
- ស្ទើរតែគ្រប់ការងារទាំងអស់ត្រូវការស្ត្រីអោយមានចំណេះដឹងផ្នែក ICT
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា កំពុងតែមានការរីកចម្រើនក្នុងប្រទេសកម្ពុជា
- នឹងមានក្រុមហ៊ុន និងស្ថាប័នកាន់តែច្រើនចូលមកវិនិយោគក្នុងផ្នែកនេះនាពេលអនាគត
- មានកម្មវិធីមួយចំនួនជាភាសាខ្មែរហើយនៅក្នុងប្រទេសកម្ពុជា
- ទូរសព្ទអាចភ្ជាប់អ៊ីនធឺណិតបាន
- ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានឹងរីកចម្រើនដល់ជនបទ
- មនុស្សប្រើប្រាស់ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាដើម្បីសិក្សា នឹងមានកាន់តែច្រើន
- តម្លៃសេវាកម្មអ៊ីនធឺណិតនឹងធ្លាក់ចុះ
- សេវាកម្មអ៊ីនធឺណិតឥតគិតថ្លៃនៅទី

សាធារណៈអាចនឹងមានផ្តល់ជូននាពេល អនាគត

ទស្សនៈទុទិដ្ឋិនិយម

- មានស្ត្រីចូលរួមសិក្សាផ្នែកនេះតិចតួច ណាស់ ដែលទាមទារអោយមានការ លើកទឹកចិត្តបន្ថែមទៀត
- ភាពក្រីក្រក៏ជាកត្តាដែលរាំងស្ទះមួយដែរ
- មុខវិជ្ជា ICT មិនសមស្របឡើយចំពោះស្ត្រី ភេទ
- ការអភិវឌ្ឍផ្នែក ICT មានតែនៅទីក្រុងតែ ប៉ុណ្ណោះ
- ការរីកចម្រើននៃ ICT ក្នុងប្រទេសកម្ពុជា មានភាពយឺតយ៉ាវ និងគុណភាពនៅមាន កម្រិត

១១. អ្នកតំណាងស្ថាប័ន និងបុគ្គលិក យល់ថា រដ្ឋាភិបាល និងសង្គមស៊ីវិល គួរតែធ្វើ សកម្មភាពអោយបានច្រើនថែមទៀត ដើម្បី ជំរុញអោយមានស្ត្រី ចូលរួមក្នុងផ្នែក ICT ។ ស្របជាមួយគ្នានេះដែរ និស្សិត មានសំណូមពរ ដូចតទៅៈ

រដ្ឋាភិបាលគួរ

- បញ្ចុះតម្លៃអ៊ីនធឺណិត និងគួរតែមិនយកថ្លៃ សេវានៃការប្រើប្រាស់អ៊ីនធឺណិតនៅកន្លែង សាធារណៈមួយចំនួន
- គួរតែបញ្ជ្រាបមុខវិជ្ជាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាតាំងពីបឋមសិក្សា
- គួរបង្កើនការយកចិត្តទុកដាក់ដល់តំបន់ដាច់ ស្រយាល ជាជាងផ្តោតតែទៅលើទីក្រុង
- ផ្តល់ការលើកទឹកចិត្តចំពោះការរកឃើញថ្មីៗ
- ផ្តល់ជាអាហារូបករណ៍អោយបានច្រើន
- បង្កើតជាសិក្ខាសាលា អំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាអោយបានច្រើន
- គួរតែផ្តោតលើគុណភាពជាជាងបរិមាណ
- ផ្តល់ឱកាសការងារដល់អ្នកដែលមាន ជំនាញបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- បញ្ចុះតម្លៃគ្រប់សម្ភារៈដែលទាក់ទងនឹង បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- បង្កើតច្បាប់អ៊ីនធឺណិត
- ធ្វើការសិក្សាស្រាវជ្រាវអោយបានច្រើនពីផ្នែក បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ផ្តល់ប្រាក់ខែ ដល់បុគ្គលិកអោយបាន គ្រប់គ្រាន់
- បង្កើតការបង្ហាត់បង្រៀនអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាតាមទូរទស្សន៍

អង្គការសង្គមស៊ីវិលគួរ

- ផ្តល់ជាអាហារូបករណ៍
- ជួយបណ្តុះបណ្តាលដល់ប្រជាជនដែលរស់ នៅជនបទ
- បង្កើតជាសិក្ខាសាលាដើម្បីផ្សព្វផ្សាយ ពីសារសំខាន់នៃការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ផ្តល់ឱកាសការងារដល់អ្នកដែលសិក្សាខាង ផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ផ្តល់ឱកាសអោយបានចុះកម្មសិក្សា
- រៀបចំការប្រកួតប្រជែងផ្នែកព័ត៌មានវិទ្យា
- ផ្តល់ការលើកទឹកចិត្តចំពោះការរកឃើញថ្មីៗ
- ជួយបង្កើតកម្មវិធីសិក្សា ផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- ជួយផ្តល់ជាឯកសារបន្ថែមទាក់ទងនឹងផ្នែក បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

# ៧. អនុសាសន៍

- រដ្ឋាភិបាល គួរបន្តជំរុញ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ សម្រាប់ផ្នែកICT អោយបានគ្រប់គ្រាន់នៅទូទាំងប្រទេស ។
- បើអាចធ្វើបាន រដ្ឋាភិបាល គួរបញ្ចូលកម្មវិធីសិក្សា ICT តាំងពីថ្នាក់វិទ្យាល័យ នៅជនបទ និងនៅទីក្រុង ។
- បន្តអនុវត្ត គោលនយោបាយ ជំរុញ និងលើកទឹកចិត្តអោយមានស្ត្រីកាន់តែច្រើនថែមទៀត បានចូលសិក្សាក្នុងមុខវិជ្ជា ICT ដោយផ្តល់ជាអាហារូបករណ៍ ការបញ្ចុះតម្លៃសិក្សា និងលើកទឹកចិត្តគ្រប់បែបយ៉ាងដល់និស្សិតស្រី ។
- ក្រសួង និងស្ថាប័ននានាទាំងផ្នែកសាធារណៈ និងឯកជន រួមទាំងសហគ្រាស និងផ្នែកឯកជន គួរផ្តល់ឱកាសដល់និស្សិតដែលទើបបញ្ចប់ការសិក្សាពិសេសនិស្សិតស្រី អោយបានចូលបម្រើការងារសាកល្បង និងផ្តល់ឱកាសការងារ ។
- រដ្ឋាភិបាលគួរ លើកទឹកចិត្តបង្កើតអោយមានកម្មវិធីកុំព្យូទ័រជាភាសាខ្មែរ អោយបានកាន់តែច្រើន ។
- បើអាចធ្វើទៅបាន សូមអោយមានការសិក្សាស្រាវជ្រាវថ្មីបន្ថែមទៀត ស្តីអំពីបញ្ហានេះអោយបានទូលំទូលាយទូទាំងប្រទេស ក៏ដូចជាធ្វើការសិក្សាអោយបានស៊ីជម្រៅបន្ថែមទៀត។

# ឯកសារយោង

អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន. (២០០៩). គោលនយោបាយជាតិស្តីពី បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន សំណើគោលនយោបាយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា. ភ្នំពេញ.

Bhatia, S. (2001). e-ASEAN REAdiness Assessment. Singapore.

Cynthia C.et al. (1993). Gender and technology in the making. London, Sage.

Daniel,B.(1973) The coming of the post-industrial society: a venture in social forecasting. Harmondsworth,Penguin.

European Commission. (2009). Women in ICT; available from www.ec.europa.eu/itgirls

European Commission(2006).Women and Science. Statistics and Indicators. available from www.ec.europa.eu/itgirls

EUROSTAT Yearbook (2009). Science, technology, innovation and entrepreneurship: 2009, the year of creativity and innovation.

Financial Times (2006) . Where are all the women in IT?., 8 November.

Global Networking for Change: Experiences from the Association for Progressive Communications (APC) Women's Program. http://www.community.web.net/apcwomen.

Habtu, R. (2003). Information Technology Workers. Perspectives on Labour and Income, Vol. 4, nº7, July, Statistics Canada. Available at: http://www.statcan.ca/english/freepub/75-001-XIE/75-001-XIE2003107.pdf

Hafkin, N. (2001). Are ICTs Gender Neutral? A Gender Analysis of Six Case Studies of Multi-Donor ICT projects. http://www.un-instraw.org/en/docs/gender_and_ict/Hafkin.pdf

Huyer S. et al. (2005). Women in the Information Society, in Sciadas (ed.) (2005) From the Digital Divide to Digital Opportunities: Measuring Infostates for Development. Orbicom. Montreal (Quebec), Canada.

ILO (2008), Global Employment Trends. ILO, Geneva.

Kolev and Sirven (2007). Gender Disparities in Africa's Labour Markets: a Cross-Country Comparison Using Standardized Survey Data. Study prepared as part of a joint research project by the French Development Agency, Paris, and the World Bank, Washington D.C.

McGregor, Elizabeth and Harding. (1996). Science by whom? Paris.

OECD (2006). New Millennium Learners: Challenging our views on ICT and learning, OECD Center for Educational Research and Innovation (CERI)

background paper. Reference EDU/CERI/CD/RD(2006)3.

OECD (2005). Science, Technology and Industry Scoreboard 2005, OECD, Paris.

OECD (2004b). Babies and bosses, reconciling work and family life, Volume 3, New Zealand, Portugal and Switzerland, OECD, Paris

Orbicom (2005). From the digital divide to digital opportunities, measuring infostates for development. Available at: http://www.orbicom.ca/media/projets/ddi2005/index_ict_opp.pdf

Papastergiou, M., Are Computer Science and Information Technology still masculine fields? High school students' perceptions and career choices. Computers & Education, 51 (2) (September 2008): 594-608.

Porat, Marc Uri, 'The information economy. Vol. I. Definition and measurement'. Washington, DC, US

Department of Commerce, 1984.

Stamp, P., 'Gender, technology and power'. Ottawa, IDRC, 1990.

Statistics Canada (2005). Women in Canada, A Gender-based Statistical Report, Fifth Edition. Available at: http://www.statcan.ca/english/freepub/89-503-XIE/0010589-503-XIE.pdf

Steeves, H. Leslie, 'Development communication as marketing, collective resistance, and spiritua

awakening: a feminist critique'. In: William B. Gudykunst and Bella Mody (eds), Handbook of international and intercultural communication. London, Sage, 2002, pp. 519-536.

UNDP. (2001). Human Development Report. New York:United Nations.

UNDP. (2002). Human Development Report. New York:United Nations.

UNESCAP (UNITED NATIONS ECONOMIC AND SOCIAL COMMISSION FOR ASIA AND THE PACIFIC). (2009). "RECASTING THE BEIJING PLATFORM FOR ACTION THROUGH THE INFORMATION SOCIETY LENS"

UNESCAP (United Nations Economic and Social Commission for Asia and the Pacific) (2007). "Economic and Social Survey of Asia and the Pacific 2007 - Surging Ahead in Uncertain Times", UNESCAP, United Nations, New York.

UNITED NATION. (2010). Beijing and its Follow-up. Retrieved November 12, 2010, from Division for the Advancement of Women Department of Economic and Social Affairs: http://www.un.org/womenwatch/daw/beijing/index.html

US Department of Labor (1999). Futurework-Trends and Challenges for Work in the 21st Century. Quoted in EnGauge,"21st Century Skills," North Central Regional Educational Laboratory; available from http://www.ncrel.org/engauge/skills/21skills.htm; accessed 31 May 2002.

World Bank (1998). The World Development Report 1998/99. Quoted in Blurton, C., New Directions of ICT-Use in Education.

World Bank (2000). "The Gender Imbalances in the Export Oriented Garment Industry in Bangladesh" Gender and Development Woking Paper Series, No. 12, prepared by Pratima Paul-Majumder and Anware Begum, Poverty Reduction and Economic Management (PREM) Network, World Bank, Washington D.C.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ កម្រងសំណួរសម្រាប់អ្នកតំណាងស្ថាប័ន

### I. អំពីក្រសួង

០០១. ឈ្មោះរបស់ក្រសួង..................................................................................................................................

០០២. នៅក្នុងឆ្នាំ២០១០ ក្រសួងរបស់លោកអ្នកមាន

ការកំណត់៖

- តំណែងទាបៈ គឺជាអ្នកដែលធ្វើការមិនមានជំនាញ (ប្រើកំលាំងបាយ) ដូចជាអ្នកបោសសំអាត ឬអ្នកយាម
- តំណែងកណ្តាលៈ គឺជាអ្នកធ្វើការដោយប្រើកំលាំងប្រាជ្ញា តែមិនស្ថិតក្នុងតំណែងអ្នកសម្រេចចិត្ត ដូចជាអ្នកធ្វើការក្នុងការិយាល័យ បុគ្គលិកបង្រៀន
- តំណែងខ្ពស់ៈ គឺជាអ្នកធ្វើការក្នុងតំណែងអាចធ្វើការសម្រេចចិត្តបានដូចជា អ្នកគ្រប់គ្រង ប្រធាន ឬអនុប្រធានដេប៉ាតឺម៉ង់

1 ☐ បុគ្គលិកសរុប.................................................................................................................នាក់
2 ☐ បុគ្គលិកស្រីសរុប.............................................................................................................នាក់
3 ☐ ចំនួនបុគ្គលិកស្ត្រីស្ថិតនៅក្នុងតំណែងទាប................................................................................នាក់
4 ☐ ចំនួនបុគ្គលិកស្ត្រីស្ថិតនៅក្នុងតំណែងកណ្តាល............................................................................នាក់
5 ☐ ចំនួនបុគ្គលិកស្ត្រីស្ថិតនៅក្នុងតំណែងខ្ពស់.................................................................................នាក់
6 ☐ ចំនួនបុគ្គលិកដែលចេះប្រើប្រាស់កុំព្យូទ័រ/អ៊ីនធឺណិត.....................................................................នាក់
7 ☐ ចំនួនបុគ្គលិកស្ត្រីដែលចេះប្រើប្រាស់កុំព្យូទ័រ/អ៊ីនធឺណិត................................................................នាក់
8 ☐ ចំនួនវគ្គបណ្តុះបណ្តាលICT ដែលផ្តល់ជូនដល់បុគ្គលិកទាំងអស់ក្នុងរយៈពេល១២ខែកន្លងទៅ......................វគ្គ
9 ☐ ចំនួនបុគ្គលិកស្ត្រីដែលដែលបានចូលរួមវគ្គបណ្តុះបណ្តាល ស្ត្រី និង ICT...............................................នាក់

### II. បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា សម្រាប់ស្ត្រី

#### A. ស្ត្រី នៅកន្លែងការងារ

០០៣. តើស្ថាប័នរបស់លោកអ្នកកំពុងតែស្វែងរកបុគ្គលិកដែលមានចំណេះដឹងផ្នែក ICT ទេ?

1 ☐ បាទ/ចាស     2 ☐ មិនត្រូវការ

☐ គ្មានយោបល់

០០៣.A. បើត្រូវការ ត្រូវការប៉ុន្មាននាក់ .................................. ស្រីប៉ុន្មាននាក់ .............................................

០០៤. ប្រៀបធៀបរវាងបុរស និងស្ត្រីដែលមានឋានៈ គុណសម្បត្តិ និងបទពិសោធ ដូចគ្នា ត្រូវបានគេផ្តល់អោយមានការទទួលខុសត្រូវតិចជាង បុរស នៅក្នុងស្ថាប័នរបស់លោកអ្នក

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០០៥. ប្រៀបធៀបរវាងបុរស និងស្ត្រីដែលមានឋានៈ គុណសម្បត្តិ និងបទពិសោធ ដូចគ្នា ស្ត្រីទទួលបានផលប្រយោជន៍(ប្រាក់ខែ ប្រាក់បន្ថែម គ្រឿងលើកទឹកចិត្ត និងការលើកទឹកចិត្ត)ដូចបុរសនៅក្នុងស្ថាប័នរបស់លោកអ្នក

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

005.A តើលោកអ្នកអាចផ្តល់ព័ត៌មានលំអិតមួយចំនួន ខ្លះបានទេ ?..............................................................................

.......................................................................................................................................................

.......................................................................................................................................................

០០៦. ប្រៀបធៀបរវាងបុរស និងស្ត្រីដែលមានឋានៈ គុណសម្បត្តិ និងបទពិសោធន៍ដូចគ្នា ស្ត្រីមានសិទ្ធិច្រើនជាង ជាងបុរសក្នុងការធ្វើការសម្រេចចិត្ត នៅក្នុងស្ថាប័នរបស់លោកអ្នក

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០០៦.A. សូមលោកអ្នកធ្វើអត្ថាធិប្បាយបន្ថែមលើអំណោះអំណាងខាងលើនេះ ?..............................................................

.......................................................................................................................................................

០០៧. ប្រៀបធៀបរវាងបុរស និងស្ត្រីដែលមានឋានៈ គុណសម្បត្តិ និងបទពិសោធន៍ ដូចគ្នា បុរសធ្វើការផ្នែក ICT បានល្អជាងស្ត្រី នៅក្នុងស្ថាប័នរបស់លោកអ្នក

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០០៨. ការងារ ICT មានភាពសមស្របចំពោះបុរសច្រើនជាងស្ត្រី

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០០៨.A មូលហេតុអ្វី?..............................................................................................................................

០០៩. នៅក្នុងស្ថាប័នរបស់លោកអ្នក ស្ត្រីមានឱកាសតិចតួច ក្នុងការទទួលបានការងារក្នុងវិស័យ ICT ដោយសារ លក្ខណៈជីវសាស្ត្រ បញ្ហាវប្បធម៌សង្គម និងឧបសគ្គផ្សេងៗទៀត

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០០៩.A. តើលោកអ្នកអាចប្រាប់យើងខ្ញុំអំពីអ្វី ដែលបានបានឃើញទេ?..............................................................

..............................................................................................................................................

***B. គោលនយោបាយស្ថាប័ន ដើម្បីលើកកម្ពស់ស្ត្រី***

០១០. ស្ថាប័នរបស់លោកអ្នក បានជម្រុញ ឬមានគោលនយោបាយដើម្បីជម្រុញ អោយបុគ្គលិកស្ត្រីធ្វើការកសាងសមត្ថភាព លើផ្នែក ICT

1 ☐ មាន 2 ☐ ត្រៀមអោយមាន 3 ☐ មិនមាន

០១០. A បើមានតើនេះជាគោលនយោបាយអ្វី?....................................................................................................

..............................................................................................................................................

..............................................................................................................................................

តើលោកអ្នកបានធ្វើយ៉ាងដូចម្តេចក្នុងការជម្រុញបុគ្គលិកស្ត្រី អោយ ធ្វើការកសាងសម្ថភាពផ្នែក ICT ?.........................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

០១១. តើស្ថាប័នរបស់លោកអ្នក បានផ្តល់វិភាគទានអ្វីខ្លះ ដើម្បីកសាងសមត្ថភាពរបស់ស្ត្រី (ពេលវេលា ថវិកា ការលើកទឹកចិត្ត)?...........................................................................................................................

..............................................................................................................................................

..............................................................................................................................................

០១២. តើលោកអ្នកមានគំនិតយ៉ាងដូចម្តេចចំពោះបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា របស់ស្ត្រីនៅក្នុងវិស័យការងារ?............
...........................................................................................................................................................
...........................................................................................................................................................
...........................................................................................................................................................

០១៣. តើលោកអ្នកមានគំនិតយ៉ាងដូចម្តេច ចំពោះបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា របស់ស្ត្រីនៅក្នុងវិស័យអប់រំ?...............
...........................................................................................................................................................
...........................................................................................................................................................

សូមលោកអ្នកបញ្ជាក់ពីកម្រិតនៃការយល់ស្របលើប្រយោគ ខាងក្រោមនេះ៖

០១៤. ស្ត្រី អាចត្រូវបានគេផ្តល់ភាពអង់អាច តាមរយៈការប្រើប្រាស់ ICT (កុំព្យូទ័រ និងអ៊ីនធឺណិត)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០១៥. រដ្ឋាភិបាល អង្គការ និងផ្នែកឯកជន គួរតែធ្វើសកម្មភាពអោយបានច្រើនថែមទៀត ក្នុងការធ្វើអោយស្ថានភាពស្ត្រីក្នុងវិស័យអប់រំ និងការងារ មានភាពប្រសើរឡើង

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០១៦. តើលោកអ្នកមានអ្វីចង់បន្ថែម ឬចង់និយាយប្រាប់ខ្ញុំដែរឬទេ?...........................................................................
...........................................................................................................................................................
...........................................................................................................................................................
......

**សូមអរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក!**

ភ្នំពេញថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១០

រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី និងអង្គការវិទ្យាស្ថានបើកទូលាយ

ឧបសម្ព័ន្ធទី២៖ កម្រងសំណួរបន្ថែមសម្រាប់អ្នកតំណាងស្ថាប័នអប់រំ

## I. អំពីស្ថាប័ន

### A. ព័ត៌មានទូទៅ

**០០១. នៅក្នុងឆ្នាំ២០១០ ស្ថាប័នរបស់អ្នកមាន**

**ការកំណត់ន័យ ៖**

- *តំណែងទាបៈ គឺជាអ្នកដែលធ្វើការដោយប្រើជំនាញតិចតួច (ប្រើកំលាំងបាយច្រើន) ដូចជាអ្នកបោសសំអាត ឬអ្នកយាម*
- *តំណែងកណ្តាលៈ គឺជាអ្នកធ្វើការដោយប្រើកំលាំងប្រាជ្ញាច្រើន តែមិនស្ថិតក្នុងតំណែងអ្នកសម្រេចចិត្ត ដូចជាអ្នកធ្វើការក្នុងការិយាល័យ បុគ្គលិកបង្រៀន*
- *តំណែងខ្ពស់ៈ គឺជាអ្នកធ្វើការក្នុងតំណែងអាចធ្វើការសម្រេចចិត្តបានដូចជា អ្នកគ្រប់គ្រង ប្រធាន ឬអនុប្រធានដេប៉ាតឺម៉ង់*

1 ☐ ចំនួនបុគ្គលិកសរុប.......................................................................................................នាក់
2 ☐ ចំនួនបុគ្គលិកស្រីសរុប..................................................................................................នាក់
3 ☐ ចំនួនបុគ្គលិកស្ត្រីស្ថិតនៅក្នុងតំណែងទាប.......................................................................នាក់
4 ☐ ចំនួនបុគ្គលិកស្ត្រីស្ថិតនៅក្នុងតំណែងកណ្តាល..................................................................នាក់
5 ☐ ចំនួនបុគ្គលិកស្ត្រីស្ថិតនៅក្នុងតំណែងខ្ពស់........................................................................នាក់
6 ☐ ចំនួនបុគ្គលិកដែលចេះប្រើប្រាស់កុំព្យូទ័រ/អ៊ីនធឺណិត.........................................................នាក់
7 ☐ ចំនួនបុគ្គលិកស្ត្រីដែលចេះប្រើប្រាស់កុំព្យូទ័រ/អ៊ីនធឺណិត....................................................នាក់
8 ☐ ចំនួនវគ្គបណ្តុះបណ្តាលICT ដែលផ្តល់ជូនដល់បុគ្គលិកទាំងអស់ក្នុងរយៈពេល១២ខែកន្លងទៅ..........................វគ្គ
9 ☐ ចំនួនបុគ្គលិកស្ត្រីដែលបានចូលរួមវគ្គបណ្តុះបណ្តាល ICT ខាងលើ..........................................នាក់

### B. ស្ថិតិនិស្សិតរៀនផ្នែក ICT

**០០២. យើងខ្ញុំចង់អោយលោកអ្នក ជួយប្រាប់អំពីស្ថិតិនិស្សិត រៀនផ្នែក ICT នៅក្នុងស្ថាប័នរបស់លោកអ្នក**
**ការកំណត់ន័យ៖** *មុខវិជ្ជាទាក់ទងនឹង ICT រួមមានកូដដូចខាងក្រោម៖*

*១ = វិស្វករ និងវិទ្យាសាស្ត្រកុំព្យូទ័រ ឬព័ត៌មានវិទ្យា (Computer Science and Engineering/Information Technology)*
*២ = អគ្គីសនី និងអេឡិចត្រូនិក (Electronics and Electrical Science)*
*៣ = ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (Media and Telecommunication)*

**សម្រាប់កម្រិតបរិញ្ញាបត្រ**

| | | | |
|---|---|---|---|
| ឆ្នាំសិក្សា ២០០៩ - ២០១០<br>ឆ្នាំទី១ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |
| ឆ្នាំសិក្សា២០០៩ - ២០១០<br>ឆ្នាំទី២ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |
| ឆ្នាំសិក្សា២០០៩ - ២០១០<br>ឆ្នាំទី៣ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |
| ឆ្នាំសិក្សា២០០៩ - ២០១០<br>ឆ្នាំទី៤ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |

| | | | |
|---|---|---|---|
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |
| និស្សិតបញ្ចប់ការសិក្សាឆ្នាំ ២០០៨ - ២០០៩ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |
| និស្សិតបញ្ចប់ការសិក្សាឆ្នាំ ២០០៧- ២០០៨ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |
| និស្សិតបញ្ចប់ការសិក្សាឆ្នាំ ២០០៦ - ២០០៧ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |

| | | | |
|---|---|---|---|
| និស្សិតបញ្ចប់ការសិក្សាឆ្នាំ ២០០៥ - ២០០៦ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |

**សម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ (ប្រសិនបើមាន)**

| | | | |
|---|---|---|---|
| ឆ្នាំសិក្សា ២០០៩ - ២០១០ ឆ្នាំទី១ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |
| ឆ្នាំសិក្សា២០០៩ - ២០១០ ឆ្នាំទី២ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |
| និស្សិតបញ្ចប់ការសិក្សាឆ្នាំសិក្សា ២០០៨ - ២០០៩ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |

| | | | |
|---|---|---|---|
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |
| និស្សិតបញ្ចប់ការសិក្សាឆ្នាំសិក្សា ២០០៧ - ២០០៨ | ចំនួននិស្សិតរៀនព័ត៌មានវិទ្យា (១) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនអគ្គិសនីឬអេឡិចត្រូនិក (២) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតរៀនប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍(៣) | សរុប | ................................ |
| | | ស្រី | ................................ |
| | ចំនួននិស្សិតសរុប (១+២+៣) | សរុប | ................................ |
| | | ស្រី | ................................ |

**សូមអរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក!**

ភ្នំពេញថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១០

រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី និងអង្គការវិទ្យាស្ថានបើកទូលាយ

## ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរសម្រាប់បុគ្គលិក

### I.ទិន្នន័យប្រជាសាស្ត្រ

០០១. អាយុ..................................................................ឆ្នាំ

០០២. ភេទ 1☐ ប្រុស 2☐ ស្រី

០០៣. កម្រិតវប្បធម៌

- 0☐ មិនបានចូលរៀន
- 1☐ បឋមសិក្សា
- 2☐ អនុវិទ្យាល័យ
- 3☐ វិទ្យាល័យ
- 4☐ បណ្តុះបណ្តាលវិជ្ជាជីវៈ
- 5☐ មហាវិទ្យាល័យ
- 6☐ ក្រោយមហាវិទ្យាល័យ

០០៤. មុខរបរ

1☐ សិស្ស/និស្សិត 2☐ បុគ្គលិករដ្ឋ 3☐ បុគ្គលិកអង្គការ
4☐ បុគ្គលិកក្រុមហ៊ុន 5☐ អ្នកជំនួយ/ពាណិជ្ជករ 6☐ ផ្សេងទៀត ..............................

០០៥. តើអ្នកចាត់ចំណាត់ថ្នាក់ខ្លួនឯង (កម្រិតនៃការងារ)

1☐ កម្រិតទាប 2☐ កម្រិតកណ្តាល 3☐ កម្រិតខ្ពស់

០០៦. តើអ្នកចាត់ចំណាត់ថ្នាក់ខ្លួនឯង (កម្រិតនៃជីវភាព)

1☐ ប្រសើរ 2☐ សមរម្យ 3☐ លំបាក

០០៧. តើលោកអ្នកអាចនិយាយ ឬសរសេរបានភាសាអ្វីខ្លះ?

1☐ ខ្មែរ 2☐ អង់គ្លេស 3☐ បារាំង
4☐ ចិន 5☐ ផ្សេងៗទៀត ..............

### II. ការប្រើប្រាស់កុំព្យូទ័រ

#### 2.A. ការប្រើប្រាស់ កុំព្យូទ័រ

០០៨. តើលោកអ្នកចាត់ចំណាត់ថ្នាក់ខ្លួនឯងក្នុងកម្រិតណាមួយនៃចំណេះដឹងកុំព្យូទ័រ

1☐ អ្នកចាប់ផ្តើម 2☐ មានចំណេះដឹងខ្លះ
3☐ អ្នកជំនាញ 4☐ មិនដែលប្រើកុំព្យូទ័រ (រំលងទៅសំណួរទី២០)

០០៩. ជាទូទៅលោកអ្នកប្រើប្រាស់កុំព្យូទ័រ និងអ៊ីនធឺណិតនៅទីណា? (គូសអ្វីដែលមាន)

1 ☐ នៅកន្លែងការងារ　2 ☐ នៅផ្ទះ　3 ☐ នៅសាលា

4 ☐ នៅកន្លែងហាងអ៊ីនធឺណិត　5 ☐ កន្លែងផ្សេងទៀត .........................................

០១០. តើលោកអ្នកធ្វើការជាអ្នកជំនាញកុំព្យូទ័រ ឬត្រឹមជាអ្នកប្រើប្រាស់កុំព្យូទ័រជាមធ្យោបាយសម្រាប់ធ្វើការ?

1 ☐ អ្នកជំនាញកុំព្យូទ័រ　2 ☐ ប្រើកុំព្យូទ័រជាមធ្យោបាយសម្រាប់ធ្វើការ

០១១. តើលោកអ្នកធ្លាប់បានរៀន/ចូលរួមវគ្គបណ្តុះបណ្តាលកុំព្យូទ័រទេ? (គូសអ្វីដែលមាន)

1 ☐ ការសិក្សានៅមហាវិទ្យាល័យ　2 ☐ វគ្គបណ្តុះបណ្តាល　3 ☐ រៀនដោយខ្លួនឯង

4 ☐ មិនបានទទួលការបណ្តុះបណ្តាល　4 ☐ ផ្សេងទៀត ......................................................

០១២. សម្រាប់លោកអ្នកដែលមានសញ្ញាប័ត្រ ផ្នែក ICT តើលោកអ្នកគិតថា វាមានការការលំបាកទេ ដើម្បីរកការងារ បើធៀបជាមួយអ្នកដែលមានកម្រិតសញ្ញាប័ត្រដូចគ្នា (មុខវិជ្ជាខុសគ្នា)?

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

តើលោកអ្នកអាចប្រាប់ខ្ញុំបានទេ អំពីការលំបាកទាំងនោះ?.......................................................................................

០១៣. តើលោកអ្នកគិតថា ចំណេះវិជ្ជាទាំងនេះអាចយកទៅប្រើប្រាស់បានទេ ចំពោះការងារ ?

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

## 2B ការប្រើប្រាស់អ៊ីនធឺណិត

០១៤. តើលោកអ្នកបានប្រើប្រាស់អ៊ីនធឺណិត អស់រយៈពេលប៉ុន្មានខែ/ឆ្នាំមកហើយ?

1 ☐ 0 ≤ ៣ខែ　2 ☐ ៣ ≤ ៦ខែ　3 ☐ ៦ ≤ ១២ខែ

4 ☐ ១ ≤ ២ឆ្នាំ　5 ☐ ២ ≤ ៣ឆ្នាំ　6 ☐ ច្រើនជាង៣ឆ្នាំ

០១៥. តើលោកអ្នកប្រើប្រាស់អ៊ីនធឺណិតញឹកញាប់ ប៉ុណ្ណាដែរ ? A ដង..............សប្តាហ៍　B ម៉ោង.............ថ្ងៃ

០១៦. ចំនួនម៉ោងសម្រាប់ការអាន និងដាក់អត្ថបទចូលនិងការពិភាក្សាក្រុម　ម៉ោង....................សប្តាហ៍

០១៧. តើលោកអ្នកបើកអ៊ីមែលញាប់ទេ?

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| មិនដែលសោះ | ពីរ បីដងក្នុង១សប្តាហ៍ | រាល់ថ្ងៃ | ច្រើនជាង ២ដងក្នុង១ថ្ងៃ | ស្ទើរតែរាល់ពេល |

☐ គ្មានយោបល់

០១៨. តើការប្រើប្រាស់កុំព្យូទ័រ របស់លោកអ្នកមានការផ្លាស់ប្តូរ ទេកាលពីឆ្នាំកន្លងទៅ?

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| កើនឡើងខ្លាំង | កើនឡើងតិចតួច | នៅដដែល | ថយចុះតិចតួច | ថយចុះខ្លាំង |

☐ គ្មានយោបល់

០១៩. ជាញឹកញយតើលោកអ្នកអាចស្វែងរកព័ត៌មានដែលលោកអ្នកស្វែងរកតាមអ៊ីនធឺណិតដែរឬទេ?

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| គ្រប់ពេលទាំងអស់ | ស្ទើរគ្រប់ពេល | ពេលខ្លះ | ម្តងម្កាល | កម្រណាស់ |

☐ គ្មានយោបល់

## IV. បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា សម្រាប់ស្ត្រី

### 3A. ការផ្តល់នាពអង់អាចដល់ស្ត្រីតាមរយៈ ICT

សូមលោកអ្នកបញ្ជាក់ពីកម្រិតនៃការយល់ស្របលើប្រយោគដូចខាងក្រោម

០២០. ស្ត្រីអាចត្រូវបានគេផ្តល់ភាពអង់អាច តាមរយៈ (កុំព្យូទ័រ និងអ៊ីនធឺណិត)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០២១. រដ្ឋាភិបាល អង្គការ និងផ្នែកឯកជន គួរតែធ្វើសកម្មភាពអោយបានច្រើនថែមទៀត ក្នុងការធ្វើអោយស្ថានភាពស្ត្រីក្នុងវិស័យអប់រំ និងការងារ មានភាពប្រសើរឡើង

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

### 3B. ICT នៅកន្លែងការងារ

សូមលោកអ្នកបញ្ជាក់ពីកម្រិតនៃការយល់ស្របលើប្រយោគដូចខាងក្រោម

០២២. នៅក្នុងស្ថាប័នអប់រំរបស់អ្នក ស្ត្រីមានឱកាសតិចតួចដើម្បីទទួលបានការអប់រំ និងការងារផ្នែក ICT ដោយសារតែលក្ខណៈជីវសាស្ត្រ បញ្ហាវប្បធម៌សង្គម បញ្ហាថវិកា និងការគំនាបដទៃទៀត

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០២៣. ប្រៀបធៀបជាមួយបុគ្គលិកបុរស និងបុគ្គលិកស្ត្រីដែលមានតួនាទី/ឋានដូចគ្នា សញ្ញាប័ត្រ និងបទពិសោធន៍ដូចគ្នា ស្ត្រីត្រូវបានគេអោយការទទួលខុសត្រូវតិចជាងបុរស

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០២៤. ប្រៀបធៀបជាមួយបុគ្គលិកបុរស និងបុគ្គលិកស្ត្រីដែលមានតួនាទី/ឋានដូចគ្នា សញ្ញាប័ត្រ និងបទពិសោធន៍ដូចគ្នា ស្ត្រីមានអំណាចច្រើនជាងបុរសក្នុងការធ្វើសេចក្ដីសម្រេចចិត្ត

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០២៥. ប្រៀបធៀបជាមួយបុគ្គលិកបុរស និងបុគ្គលិកស្ត្រីដែលមានតួនាទី/ឋានដូចគ្នា សញ្ញាប័ត្រ និងបទពិសោធន៍ដូចគ្នា ស្ត្រីទទួលបានផលប្រយោជន៍ដូចបុរស (ប្រាក់ខែ ប្រាក់បន្ថែម គ្រឿងលើកទឹកចិត្ត និងការលើកទឹកចិត្ត -ល-។)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

## 3C. ICT គំនាបនិងឧបសគ្គដើម្បីទទួលបាន ICT

សេចក្ដីថ្លែងការខាងក្រោមនិយាយអំពី គំនាប់ និងឧបសគ្គដែលរារាំងស្ត្រី មិនអោយទទួលបាន និងប្រើប្រាស់ ICT ។ សូមលោកអ្នកបញ្ជាក់ពីកម្រិតនៃការយល់ស្របលើប្រយោគដូចខាងក្រោម

០២៦. តម្លៃអ៊ីនធឺណិតថ្លៃ

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០២៧. បទដ្ឋានសង្គម និងវប្បធម៌ (មិនអោយតម្លៃស្ត្រី, មិនអោយទៅឆ្ងាយពីផ្ទះ, មិនអោយមិនចំណេះដឹងជ្រៅជ្រះ)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០២៨. លក្ខណៈជីវសាស្ត្ររបស់ស្ត្រី (មានផ្ទៃពោះ កម្លាំង)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០២៩. ការចំណាយក្នុងគ្រួសារ/ ការវិនិយោគរបស់គ្រួសារលើការអប់រំ

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៣០. តួនាទី និងភាពទទួលខុសត្រូវរបស់ស្ត្រីនៅក្នុងគ្រួសារ (ការធ្វើការសម្រេចចិត្ត និងការងារផ្ទះ)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៣១. ប្រភេទការងារ (វាមិនសមស្របសម្រាប់ស្ត្រី, ជាការងារបច្ចេកទេស)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៣២. ឱកាសស្មើគ្នាសម្រាប់ការងារ (នៅពេលដាក់ពាក្យសុំបម្រើការងារ និងការផ្សព្វផ្សាយការងារ)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៣៣. ហេដ្ឋារចនាសម្ព័ន្ធ ICT (ហេដ្ឋារចនាសម្ព័ន្ធ, បណ្តាញគ្របដណ្តប់, បច្ចេកវិទ្យា)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៣៤. បច្ចេកវិទ្យាដើរលឿនពេក (នៅក្នុងប្រទេសកម្ពុជា និង ពិភពលោក)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៣៥. ភាសា (ភាសាខ្មែរ, ភាសាអង់គ្លេស ភាសាបារាំង ...)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៣៦. ខ្ញុំទើបតែបញ្ចប់ការសិក្សា ហើយមិនមានបទពិសោធន៍ការងារ ដែលវាមានសារសំខាន់ សម្រាប់ការប្រកួតប្រជែងដ៏ជោគជ័យនៅលើទីផ្សារការងារ

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៣៧. គោលនយោបាយ/កម្មវិធីរដ្ឋ និងការអនុវត្តតាមផ្នែក (គោលនយោបាយ ICT និងគោលនយោបាយ ICT ក្នុងវិស័យអប់រំ)

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៣៨. ខ្ញុំមានអារម្មណ៍ថាមិនត្រូវបានគេលើកទឹកចិត្ត អោយចូលរួមមុខវិជ្ជា/វគ្គ បណ្តុះបណ្តាល អំពី ICT ពីចៅហ្វាយនាយ អ្នករួមការងារ...។

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

## 3D. ទស្សនវិស័យ/ការប្តេជ្ញា/និងការលះបង់ ដើម្បី ICT

សូមលោកអ្នកបញ្ជាក់ពីកម្រិតនៃការយល់ស្របលើប្រយោគដូចខាងក្រោម

០៣៩. ខ្ញុំនឹងណែនាំកូនស្រី បងប្អូនស្រី មិត្តភ័ក្តិស្រី និងស្ត្រីដទៃទៀតអោយចូលរៀន និងធ្វើការក្នុងវិស័យ ICT

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៤០. ខ្ញុំគិតថា ICT មានផលប្រយោជន៍សម្រាប់ខ្ញុំ ដើម្បីការធ្វើការងារ ទំនាក់ទំនងសង្គម និងការអភិវឌ្ឍខ្លួន

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៤១. ខ្ញុំគិតថា ICT (កុំព្យូទ័រ និង អ៊ីនធឺណិត) មានសារប្រយោជន៍សម្រាប់សង្គមរបស់យើង

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៤២. ខ្ញុំតែងតែអភិវឌ្ឍខ្លួនខ្ញុំអោយដើរទាន់បច្ចេកវិទ្យាថ្មីៗ

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៤៣. តើអ្នកបានរៀបចំយ៉ាងដូចម្តេច ដើម្បីធ្វើអោយទាន់សម័យនូវបច្ចេកវិទ្យា ICT ?..........................................................

..........................................................................................................................................................

០៤៤. តើអ្នកមានទស្សនវិស័យ(ការយល់ឃើញ) យ៉ាងដូចម្តេច ចំពោះស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងវិស័យអប់រំ?..........................................................................................................................................

០៤៥. តើអ្នកមានទស្សនវិស័យ(ការយល់ឃើញ) យ៉ាងដូចម្តេច ចំពោះស្ត្រី និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងវិស័យការងារ?.......................................................................................................................................

..........................................................................................................................................................

## 3E. ការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យាផ្សេងទៀត

សូមលោកអ្នកបញ្ជាក់ពីភាពញឹកញាប់ក្នុងការធ្វើសកម្មភាពដូចខាងក្រោម៖

០៤៦. ការអានកាសែត និងទស្សនាវដ្តី សៀវភៅ និងឯកសារដទៃទៀត

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៤៧. ការស្តាប់វិទ្យុ

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៤៨. ការមើលទូរទស្សន៍

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៤៩. ទូរសព្ទ

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៥០. MP3, MP4, ប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងឧបករណ៍កម្សាន្តផ្សេងៗទៀត

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៥១. អ៊ីនធឺណិត

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៥២. កុំព្យូទ័រ

| 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|
| យល់ស្របខ្លាំង | យល់ស្រប | ធម្មតា | មិនយល់ស្រប | មិនយល់ស្របខ្លាំង |

☐ គ្មានយោបល់

០៥៣. តើអ្នកមានអ្វីចង់បន្ថែម ឬចង់និយាយប្រាប់ខ្ញុំដែរទេ?.......................................................................................
............................................................................................................................................................................
............................................................................................................................................................................

**សូមអរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក!**

ភ្នំពេញថ្ងៃទី ២៤ ខែមិថុនាឆ្នាំ២០១០

រៀបចំដោយក្រសួងអប់រំ យុវជន និង កីឡា ក្រសួងកិច្ចការនារី និងអង្គការវិទ្យាស្ថានបើកទូលាយ

## ឧបសម្ព័ន្ធទី៨៖ កម្រងសំណួរសម្រាប់សម្ភាសស៊ីជម្រៅជាមួយបុគ្គលិកដែលមានតួនាទីសំខាន់ក្នុងផ្នែកបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា

### I. ទិន្នន័យប្រជាសាស្ត្រ

០០១. ភេទ 1☐ ប្រុស 2☐ ស្រី

០០២. តួនាទី.......................................................................................................................................

០០៣. ឈ្មោះស្ថាប័ន/ផ្នែក.........................................................................................................................

០០៤. អាយុ...........................................................................................................................................

០០៥. ស្ថានភាពអាពាហ៍ពិពាហ៍ 1☐ នៅលីវ 2☐ រៀបអាពាហ៍ពិពាហ៍ 3☐ មេម៉ាយ/ពោះម៉ាយ

០០៦. កម្រិតវប្បធម៌ខ្ពស់បំផុតដែលទទួលបាន

| | | |
|---|---|---|
| 1☐ មិនបានចូលរៀន | 4☐ វិទ្យាល័យ | 7☐ បរិញ្ញាបត្រ |
| 2☐ បឋមសិក្សា | 5☐ ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ | 8☐ បរិញ្ញាបត្រជាន់ខ្ពស់ |
| 3☐ អនុវិទ្យាល័យ | 6☐ បរិញ្ញាបត្ររង | 9☐ បណ្ឌិត |

០០៧. បើនិយាយពីស្ថានភាពហិរញ្ញវត្ថុ, តើលោកអ្នកចាត់ចំណាត់ថ្នាក់ខ្លួនលោកអ្នកជា

31☐ ប្រសើរ 2☐សម ល្មម 3☐ លំបាកលំបិន

### II. ចំណេះដឹង

០០៨. តើលោកអ្នកអាចប្រាប់ខ្ញុំអំពីចំណេះដឹងផ្នែកកុំព្យូទ័ររបស់លោកអ្នកបានទេ ? (កម្រិតសញ្ញាប័ត្រ, ការបណ្តុះបណ្តាលស្វ័យសិក្សា និងការអនុវត្តប្រចាំថ្ងៃ)

០០៩. តើលោកអ្នកគិតថាកុំព្យូទ័រ និងអ៊ីនធឺណិតមានប្រយោជន៍ទេចំពោះសង្គមរបស់យើង? មូលហេតុអ្វី?.............................

០១០. តើលោកអ្នកគិតថាបុគ្គលិករបស់លោកអ្នកមានចំណេះដឹងផ្នែកកុំព្យូទ័រ និងអ៊ីនធឺណិត គ្រប់គ្រាន់ហើយឬនៅ? (កុំព្យូទ័រ, អ៊ីនធឺណិត, និងបច្ចេកវិទ្យាទំនាក់ទំនងដទៃទៀត)? មូលហេតុអ្វី?

០១១. តើលោកអ្នកមានទស្សនវិស័យដូចម្តេចចំពោះបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យារបស់ស្ត្រី? រវាងបុរសនិងស្ត្រី តើមួយណាមានភាពប្រសើរជាង? ហេតុអ្វី?

### III. អាកប្បកិរិយា

០១៣. តើស្ថាប័នរបស់លោកអ្នកមានគោលនយោបាយ/ កម្មវិធី/ គម្រោង ដើម្បីធ្វើអោយប្រសើរឡើងនូវវគ្គបណ្តុះបណ្តាលស្ត្រី អំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា?

០១៤. តើលោកអ្នកបានណែនាំបុគ្គលិករបស់លោកអ្នកអោយចូលរៀន ឬចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីអំពី ICT? តើលោកអ្នកជំរុញពួកគេដោយរបៀបណា?

០១៥. តើលោកអ្នកនឹងណែនាំកូនស្រីរបស់លោកអ្នក ប្អូនស្រីរបស់លោកអ្នក និងមនុស្សស្រីដទៃទៀត អោយសិក្សា និងធ្វើការលើវិស័យ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា? ហេតុអ្វី?.............................................................................................

### IV. ការអនុវត្ត

០១៦. តើលោកអ្នកអាចប្រាប់ខ្ញុំបានទេ អំពីទំហំការងារ និងការទទួលខុសត្រូវរបស់លោកអ្នកចំពោះការងារ?

០១៧. តើលោកអ្នកមានស្វ័យសម្រេចចិត្តបានទេ ក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅកន្លែងការងាររបស់អ្នក (ស្ថិតនៅក្រោមតួនាទី និងភារកិច្ចរបស់ខ្លួន)?

០១៨. បើប្រៀបធៀបជាមួយបុរស តើស្ត្រីមានតួនាទីសំខាន់ ច្រើនជាង ឬតិចជាងក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុងស្ថាប័នរបស់អ្នក (ច្រើនជាងពីមុន ឬតិចជាងពីមុន)?

០១៩. តើអ្នកធ្លាប់បានទទួលឱកាសក្នុងការដំឡើងឋានន្តរសក្តិ?

០២០. តើអ្នកបានដឹងទេថា ឥឡូវអ្នកទទួលបានការគោរពច្រើនជាងមុនពីសំណាក់អ្នករួមការងារ និយោជិក ក្រុមគ្រួសារ និងមិត្តភក្តិ ដោយសារតែអ្នកមានចំណេះដឹងផ្នែក ICT ?

០២១. តើអ្នកបានដឹងទេថា ឥឡូវនេះអ្នកកាន់តែមានស្វ័យភាពសេដ្ឋកិច្ចច្រើនជាងមុន (មានចំណូលច្រើនជាងមុន) ដោយសារតែលោកអ្នកមានចំណេះដឹងផ្នែក ICT?

០២២. តើអ្នកមានអ្វីចង់បន្ថែមទៀតទេ ឬអ្នកមានអ្វីចង់សាកសួរយើងខ្ញុំវិញ?

**សូមអរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក!**

ភ្នំពេញថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១០

រៀបចំដោយក្រសួងអប់រំ យុវជន និង កីឡា ក្រសួងកិច្ចការនារី និងអង្គការវិទ្យាស្ថានបើកទូលាយ

## ឧបសម្ព័ន្ធទី៨៖ កម្រងសំណួរសម្រាប់ការពិភាក្សាជាក្រុមជាមួយនិស្សិតសិក្សាផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

### សំណួរសម្រាប់ធ្វើការពិភាក្សា

១. ហេតុអ្វីបានជាលោកអ្នកជ្រើសរើសយកមុខវិជ្ជាICT?

២. ហេតុអ្វីបានជាស្ត្រីរៀនផ្នែកICT មានចំនួនតិចជាងបុរស? តើលោកអ្នកចង់អោយមានស្ត្រីចូលសិក្សាផ្នែក ICTកាន់តែច្រើនជាងមុនដែរឬទេ?

៣. តើលោកអ្នកបានជួបប្រទះផលលំបាកអ្វីខ្លះក្នុងការសិក្សាមុខវិជ្ជា ICT ?

៤. តើលោកអ្នក គិតថានិស្សិតស្រីបានជួបប្រទះផលលំបាកអ្វីខ្លះក្នុងការសិក្សាមុខវិជ្ជា ICT?

៥. តើលោកអ្នកយល់ថាសាកលវិទ្យាល័យដែលលោកអ្នកកំពុងសិក្សា បានរៀបចំកម្មវិធីសិក្សាដែលមានលក្ខណៈទាន់សម័យអាចឆ្លើយតបនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគត? ហេតុអ្វី?

៦. តើលោកអ្នករំពឹងទុកថាលោកអ្នកនឹងមានចំណេះដឹងគ្រប់គ្រាន់ដែរឬទេ ក្រោយពេលបញ្ចប់ការសិក្សាមុខវិជ្ជាICT នេះ? សូមបញ្ជាក់?

៧. តើលោកអ្នកគិតថានិស្សិតជាស្ត្រីមានឱកាសច្រើនជាង ឬតិចជាងបុរស ក្នុងការទទួលបានការងារផ្នែកICT?

៨. តើលោកអ្នកគិតថានិស្សិតដែលសិក្សាផ្នែកICT ជួបប្រទះផលលំបាកអ្វីខ្លះ ក្នុងការទទួលបានការងារផ្នែកICT? ចុះចំពោះនិស្សិតស្រី?

៩. តើលោកអ្នក គិតថាស្ត្រីបានជួបប្រទះផលលំបាកអ្វីខ្លះក្នុងការធ្វើការងារផ្នែក ICT? តើលោកអ្នកចង់អោយមានស្ត្រីចូលធ្វើការងារផ្នែក ICT កាន់តែច្រើនជាងមុនដែរឬទេ?

១០. តើលោកអ្នកយល់ឃើញយ៉ាងដូចម្តេចចំពោះបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងពេលអនាគត?

១១. តើលោកអ្នកគិតថារដ្ឋាភិបាល អង្គការសង្គមស៊ីវិល គួរធ្វើសកម្មភាពអ្វីខ្លះ ដើម្បីអោយស្ថានភាពនៃការសិក្សា និងប្រើប្រាស់ ICT មានលក្ខណៈទូលំទូលាយ និងល្អប្រសើរជាងមុន?

១២. តើអ្នកមានអ្វីចង់បន្ថែមទៀតទេ ឬអ្នកមានអ្វីចង់សាកសួរយើងខ្ញុំវិញ?

**សូមអរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក!**

ភ្នំពេញថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១០

រៀបចំដោយក្រសួងអប់រំ យុវជន និង កីឡា ក្រសួងកិច្ចការនារី និងអង្គការវិទ្យាស្ថានបើកទូលាយ

## ឧបសម្ព័ន្ធទី៦៖ សូចនាករក្នុងការវាយតម្លៃការងារផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានៅលើគេហទំព័រការងារ

សូចនាករ សំខាន់ៗ ក្នុងការស្រង់ចំនួនការងារដែល បានផ្សាយនៅលើគេហទំព័រការងារសំខាន់ៗពីក្នុងប្រទេសកម្ពុជា៖

- ចំនួនការងារ ( ការងារ ICT ការងារទាក់ទងICT និងមិនមែនការងារICT )
- កម្រិតនៃការងារ ( ទាប កណ្ដាល ខ្ពស់ )
- រយៈពេលការងារ (វែង ឬខ្លី )
- ទីតាំងរបស់ការងារ
- ស្ត្រីត្រូវបានលើកទឹកចិត្ត
- កម្រិតវប្បធម៌
- មុខជំនាញ
- រយៈពេលបទពិសោធន៍
- ជំនាញគ្រប់គ្រង
- ជំនាញទំនាក់ទំនង
- ជំនាញភាសាអង់គ្លេស

## ឧបសម្ព័ន្ធទី៧៖ ការដកស្រង់ចំណុចសំខាន់ៗដែលបានចែង ក្នុងច្បាប់ និងគោលនយោបាយក្នុងប្រទេសកម្ពុជា ដែលនិយាយពីបញ្ហាការងារ និងបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

### ១. ច្បាប់រដ្ឋធម្មនុញ្ញ

http://women.open.org.kh/km/constitution_kingdom_cambodia

មាត្រា ៣៦

- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្ដីត្រូវការរបស់សង្គម។
- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា។
- ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃ ដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។
- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់។
- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ។
- ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់។

មាត្រា ៦៥

- រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និង ត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។
- រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និង កីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

មាត្រា ៦៧

- រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។
- រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈ និងឯកជននៅគ្រប់ភូមិសិក្សា ។

### ២. ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៩-២០១៣

http://www.mop.gov.kh/LinkClick.aspx?fileticket=70K84Tl9ca8%3d&tabid=206&mid=663

## ជំពូកទី២ សមិទ្ធផល និង បញ្ហាប្រឈមចម្បងៗក្នុងការអនុវត្ត ផយអជ ២០០៦-២០១០

### ៤. ការបន្តស្តារ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### iv. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍

១៦៨- បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ រួមបញ្ចូលនូវ ទូរសព្ទ និង ប្រព័ន្ធទូរគមនាគមន៍ផ្សេងៗ ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ដោយមានការកើនឡើងនៃការប្រកួតប្រជែង ដែលភាគច្រើនដឹកនាំដោយវិស័យឯកជន កម្ពុជា បានបោះជំហានទៅមុខ

យ៉ាងលឿនក្នុងការប្រើប្រាស់ទូរសព្ទចល័ត។ សមិទ្ធផលសំខាន់ៗ និង បញ្ហាប្រឈមមួយចំនួន រួមមានដូចខាងក្រោម ៖

- បន្ទាប់ពីការបើកទូលាយវិស័យទូរគមនាគមន៍ក្នុងខែមករាឆ្នាំ ២០០៦ មក វិនិយោគិនឯកជនកាន់តែច្រើនឡើងបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យនេះ។ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ បាននឹងកំពុងគ្រប់គ្រងគម្រោងការងារធំៗជាច្រើនដែលមានទឹកប្រាក់ប្រមាណ ២៣៥,៨ លានដុល្លារអាមេរិក ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាបអុបទិក សំដៅពង្រីកសេវាកម្មទូរគមនាគមន៍នៅទូទាំងប្រទេស។
- មកដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៨ ចំនួនទូរសព្ទសរុបដែលកំពុងត្រូវបានប្រើប្រាស់ បានកើនឡើងដល់ ៤ ១៤៣ ៤១៧ គ្រឿង(ដែលក្នុងនោះ ទូរសព្ទចល័តមានចំនួន ៤ ១០០ ០០០ គ្រឿង និង ទូរសព្ទអចល័តមានចំនួន ៤៣ ៤១៧ គ្រឿង)។ នៅក្នុងឆ្នាំ២០០៥ ទូរសព្ទអចល័ត និងចល័ត មានចំនួន៨៨២ ០២០គ្រឿង។ កំណើនយ៉ាងលឿននៃទូរសព្ទប្រើប្រាស់នេះបានកើតមានឡើង ជាពិសេសនៅតំបន់ជនបទ ស្របពេលដែលអ៊ីមែល និង អ៊ីនធឺណិត ត្រូវបានប្រើប្រាស់កាន់តែច្រើនជាងមុននៅទូទាំង ២៤ រាជធានី-ខេត្ត និង ក្រុង។
- ចំនួនអ្នកចុះឈ្មោះប្រើអ៊ីនធឺណិតមានចំនួន២០ ១០០នាក់ក្នុងឆ្នាំ២០០៨ បើប្រៀបធៀបនឹងចំនួននៅក្នុងឆ្នាំ២០០៥ ដែលមានតែ ៨ ៦៣០នាក់ប៉ុណ្ណោះ។
- ចំនួនទូរសព្ទអចល័តសាធារណៈបានកើនឡើងពី ៤៣៩ គ្រឿងក្នុងឆ្នាំ ២០០៥ ដល់ ៤៥៦ គ្រឿង ក្នុងឆ្នាំ ២០០៨។
- ការប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រ និង អ៊ីនធឺណិតក៏បានរីកសាយយ៉ាងលឿនជាមួយនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃចំណេះដឹង ជំនាញក្នុងវិស័យនេះនៅចំណោមស្រទាប់យុវជនផងដែរ។
- ពីឆ្នាំ ២០០៦ មកដល់ពេលបច្ចុប្បន្ននេះ សេវាកម្មវិស័យប្រៃសណីយ៍ត្រូវបានធ្វើអោយប្រសើរឡើងដូចជា (១) ការកាត់បន្ថយរយៈពេលចែកបញ្ញើ (២) ការដាក់អោយដំណើរការនូវសេវាបញ្ញើឆាប់រហ័សនៅរាជធានី-ខេត្តទាំងអស់។(៣) ការពង្រីកសេវាកម្មប្រៃសណីយ៍ទៅដល់តំបន់ទីប្រជុំជនសំខាន់ៗ (៤) ការបង្កើតប្រព័ន្ធគ្រប់គ្រង-តាមដានត្រួតពិនិត្យបញ្ញើដោយប្រើប្រាស់ប្រព័ន្ធ អាយភីអេស(IPS)ចំពោះបញ្ញើប្រៃសណីយ៍ឆាប់រហ័ស ប្រៃសណីយ៍ភណ្ឌ និង បញ្ញើអនុសិដ្ឋជាដើម។
- រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តប្រព័ន្ធព័ត៌មានរដ្ឋបាលរបស់រាជរដ្ឋាភិបាល និង រដ្ឋាភិបាល-អេឡិចត្រូនិក។
- ក្រសួងព័ត៌មាន បានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សំគាល់ក្នុងការលើកកម្ពស់ និង ការពង្រីកការគ្របដណ្តប់ប្រសិទ្ធភាព និង គុណភាពរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន(វិទ្យុ ទូរទស្សន៍ និង ភ្នាក់ងារសារព័ត៌មាន)។ នៅពេលបច្ចុប្បន្ននេះ ប្រមាណ ៧០% (ក្នុងឯកសារខ្មែរ៨០%) នៃប្រជាជនកម្ពុជាអាចទទួលបាននូវព័ត៌មាន ការអប់រំ និង ការកម្សាន្ត តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមានស្រាប់ទាំងរដ្ឋ និង ឯកជន ដែលតាមរយៈនេះអាចជួយលើកតម្កើង អត្តសញ្ញាណជាតិ និង សាមគ្គីភាពជាតិ។
- បញ្ហាប្រឈមចម្បងនៅក្នុងវិស័យនេះរួមមាន ៖ (១) ប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យទូរគមនាគមន៍នៅមានកម្រិត ដោយសារ ច្បាប់ស្តីពីទូរគមនាគមន៍ ពុំទាន់បានអនុម័តពីរដ្ឋសភានៅឡើយ (២) សេវាមាត់ច្រកទូរគមនាគមន៍អន្តរជាតិខុសច្បាប់នៅតែបន្តកើតមាន ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងលុបបំបាត់ពី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ក៏ដោយ ដែលជាហេតុនាំឱ្យមានផលប៉ះពាល់ដល់សេវាកម្មមាត់ច្រកអន្តរជាតិ និង ចំណូលរដ្ឋ។ (៣)

កិច្ចសហការរវាង ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ប្រតិបត្តិករ-ភ្នាក់ងារអភិវឌ្ឍន៍ពុំទាន់មានភាពល្អប្រសើរនៅឡើយ (៤) តម្លៃប្រើប្រាស់សេវាអ៊ីនធឺណិត នៅតែមានតម្លៃថ្លៃនៅឡើយ (៥) សេវាប្រៃសណីយ៍របស់ក្រុមហ៊ុនឯកជនមានលក្ខណៈប្រកួតប្រជែងខ្លាំងជាងសេវាប្រៃសណីយ៍របស់រដ្ឋ ហើយសមត្ថភាពធនធានមនុស្សនៅក្នុងវិស័យប្រៃសណីយ៍នៅមានកម្រិតនៅឡើយ។

## ៩. ការអភិវឌ្ឍ វិស័យឯកជន និងការងារ

១៦៩. រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់និងឯកភាពលើចំណុចមួយដ៏សំខាន់ដែលថា ផ្នែកឯកជនជាកម្លាំងដ៏សំខាន់សម្រាប់ការវិនិយោគនិងកំណើនក្នុងប្រទេស ។ តួនាទីរបស់រាជរដ្ឋាភិបាល គឺជាអ្នកជំរុញ អ្នកលើក ទឹកចិត្ត អ្នកជួយបង្កលក្ខណៈ អ្នកជួយសម្របសម្រួល និងជានិយតករ ។ កម្រិតដ៏ធំនៃការវិនិយោគ គឺជាតម្រូវការ ចាំបាច់ ក្នុងពីរ-បីឆ្នាំខាងមុខ ដើម្បីថែរក្សា និងបង្កើនល្បឿនសន្ទុះនៃកំណើនសេដ្ឋកិច្ច ដែលត្រូវផ្អែកលើមូលដ្ឋានច្រើន ។ ផ្នែកឯកជនដែលមានកំណើនដ៏រឹងមាំ បំពេញបន្ថែមវិនិយោគសាធារណៈក្នុងវិស័យសង្គមកិច្ច ស្រូបយកអ្នកចូលរួមក្នុងកម្លាំងពលកម្មដែលចេះតែកើនឡើង និងបង្កើតជំនាញផ្សេងៗជាច្រើន ។ មុំទាំង៤ នៃចតុកោណនេះគឺ (១) ការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ (រួមមាន វិស័យកាត់ដេរសំលៀកបំពាក់ និងទេសចរណ៍) (២) ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនដល់កម្មករនិងនិយោជិក (៣) ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និង (៤) ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សម្រាប់មន្ត្រីបុគ្គលិកកម្មករ។ រាជរដ្ឋាភិបាលកម្ពុជា បានកាត់បន្ថយចំណាយក្នុងការធ្វើធុរកិច្ច បានពង្រីកលទ្ធភាពប្រើប្រាស់ទីផ្សារ បានកាត់បន្ថយចំណាយក្នុងការដឹកជញ្ជូនក្នុងស្រុក ហើយបានលើកកម្ពស់សុវត្ថិភាព តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ដែលជំរុញឱ្យមានផងដែរនូវការបញ្ចូលគ្នារវាងសេដ្ឋកិច្ចទីប្រជុំជននិងសេដ្ឋកិច្ចជនបទ ។ វឌ្ឍនភាពដែលធ្វើឱ្យកើតមានឡើងមកទល់ពេលនេះដើម្បីឈានទៅសម្រេចបានអាទិភាពទាំងនេះបានចូលរួមចំណែកយ៉ាងធំធេង ចំពោះការអភិវឌ្ឍថ្មីៗក្នុងវិស័យជាច្រើនផ្សេងទៀតនិងចំពោះការពង្រឹងស្ថានភាព សេដ្ឋកិច្ច-សង្គមកិច្ច របស់ប្រជាជនជនបទ ជាពិសេស អ្នកក្រីក្រ ។

១៩៣. ការបង្កើតការងារនិងការធានាកែលម្អលក្ខខណ្ឌការងារ គឺជាគោលដៅបន្តរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនការកាត់បន្ថយភាពក្រីក្រ និងការពន្លឿនកំណើនសេដ្ឋកិច្ច ។ ទោះជាដូចនេះក្តីការបង្កើតឱកាសការងារថ្មី ក៏អាស្រ័យលើកម្រិតនៃការវិនិយោគរបស់ផ្នែកឯកជនក្នុងវិស័យផ្លូវការនិងក្រៅផ្លូវការនៅតំបន់ទីប្រជុំជននិងតំបន់ជនបទផងដែរ ។ ការធានាឱ្យអ្នកចូលបម្រើការងារថ្មីមានជំនាញសមស្របទៅនឹងតម្រូវការរបស់ការងារថ្មីគឺជាបញ្ហាប្រឈមមួយដែលទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងជាច្រើនថែមទៀតដែលផ្តោតលើការពង្រីក ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ។ ការធ្វើឱ្យសម្រេចបាន នូវការបង្កើតការងារឱ្យបានច្រើនជាងមុនថែមទៀត និង ការធ្វើឱ្យប្រសើរឡើងនូវផលិតភាពនិងពិពិធ កម្មក្នុងវិស័យកសិកម្មគឺអាស្រ័យទៅនឹង ពលកម្មជំនាញនិងមីក្រូឥណទាន ដែលអាចត្រូវបានបង្កើតឱ្យមានឡើងតាមរយៈការអប់រំបណ្តុះបណ្តាល វិជ្ជាជីវៈបច្ចេកទេសនិងការអភិវឌ្ឍមីក្រូហិរញ្ញវត្ថុ ។

១៩៤. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានផ្តល់សេវាកម្មរកការងារឱ្យធ្វើ ដើម្បីជួយដល់អ្នកស្វែងរក ការងារធ្វើនៅក្នុងវិស័យឯកជនទាំងក្នុងនិងក្រៅប្រទេស ។

១៩៥. ក្នុងឆ្នាំ២០០៧-២០០៨ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានផ្តល់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមរយៈគ្រឹះស្ថានបណ្តុះបណ្តាលកម្រិតបឋមមធ្យមនិងឧត្តមចំនួន ២៥៤ (គ្រឹះស្ថានក្រោម ឱវាទក្រសួង ចំនួន ៥៨) ដល់សិស្សនិស្សិតចំនួនប្រមាណ ១១៣.៦៤៨ នាក់ (ស្រីចំនួន ៥៣.៥០៣ នាក់) ។ ដោយឡែកនៅចុងឆ្នាំ២០០៨ ក្រសួងបាន

ប្រើប្រាស់ មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីដែលមាន ថវិកាសរុបចំនួន ៣១,២០ ពាន់លានរៀល ដើម្បីបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលខ្លីជូនដល់ កម្មករ កម្មការិនីនិងយុវជនយុវនារីដែលបាត់បង់និងគ្មានការងារធ្វើសរុបចំនួន ៤០.១៤០នាក់ (ស្រីចំនួន ២២.៥៨៦ នាក់) នៅ រាជធានី និង ២៣ខេត្ត លើមុខជំនាញសំខាន់ៗពីរ គឺ (១) ជំនាញផ្នែកកសិកម្ម និង (២) ជំនាញផ្នែកឧស្សាហកម្មបច្ចេកទេសសិប្បកម្មនិងបច្ចេកទេសសេវាកម្ម ។ ទន្ទឹមនេះ ក្រសួង ក៏បានហ្វឹកហ្វឺនកូនជាងនិងកម្មករ ចំនួន ៤.៥០១ នាក់ (ស្រី ៤.០៨២ នាក់) នៅតាមសហគ្រាស ចំនួន ៦៩ ហើយ បានបង្កើតភ្នាក់ងារជាតិមុខរបរ ដើម្បីជួយដល់សិក្ខាកាមរកការងារធ្វើ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលជាស្ពានតភ្ជាប់ទៅរកទីផ្សារការងារ និងជាស្ពានភ្ជាប់រវាងកម្លាំងពលកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាល ។

២០៩. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានភារកិច្ចរៀបចំដំណើរការការងារនិងគ្រប់គ្រងប្រព័ន្ធសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។ កន្លងមកក្រសួងបានដាក់ឱ្យដំណើរការការធានារ៉ាប់រងហានិភ័យការងារ ដែលកំពុងធានារ៉ាប់រងកម្មករនិយោជិកប្រមាណ៤០ម៉ឺននាក់ ដែលធ្វើការងារនៅតាមសហគ្រាសគ្រឹះស្ថានគ្រប់ប្រភេទហើយនឹងបន្តពង្រីកវិសាលភាពបបនេះឱ្យបានទូទាំងប្រទេស។ ការអនុវត្តប្រព័ន្ធសន្តិសុខសង្គម សម្រាប់កម្មករនិយោជិកក្នុងផ្នែកឯកជនគឺជារបត់ថ្មីនៃប្រវត្តិសាស្ត្រសន្តិសុខសង្គមនៅកម្ពុជា ដែលបង្ហាញឱ្យឃើញកាន់តែច្បាស់ ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាមកលើកម្មករនិយោជិកក្នុងផ្នែកឯកជន ។

## ៦. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស

### i. ការពង្រឹងគុណភាពវិស័យអប់រំ

២១១. ការពង្រឹងគុណភាពសេវាអប់រំគឺ អាទិភាពចម្បងមួយរបស់ រាជរដ្ឋាភិបាលកម្ពុជា ។ ការងារនេះមានសារសំខាន់ និងជាគន្លឹះចាំបាច់ក្នុងការអភិវឌ្ឍធនធាន និង កាត់បន្ថយភាពក្រីក្រ។ ដើម្បីប្រឈមមុខនឹងបញ្ហាទាំងឡាយនៅក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលបានជំរុញឱ្យអនុវត្តនូវ អភិក្រមទូទាំងវិស័យ តាមរយៈការបង្កើតភាពជាដៃគូក្នុងការកសាងផែនការ និង កម្មវិធីសម្រាប់វិស័យអប់រំ ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០១-២០០៥ និង កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ ២០០១-២០០៥ ត្រូវបានរៀបចំឡើងក្នុងឆ្នាំ ២០០១ និង បានធ្វើការពិនិត្យឡើងវិញ និង វាយតម្លៃមគ្គាក្នុងខែមិថុនា ឆ្នាំ ២០០១ ។ នៅក្នុងខែកញ្ញា ឆ្នាំ ២០០៤ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ ២០០៤-២០០៨ ត្រូវបានកែលម្អឡើងវិញដោយមានការឯកភាពជាមួយដៃគូអភិវឌ្ឍទាំងអស់។ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៦-២០១០ បានរួមចំណែកបង្កើនសមធម៌នៃការចូលរៀនរបស់កុមារកម្ពុជាដើម្បីជួយពួកគេឱ្យក្លាយជា សិស្សល្អ កូនល្អ និង ពលរដ្ឋល្អ ដែលនឹងក្លាយទៅជាកម្លាំងស្នូលដ៏សំខាន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជានាពេលអនាគត ។

២១៣. គោលនយោបាយជាអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០បានផ្តោតសំខាន់លើ ៣ ចំណុច ៖

(១) ការធានាសមធម៌នៃការចូលរៀន

(២) ការកែលម្អគុណភាព និង ប្រសិទ្ធភាពនៃការអប់រំ

(៣) ការពង្រឹងស្ថាប័ន និង ការអភិវឌ្ឍសមត្ថភាពដើម្បីអភិវឌ្ឍវិមជ្ឈការ

## ជំពូក ៤ : គោលនយោបាយសកម្មភាពអាទិភាព ២០០៩-២០១៣

### ៤. ការបន្តស្តារ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### iv. ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា

#### ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤៧៥. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នឹងធ្វើការពង្រីកសេវាកម្មប្រៃសណីយ៍និងកាត់បន្ថយថ្លៃដោយៈ

- ធ្វើការអភិវឌ្ឍ និង ផ្តល់ព័ត៌មានស្តីពីកាលានុវត្តភាពនៃការវិនិយោគទាក់ទងនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ។
- គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់នូវការអនុវត្តគម្រោងអភិវឌ្ឍន៍ នានាដែលកំពុងដំណើរការដើម្បីធានាការបញ្ចប់គម្រោងទាំងនេះទៅតាមកម្មវិធីដែលបានគ្រោងទុក។ គម្រោងទាំងនោះរួមមាន ៖
  - ☐ បណ្តាញទូរគមនាគមន៍ ឆ្អឹងខ្នងមហាអនុតំបន់មេគង្គ GMTBN (របៀងសេដ្ឋកិច្ច) ឬគម្រោង JICA CP-P5
  - ☐ ស្តារខ្សែកាបអុបទិកនៅក្រោមសមុទ្រ
  - ☐ សាងសង់បណ្តាញទូរគមនាគមន៍ខ្សែអុបទិក
  - ☐ គម្រោងក្នុងមហាអនុតំបន់ទន្លេមេគង្គដែលភ្ជាប់បណ្តាញពីសៀមរាបទៅស្ទូង ពីកំពង់ចាមទៅព្រំប្រទល់ប្រទេសឡាវ(ស្ទឹងត្រែង) និង ការធ្វើឱ្យប្រសើរឡើងនូវសេវាទូរគមនាគមន៍ក្នុងតំបន់ទីប្រជុំជន និង តំបន់ជនបទ ។
- បន្តតាមដានត្រួតពិនិត្យ និង អនុវត្តវិធានការច្បាប់នានាចំពោះអ្នកផ្តល់សេវាទូរគមនាគមន៍នានាដែលរំលោភលើកិច្ចសន្យា ។
- រៀបចំ និងប្រកាសឲ្យប្រើប្រាស់ លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងវិស័យនេះ ដែលត្រូវការចាំបាច់ ដើម្បីតម្រង់ទិសដល់ក្រុមហ៊ុនវិនិយោគនានា។
- បន្ត និង ផ្តល់អាទិភាពក្នុងការលុបបំបាត់ការបាត់បង់ចំណូលពីប្រព័ន្ធទូរគមនាគមន៍ចល័ត ។
- បន្តជំរុញការអភិវឌ្ឍ បណ្តាញខ្សែកាបអុបទិកដោយប្រើប្រាស់ខ្សែកាបនៅក្រោមដី និង ក្រោមសមុទ្រដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាកម្មទូរគមនាគមន៍ក្នុងប្រទេស និង សេវាកម្មទូរគមនាគមន៍ទៅក្រៅប្រទេស ។
- លើកកម្ពស់និងធ្វើឱ្យប្រសើរឡើងនូវការស្រាវជ្រាវ និង ការអភិវឌ្ឍផ្តោតលើបញ្ហាយេនឌ័រ
- សាងសង់ការិយាល័យទូរគមនាគមន៍នៅ រតនគិរី តាកែវ ស្ទឹងត្រែង និង កំពង់ធំ ។

៤៧៦. ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ នឹងស្នើសុំការអនុម័តជាផ្លូវការលើៈ

- ច្បាប់ស្តីពី ទូរគមនាគមន៍ (២០០៩)
- ច្បាប់ស្តីពី វិទ្យុទូរគមនាគមន៍ (២០១០-២០១១)

- ច្បាប់ស្តីពី ប្រព័ន្ធខ្សែកាបអុបទិក (២០១១-២០១២)
- អនុក្រឹត្យស្តីពី ការបង្កើតសេវាទូរគមនាគមន៍សកល (២០០៩-២០១១)
- ការផ្តល់សច្ចាប័នដល់ ធម្មនុញ្ញ និង អនុសញ្ញា ស្តីពីសហគមន៍ទូរគមនាគមន៍អន្តរជាតិ (២០០៩) ។
- ការផ្តល់សច្ចាប័នលើការឱ្យកម្ពុជាចូលជាហត្ថលេខីលើ អនុសារណៈអង្គការអ៊ីនធឺណិតរបស់សហរដ្ឋអាមេរិក (២០០៩-២០១០)
- ការផ្តល់សច្ចាប័នលើការឱ្យកម្ពុជាចូលជាសមាជិក អង្គការអន្តរជាតិពហុភាគីប្រឆាំងភេរវកម្មអ៊ីនធឺណិត (២០១០-២០១១)
- សេចក្តីប្រកាសស្តីពី តារាងផែនការហ្សូកេង់ជាតិ (២០០៩)
- សេចក្តីប្រកាសស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យការប្រើប្រាស់រលកអាកាសវិទ្យុ (២០១០) ។
- សារាចរស្តីពី បទដ្ឋានដំឡើងបង្គោលអង់តែនវិទ្យុគមនាគមន៍គ្រប់ប្រភេទ (២០០៩)
- ប្រកាសស្តីពី ប្លង់លេខទូរសព្ទជាតិ (២០០៩-២០១០)
- ប្រកាសស្តីពី តម្លៃប្រើប្រាស់ប្លង់លេខទូរសព្ទ (២០០៩-២០១០)
- ប្រកាសស្តីពី ការភ្ជាប់បណ្តាញទូរគមនាគមន៍សាធារណៈ (២០០៩-២០១០)
- ប្រកាសស្តីពី ការគ្រប់គ្រងសម្ភារៈបរិក្ខារវិទ្យុទាក់ទង និង ថ្លៃនៃការប្រើប្រាស់រលកវិទ្យុ (២០១១)
- ប្រកាសស្តីពី ការគ្រប់គ្រងបច្ចេកវិទ្យា ការស្ថាបនា និង ការប្រើប្រាស់សេវាទូរសព្ទចល័ត និង អចល័ត (២០០៩)

## ៩. ការអភិវឌ្ឍវិស័យឯកជន និងការងារ

៤៧៩.មុំឬសមាសធាតុរងទាំងបួន នៃចតុកោណនេះ រួមមាន៖ (១) ការពង្រឹងវិស័យឯកជន និងការទាក់ទាញ ការវិនិយោគ (២) ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ (៣) ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម (៤) ការរៀបចំសុវត្ថិភាពសង្គម។

### ៩.១ ការពង្រឹងវិស័យឯកជន និង ការទាក់ទាញការវិនិយោគ

#### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤៨០. រាជរដ្ឋាភិបាលកម្ពុជា បានធានាធ្វើថយចុះនូវចំណាយនៃប្រតិបត្តិការធុរកិច្ច និងពង្រីកលទ្ធភាពចូលទីផ្សារក៏ដូចជាកាត់បន្ថយចំណាយលើការដឹកជញ្ជូន និងកែលម្អសុវត្ថិភាពធ្វើដំណើរតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលធានាបាននូវការធ្វើសមាហរណកម្ម សេដ្ឋកិច្ចជនបទជាមួយនឹងសេដ្ឋកិច្ចទីប្រជុំជន ។ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំក្របខ័ណ្ឌគតិយុត្តិចាំបាច់ជាច្រើន សម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន និងបានពង្រឹង "វេទិការាជរដ្ឋាភិបាល-វិស័យឯកជន" ឱ្យទៅជាយន្តការដោះស្រាយបញ្ហាដ៏មានប្រសិទ្ធភាព ។ ការកាត់បន្ថយនូវការតម្រូវខាងឯកសារ បានជួយសម្រួលដល់ធុរកិច្ចនានា ជាពិសេសតាមរយៈការដាក់អនុវត្តនូវប្រព័ន្ធ"ឯកសារ រដ្ឋបាលតែមួយ"  និងសេវា"ច្រកចេញ-ចូលតែមួយ"។

៤៩២. រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈ ការអនុវត្តយ៉ាងម៉ឺងម៉ាត់ នូវកាតព្វកិច្ចរបស់ខ្លួន ក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក ក្របខ័ណ្ឌអាស៊ាន និងក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើមធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងអនុតំបន់ដទៃទៀត ។ បន្ថែមលើនេះទៀត រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តពង្រឹងបទដ្ឋានគតិយុត្តិ សម្រាប់គាំទ្រវិស័យឯកជនរួមមាន បទប្បញ្ញត្តិច្បាប់និងនីតិវិធីរដ្ឋបាល ការលើកកម្ពស់ផលិតភាព តាមរយៈ ការបណ្តុះបណ្តាលបុគ្គលិក អ្នកបច្ចេកទេស និងកម្មករជំនាញ ការធានាឱ្យមានការប្រកួតប្រជែងដោយយុត្តិធម៌ ការបន្តជំរុញកិច្ច សម្រួលពាណិជ្ជកម្មការជំរុញការអនុវត្តច្បាប់ស្តីពីការងារ និងការពង្រឹងយន្តការដោះស្រាយវិវាទឱ្យមានប្រសិទ្ធភាព ។

៤៩៦. នៅក្នុងនីតិកាលទី៣ នៃរដ្ឋសភា ចំនួនសហគ្រាស និងគ្រឹះស្ថានសេដ្ឋកិច្ច បានកើនឡើងគួរឱ្យកត់សម្គាល់ដល់ចំនួន ២.៤០០ ហើយស្រូបយកកម្មករ និយោជិកប្រមាណ៤៤០.៥០០នាក់ ។ ពលករកម្ពុជាចំនួនជាង៥០.០០០នាក់ ត្រូវបានបញ្ជូនទៅធ្វើការនៅបរទេស ។ ការអនុវត្តគោលនយោបាយបើកចំហដើងមេឃបាននាំឱ្យមានការកើនឡើងយ៉ាងខ្លាំងនូវចំនួនភ្ញៀវទេសចរ និងបានបង្កើនការងារជាច្រើនជូនប្រជាពលរដ្ឋ ។ សេរីភាពសហជីព ក៏ត្រូវបានលើកកម្ពស់ ផងដែរ ។ យន្តការត្រួតពិនិត្យការងារ និងដោះស្រាយវិវាទការងារ ត្រូវបានពង្រឹងដើម្បីតាមដានត្រួតពិនិត្យ ការជំរុញការអនុវត្តច្បាប់ស្តីពីការងារ និងធានានូវបរិស្ថានការងារ ប្រកបដោយសុខដុមរមនា ។

៤៩៧. រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ ស្តង់ដារការងារ បទដ្ឋានពលកម្មនិងច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិនានា រួមទាំង ការបន្តជំរុញយន្តការ "រោងចក្រប្រសើរនៅកម្ពុជា" ការនាំចេញពលករទៅបរទេស ការពង្រឹងសមត្ថភាពជំនាញតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យសមស្របតាមតម្រូវការទីផ្សារ ដោយផ្តោតជាសំខាន់លើមុខសញ្ញាយុវជនដែលពុំមានលទ្ធភាពបន្តការសិក្សានៅសាលាចំណេះទូទៅ ជនពិការ ស្ត្រី ជនបាត់បង់ឱកាស និងជនជាតិភាគតិច ការកសាងប្រព័ន្ធស្ថិតិការងារ និងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវព័ត៌មានស្តីពីតម្រូវការទីផ្សារការងារ ដើម្បីធានាឱ្យបាននូវចល័តភាពនៃពលកម្ម និងការពង្រឹងយន្តការដោះស្រាយវិវាទ ការងារដែលមានស្រាប់ ដូចជា ក្រុមប្រឹក្សាអាជ្ញាកណ្តាលគណៈកម្មការដោះស្រាយបាតុកម្ម កូដកម្មគ្រប់ថ្នាក់ ។

៤៩៨. រាជរដ្ឋាភិបាលកម្ពុជា នឹងបណ្តុះបណ្តាលអ្នកផ្សះផ្សារវិវាទស្ម័គ្រចិត្ត ក្នុងចំណោមអាជ្ញាធរមូលដ្ឋានសំដៅដោះស្រាយវិវាទប្រកបដោយសន្តិវិធី ។ បន្ថែមលើនេះ កិច្ចខិតខំប្រឹងប្រែង នឹងត្រូវធ្វើឡើងដើម្បីធានានូវ ស្ថិរភាពនៃការបង្កើតការងារ ការជំរុញការអនុវត្តច្បាប់ស្តីពីការងារ តាមរយៈ ការអប់រំបណ្តុះបណ្តាល និងការចុះអធិការកិច្ចការងារ តាមរោងចក្រសហគ្រាស ដើម្បីបង្កើនការយល់ដឹងពីលក្ខខណ្ឌការងារ រួមទាំង អនាម័យនិងសុខភាពសុវត្ថិភាពការងារការប្រឆាំងនឹងពលកម្មកុមារនិងការប្រើប្រាស់ពលករបរទេស ការអនុវត្តសេរីភាពរបស់សហជីព ស្របតាមច្បាប់ស្តីពីការងារ និងកសាង ច្បាប់សហជីព ព្រមទាំង ក្របខ័ណ្ឌបទដ្ឋានគតិយុត្តិនានា ស្តីពីការបង្កើតតុលាការការងារ តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយភាគីពាក់ព័ន្ធ ។

**ខ.សកម្មភាពកម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព**

៤៩៩. ការធានាឱ្យមានលក្ខខណ្ឌការងារល្អ មានសុវត្ថិភាពត្រឹមត្រូវ មានអនាម័យល្អ និងមានលក្ខខណ្ឌកិច្ចសន្យាត្រឹមត្រូវនិងយុត្តិធម៌ សម្រាប់ពលករ នៅកន្លែងធ្វើការ គឺជាកិច្ចការមួយដ៏សំខាន់ក្នុងការជំរុញការអនុវត្តនូវគោលនយោបាយនិងយុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធវិស័យការងារ ។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបាននិងកំពុងដោះស្រាយជាប្រចាំនូវកិច្ចការទាំង

អស់នេះដោយបានដាក់កម្រិតអប្បបរមានៃ ប្រាក់ឈ្នួលប្រចាំខែនិងថ្ងៃឈប់ សម្រាកកាត់បន្ថយវិសមភាពប្រាក់ឈ្នួលរវាងបុរស និងស្ត្រី ដោះស្រាយជម្លោះនិងការមិនឯកភាពគ្នា ដោយសន្តិវិធីដោយមិនបង្កឡើងនូវការអាក់ខានដល់ចង្វាក់ផលិតកម្ម និង ការបាត់បង់ប្រាក់ឈ្នួលរបស់កម្មករ-និយោជិក។ ជាមួយគ្នានេះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក៏បានលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យទាំងពីរ (ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ) សំដៅបង្កើតឱកាសការងារសមស្រប ទាំងក្នុងនិងក្រៅប្រព័ន្ធ បង្កើតបណ្តាញអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសម្រាប់ពលករទាំងពីរភេទ បង្កើតប្រព័ន្ធទិន្នន័យស្ថិតិពលករដែលមាន ការបែងចែកតាមភេទ លើកកម្ពស់លក្ខខណ្ឌការងារល្អប្រសើរសម្រាប់កម្មករទាំងពីរភេទ ជាពិសេសកម្មការិនីទាំងនៅក្នុងនិងក្រៅប្រទេស ដោះស្រាយគម្លាតប្រាក់បៀវត្សរ៍រវាងបុរសនិងស្ត្រី និងពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និង ច្បាប់ស្តីពីរបបសន្តិសុខសង្គម ។ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- សិក្សានិងរៀបចំ គោលនយោបាយជាតិស្តីពីការគ្រប់គ្រងមុខរបរនិងហត្ថពលកម្ម ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់ពលករក្នុងប្រទេស និងកែលម្អការគ្រប់គ្រងការផ្តល់សេវាមុខរបរនៅក្រៅប្រទេសតាមរយៈទីភ្នាក់ងារស្របច្បាប់របស់ក្រសួងការបង្កើតប្រព័ន្ធសាធារណៈនៃសេវាមុខរបរក្រៅប្រទេស និង ការការពារពលករទេសន្តរប្រវេសន៍ ក៏ដូចជាដើម្បីរួមចំណែកក្នុងការបង្កើតការងារគ្រប់ប្រភេទ សំដៅបង្កើន ប្រាក់ចំណូលដោយមិនមានការរើសអើង ជាពិសេសសំដៅលើកកម្ពស់តម្លៃស្ត្រី ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ។ គោលនយោបាយនេះ នឹងផ្តោតលើ ៖
  - ការអភិវឌ្ឍមុខរបរក្នុងប្រទេស និង ការងារនៅបរទេស ។
  - ការអភិវឌ្ឍការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។
  - ការរៀបចំឯកសណ្ឋានអធិការកិច្ចការងារ ។
  - ការបង្កើតវិទ្យាស្ថានការងារ ។
  - ការបង្កើតគណៈកម្មការស្រាវជ្រាវ និងផ្សព្វផ្សាយ ព័ត៌មានស្តីពី សហគ្រាសគ្រឹះស្ថាន ។
- ធានាលក្ខខណ្ឌការងារល្អប្រសើរសំដៅលើកកម្ពស់សិទ្ធិការងារជាមូលដ្ឋានរបស់កម្មករ-និយោជិក និងរក្សា លក្ខខណ្ឌការងារល្អក្នុងកន្លែងធ្វើការងារ ជាពិសេសសម្រាប់ជនពិការនិងកម្មការិនី ។ សកម្មភាពអាទិភាព នានា ដែលត្រូវអនុវត្តដើម្បីសម្រេចឱ្យបានតាមទិសដៅការងារខាងលើ រួមមាន ដូចខាងក្រោម ៖
  - លើកកម្ពស់សិទ្ធិការងារជាមូលដ្ឋានរបស់ កម្មករ-និយោជិក ។
  - ការរក្សាលក្ខខណ្ឌល្អក្នុងកន្លែងធ្វើការ ។
  - ការពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារថ្នាក់ជាតិ ។
  - ការកែលម្អការធ្វើអធិការកិច្ច ផ្នែកសុខភាពនិងសុវត្ថិភាពការងារ និង ការអនុវត្តតាមច្បាប់ ។
  - ការជំរុញសកម្មភាព ផ្នែកសុខភាព និងសុវត្ថិភាពការងារ តាមរយៈ អង្គការនិយោជក និង អង្គការ កម្មករ-និយោជិក ។
  - ការអនុវត្តកម្មវិធីពិសេស សម្រាប់ មុខរបរគ្រោះថ្នាក់ ។
  - ការពង្រីកការការពារ ផ្នែកសុខភាព និងសុវត្ថិភាពការងារ ដល់ សហគ្រាសខ្នាតតូច និងកន្លែងការងារ នៅតាមជនបទ និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។
  - ការជំរុញឱ្យមានការបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារ សម្រាប់កសិករ ។

- ☐ ការចូលរួមកាត់បន្ថយករណីឆ្លងថ្មីនិង ផលប៉ះពាល់នៃមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈការ
- ☐ កាត់បន្ថយភាពងាយរងគ្រោះចំពោះ ការឆ្លងមេរោគអេដស៍ ក្នុងចំណោមកម្មករ-និយោជិក នៅតាមរោងចក្រ កាត់ដេរ គ្រឹះស្ថានសហគ្រាស និងសិស្ស និស្សិត នៅតាមបណ្តាគ្រឹះស្ថានអប់រំ ។
- ☐ ការផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់ប្រជាជនចំណាកស្រុក ដើម្បីឱ្យពួកគាត់មានភាព ងាយស្រួលក្នុងការស្វែងរកការងារធ្វើ ។
- ☐ លើកកម្ពស់សុវត្ថិភាពការងារសម្រាប់ កុមារអាយុ១៥ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ (អាយុអប្បបរមា អាចបម្រើ ការងារបាន) ។
- ☐ ឆ្ពោះទៅរកការលុបបំបាត់ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនាឆ្នាំ២០១៦ ។
- ☐ រៀបចំផែនការសកម្មភាពរាជធានី-ខេត្ត ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។
- ☐ តាមដានត្រួតពិនិត្យ និងធ្វើអធិការកិច្ចពលកម្មកុមារ ក្នុងតំបន់ដែលមានសហគ្រាសឧស្សាហកម្ម ។
- ☐ ទប់ស្កាត់ និងដកហូត កម្មពលករកុមារ ព្រមទាំងធ្វើសមាហរណកម្មពលករកុមារទៅក្នុងសង្គមក្នុងគោលដៅ លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។
- ☐ តាមដានត្រួតពិនិត្យ និងវាយតម្លៃការងារលុបបំបាត់ពលកម្មកុមារ ។ ជំរុញការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខ សង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារតាមរយៈសកម្មភាពអាទិភាព ដូចខាងក្រោម ៖
- ☐ ពង្រីក និងពង្រឹងការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ ឱ្យបានលើគ្រប់សហគ្រាសគ្រឹះស្ថាននៅទូទាំង ប្រទេស ។
- ☐ សិក្សានិងរៀបចំបង្កើតរបបថែទាំសុខភាពសម្រាប់កម្មករ-និយោជិក ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពី ការងារ ។
- ☐ សិក្សានិងរៀបចំបង្កើតរបបប្រាក់សោធន សម្រាប់កម្មករ-និយោជិក ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពី ការងារ ។

■ ជំរុញការអភិវឌ្ឍសមត្ថភាពជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ជូនប្រជាពលរដ្ឋ សំដៅរួមចំណែកក្នុងការកាត់ បន្ថយភាព ក្រីក្រ ជាពិសេស ការលើកកម្ពស់សិទ្ធិជនពិការ និងការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងវិស័យអប់រំបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ ។ សកម្មភាពអាទិភាព នៅក្នុងការងារនេះ រួមមានដូចខាងក្រោម ៖

- ☐ ផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យបានសមស្របតាមតម្រូវការទីផ្សារពលកម្មទាំង ក្នុងនិងក្រៅប្រទេស ។
- ☐ ការអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដារជាតិសមត្ថភាព ការធ្វើតេស្ត និង ការទទួលស្គាល់វគ្គកម្មវិធីសិក្សា និងគ្រឹះស្ថានសិក្សា ។
- ☐ ការពង្រាយកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈ ការហ្វឹកហ្វឺនកូនជាង ការ បណ្តុះបណ្តាលតាមលិខិតបញ្ជាក់ និង មូលនិធិជាតិកាត់បន្ថយភាពក្រីក្រ ។
- ☐ ការអភិវឌ្ឍ ប្រព័ន្ធព័ត៌មានទីផ្សារការងារ ។
- ☐ ការជំរុញ ការផ្សព្វផ្សាយអំពីសមភាពយេនឌ័រ និង ការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ ។

## ៦. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស

### i. ការពង្រឹងគុណភាពវិស័យអប់រំ

#### ក. គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៤

៥២៥. ក្នុងនីតិការទី៤ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនកម្ពុជាទាំងអស់ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត និងឋានៈនៅក្នុងសង្គមឡើយ។ ម៉្យាងវិញទៀត ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្សារភ្ជាប់នឹងការអប់រំ វប្បធម៌ សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាពប្រជាធិបតេយ្យ និងយុត្តិធម៌ ដោយប្រឆាំងនឹងអំពើហិង្សា ប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន ការជួញដូរកុមារនិងស្ត្រី និងការរើសអើងគ្រប់ប្រភេទ ក្នុងសង្គម។

៥២៦. រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តយកចិត្តទុកដាក់លើ ការកែលម្អគុណភាពការអប់រំតាមរយៈ ការលើកទឹកចិត្តគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា ការលើកទឹកចិត្តសិស្សពូកែ ការបណ្តុះបណ្តាលគ្រូបង្រៀន និងបំប៉នវិធីសាស្ត្របង្រៀន ព្រមទាំងការកែលម្អលក្ខខណ្ឌនៃការសិក្សា និងការផ្គត់ផ្គង់សម្ភារសិក្សា ការបង្កើតបណ្ណាល័យ មន្ទីរពិសោធន៍ ជាដើម។ ក្នុងទិសដៅធានាកាលានុវត្តភាពប្រកបដោយសមធម៌ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តបង្កើតអន្តេវាសិកដ្ឋានសម្រាប់សិស្ស-និស្សិត ជាពិសេសសម្រាប់សិស្ស-និស្សិតជានារីភេទ និងបន្តសាងសង់សាលារៀនគ្រប់កម្រិតសិក្សា ជាពិសេសនៅតាមតំបន់ជនបទនិងតំបន់ដាច់ស្រយាល និង បង្កើនអាហារូបករណ៍សម្រាប់សិស្សនិស្សិតក្រីក្រ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាពឱ្យបានគ្រប់គ្រាន់ និង អនុវត្តគោលនយោបាយពង្រាយគ្រូឱ្យមានប្រសិទ្ធភាព។ រាជរដ្ឋាភិបាលកម្ពុជា នឹងលើកទឹកចិត្តឲ្យគ្រូបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និងគ្រូដែលបានបន្តរៀនចប់បរិញ្ញាបត្រ បានប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀន កម្រិតឧត្តមដោយគ្មានកម្រិតអាយុ និងបង្កលក្ខណៈសម្បត្តិឲ្យគ្រូបឋមសិក្សាដែលមិនទាន់មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិមានលទ្ធភាពប្រឡងយកសញ្ញាប័ត្រសមមូលមធ្យមសិក្សាទុតិយភូមិ ដើម្បីផ្តល់ឱកាសឲ្យពួកគាត់មានលទ្ធភាពរៀននៅថ្នាក់ឧត្តមសិក្សា ឬក្រោយឧត្តមសិក្សា និងផ្លាស់ប្តូរកាំប្រាក់បៀវត្សរ៍បាន។

៥២៧. រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និង ជាមួយសហគមន៍ជាតិ និង អន្តរជាតិដើម្បីបង្កើន និង លើកកម្ពស់គុណភាពសេវាអប់រំ ក្នុងនោះមានការយកចិត្តទុកដាក់បន្ថែមលើការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យានិងភាសាបរទេស នៅក្នុងគ្រប់កម្រិតមធ្យមសិក្សាចំណេះទូទៅ នៅក្នុងការបណ្តុះបណ្តាលមុខវិជ្ជាជីវៈ និងបច្ចេកទេស និង នៅក្នុងកម្រិតឧត្តមសិក្សាអោយស្របទៅនឹងស្តង់ដារអន្តរជាតិ និង តម្រូវការអភិវឌ្ឍន៍របស់ប្រទេស ។ ពិសេសជាងនេះទៅទៀត ក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេស និង ឧត្តមសិក្សារាជរដ្ឋាភិបាលកម្ពុជា នឹងបន្តការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលវិស្វករ និង អ្នកបច្ចេកទេស អោយបានសមស្រប។ ទន្ទឹមនេះ ដើម្បីកាត់បន្ថយគម្លាតរវាងការផ្គត់ផ្គង់ និងតម្រូវការការងារ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តគោលនយោបាយបណ្តុះបណ្តាលមុខវិជ្ជាជីវៈផ្សារភ្ជាប់នឹងទីផ្សារពលកម្មដោយសហការយ៉ាងជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធតាមរយៈវិធានដូចតទៅ ( ទី១ ) ផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាពលរដ្ឋនៅតាមជនបទដើម្បីបង្កើនប្រាក់ចំណូល ( ទី២ ) ផ្តល់ការបណ្តុះបណ្តាល ឬវិក្រិតការដល់ពលករតាមរោងចក្រដោយសហការជាមួយនិយោជក ( ទី៣ ) បន្តជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង មុខវិជ្ជាជីវៈដោយពង្រីកសេវានេះឱ្យទៅដល់រាជធានី-ខេត្ត ក្នុងនោះ រួមទាំងការបញ្ចូលការបណ្តុះបណ្តាលសហគ្រិនទៅក្នុងកម្មវិធីផងដែរ ។ ( ទី៤ ) ការរៀបចំបង្កើតទីភ្នាក់ងារជាតិមុខរបរ និង ការងារ និង

មជ្ឈមណ្ឌលការងារតាមរាជធានី-ខេត្តសម្រាប់យន្តការសម្រួលដល់ការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ។

៥២៨. រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តពង្រីកការអប់រំក្រៅប្រព័ន្ធតាមរយៈកម្មវិធីអក្ខរកម្ម និង អក្ខរកម្មវិជ្ជាជីវៈបង្កើនការសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ ព្រមទាំងអនុវត្តកម្មវិធីសមធម៌ ។ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តបង្កើនចំណាយថវិកា និង កៀរគរហិរញ្ញប្បទានឱ្យបានច្រើនថែមទៀត សម្រាប់គាំទ្រការអប់រំ ដើម្បីធានាគុណភាពអប់រំ ឱ្យកាន់តែមានកម្រិតខ្ពស់ និងប្រកបដោយប្រសិទ្ធភាព ។ នៅកម្រិតឧត្តមសិក្សា បានបង្ហាញពីតម្រូវការនិស្សិតដែលបញ្ចប់ការសិក្សានៅឧត្តមសិក្សានឹងក្លាយជា អ្នកវិទ្យាសាស្ត្រ និយោជិក និងជាប្រជាពលរដ្ឋដែលអាចគិតត្រិះរិះបានល្អិតល្អន់ និងធ្វើសេចក្តីសម្រេចចិត្តដោយមានអំណះអំណាងត្រឹមត្រូវ នាពេលអនាគត រយៈពេលខ្លី និងរយៈពេលវែងរបស់កម្ពុជា។

## ៣. ច្បាប់អប់រំ

មាត្រា ១ - គោលដៅ

- ច្បាប់ នេះមានគោលដៅកំណត់អំពីវិធាន និង លក្ខខណ្ឌតម្រូវថ្នាក់ជាតិ សម្រាប់កសាងប្រព័ន្ធអប់រំមួយពេញលេញ និង ឯកភាព ដែលធានាបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ ការ សមស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ - គោលបំណង

- ច្បាប់នេះមានគោលបំណងអភិវឌ្ឍធនធានមនុស្សដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដើម្បីអោយអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយ សីលធម៌ សំដៅជំរុញអោយអ្នកសិក្សាស្គាល់ ស្រលាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និង ភាសាជាតិ។

មាត្រា ៣ - វិសាលភាពអនុវត្តន៍

- ច្បាប់នេះមានវិសាលភាពលើគ្រប់កម្មវិធីអប់រំ សិក្សាស្រាវជ្រាវអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈគ្រប់ប្រភេទ គ្រប់កម្រិតភូមិសិក្សាសាធារណៈ និង ឯកជននៃប្រព័ន្ធអប់រំ ទោះជាកម្មវិធីអប់រំនោះធ្វើឡើងនៅក្នុងស្ថាប័នអប់រំ ឬក៏ដោយបុគ្គលិកអប់រំ ។ វាព្រមទាំងគ្រប់ដណ្តប់រដ្ឋបាលកិច្ច និង ការគ្រប់គ្រងការអប់រំគ្រប់កម្រិត លើកលែងតែការអប់រំអំពីគម្ពីរសាសនា ការអប់រំខាងបច្ចេកទេស យុទ្ធសាស្ត្រយោធា និង សន្តិសុខ ការអប់រំខាងផ្នែកគ្រប់គ្រងរដ្ឋបាលដែនដី ការអប់រំដែលផ្តល់ដោយសាលាភូមិន្ទរដ្ឋបាល និង ការអប់រំបច្ចេកទេស និង វិជ្ជាជីវៈតុលាការ ដែលផ្តល់ដោយស្ថាប័នបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈច្បាប់ និង តុលាការ ។
- ច្បាប់នេះអនុវត្តផងដែរលើបុគ្គល និង អ្នកពាក់ព័ន្ធផ្សេងៗទៀតដូចជាកុមារដែលស្ថិតក្នុងអាយុត្រូវសិក្សា អ្នកសិក្សា មាតាបិតា ឬ អ្នកអាណាព្យាបាល ក្រុម ឬ ក្លឹបអ្នកសិក្សា និង បុគ្គលអប់រំ ឬបុគ្គលកាន់អាជ្ញាប័ណ្ណអប់រំ និង សិទ្ធិវន្តនៃអាជ្ញាប័ណ្ណអប់រំ លើកលែងតែអ្នកដែលពាក់ព័ន្ធនៅក្នុងការអប់រំ និង ប្រតិបត្តិខាងសាសនា បច្ចេកទេស យុទ្ធសាស្ត្រយោធា និង សន្តិសុខផ្នែកគ្រប់គ្រងរដ្ឋបាលដែនដី ផ្នែកភូមិន្ទរដ្ឋបាល និង ផ្នែកវិជ្ជាជីវៈតុលាការ ។

មាត្រា ៤ - និយមន័យការអប់រំ និង វាក្យសព្ទសំខាន់ៗ

- ការអប់រំក្នុងច្បាប់នេះ សំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬ ការបណ្តុះបណ្តាលកាយសម្បទា សតិ បញ្ញា និង សីលធម៌តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើអោយអ្នកសិក្សាទទួលបាននូវសំណុំចំណេះដឹង ជំនាញ សមត្ថភាព និង តម្លៃ ដើម្បីអោយក្លាយខ្លួនជាបុគ្គលល្អ ដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និង ពិភពលោក ។

មាត្រា ២១ - គុណភាព និង ប្រសិទ្ធភាពនៃការអប់រំ

- រដ្ឋត្រូវលើកកម្ពស់គុណភាពអប់រំដើម្បីបំពេញសេចក្តីត្រូវការខាងការសិក្សាមូលដ្ឋាន និង សេចក្តីត្រូវការជំនាញដើម្បីធ្វើអោយអ្នកសិក្សាមានសមត្ថភាព និងលទ្ធភាពចូលរួមក្នុងការអភិវឌ្ឍប្រទេសប្រកបដោយប្រសិទ្ធភាព។
- រដ្ឋត្រូវយកចិត្តទុកដាក់បំពាក់សម្ភារៈបច្ចេកទេសសមស្រប និង ទំនើបក្នុងការរៀន និង បង្រៀន ដើម្បីធានាអោយបាន គុណភាព និង ប្រសិទ្ធភាពខ្ពស់ ។
- ស្តង់ដារជាតិអប់រំ ស្តង់ដារជាតិបណ្តុះបណ្តាល និង/ ឬ ស្តង់ដារសមត្ថភាពត្រូវបានកំណត់ក្រសួងទទួលបន្ទុកវិស័យអប់រំស្របតាមគោលនយោបាយរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ។

មាត្រា ២៨ - វិទ្យាសាស្ត្រ និង បច្ចេកវិទ្យាសម្រាប់ការអប់រំ

- រដ្ឋត្រូវលើកកម្ពស់ និង គាំទ្រដល់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ ការច្នៃប្រឌិត និង ការផលិតដែលមានលក្ខណៈវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា សម្រាប់ការអប់រំ ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និង ស្របតាមសកលភាវូបនីយកម្ម ដើម្បីលើកស្ទួយសមត្ថភាពធនធានមនុស្ស និង ជំរុញការអភិវឌ្ឍប្រទេសជាតិ ។
- ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវកំណត់គោលការណ៍ស្តីពី វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា សម្រាប់ការអប់រំគ្រប់ភូមិសិក្សា នៃប្រព័ន្ធអប់រំកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

## ៨. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៦-២០១០

http://www.moeys.gov.kh/old_moeys.gov/education/esp06-10/ESP2006-10-kh.pdf

### ចំណុចទី៤ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០០៦-២០១០

#### ៤.៤. យុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាឆ្លងវិស័យ

បច្ចេកវិទ្យា ព័ត៌មានវិទ្យា សារទូរគមនាគមន៍៖ ក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្តថ្មីស្តីពីបច្ចេកវិទ្យាព័ត៌មានទូរគមនាគមន៍ របស់ក្រសួងអប់រំ យុវជន និងកីឡា ដោយផ្តោតជាដំបូងនៅសាលាមធ្យមសិក្សាទុតិយភូមិ និងសាលាគរុកោសល្យ និងភ្ជាប់ភាពជាដៃគូជាមួយអ្នកផ្តល់សេវាឯកជន។

### ចំណុចទី៦ ក្របខ័ណ្ឌកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ ២០០៦-២០១០
### ៦.២. អាទិភាពកម្មវិធីចំណាយមូលធន

